ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនការយុទ្ធសាស្ត្រថវិកា
# ២០២៤ - ២០២៦

ខែកក្កដា ឆ្នាំ ២០២៣

## I. សេចក្ដីផ្ដើម

ក្រសួងអប់រំ យុវជន និងកីឡានៅតែបន្តធ្វើការងារយ៉ាងសកម្ម ដោយបានក្លាយទៅជាទម្លាប់នៃការអនុវត្តការដ្ឋានកំណែទម្រង់យុទ្ធសាស្ត្រវិស័យអប់រំដែលឥតឈប់ឈរ ឆ្ពោះទៅមុខជានិច្ចប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់ ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧ ជាពិសេសបញ្ចកោណទី១៖ ការអភិវឌ្ឍមូលធនមនុស្ស ក្នុងនោះការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ ការលើក កម្ពស់សេវាសាធារណៈ និងអាហារូបត្ថម្ភ និងការពង្រឹងសមភាពយេនឌ័រ និងការគាំពារ សង្គម។

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ដោយផ្តោតលើអាទិភាពកំណែទម្រង់ចំនួន៣កម្រិត៖ (១) ការអនុវត្តកំណែទម្រង់គោលនយោបាយអប់រំកម្រិតជាតិក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ (២) ការអនុវត្តកំណែទម្រង់គ្រូបង្រៀននៅតាមសាលាគរុកោសល្យ និង (៣) ការអនុវត្តកំណែទម្រង់សាលារៀន។ ក្រសួងនៅតែបន្តឈរលើមូលដ្ឋានគ្រឹះរឹងមាំ ដោយមានកិច្ចសហការពីដៃគូអភិវឌ្ឍន៍ដើម្បីអភិវឌ្ឍវិស័យអប់រំរបស់ខ្លួន ក្នុងការផ្តល់សេវាអប់រំមូលដ្ឋានប្រកបដោយសមធម៌ បរិយាបន្ន និងមានគុណភាពខ្ពស់ក្នុងការឈានទៅសម្រេចវត្ថុបំណង គោលនយោបាយអប់រំ។ ក្រសួងបានដាក់ចេញនូវអាទិភាពគន្លឹះចំនួន៨ សម្រាប់វិស័យអប់រំ យុវជន និងកីឡា នៅក្នុងសន្និបាតអប់រំសម្រាប់ឆ្នាំសិក្សា២០២១-២០២២ កន្លងទៅ ដោយផ្តោតលើ៖ (១) កំណែទម្រង់សាលារៀន (២) ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន (៣) ការអប់រំឌីជីថល (៤) ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (៥) ការលើកកម្ពស់សុខភាពសិក្សា (៦) ការអភិវឌ្ឍយុវជន ដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ ទី២១ (៧) ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព នៅគ្រឹះស្ថានឧត្តមសិក្សា (៨) ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព និង(៩) ការអភិវឌ្ឍការអប់រំកាយ និងកីឡា។

## ១. ចក្ខុវិស័យ បេសកកម្ម និងភារកិច្ចចម្បងៗ របស់ក្រសួង

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់នូវចក្ខុវិស័យ គឺកសាងនិងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និងកីឡា មានបេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់និងសកលលោក។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជននិងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍

មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថានៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូល សម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវខ្ពស់ជាអាទិ៍៖ (i) កំណត់នយោបាយអប់រំ យុវជន និងកីឡាសំដៅការអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព (ii) កសាងនីតិក្រមសម្រាប់អភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា (iii) កសាងផែនការអនុវត្ត ពិនិត្យតាមដាន និងវាយតម្លៃនយោបាយអប់រំ យុវជន និងកីឡា ដើម្បីអភិវឌ្ឍធនធានមនុស្ស ព្រមទាំងលើកទិសដៅ និងវិធានការកែលម្អជាបន្តបន្ទាប់តាមមុខជំនាញ (iv) លើកកម្ពស់គុណភាពវិស័យអប់រំ យុវជន និងកីឡាឱ្យឆ្លើយតបទៅនឹងដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងអន្តរជាតិ ដើម្បីកសាងសមត្ថភាពខាងចំណេះដឹង និងចំណេះធ្វើ សីលធម៌ និងចេះរួមរស់ជាមួយគ្នា (v) តម្រង់ទិសវិជ្ជាជីវៈ បំណិនជីវិត និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅគ្រប់ភូមិសិក្សា (vi) លើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាដោយជានាសមធម៌ និងបរិយាបន្ន (vii) អភិវឌ្ឍធនធានមនុស្សលើផ្នែកបច្ចេកទេសសហគ្រិនភាព និងអប់រំបច្ចេកទេសក្នុងតំបន់ (viii) សិក្សាសំណើបង្កើត បើក បិទ បញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ (ix) សិក្សាលើសំណើទទួលស្គាល់ការបង្កើត បើក បិទ បញ្ចូលគ្នា ជំនាញថ្មី បំបែក ប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាឯកជន (x) លើកកម្ពស់ការស្រាវជ្រាវ និងបច្ចេកវិទ្យាព័ត៌មាន ដើម្បីអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា (xi) គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃដំណើរការសិក្សា ការនិពន្ធ ការផ្សាយ ការនាំចូលសៀវភៅសិក្សា និងឯកសារពាក់ព័ន្ធនឹងការបង្រៀន និងរៀននៅគ្រប់កម្រិតសិក្សា គ្រប់ភូមិសិក្សា និងដាក់ពិន័យ (xii) ការអភិវឌ្ឍការងារយុវជន និងការងារអប់រំកាយនិងកីឡា ដោយ កំណត់វិធានការគ្រប់គ្រង បណ្តុះបណ្តាល និងបំប៉នបច្ចេកទេស (xiii) បង្កើនការយល់ដឹងវប្បធម៌ជាតិ និងវប្បធម៌អន្តរជាតិ (xiv) គ្រប់គ្រងបុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់ គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា (xv) ពិនិត្យនិងផ្តល់យោបល់គោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន និងកីឡា (xvi) ធ្វើរបាយការណ៍ស្តីពីសកម្មភាព ការងារតាមកាលកំណត់ជូនរាជរដ្ឋាភិបាល និង (xvii) ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

ការលើកកម្ពស់គុណភាពការអប់រំត្រូវផ្តោតលើការលើកកម្ពស់គុណភាពរបស់ធាតុចូល ដំណើរការរៀននិងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។ គុណភាពរបស់ធាតុចូលនឹងផ្តោតសំខាន់លើ គុណវុឌ្ឍិគ្រូបង្រៀន ដែលនឹងត្រូវបង្កើនរូបមន្តពី ១២ បូក ២ ទៅដល់ ១២ បូក ៤ នៅឆ្នាំ ២០២០។ គុណភាពកម្មវិធីសិក្សានៅអប់រំចំណេះទូទៅ និងឧត្តមសិក្សា ឱ្យស្របនឹងគុណភាពស្តង់ដាអាស៊ាន។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ បានកំណត់វិធានការកែលម្អការគ្រប់គ្រងថវិកាឱ្យមានប្រសិទ្ធភាពក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងលទ្ធផលការងារ និងការបែងចែកធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយសមធម៌ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអន្តរកាលដំណាក់កាលទី៣ ដែលរាជរដ្ឋាភិបាលបានសម្រេចបន្តរយៈពេល២ឆ្នាំទៀត (ឆ្នាំ២០២១ និងឆ្នាំ២០២២) ដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការកែទម្រង់ក្នុងខឿន

ទាំង៣ខាងដើម មុនឈានទៅអនុវត្តខឿនទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ដំណាក់កាលអន្តរកាល ឆ្ពោះទៅខឿនទី៤ មានគោលដៅក្នុងការកសាងលក្ខខណ្ឌចាំបាច់នានា ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដែលជាគន្លឹះក្នុងការកសាង " វប្បធម៌សមិទ្ធកម្ម"។

ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំនេះ បានគាំទ្រដោយផែនការយុទ្ធសាស្ត្រថវិការយៈពេលបីឆ្នាំរំកិល ថវិកាកម្មវិធីប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២០-២០២២ និងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ នាពេលកន្លងមកលើមូលដ្ឋានជាក់ស្តែង។ ថវិកាដែលត្រូវការសម្រាប់អនុវត្តកម្មវិធីទាំង ៥ សម្រាប់រយៈពេល៣ឆ្នាំ។ តាមការធ្វើចំណោលលើគម្រោងចំណាយថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២២ ប្រៀបធៀបទៅនឹងថវិកាឆ្នាំ២០២១ មានការកើនឡើង ៣,២ ភាគរយ។ ប្រៀបធៀបថវិកាឆ្នាំ២០២៣ ទៅនឹងឆ្នាំ២០២២ មានការកើនឡើង ១,៧ ភាគរយ ហើយឆ្នាំ២០២៤ ទៅនឹងឆ្នាំ២០២៣ មានការកើនឡើង ៤,៥ ភាគរយ។

## ២. លទ្ធផលសម្រេចបានក្នុងឆ្នាំ២០២២ និងវឌ្ឍនភាពនៃសូចនាករគន្លឹះ

### ផ្នែកទី១. សមិទ្ធផលការងារសំខាន់ៗ ក្នុងរយៈពេល ១០ ឆ្នាំ

ក្នុងរយៈពេល១០ឆ្នាំ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និង២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ដូចជា ការបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់ភូមិសិក្សា ជាពិសេសការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ តាមរយៈការបង្កលក្ខណៈសម្បត្តិអនុគ្រោះ ឱ្យកូនចៅប្រជាជនដែលជួបការលំបាកមានលទ្ធភាពចូលរៀន រៀនបន្ត ការពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សា ការដោះស្រាយការខាតបង់ការសិក្សាក្នុងបរិបទកូវីដ-១៩ និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និងនិស្សិតមកពីគ្រួសារក្រីក្រ។ ក្រសួងបានសម្រួចវិធានការលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំ តាមរយៈការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន និងការលើកទឹកចិត្ត ព្រមទាំងបង្កើនស្វ័យភាព គណនេយ្យភាព និងភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងសេវាអប់រំគ្រប់ លំដាប់ថ្នាក់។

វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំទាំងពីរដំណាក់កាល ក៏ត្រូវបានឆ្លុះបញ្ចាំងផងដែរ តាមរយៈវឌ្ឍនភាពនៃការអនុវត្តវិធានការកំណែទម្រង់បួនដំណាក់កាល គឺដំណាក់កាលទី១ កំណែទម្រង់ថ្នាក់ជាតិមាន ៨ចំណុច នៅឆ្នាំ២០១៤ ដំណាក់កាលទី២ កំណែទម្រង់កម្រិតសាលារៀនមាន ១៥ចំណុច ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៨ ដំណាក់កាលទី៣ កំណែទម្រង់ការកសាងប្រព័ន្ធ និងអភិវឌ្ឍធនធានមនុស្សឈរលើសសរស្តម្ភ៥ ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ និងដំណាក់កាលទី៤ កំណែទម្រង់ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បរិវត្តកម្មសេដ្ឋកិច្ចឌីជីថលចាប់ពីឆ្នាំ២០២២ ព្រមទាំងវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសដើម្បីពង្រឹងមូលដ្ឋានគ្រឹះនៃការអនុវត្តកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈខឿនទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ស្របនឹងបរិបទកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈជាកម្មវិធីកំណែទម្រង់រយៈពេលវែង ដើម្បីជានាដល់ការផ្លាស់ប្តូរជាបណ្តើរនូវប្រព័ន្ធគ្រប់គ្រងថវិកាកម្មជាពីការផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាការផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ។

ជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានចុះកិច្ចព្រមព្រៀងសមិទ្ធកម្ម ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឆ្នាំ២០២៣ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមអនុវត្តប្រព័ន្ធព័ត៌មានថវិកាសមិទ្ធកម្ម ឬ "ថវិកាសមិទ្ធកម្ម" ក្នុងស្មារតីតម្រូវឱ្យមានការវាស់វែងប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធី តាមរយៈសូចនាករសមិទ្ធកម្មដោយផ្សារភ្ជាប់លទ្ធផលក្នុងឆ្នាំនិងអាទិភាពគោលនយោបាយសម្រាប់ធ្វើសេចក្ដីសម្រេចចិត្តលើការវិភាជថវិកា ឬធនធានហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ ក្នុងកិច្ចព្រមព្រៀងនេះ ក្រសួងអប់រំ យុវជន និងកីឡា បានយល់ព្រមលើការអនុវត្តកម្មវិធីចំនួន ០៥ មានទឹកប្រាក់ សរុបចំនួន ៣៧៧ ៤៧៨,៦ លានរៀល និងសូចនាករសមិទ្ធកម្មចំនួន១០សម្រាប់វាស់វែងលទ្ធផលការងាររបស់ក្រសួង។

ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចសមិទ្ធផលបានក្នុងរយៈពេល១០ឆ្នាំ ពីឆ្នាំសិក្សា២០១៣-២០១៤ ដល់ឆ្នាំសិក្សា២០២២-២០២៣ ដែលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃកំណែទម្រង់សំខាន់ៗ និងវឌ្ឍនភាពតាមអនុវិស័យទាំង ៧ ដូចខាងក្រោម ៖

## ១.១ វឌ្ឍនភាពផ្នែកបរិមាណវិស័យ

សាលារៀនគ្រប់កម្រិតសិក្សាបានកើនឡើងជាលំដាប់ ស្ទើរតែគ្រប់ទីតាំងភូមិសាស្ត្រទូទាំងប្រទេស ក្នុងគោលដៅបង្កិតសាលារៀនឱ្យទៅជិតលំនៅឋានរបស់ប្រជាជន ស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ ជាលទ្ធផលក្នុងរយៈពេល ១០ឆ្នាំកន្លងមកនេះ វិស័យអប់រំសម្រេចបាន តាមរយៈអន្តរាគមន៍មួយចំនួន ដូចជាការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្ដល់គ្រូបង្រៀន ការផ្ដល់ថវិកាដំណើរការសាលារៀន ការផ្ដល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ដែលបានបង្កលក្ខណៈឱ្យសិស្សានុសិស្ស និងនិស្សិតមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិត។ សាលាមត្តេយ្យសិក្សា និងសាលារៀនចំណេះទូទៅ (រដ្ឋ សហគមន៍ និងឯកជន) កើនពី ១៤ ៨៥២ នៅឆ្នាំសិក្សា២០១៣-២០១៤ ដល់ ១៨៨៣០ នៅឆ្នាំសិក្សា ២០២២-២០២៣ ក្នុងនោះសាលាមត្តេយ្យសិក្សា គ្រប់រូបភាព ៨ ៦០៧ សាលា/កន្លែង សាលាបឋមសិក្សា ៨ ០៦៧ អនុវិទ្យាល័យ ១ ៣៤០ វិទ្យាល័យ ៨១៦ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស មាន ១៩។ គិតត្រឹមខែមេសា ឆ្នាំ២០២៣ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** មាន ៤៥២២ ខ្នង ស្មើ ២៩៣៥១ បន្ទប់។

គ្រឹះស្ថានឧត្តមសិក្សាកើនពី ១១០ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១៣២ នៅឆ្នាំសិក្សា ២០២១-២០២២ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋកើនពី ៦៧ ដល់ ៨៤។ គ្រឹះស្ថានរដ្ឋ ៥ បានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល រួមមាន៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យជាតិបាត់ដំបង សាកលវិទ្យាល័យស្វាយរៀង សាកលវិទ្យាល័យជា ស៊ីមកំចាយមារ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។

កុមារតូចទទួលបានសេវាអប់រំគ្រប់រូបភាពកើនពី ២៤៩ ៤៩៩នាក់ ស្រី ១២១ ៩១២នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៣៨៧ ២៧៩នាក់ ស្រី ១៩៤ ០៧២នាក់ នៅឆ្នាំសិក្សា ២០២២-២០២៣។ កុមារអាយុ៥ឆ្នាំ កើនពី ១៧០ ៥២១នាក់ ស្រី ៨២ ៦៨៩នាក់ ដល់ ២១៣ ៨៣៤នាក់ ស្រី ១០៥ ៥៣៦នាក់ នៅឆ្នាំសិក្សា ២០២២-២០២៣។

សិស្សបឋមសិក្សាស្ថិតក្នុងរង្វង់ ២,១លាននាក់ នៅឆ្នាំសិក្សា២០១៣-២០១៤ ដល់ ២,២លាននាក់ នៅឆ្នាំសិក្សា២០២២-២០២៣។ ការចូលរៀននៅបឋមសិក្សាសម្រេចបានអត្រាពិតនៃការសិក្សាក្នុងរង្វង់ ៩៥,៧ ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣។

សិស្សមធ្យមសិក្សាបឋមភូមិកើនពី ៥៤០ ៥៥៤នាក់ ស្រី ២៦៨ ៨០៥នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៦៩៤ ១៦១នាក់ ស្រី ៣៦២ ៦៥៥នាក់ នៅឆ្នាំសិក្សា២០២២-២០២៣។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិកើនពី ៥៥,៣ភាគរយ ស្រី ៥៥,០ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៨៣,៧ភាគរយ ស្រី ៨៥,៩ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣។

សិស្សមធ្យមសិក្សាទុតិយភូមិកើនពី ២៩៣ ៩៣៧នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៤០១ ៦០៥នាក់ ស្រី ២១៨ ៥១៦នាក់ នៅឆ្នាំសិក្សា២០២២-២០២៣។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ កើនពី ២៤,៩ភាគរយ ស្រី ២៤,៩ភាគរយ នៅឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៣៩,៤ ភាគរយ ស្រី ៤៩,២ ភាគរយ នៅឆ្នាំសិក្សា២០២២-២០២៣។

សិស្សមធ្យមសិក្សាចំណេះទូទៅនិងបច្ចេកទេស កើនពី ៦៥៣នាក់ ស្រី ២៣៨នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៣ ២៥៩នាក់ ស្រី ១១៦០នាក់ នៅឆ្នាំសិក្សា២០២២-២០២៣។ ជំនាញបណ្តុះ-បណ្តាលរួមមាន៖ ជំនាញអគ្គិសនី ១ ២០៦នាក់ ស្រី ១៣៥នាក់ ជំនាញអេឡិចត្រូនិក ៤៩៩នាក់ ស្រី ១១០នាក់ ជំនាញបសុវប្បកម្ម ៣១៥នាក់ ស្រី ១៧៦នាក់ ជំនាញក្សេត្រសាស្ត្រ ៥៣០នាក់ ស្រី ៣១២ នាក់ ជំនាញមេកានិក ១២៨នាក់ ស្រី ២៣នាក់ ផ្នែកទេសចរណ៍ ៨៣នាក់ ស្រី ៥៦នាក់ ជំនាញកុំព្យូទ័រ ១៦៥នាក់ ស្រី ៩៥នាក់ ផ្នែកគណនេយ្យ ១២៥នាក់ ស្រី ៩៩នាក់ ជំនាញកែច្នៃអាហារ ១៥១នាក់ ស្រី ១៣៦ ជំនាញឌីជីថលមេឌៀឌីហ្សាញ ៥៧នាក់ ស្រី ១៨នាក់។

និស្សិតឧត្តមសិក្សាមាន ២៤៩ ០៩២នាក់ ស្រី ១០៣ ៦៧៤នាក់ នៅឆ្នាំសិក្សា ២០១៣-២០១៤ និង ២០៩ ០៥៩នាក់ ស្រី ៩៥ ៦១៩នាក់ នៅឆ្នាំសិក្សា ២០២១-២០២២។ ឆ្នាំសិក្សា ២០២១-២០២២ និស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង ២០ ២៣៥នាក់ ស្រី ៧ ៨៦៣នាក់។ និស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ ១៧៥ ៩៦២នាក់ ស្រី ៨៤ ៥៣៨នាក់។ និស្សិតសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៩ ៤៨៣នាក់ ស្រី ៣ ១៥៨នាក់។ និស្សិតសិក្សាថ្នាក់បណ្ឌិត ១ ២១៣នាក់ ស្រី ១៣៣នាក់។ ការសិក្សាជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា (STEAM) បានកើនពី ១៩,៦ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ២៥,៦ ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២។

## ការអប់រំកុមារតូច

អត្រាចូលរៀនរបស់កុមារអាយុ៥ឆ្នាំ គ្រប់រូបភាពមានកំណើនគួរឱ្យកត់សម្គាល់ក្នុងរង្វង់ ៥ភាគរយ នៅឆ្នាំសិក្សា២០១៩-២០២០។ ផ្ទុយមកវិញអត្រានេះបានធ្លាក់ចុះខ្លាំងនៅឆ្នាំសិក្សា២០២១-២០២២ ប្រមាណ ៣,៣ភាគរយ ក្រោយពីទទួលរងនូវផលប៉ះពាល់វិជ្ជមានដោយសារពីជំងឺកូវីដ-១៩។ ផ្អែកលើនិន្នាការនេះ ក្រសួងនិងដៃគូអភិវឌ្ឍន៍បានខិតខំប្រឹងប្រែងពង្រឹងកិច្ចអន្តរាគមន៍បន្ថែម ដើម្បីស្តារកំណើននៃការចូលរៀនឡើងវិញ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ជាលទ្ធផលនៃការអនុវត្តនៅឆ្នាំចុងក្រោយ អត្រានេះបានកើនឡើងខ្ពស់រហូតដល់ ៥,២ភាគរយ សម្រេចបានលើសពីចំណុចដៅដែលបានកំណត់នៅឆ្នាំ២០២៣ (រូបភាពទី១)។

## រូបភាពទី១៖អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាព




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

## ការអប់រំបឋមសិក្សា

អត្រាពិតនៃការសិក្សានៅបឋមសិក្សារក្សាបានកម្រិតខ្ពស់នៅចន្លោះពី ៩៧ ភាគរយ ដល់ ៩៨ ភាគរយ រហូតដល់ឆ្នាំសិក្សា ២០១៩-២០២០។ ផ្ទុយមកវិញ នៅឆ្នាំសិក្សា ២០២០-២០២១ អត្រានេះបានធ្លាក់ចុះខ្លាំង រហូតដល់ ៦,១ភាគរយ ធៀបនឹងឆ្នាំសិក្សា ២០១៨-២០១៩។ នៅឆ្នាំសិក្សា ២០២១-២០២២ អត្រានេះ បានកើនឡើងបន្តិចវិញ ប៉ុន្តែសិស្សស្រីមានការឡើងខ្ពស់ជាងសិស្សប្រុស។ ចំពោះការចូលរៀនរបស់សិស្សនៅជនបទបានកើនឡើង ៩,៣ ភាគរយ ខណៈសិស្សនៅទីប្រជុំជនបានកើនឡើងត្រឹមតែ ១,៨ភាគរយ ប៉ុណ្ណោះ។ នៅឆ្នាំចុងក្រោយនៃការអនុវត្តផែនការនេះ ស្របពេលដែលសាលារៀនបានបើកដំណើរការឡើងវិញ អត្រាពិតនៃការសិក្សាហាក់មានកំណើនកាន់តែល្អប្រសើរឡើង បើទោះមិនសម្រេចតាមចំណុចដៅ ដែលកំណត់ នៅឆ្នាំ២០២៣។ (រូបភាពទី២)។

## រូបភាពទី២៖ អត្រាពិតនៃការសិក្សានៅបឋមសិក្សា




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

អត្រារួមនៃការសិក្សានៅបឋមសិក្សាបានថយចុះច្រើនរហូតដល់ជាង ១០ភាគរយ នៅចន្លោះពីឆ្នាំគោល ២០១៧-២០១៨ ដល់ ឆ្នាំសិក្សា២០២០-២០២១។ និន្នាការនេះបង្ហាញថា ការចូលរៀនរបស់កុមារកាន់តែមានភាពល្អប្រសើរ ក្នុងន័យនេះបញ្ជាក់ថា អាយុចូលរៀនរបស់កុមារក្នុងវ័យសិក្សានៅបឋម

សិក្សាមានភាពត្រឹមត្រូវច្រើនទៅតាមភូមិសិក្សារបស់ខ្លួន។ ផ្ទុយមកវិញ នៅឆ្នាំសិក្សា ២០២១-២០២២ អត្រានេះបានបន្តកើនឡើងវិញ ៧,៥ ភាគរយ។ ចំពោះសិស្សប្រុស និងសិស្សស្រីបានកើនឡើងខ្ពស់ផងដែរ នៅចន្លោះពី ៦ភាគរយ ទៅ ៩ភាគរយ ប៉ុន្តែគេសង្កេតឃើញថាសិស្សស្រីកើនឡើងខ្ពស់ជាងសិស្សប្រុស ២,៧ភាគរយ។ ការកើនឡើង នៃអត្រានេះអាចបណ្ដាលមកពីកត្តាមួយចំនួនដូចជា ការចូលរៀនយឺត ឬ ការចូលរៀនមិនបានត្រឹមត្រូវទៅតាមអាយុរបស់កុមារក្នុងវ័យសិក្សា និងបញ្ហាការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យកុមារបាត់បង់ការសិក្សាជាច្រើននៅក្នុងអំឡុងពេលនោះ ជាហេតុនាំឱ្យកុមាររៀនយឺត និងប្រឈមនឹងការរៀនត្រួតថ្នាក់នៅឆ្នាំសិក្សាបន្ទាប់។ នៅឆ្នាំអនុវត្តចុងក្រោយ អត្រានេះសម្រេចបានលទ្ធផលលើសពីការរំពឹងទុក លើសពីចំណុចដៅដែលបានកំណត់នៅឆ្នាំ២០២៣ (រូបភាពទី៣)។

**រូបភាពទី៣៖ អត្រារួមនៃការសិក្សានៅបឋមសិក្សា**




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាបានធ្លាក់ចុះបន្តិច នៅឆ្នាំដំបូងនៃការអនុវត្តផែនការនេះ បើធៀបនឹងឆ្នាំគោល ២០១៧-២០១៨។ អត្រានេះបានកើនឡើងខ្ពស់រហូតដល់ ៦ភាគរយ ពីឆ្នាំសិក្សា ២០១៨-២០១៩ ដល់ឆ្នាំសិក្សា ២០២១-២០២២ សម្រេចលើសពីចំណុចដៅនៅឆ្នាំ២០២៣ទៀត។ ចំណែកអត្រាកំណើនបញ្ចប់ការសិក្សារបស់សិស្សប្រុសបានកើនឡើង ១១ភាគរយ ខណៈដែលសិស្សស្រីកើនត្រឹមតែ ៨,៣ភាគរយ ប៉ុន្តែអត្រាបញ្ចប់ការសិក្សារបស់សិស្សស្រីបានឈានដល់កម្រិតមួយខ្ពស់រហូតដល់ ៩៤,៣ភាគរយ ដែលសិស្សប្រុសសម្រេចបានត្រឹមតែ ៨៩,២ភាគរយ។ ជាលទ្ធផលរួមនៃការអនុវត្តនៅឆ្នាំចុងក្រោយ អត្រានេះបានធ្លាក់ចុះបន្តិចប្រមាណ ១,៣ភាគរយ។ ទោះយ៉ាងណាលទ្ធផលនេះនៅតែសម្រេចបានលើសពីចំណុចដៅដែលបានកំណត់នៅឆ្នាំ២០២៣ (រូបភាពទី៤)។

### រូបភាពទី៤៖ អត្រាបញ្ចប់នៃការសិក្សានៅបឋមសិក្សា




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

## ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ បានកើនឡើងតិចតួចចាប់ពីឆ្នាំគោល២០១៧-២០១៨ ដល់ឆ្នាំសិក្សា ២០២០-២០២១ ត្រឹមតែ ១,៥ភាគរយ ប៉ុណ្ណោះ។ មូលហេតុនេះអាចបណ្តាលមកពីការបាត់បង់ការសិក្សាដោយសារបញ្ហារីករាលដាលនៃជំងឺកូវីដ-១៩ សមត្ថភាពសិក្សារបស់សិស្សនៅមិនទាន់សមស្របទៅតាមកម្រិតថ្នាក់ ទាំងនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងសាលារៀននៅតាមតំបន់មួយចំនួននៅឆ្ងាយពីផ្ទះរបស់សិស្ស។ ផ្ទុយមកវិញ អត្រារួមនៃការសិក្សាបានកើនឡើងគួរឱ្យកត់សម្គាល់នៅឆ្នាំសិក្សា ២០២១-២០២២ រហូតដល់ ៧,៩ភាគរយ នៅពេលដែលសាលានៅទូទាំងប្រទេសបានបើកដំណើរការឡើងវិញក្រោយបញ្ហារីករាលនៃជំងឺកូវីដ-១៩បានធូរស្រាល ហើយលទ្ធផលដែលសម្រេចនេះលើសពីចំណុចដៅនៅឆ្នាំ២០២៣ទៀត។ ជាលទ្ធផលនៃការអនុវត្តនៅឆ្នាំចុងក្រោយអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិមានការកើនឡើងតិចតួច និងមិនអាចសម្រេចចំណុចដៅដែលបានកំណត់នៅឆ្នាំ២០២៣ (រូបភាពទី៥)។

### រូបភាពទី៥៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិបានកើនឡើងតិចតួច នៅក្នុងអំឡុងពេលអនុវត្តផែនការរយៈពេល៣ឆ្នាំ។ អត្រានេះមានកំណើនត្រឹមតែ ១,៦ភាគរយ ប៉ុណ្ណោះ បើធៀបនឹងឆ្នាំគោល ២០១៧-២០១៨។ មូលហេតុនេះ ដោយសារបញ្ហានៃការរីករាលដាលជំងឺកូវីដ-១៩ ដែលមិនអាចឱ្យសិស្សបន្តរៀន នៅក្នុងថ្នាក់រៀន ដោយផ្ទាល់បានតម្រូវសិស្សត្រូវរៀនតាមអនឡាញ រៀនតាមបណ្ដុំ រៀនពីចម្ងាយ និងតាមមធ្យោបាយផ្សេងៗទៀត។ លើសពីនេះទៀត សិស្សមួយចំនួនដែលរស់នៅក្នុងតំបន់ជួបការលំបាកមិនមាន លទ្ធភាពទទួលបានការរៀនពីចម្ងាយ ឬតាមអនឡាញ ពីព្រោះសិស្សទាំងនោះមិនមានឧបករណ៍សិក្សាតាមបែបឌីជីថល មិនមានសេវាអ៊ីនធឺណិត និងពុំមានបណ្ដាញអគ្គិសនីប្រើប្រាស់។ ផ្ទុយមកវិញ អត្រាបញ្ចប់ការសិក្សាបានកើនឡើងខ្ពស់ពី ៤៨,១ភាគរយ នៅឆ្នាំសិក្សា ២០២០-២០២១ ដល់ ៥៦,៥ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២ ខ្ពស់ជាងចំណុចដៅឆ្នាំ២០២៣ទៀត។ នៅឆ្នាំចុងក្រោយ អត្រានេះសម្រេចបានរហូតដល់ ៥៩,៧ ភាគរយ លើសពីចំណុចដៅឆ្នាំ២០២៣ ប្រមាណ ៧,១ភាគរយ (រូបភាពទី៦)។

**រូបភាពទី៦៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ**




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ មានកំណើនជាវិជ្ជមានជារៀងរាល់ឆ្នាំ បើធៀបនឹងឆ្នាំគោល ២០១៧-២០១៨ ទោះបីជា មិនសម្រេចចំណុចដៅដែលរំពឹងទុកតាមឆ្នាំនីមួយៗក៏ដោយ។ អត្រានេះមានកំណើន ៣,៧ភាគរយ ក្នុងរយៈពេល៣ឆ្នាំកន្លងមក។ ទន្ទឹមនឹងនេះ អត្រាចូលរៀនរបស់សិស្សស្រី នៅតែបន្តខ្ពស់ជាងសិស្សប្រុស។ លើសពីនេះទៀត អត្រារួមនៃការសិក្សានេះសម្រេចបានរហូតដល់ ៣៩,៤ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២ លើសពីចំណុចដៅឆ្នាំ២០២៣ទៀត។ ចំពោះអត្រាចូលរៀនរបស់សិស្សទាំងពីរភេទបានកើនឡើងខ្ពស់ ប៉ុន្តែសិស្សស្រីកាន់មានភាពល្អប្រសើរឡើងជាងសិស្សប្រុស។ អត្រាគម្លាតនៃការចូលរៀនរវាងសិស្សទាំងពីរភេទបានកើនដល់ ៨,៣ភាគរយ នៅឆ្នាំសិក្សា២០២១-២០២២ ខណៈដែលនៅសិក្សាឆ្នាំ២០២០-២០២១ អត្រានេះមានត្រឹមតែ ៣,៨ភាគរយ។ នៅឆ្នាំចុងក្រោយ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិសម្រេចបានរហូតដល់ ៤៤,២ភាគរយ លើសពីចំណុចដៅឆ្នាំ២០២៣ ប្រមាណ ៦,២ភាគរយ (រូបភាពទី៧)។

### រូបភាពទី៧៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

ចំនួនសិស្សក្នុងការអប់រំចំណេះទូទៅនិងបច្ចេកទេស មានកំណើនគួរឱ្យកត់សម្គាល់ក្នុងពេលកន្លងមក។ ការចុះឈ្មោះចូលរៀនបានកើនពី ១ ៤៧១នាក់ នៅឆ្នាំសិក្សា ២០១៧-២០១៨ ដល់ ៣ ៣២៤នាក់ នៅឆ្នាំសិក្សា ២០២០-២០២១។ នៅឆ្នាំដំបូង ការចុះឈ្មោះចូលរៀនកើនឡើងបានច្រើនរហូតដល់ ៦៣២នាក់ ខណៈដែល២ឆ្នាំសិក្សាបន្ទាប់ បានថយចុះមកនូវត្រឹម ៦១៤នាក់ និង៦០៧នាក់។ ផ្ទុយមកវិញ ការចូលរៀននេះ បានធ្លាក់ ចុះពី ៣ ៣២៤នាក់ នៅឆ្នាំសិក្សា២០២០-២០២១ មកនៅត្រឹម ៣ ២៥៩នាក់ នៅឆ្នាំសិក្សា២០២២-២០២៣។ បញ្ហានៃការធ្លាក់ចុះនេះ បណ្តាលមកពីខ្វះអន្តេវាសិកដ្ឋានសម្រាប់សិស្សមកពីបណ្តាខេត្តឆ្ងាយៗ និងការផ្តល់អាហារូបករណ៍នៅមានកម្រិតនៅឡើយសម្រាប់ការអប់រំបច្ចេកទេស។ លើសពីនេះទៀត ការអនុវត្តសកម្មភាព ប្រតិបត្តិទ្រឹស្តីផ្សារភ្ជាប់នឹងជំនាញបច្ចេកទេសនៅតាមសហគមន៍ ត្រូវបានផ្អាកដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ រួមទាំងកម្មវិធីចុះកម្មសិក្សាផងដែរ (រូបភាពទី៨)។

### រូបភាពទី៨៖ ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស




*ប្រភព៖ ក្រសួងអប់រំ យុវជន និងកីឡា*

ចាប់ពីឆ្នាំសិក្សា ២០១៧-២០១៨ ដល់ឆ្នាំសិក្សា ២០២១-២០២២ សិស្សផ្នែកអប់រំបច្ចេកទេសដែលបានបញ្ចប់ការសិក្សាដោយជោគជ័យចំនួន ២៦០៤នាក់ ស្រី ១ ០២៦នាក់ ក្នុងនោះនិទ្ទេស A មាន

ចំនួន ១៨នាក់ ស្រី ១១នាក់ និទ្ទេស B ចំនួន ១៨៨នាក់ ស្រី ៩៩នាក់ និទ្ទេស C ចំនួន៥៧១នាក់ ស្រី ២៦១នាក់ និទ្ទេស D ចំនួន ៩៩២នាក់ ស្រី ៣៦៥នាក់ និង និទ្ទេស E ចំនួន ៨៣៥នាក់ ស្រី ២៩០ នាក់។

ក្នុងចំណោមសិស្សដែលបានបញ្ចប់ការសិក្សាផ្នែកអប់រំបច្ចេកទេសចំនួន ២ ៦០៤នាក់ ស្រី ១ ០៥៥ នាក់ សិស្សបានចូលបម្រើការងារតាមស្ថាប័នរដ្ឋចំនួន ៣៥នាក់ ស្រី ១៣នាក់ ស្មើនឹង ១,៣៤ភាគរយ ការងារក្រុមហ៊ុនឯកជនចំនួន ៧៩៤នាក់ ស្រី ៣០៤នាក់ ស្មើនឹង ៣០,៤៩ភាគរយ ប្រកបអាជីវកម្មខ្លួនឯងចំនួន ២២៦នាក់ ស្រី ១១២នាក់ ស្មើនឹង ៨,៦៨ភាគរយ និងបន្តការសិក្សាជំនាញរបស់ពួកគេនៅឧត្តមសិក្សា ឬនៅតាម គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈចំនួន ១ ៣០៥នាក់ ស្រី ៤៩៦នាក់ ស្មើនឹង ៥០,១២ភាគរយ ដោយឡែក ៩,៣៧ភាគរយ ទៀតមិនមានព័ត៌មានជាក់លាក់។

## ការអប់រំក្រៅប្រព័ន្ធ

ការអប់រំក្រៅប្រព័ន្ធបានអនុវត្តកម្មវិធីចំនួន ៧ រួមមាន កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ក្រោយអក្ខរកម្ម ចូលរៀនឡើងវិញ បង្កើនប្រាក់ចំណូល សមមូលបឋមសិក្សា សមមូលមធ្យមសិក្សាបឋមភូមិ និងកម្មវិធីបំពេញវិជ្ជា។

ចាប់ពីឆ្នាំសិក្សា ២០១២-២០១៣ ដល់ឆ្នាំសិក្សា ២០២១-២០២២ អ្នកសិក្សាបានចូលរៀនកម្មវិធីអប់រំក្រៅប្រព័ន្ធសរុប ៧០ ៧៤១នាក់ ស្រី ៣៨ ៣៩១នាក់ នៅឆ្នាំសិក្សា ២០១២-២០១៣ បានថយមកត្រឹម ៥០ ២៥៥នាក់ ស្រី ២៦ ៦៧៧នាក់ នៅឆ្នាំសិក្សា ២០២១-២០២២ និងអ្នកសិក្សាបានបញ្ចប់កម្មវិធីសរុប ៥៥ ៨០៨នាក់ ស្រី ៣១ ៣៦១នាក់ នៅឆ្នាំសិក្សា ២០១២-២០១៣ បានថយមកត្រឹម ៣៨ ៨០០នាក់ ស្រី ២១ ៦១៤នាក់ នៅឆ្នាំសិក្សា ២០២១-២០២២។

តាមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ និងគោលនយោបាយជាតិស្តីពី ការអប់រំពេញមួយជីវិត ក្រសួងមានគោលដៅប្រែក្លាយមជ្ឈមណ្ឌលសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ មជ្ឈមណ្ឌលសិក្សាសហគមន៍ ២៤ នៅក្នុងខេត្ត៧ (ខេត្តកំពត កំពង់ឆ្នាំង ព្រះវិហារ កណ្តាល ពោធិ៍សាត់ ប៉ៃលិន និងសៀមរាប) បានប្រែក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។

អត្រាអក្ខរកម្មជនពេញវ័យអាយុ១៥ឆ្នាំឡើង នៅឆ្នាំ២០១៣ មាន ៨០,៧ភាគរយ និងបានថយចុះមកត្រឹម ៧៨,១ភាគរយ នៅឆ្នាំ២០១៤។ នៅឆ្នាំ២០១៥ ក្រសួងបានសហការជាមួយអង្គការយូណេស្កូ រៀបចំយុទ្ធនាការអក្ខរកម្មជាតិ បានធ្វើឱ្យអត្រាអក្ខរកម្មក្នុងឆ្នាំ២០១៦ កើនឡើងដល់ ៨៤,៥ភាគរយ។ ប៉ុន្តែអត្រា នេះបានបង្ហាញអំពីវឌ្ឍនភាពតិចតួចនៅចន្លោះឆ្នាំ២០១៧ ដល់ឆ្នាំ២០១៩-២០២០ ប៉ុន្តែនៅឆ្នាំ២០២១ អត្រានេះបានកើនឡើងរហូតដល់ ៨៤,៧ភាគរយ។

## ១.២ វឌ្ឍនភាពផ្នែកគុណវិស័យ

### ១.២.១ ការងារអធិការកិច្ច

ក្រសួងបានដាក់ចេញនូវបញ្ញត្តិជានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា ក្នុងគោលបំណងកំណត់ភារកិច្ច និងតួនាទីអធិការអប់រំ ដើម្បីធ្វើអធិការកិច្ចនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន និងការពង្រឹងសមត្ថភាពស្ថាប័ន។ ការងារអធិការកិច្ចសាលារៀន ក្នុងគោល

បំណងពិនិត្យតាមដាន និងវាយតម្លៃសាលារៀនទាំងមូលជាប្រព័ន្ធលើផ្នែកសំខាន់បួនគឺ៖ ១).ការដឹកនាំ និងការគ្រប់គ្រង ២).ការបង្រៀននិងការរៀន ៣).លទ្ធផលសិក្សារបស់សិស្ស និង៤).ការចូលរួមរបស់សហគមន៍ មាតាបិតា និងអាណាព្យាបាល។ កិច្ចសហការយ៉ាងជិតស្និទ្ធជាមួយការិយាល័យជំនាញមន្ទីរ និងក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្វើឱ្យការងារអធិការកិច្ចបានជួយយ៉ាងច្រើនដល់ដំណើរការបង្រៀន និងរៀន និងលទ្ធផលសិក្សារបស់សិស្ស។ តាមរយៈការពង្រឹងសមត្ថភាពស្ថាប័ន ប្រព័ន្ធអធិការកិច្ចជានាគុណភាពអប់រំ បានជួយយ៉ាងមានប្រសិទ្ធភាពដល់ការងារអធិការកិច្ច មន្ត្រីការិយាល័យដែលមិនមែនអធិការមានសមត្ថភាព ធ្វើអធិការកិច្ចសាលារៀន ដូចជាការប្រមូលព័ត៌មានតាមរយៈការសម្ភាសន៍ សង្កេត ផ្តល់ព័ត៌មានត្រឡប់ អនុសាសន៍ វិភាគ វាយតម្លៃ និងសរសេររបាយការណ៍អធិការកិច្ចដែលរួមចំណែកយ៉ាងខ្លាំងដល់ក្រសួងអប់រំ យុវជន និងកីឡាកំពុងខ្វះខាតអធិការអប់រំ។

ក្រុមបំប៉ន និងពិនិត្យតាមដាននៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រធានកម្រង នាយកសាលារៀន និងប្រធានក្រុមបច្ចេកទេសមានសមត្ថភាពវាស់វែងលទ្ធផលនៃការបំពេញការងារ តាមរយៈការធ្វើស្វ័យវាយតម្លៃសាលារៀន និងការពិនិត្យតាមដានការបង្រៀន និងរៀនដោយប្រើប្រាស់ឧបករណ៍សង្កេតការបង្រៀន និងសរសេររបាយការណ៍។

តាមរយៈលទ្ធផលរបាយការណ៍អធិការកិច្ចតាមប្រធានបទ បានជួយជំរុញដល់ការអនុវត្តកំណែទម្រង់ចាប់ពីថ្នាក់ជាតិរហូតដល់កម្រិតសាលារៀន ដូចជាថ្នាក់ជាតិបានផ្តល់ការគាំទ្រ និងអន្តរាគមន៍បានទាន់ពេលវេលាដល់សាលារៀនដែលមានតម្រូវការជាអាទិភាពដូចជា ផ្គត់ផ្គង់សៀវភៅសិក្សាគោល គ្រូបង្រៀនកញ្ចប់អំណានថ្នាក់ដំបូង។

ក្រសួងបានកែលម្អកម្មវិធីបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យ និងវិក្រឹតការ ដូចជាបញ្ចូលមុខវិជ្ជាការអនុវត្តកម្មវិធីសិក្សាសម្រាប់គរុសិស្ស ការងារអធិការកិច្ចផ្ទៃក្នុងការធ្វើស្វ័យវាយតម្លៃសាលារៀន និងថ្នាក់រៀន។

ផលជះនៃការងារអធិការកិច្ចកម្រិតសាលារៀន បង្ហាញថា គ្រូបង្រៀននៅសាលារៀនភាគច្រើនយកចិត្តទុកដាក់អនុវត្តសកម្មភាព និងវិធីសាស្ត្របង្រៀនឆ្លើយតបនឹងតម្រូវការសិស្ស ដើម្បីឈានទៅរកការកែលម្អ លទ្ធផលសិក្សាសិស្សគ្រប់មុខវិជ្ជា។ គ្រូបង្រៀនបានវាយតម្លៃ និងដាក់ពិន្ទុប្រកបដោយសមធម៌ យុត្តិធម៌ និង តម្លាភាព គ្រូបង្រៀនបានយកចិត្តទុកដាក់លើការវាយតម្លៃ និងដាក់ពិន្ទុសិស្សប្រកបដោយការទទួលខុសត្រូវ មានការរៀបចំបញ្ជីពិន្ទុ និងបិទផ្សាយលទ្ធផលសិក្សា ជាពិសេសអនុញ្ញាតឱ្យសិស្សពិនិត្យពិន្ទុឡើងវិញ ដែលនាំឱ្យពួកគេពេញចិត្តនឹងការដាក់ពិន្ទុរបស់គ្រូបង្រៀន។

## ១.២.២ វង្វាយតម្លៃលទ្ធផលសិក្សា

ដើម្បីលើកកម្ពស់គុណភាព និងការឆ្លើយតបរបស់សេវាអប់រំ ក្រសួងបានសម្រេច និងកំពុងអនុវត្តកិច្ចការសំខាន់ៗដូចជា ការអនុវត្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៣ ថ្នាក់ទី៦ ថ្នាក់ទី៨ និងថ្នាក់ទី១១ ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយសម្រាប់វាយតម្លៃគុណភាពអប់រំ ជាពិសេសគុណភាពអប់រំទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស។ លទ្ធផលនៃការអនុវត្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ថ្នាក់ទី៦ ថ្នាក់ទី៨ និងថ្នាក់ទី១១ មានដូចខាងក្រោម៖

- ថ្នាក់ទី៣ អនុវត្តបានចំនួន ២វដ្ត ដោយទទួលបានភាគរយឆ្លើយត្រូវនៅឆ្នាំ២០១៥ ភាសាខ្មែរ ៣៥% និងគណិតវិទ្យា ៤១% និងឆ្នាំ២០១៩ ភាសាខ្មែរ ៣៤% និងគណិតវិទ្យា ៤០%
- ថ្នាក់ទី៦ អនុវត្តបានចំនួន ៣វដ្ត ដោយទទួលបានភាគរយឆ្លើយត្រូវ នៅឆ្នាំ២០១៣ ភាសាខ្មែរ ៤៦% និងគណិតវិទ្យា ៤៣% និងឆ្នាំ២០១៦ ភាសាខ្មែរ ៥២% និងគណិតវិទ្យា ៤៨% ចំណែកនៅឆ្នាំ២០២១ ភាសាខ្មែរ ៤៦% និងគណិតវិទ្យា ៣៨%
- ថ្នាក់ទី៨ អនុវត្តបានចំនួន ៣វដ្ត ដោយទទួលបានភាគរយឆ្លើយត្រូវ នៅឆ្នាំ២០១៤ ភាសាខ្មែរ ៥៦% គណិតវិទ្យា ៤៤% និងរូបវិទ្យា ៥៣% និងឆ្នាំ២០១៧ ភាសាខ្មែរ ៥៤% គណិតវិទ្យា ៤៧% និងរូបវិទ្យា ៤៦% ចំណែកឆ្នាំ២០២២ ភាសាខ្មែរ ៥៤% គណិតវិទ្យា ៤៣% និងរូបវិទ្យា ៤២%
- ថ្នាក់ទី១១ អនុវត្តបានចំនួន ១វដ្ត ដោយទទួលបានភាគរយឆ្លើយត្រូវ នៅឆ្នាំ២០១៧ ភាសាខ្មែរ ៥៧% គណិតវិទ្យា ៣៨% និងរូបវិទ្យា ៣៥%
- ចូលរួមអនុវត្តវង្វាយតម្លៃការសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) ផ្ដោតលើសិស្សថ្នាក់ទី៥ អនុវត្តបាន ១វដ្ត នៅឆ្នាំ២០១៩ ដោយទទួលបានលទ្ធផល អំណាន ២៩០ពិន្ទុ សំណេរ ២៨៥ពិន្ទុ និងគណិតវិទ្យា ២៨៩ពិន្ទុ

កម្ពុជាបានចូលរួមអនុវត្តកម្មវិធីអន្តរជាតិស្ដីពី វង្វាយតម្លៃការសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ (PISA-D) ដែលផ្ដោតលើសិស្សអាយុ១៥ឆ្នាំ នៅកម្រិតមធ្យមសិក្សាចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២។ ក្រសួងអនុវត្តកិច្ចការនេះបាន ១វដ្ត នៅឆ្នាំ២០១៧ ដោយទទួលបានលទ្ធផលអំណាន ៣២១ពិន្ទុ គណិតវិទ្យា ៣២៥ពិន្ទុ និង វិទ្យាសាស្ត្រ ៣៣០ពិន្ទុ។

លទ្ធផលទាំងអស់ខាងលើបានឆ្លុះបញ្ចាំងពីឆន្ទៈ នៃការអនុវត្តកំណែទម្រង់អប់រំប្រកបដោយគណនេយ្យភាពខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្លើយតបនឹងស្តង់ដាអប់រំថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ។ គ្រប់ព័ត៌មាន ដែលវិភាគចេញពីទិន្នន័យប្រមូលបានពីតេស្តវង្វាយតម្លៃការសិក្សារបស់សិស្ស គឺជាទឡ្ហីករណ៍ដ៏សំខាន់សម្រាប់វាយតម្លៃទិដ្ឋភាព និងមុខងារសំខាន់ៗរបស់ប្រព័ន្ធអប់រំ ព្រមទាំងអាចក្លាយជាមូលដ្ឋានដ៏មានតម្លៃសម្រាប់ធ្វើការកែលម្អគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ១.២.៣ ការប្រឡងសញ្ញាបត្រមធ្យមសិក្សាចំណេះទូទៅ និងបំពេញវិជ្ជា

ចាប់ពីឆ្នាំ២០១៣ ដល់ ឆ្នាំ២០២៣ បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិក្នុងរង្វង់ ៩៨ភាគរយ។ ដោយឡែក ក្នុងឆ្នាំសិក្សា ២០១៩-២០២០ បេក្ខជនប្រឡងសញ្ញាបត្របឋមភូមិ និងទុតិយភូមិត្រូវបាន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** សម្រេចអនុញ្ញាតឱ្យជាប់ ១០០ភាគរយ ដោយសារការរីករាលដាលជំងឺកូវីដ-១៩។

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ បានប្រព្រឹត្តទៅដោយរលូនស្របតាមគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន, ស្របតាមលក្ខណៈបច្ចេកទេសប្រឡង និងស្របតាមទស្សនាទាន «**អ្នកចេះ គឺជាប់**» ព្រមទាំងក្រោមការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាល និងកិច្ចសហការ

យ៉ាងជិតស្និទ្ធពីសំណាក់ក្រសួងមហាផ្ទៃ អង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងសុខាភិបាល អាជ្ញាធរដែនដី កងកម្លាំង សហភាពសហព័ន្ធយុវជនកម្ពុជា អគ្គិសនីកម្ពុជា ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត យុវជនសម្តេចតេជោ និងគ្រប់ភាគីពាក់ព័ន្ធដទៃទៀត ជាពិសេស ការខិតខំប្រឹងប្រែងរៀនសូត្រផ្ទាល់របស់បេក្ខជន ព្រមទាំងការអនុវត្តភារកិច្ចប្រកបដោយភាពម៉ត់ចត់ វិជ្ជាជីវៈ មនសិការការងារ និងស្មារតីទទួលខុសត្រូវខ្ពស់របស់គណៈមេប្រយោគ និងគណៈកម្មការនានាគ្រប់ថ្នាក់។ លទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២។

## ១.៣ វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់

### ១.៣.១ កំណែទម្រង់ដំណាក់កាលទី១

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ស្ថាបនិក ឯកនយោបាយឈ្នះ-ឈ្នះ កម្ពុជាសម្រេចបាននូវសុខសន្តិភាពពេញលេញ ឯកភាពទឹកដី ដែលមិនធ្លាប់មាន ក្នុងរយៈពេលជាង ៥០០ឆ្នាំកន្លងទៅ។ ក្រោមម្លប់ដ៏ត្រជាក់នៃសន្តិភាព កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ច ជាមធ្យមចំនួន៧% ក្នុងរយៈពេល ២ទសវត្សរ៍កន្លងទៅនេះ។ សន្តិភាព គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ សេដ្ឋកិច្ច និងសង្គមក្នុងគ្រប់វិស័យ។ រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយចំណាយយោធា និងសន្តិសុខ ដើម្បីបង្កើន ថវិកាសម្រាប់វិស័យអប់រំ ជាពិសេសការដំឡើងបៀវត្សដល់ គ្រូបង្រៀន និងមន្ត្រីរាជការ និងការកសាង អគារសិក្សាថ្មីៗជាច្រើននៅទូទាំងប្រទេស។

ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដើម្បីប្រែប្រទេសកម្ពុជា ឱ្យទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ និងប្រទេសមានប្រាក់ចំណូលខ្ពស់ ក្នុងឆ្នាំ២០៥០ នៅក្នុងឆ្នាំ២០១៣ នៅដើមអាណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា ដោយទទួលបានការអនុម័តពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកំណែទម្រង់ ៨ចំណុច រួមមាន៖ ១.ការបង្កើនគុណភាព អប់រំ ២.ការពង្រឹងការគ្រប់គ្រងបុគ្គលិកអប់រំ ៣.ការពង្រឹងការប្រឡងគ្រប់ប្រភេទ ៤.កំណែទម្រង់ឧត្តមសិក្សា, ៥.ការអភិវឌ្ឍយុវជននូវជំនាញបច្ចេកទេស និងជំនាញទន់ ៦.កំណែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៧.កំណែទម្រង់ការអប់រំកាយនិងកីឡា និង ៨.ការបង្កើតអង្គភាពស្រាវជ្រាវគោលនយោបាយអប់រំ។

**លទ្ធផលធំៗនៃកំណែទម្រង់នៅដំណាក់កាលទី១ រួមមាន៖**

១. **ការគ្រប់គ្រងបុគ្គលិក៖** រាជរដ្ឋាភិបាលបានផ្តល់អាទិភាពដល់ការដំឡើងបៀវត្សដល់បុគ្គលិកអប់រំ ដែល មកទល់ពេលនេះ បៀវត្សមន្ត្រីអប់រំបានកើនឡើងជិត៣ដង។ ម្យ៉ាងវិញទៀត បៀវត្សត្រូវបានបើកផ្តល់ដល់បុគ្គលិកអប់រំ និងថវិកាដំណើរការសាលារៀនត្រូវបានផ្ទេរផ្ទាល់ទៅសាលារៀន តាមប្រព័ន្ធធនាគារទៀតផង។

២. **កំណែទម្រង់ការប្រឡង៖** ក្រសួងបានផ្ទេរការទទួលខុសត្រូវការប្រឡងថ្នាក់ទី៩ ដល់ថ្នាក់ក្រោមជាតិ ចាប់ផ្តើមអនុវត្តកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១២) ដោយឈរលើគោលការណ៍ "អ្នកចេះជាប់" ព្រមទាំងកែទម្រង់ការប្រឡងជ្រើសរើស គ្រូបង្រៀន ដើម្បីលើកទឹកចិត្ត ដល់សិស្សឆ្នើមចូលបម្រើការងារជាគ្រូបង្រៀន។

៣. **កំណែទម្រង់ឧត្តមសិក្សា៖** ក្រសួងបានផ្ទេរសិទ្ធិចុះហត្ថលេខាលើសន្លឹកសញ្ញាបត្រ ការបញ្ជាក់វិញ្ញាបនបត្របណ្ដោះអាសន្ននិងសន្លឹកសញ្ញាបត្រថតចម្លង និងការចេញសន្លឹកសញ្ញាបត្រលើកទី២ (ទុតិយតា) ជូនគ្រឹះស្ថានឧត្តមសិក្សាទទួលខុសត្រូវ។ ក្រសួងបានផ្អាកការស្នើសុំបើក គ្រឹះស្ថានឧត្តមសិក្សា តែអនុញ្ញាតដល់គ្រឹះស្ថានឧត្តមសិក្សាដែលផ្ដល់ការបណ្ដុះបណ្ដាលលើមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីទុកពេលឱ្យគ្រឹះស្ថានឧត្តមសិក្សាដែលមានអាជ្ញាបណ្ណស្រាប់ ពង្រឹងគុណភាពនៃការបណ្ដុះបណ្ដាល។ ក្រសួងបានជំរុញ និងលើកទឹកចិត្តឱ្យគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ពិនិត្យលទ្ធភាពក្នុងការប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និងផ្ដល់ស្វ័យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស។

៤. **កំណែទម្រង់ការអប់រំកាយ និងកីឡាដើម្បីត្រៀមឆ្ពោះទៅកីឡាស៊ីហ្គេម ឆ្នាំ២០២៣៖** ក្រសួងបានអនុម័តគោលនយោបាយស្ដីពីការអប់រំកាយ និងកីឡា បង្កើតគណៈកម្មការគ្រប់គ្រងពហុកីឡដ្ឋានជាតិ អូឡាំពិក និងចាប់ផ្ដើមអភិវឌ្ឍ និងបានផ្ដល់ការលើកទឹកចិត្តតាមគ្រប់រូបភាព ជាពិសេសការបង្កើនប្រាក់រង្វាន់សម្រាប់ជ័យលាភីដែលប្រកួតបានមេដាយ។

៥. **ការកែលម្អប្រសិទ្ធភាពនៃការផ្ដល់សេវាអប់រំ៖** ក្រសួងបានអនុម័តគោលនយោបាយជាតិ និងផែនការ សកម្មភាពជាតិ ស្ដីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច, ផ្ដួចផ្ដើមរៀបចំសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យ ព្រះស៊ីសុវត្ថិ, និងបង្កើនអាហារូបករណ៍ដល់សិស្សក្រីក្រនៅមធ្យមសិក្សាបឋមភូមិ។

## ១.៣.២ កំណែទម្រង់ដំណាក់កាលទី២

បន្ទាប់ពីអនុវត្តកំណែទម្រង់អប់រំ និងយោងទៅលើលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (នៅឆ្នាំ២០១៤ លទ្ធផលទទួលបានត្រឹមតែ១៥ភាគរយ នៅការប្រឡងលើកទី១ និង ២៥ ភាគរយ នៅការប្រឡងលើកទី២) ដែលបង្កើតបានជាចំណុចគន្លឹះ សម្រាប់ការដាក់ចេញនូវចក្ខុកំណែទម្រង់អប់រំនៅឆ្នាំ ២០១៥ ដោយផ្ដោតលើសសរស្ដម្ភប្រាំ រួមមាន៖ ១.ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ២.ការធ្វើអធិការកិច្ច, ៣.រង្វាយតម្លៃការសិក្សា ៤.ការកែលម្អកម្មវិធីសិក្សា ៥.កំណែទម្រង់ឧត្តមសិក្សា ដែលត្រូវក្លាយជាអាទិភាពកំណែទម្រង់១៥ចំណុច។ ជាលទ្ធផលធំៗ នៅដំណាក់កាលៗទី២ នៃកំណែទម្រង់ អប់រំពី ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ រួមមាន៖

**កំណែទម្រង់ទី១-ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖** ក្រសួងបានបង្កើតអង្គភាពថវិកាចំនួន ៣៩ នៅថ្នាក់ជាតិ និង២៥នៅថ្នាក់រាជធានី ខេត្ត ដើម្បីឱ្យអង្គភាពនីមួយៗមានទាំងគោលនយោបាយ និងថវិកាដើម្បីអនុវត្តគោលនយោបាយ ក្នុងគោលដៅពង្រឹងភាពជាម្ចាស់ និងសមត្ថភាពស្ថាប័ន និងសមត្ថភាពមន្ត្រីរាជការ ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់អង្គភាពថវិកា និងការបង្កើនថវិកាដំណើរការសាលារៀន និងថវិកាដំណើរការការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ព្រមទាំងផ្ដល់ថវិកាសម្រាប់ទិញបរិក្ខារកុំព្យូទ័រដល់សាលារៀន។

**កំណែទម្រង់ទី២ការពង្រាយគ្រូបង្រៀន៖** ក្រសួងបានរៀបចំគោលការណ៍នៃការគ្រប់គ្រងធនធានមនុស្ស និងដាក់ឱ្យអនុវត្តសេចក្ដីណែនាំស្ដីពីនិយាមប្រើប្រាស់បុគ្គលិក ដើម្បីដោះស្រាយបញ្ហាលើសខ្វះ

គ្រូបង្រៀន និងពង្រាយគ្រូបង្រៀនឱ្យដល់កន្លែងខ្វះគ្រូ, និងបានបញ្ចូលគ្រូខ្មែរឥស្លាម ១៤៤១នាក់ និងគ្រូជនជាតិដើមភាគតិច ២០នាក់ ទៅក្នុងក្របខណ្ឌរដ្ឋ។

**កំណែទម្រង់ទី៣-កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន៖** ក្រសួងបានប្រែក្លាយមជ្ឈមណ្ឌល គរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបងទៅជាវិទ្យាស្ថានគរុកោសល្យ និងដំឡើងកម្រិតបណ្តុះបណ្តាល គ្រូបង្រៀនកម្រិតមូលដ្ឋានពី១២+២ ទៅ ១២+៤ និងបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស។

**កំណែទម្រង់ទី៤-ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន៖** ក្រសួងបានបង្កើតគណៈកម្មការអភិវឌ្ឍធនធានគ្រូបង្រៀន និងអនុវត្តប្រព័ន្ធក្រេឌីតសម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំ កែលម្អលក្ខខណ្ឌជ្រើសរើសបេក្ខជនគ្រូបង្រៀន ដោយផ្តល់អាទិភាពលើបេក្ខជនមាននិទ្ទេស A, B, C, និងបំប៉នគ្រូបង្រៀនថ្នាក់ទី១២ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ។

**កំណែទម្រង់ទី៥-ការងារអធិការកិច្ច៖** ក្រសួងបានអនុម័តបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅនៅកម្ពុជា និងសេចក្តីណែនាំស្តីពីការអនុវត្តការងារ អធិការកិច្ចធានាគុណភាពអប់រំសម្រាប់រាជធានី ខេត្ត និង រៀបចំរចនាសម្ព័ន្ធអធិការកិច្ចនៅថ្នាក់ក្រោមជាតិ ជាតំបន់អធិការកិច្ច ៨តំបន់។

**កំណែទម្រង់ទី៦-វាយតម្លៃលទ្ធផលសិក្សា៖** ក្រសួងបានរៀបចំក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សា និង រៀបចំនីតិវិធីវាស់ស្ទង់សមត្ថភាពកម្រិតសមមូល, ធ្វើតេស្ត និងផ្សព្វផ្សាយលទ្ធផលវាយតម្លៃថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា, និងចូលរួមអនុវត្ត និងផ្សព្វផ្សាយកម្មវិធីតេស្តវាយ តម្លៃសិស្សកម្រិតអន្តរជាតិ សម្រាប់ការអភិវឌ្ឍ (PISA-D)។

**កំណែទម្រង់ទី៧-កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ៖** ក្រសួងបានបង្កើតនាយកដ្ឋានកិច្ចការប្រឡង និងបន្តអនុវត្តកំណែទម្រង់ការប្រឡង ដោយឈរលើគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព និងលទ្ធផលទទួលយកបាន ស្របតាមពាក្យស្លោក "អ្នកចេះគឺជាប់"។

**កំណែទម្រង់ទី៨-កំណែទម្រង់កម្មវិធីសិក្សានិងសៀវភៅសិក្សាគោល៖** ក្រសួងបានអនុម័តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសពីមត្តេយ្យសិក្សាដល់មធ្យមសិក្សា អនុម័តកម្មវិធីសិក្សាលម្អិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ គ្រប់មុខវិជ្ជា គ្រប់កម្រិតថ្នាក់។

**កំណែទម្រង់ទី៩-ការសាងសង់អគារសិក្សានិងការជួសជុល៖** ក្រសួងបានសាងសង់អគារសិក្សាមត្តេយ្យសិក្សាធនធាន ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងអគារសិក្សា។ ជាមួយគ្នានេះ នៅមុនពេលដែលជំងឺកូវីដ-១៩បានផ្ទុះឡើង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានចុះទៅពិនិត្យ ជ្រើសរើស និងសាងសង់អគារសិក្សាធំៗ «ស្តង់ដាតេជោ» ដែលមានគុណភាពខ្ពស់ មានច្រើនជាន់ ដើម្បីកែលម្អបរិស្ថានសិក្សា និងធានាការរៀន និងបង្រៀនមានផាសុខភាពផង ហើយជាពិសេស នៅជំនាន់នៃការរាតត្បាតនៃជំងឺកូវីដ-១៩ អគារ «តេជោ» ត្រូវបានប្រើប្រាស់ជាមណ្ឌលព្យាបាលផង និងចត្តាឡីស័ក្តិផង។

**កំណែទម្រង់ទី១០-ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា៖** ក្រសួងបានវាយតម្លៃទទួលស្គាល់គុណភាពឧត្តមសិក្សា និងអនុវត្តការធានាគុណភាពអប់រំ តាមស្តង់ដាធានាគុណភាពអប់រំផ្ទៃក្នុង សម្រាប់គ្រឹះស្ថានឧត្តមសិក្សា។

**កំណែទម្រង់ទី១១-ការលើកកម្ពស់វិស័យកីឡា៖** ក្រសួងបានបង្កើនចំណាយសម្រាប់ការប្រមូលផ្តុំហាត់ហ្វឹកហ្វឺនក្រុមជម្រើសជាតិ និងបង្កើនប្រាក់រង្វាន់ដល់ជ័យលាភី អនុម័តកម្មវិធីសិក្សាអប់រំកាយនៅមធ្យមសិក្សាបឋមភូមិ កំណត់គោលការណ៍រៀបចំប្រកួតកីឡាជាតិដោយប្រព្រឹត្តទៅរៀងរាល់ពីរឆ្នាំម្តង ធ្វើវិមជ្ឈការថវិកាដល់សហព័ន្ធកីឡាជាតិ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងជួសជុល និងកែលម្អពហុកីឡដ្ឋានជាតិអូឡាំពិក ព្រមទាំងកសាងហេដ្ឋារចនាសម្ព័ន្ធកីឡានៅតាមគ្រឹះស្ថានសិក្សា។ ការសម្រេចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការសាងសង់ពហុកីឡដ្ឋានមរតកតេជោ សម្រាប់ការរៀបចំការប្រកួតកីឡា អាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ គឺជាមរតក មិនអាចកាត់ថ្លៃបាន សម្រាប់ការអភិវឌ្ឍវិស័យកីឡានៅកម្ពុជា។

**កំណែទម្រង់ទី១២-ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន៖** ក្រសួងបានបង្កើតនាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ ដាក់ឱ្យដំណើរការមជ្ឈមណ្ឌលព័ត៌មានទីផ្សារនៅខេត្តមួយចំនួន រៀបចំកម្មវិធី សមមូលអប់រំមូលដ្ឋានតាមប្រព័ន្ធព័ត៌មានវិទ្យា (BEEP) ដំណើរការកម្មវិធីការចូលរួមរបស់យុវជន និងការងារ ស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ អនុវត្តកម្មវិធីការអប់រំសហគ្រិនភាពនៅតាមសហគមន៍ និងនៅតាមវិទ្យាល័យ។

**កំណែទម្រង់ទី១៣-ការអប់រំបច្ចេកទេស៖** ក្រសួងបានអនុម័តផែនការគោល និងផែនការសកម្មភាពស្តីពីការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ អនុម័តកម្មវិធីសិក្សាជំនាញថ្មីៗ ដែលទាក់ទងនឹងឌីជីថល និងបច្ចេកវិទ្យា និងសៀវភៅសិក្សាគោលផ្នែកអប់រំបច្ចេកទេស បង្កើតវិទ្យាល័យចំណេះទូទៅនិង បច្ចេកទេសរដ្ឋ និងឯកជនចំនួន ១៦ មជ្ឈមណ្ឌលអប់រំបច្ចេកទេសចំនួន ១ និងបង្កើតវិទ្យាស្ថានបច្ចេក វិទ្យា កំពង់ឈើទាល និង វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ។

**កំណែទម្រង់ទី១៤-ការបង្កើតសាលារៀនជំនាន់ថ្មី៖** ក្រសួងបានបង្កើតសាលារៀន ជំនាន់ថ្មីចំនួន ១១ ក្នុងនោះបឋមសិក្សា ៤ និងមធ្យមសិក្សា ៧។

**កំណែទម្រង់ទី១៥-ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា៖** ក្រសួងបានអនុម័តក្របខណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងរៀបចំក្របខណ្ឌផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលា និងគ្រូបង្រៀន។

### ១.៣.៣ កំណែទម្រង់ដំណាក់កាលទី៣

នៅឆ្នាំ២០១៧ ក្រសួងបានដាក់ចេញនូវកំណែទម្រង់ដំណាក់កាលទី៣ ដោយផ្តោតលើកំណែទម្រង់សាលារៀន ដែលរួមមានសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ និងកំណែទម្រង់សាលាគរុកោសល្យ។ ជាលទ្ធផលធំៗ នៅដំណាក់កាលទី៣ នៃកំណែទម្រង់អប់រំពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២២ រួមមាន៖

ក្រសួងបានបង្កើត**សាលារៀនជំនាន់ថ្មី**ចំនួន ១១កន្លែង (នៅបឋមសិក្សា ៤កន្លែង និងនៅមធ្យមសិក្សា ៧កន្លែង)។ ក្រសួងបានសាកល្បងរៀបចំ**សាលារៀនគំរូ ឬសាលារៀនមានប្រសិទ្ធភាព**ចំនួន ១០០

កន្លែង និងមានផលជះដល់សាលារៀនចំនួន៥០០ទៀត ដោយក្រសួងបានពង្រឹងការគ្រប់គ្រងតាមសាលារៀន ឆ្ពោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងផ្លាស់ប្តូរវប្បធម៌សាលារៀន ដោយផ្តោតលើ៖ ១).វាយតម្លៃសមត្ថភាពរបស់សិស្ស តាមរយៈការធ្វើតេស្តដោយតម្លាភាព ២).ការបង្កើនគណនេយ្យភាពរបស់សាលារៀន ៣).ការបង្កើនស្វ័យភាព និងសិទ្ធិអំណាច ក្នុងការសម្រេចចិត្តនៅកម្រិតសាលារៀន តាមរយៈគណៈកម្មការ គ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន ៤).ការបង្កើនការចូលរួមរបស់មាតាបិតា និងភាគី ពាក់ព័ន្ធនៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍសាលារៀន។

ក្រសួងបានធ្វើ**កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ** ដោយផ្តោតលើ៖ ១).ការកែលម្អកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការគ្រូ ២).ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេសលើផ្នែកខ្លឹមសារមេរៀន គរុកោសល្យ និងវិធីសាស្ត្របង្រៀនសម្បូរបែប និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន ៣).ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ និងសម្ភារឧបទេសទំនើបសម្បូរបែប ៤).ការអភិវឌ្ឍភាពជាអ្នកដឹកនាំ គ្រប់គ្រង ៥).ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ និង ៦).ការធានាគុណភាពនៃការបណ្តុះបណ្តាល។ ក្រសួងបានកែលម្អកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ដោយបានអនុម័ត និងដាក់ឱ្យប្រើប្រាស់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀនកម្រិតមូលដ្ឋាន (១២+២) តាមប្រព័ន្ធក្រេឌីត បញ្ចូលកញ្ចប់អំណានដំបូង និងគណិតវិទ្យាថ្នាក់ដំបូងទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា អនុម័តក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) និងអនុម័ត សៀវភៅណែនាំស្តីពី ការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។

ក្រសួងបានអនុម័តក្របខណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ព្រមទាំងបានអនុម័តក្របខណ្ឌ និងផែនការសកម្មភាព ស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀននិងនាយកសាលា និងដាក់ឱ្យអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយកម្រិតបរិញ្ញាបត្រ (១២+៤) នៅវិទ្យាស្ថានជាតិអប់រំកាយនិងកីឡា។ ក្រសួងបានបន្តអភិវឌ្ឍសមត្ថភាព និងពង្រឹងគុណភាពគ្រូឧទ្ទេស តាមរយៈការលើកកម្ពស់គុណវុឌ្ឍិ ការអនុម័តស្តង់ដាគ្រូឧទ្ទេស និងការអនុម័តគោលការណ៍ផ្តល់ឋានៈជាគ្រូឧទ្ទេស និងគ្រូឧទ្ទេសរងនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបងបន្ទាប់ពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅវិទ្យាស្ថានគរុកោសល្យទាំងពីរត្រូវបានបញ្ចប់ ដើម្បីធានានិរន្តរភាព និងការអភិវឌ្ឍ។

នៅក្នុងដំណាក់កាលនេះ ក្រសួងបានផ្តល់អាទិភាពខ្ពស់ផងដែរក្នុងការពង្រឹងគុណភាពនៃការអប់រំកម្រិតបឋមសិក្សាតាមរយៈ៖

ទី១. ការលើកកម្ពស់«អំណានដំបូង» តាមរយៈការផលិតកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង ដែលរួមមាន សៀវភៅណែនាំសម្រាប់គ្រូ សៀវភៅជំនួយសិស្ស បណ្ណអក្សរ-រូបភាព សៀវភៅហ្វឹកហាត់សរសេរ និងសៀវភៅរឿងចំនួន៦០ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ វិធីសាស្ត្របង្រៀនអំណានថ្នាក់ដំបូង មានគោលដៅ ស្គាល់សូរ ស្គាល់តួអក្សរ និងសូរ ការអានព្យាង្គនិងពាក្យ ការចេះវាក្យសព្ទ ការចេះអានស្ទាត់ ការចេះ អានយល់ន័យ និងការសរសេរ រួមជាមួយសកម្មភាពអំណានឮ អំណានដៃគូ អំណានចូលរួម និងអំណានបុគ្គល។

ទី២.ការលើកកម្ពស់«គណិតវិទ្យាថ្នាក់ដំបូង» តាមរយៈការផលិតសៀវភៅណែនាំសម្រាប់គ្រូគណិតវិទ្យា ថ្នាក់ទី១ និងទី២ សៀវភៅ ជំនួយសិស្សថ្នាក់ទី១ និងទី២ សៀវភៅលំហាត់ថ្នាក់ទី១ មាន៤ភាគ និងទី២មាន៤ភាគ, និងសម្ភារឧបទេសបម្រើឱ្យការបង្រៀននិងរៀន និងការផ្តល់ប្រឹក្សាគរុកោសល្យ។

ទី៣. ការបង្កើនចំនួនគ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣ ក្នុងមួយឆ្នាំ ៥ នាក់ ទៅ ១០នាក់ក្នុង១ឆ្នាំ និងគ្រូបង្រៀនល្អគណិតវិទ្យា ថ្នាក់ទី១ ទី២ និងទី៣ ពី៥នាក់ ដល់១០ នាក់ក្នុងមួយឆ្នាំ និងជ្រើសរើសគ្រូបង្រៀនល្អថ្នាក់ទី៤ ដល់ទី៦ ចំនួន ១០នាក់ក្នុង១ឆ្នាំ។

ទី៤.ការបង្កើត «សាលាគំរូអំណាន និងគណិតដំបូង» និងអនុវត្តការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព (SBM)។

ការលើកកម្ពស់ «អំណានដំបូង» និង «គណិតវិទ្យាថ្នាក់ដំបូង» ជាពិសេសការបណ្តុះបណ្តាលគ្រូ និងការពង្រីកការអនុវត្តនៅទូទាំងប្រទេស មានគោលដៅលើកកម្ពស់គុណភាពអប់រំ តាមរយៈការបង្កើនលទ្ធផលសិក្សារបស់សិស្សពោលគឺ កុមារកម្ពុជាចេះអាន សរសេរ និងគិតលេខទាំងអស់គ្នា។

### ១.៣.៤ កំណែទម្រង់ដំណាក់កាលទី៤

ក្នុងសន្និបាតអប់រំឆ្នាំ ២០២២ ក្រសួងបានដាក់ចេញវិធានការកែទម្រង់វិស័យអប់រំ ដំណាក់កាលទី៤ គឺ **"ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព"** ដោយដាក់ឱ្យអនុវត្តអភិក្រមស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផល ឆ្ពោះទៅរកការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធ និងតាមបែបអនុវិស័យ ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ ដោយត្រូវរួមបញ្ចូលគ្នានូវការពិនិត្យឡើងវិញមុខងារនិងភារកិច្ច ការរៀបចំផែនការប្រចាំឆ្នាំ ការអនុវត្តគន្លងអាជីព ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យតាមដាននិងវាយតម្លៃ។ ការពង្រឹងការអនុវត្តកំណែទម្រង់ ការគ្រប់គ្រងធនធានមនុស្ស ដោយត្រូវផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀន ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង និងជាអ្នកស្រាវជ្រាវ និងវាយតម្លៃ, ការកែលម្អប្រព័ន្ធលើកទឹកចិត្ត និងការផ្តល់ឱកាសសម្រាប់ការ អភិវឌ្ឍគន្លងអាជីព ក៏ដូចជាការទទួលស្គាល់អ្នកជំនាញអប់រំតាមរយៈការលើកកម្ពស់ការប្រណាំងប្រជែង, ការវាយតម្លៃនាយកសាលាល្អ គ្រូបង្រៀនល្អ គ្រូបង្រៀនល្អភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង និងនាយក សាលាស្អាតជាដើម ដោយប្រើប្រាស់ប្រព័ន្ធវង្វាយតម្លៃការបំពេញការងារប្រចាំឆ្នាំ និងការពង្រឹងប្រព័ន្ធ និងផ្លាស់ប្តូររបៀបធ្វើការ ដោយប្រែក្លាយឧត្តមានុវត្តនៃការអនុវត្តគម្រោងនានា មកជាការពង្រឹងប្រព័ន្ធ និងការរៀបចំគោលនយោបាយ និងគោលការណ៍ណែនាំ។

ជាមួយគ្នានេះ ឆ្លើយតបនឹងអនុសាសន៍របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ពាក់ព័ន្ធនឹងអន្តរាគមន៍ជួយដល់កុមារធ្វើចំណាកស្រុកតាមឪពុកម្តាយចាប់ពីឆ្នាំ២០១៨ រហូតដល់បច្ចុប្បន្ន ក្រសួងបានសហការជាមួយអ្នកពាក់ព័ន្ធ ក្នុងការផ្តល់ការគាំទ្រដល់កុមារចំនួន ៤៣ ៩៥២នាក់ ស្រី ១៨ ៤៦១នាក់ នៅតាមខេត្តគោលដៅដូចជា កោះកុង បន្ទាយមានជ័យ ព្រៃវែង សៀមរាប ខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ តាមរយៈការផ្តល់ការអប់រំនៅក្នុងមណ្ឌលអប់រំរបស់អង្គការ និងការធ្វើសមាហរណកម្មចូលទៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ។ កុមារទាំងនោះទទួលបានសម្ភារសិក្សា សំលៀកបំពាក់ មធ្យោបាយធ្វើដំណើរទៅសាលារៀន និងទទួលបានអាហារ។ ក្រៅពីនេះ កុមារទាំងនោះក៏បានទទួលការគាំទ្រការពិគ្រោះ

ពិភាក្សាផ្លូវចិត្ត សម្ភារអនាម័យ ទីជម្រក ការស្ដារនីតិសម្បទា និងការសិក្សាជំនាញសម្រាប់មុខរបរ។ ក្រុមគ្រួសាររបស់កុមារ ទាំងនោះក៏ទទួលបានការគាំទ្រផងដែរ រួមមាន៖ ការផ្តល់ដើមទុនសម្រាប់ប្រកបរបរទទួលទាន ការសិក្សា អំពីគំនិតអាជីវកម្ម ការប្រឹក្សាផ្លូវចិត្ត និងស្វែងរកការងារធ្វើ ។ល។ ជាទិសដៅខាងមុខ ក្រសួងនឹងរៀបចំ សេចក្តីណែនាំប្រតិបត្តិស្តីពី ការគាំទ្រដល់កុមារធ្វើចំណាកស្រុកតាមឪពុកម្តាយក្នុងគោលដៅធានាឱ្យកុមារ ទាំងនោះបានទទួលឱកាសសិក្សាអប់រំប្រកបដោយគុណភាព បរិយាបន្ន និងមានលទ្ធភាពទទួលបានការសិក្សា ពេញមួយជីវិត។

## ១.៤ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មី

ការសាកល្បងកម្មវិធីសាលារៀនជំនាន់ថ្មីបានចាប់ផ្តើមនៅឆ្នាំ ២០១៦ បច្ចុប្បន្ន កម្មវិធីនេះបានបង្ហាញនូវលទ្ធផលវិជ្ជមានគួរជាទីកត់សម្គាល់ និងការសាទរពីភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសឪពុកម្តាយ។ ការពង្រីកការវិនិយោគនៅក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី សង្ឃឹមថានឹងពន្លឿនសមត្ថភាពនៃប្រព័ន្ធអប់រំកម្ពុជា ក្នុងការផលិតធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ ដើម្បីបំពេញតម្រូវការដែលកំពុងកើនឡើងសម្រាប់អ្នកជំនាញដែលអាចធ្វើការក្នុងសេដ្ឋកិច្ចសតវត្សន៍ទី២១។ គោលដៅនៃកម្មវិធីសាលាជំនាន់ថ្មីដែលបានពង្រីកនឹងមានភាពចម្រុះ ដោយផ្តោតលើគុណភាព ការកែលម្អលទ្ធភាពប្រើប្រាស់ និងប្រតិបត្តិការប្រកបដោយនិរន្តរភាព។

***Key Metrics for New Generation Secondary School Performance (2022)***

| *Metric* | *NGS* | *National* |
|---|---|---|
| 1. Bac II Examination Pass Rate: | 82% | 69%[1] |
| 2. Students with A, B, or C Bac II Pass: | 43% | 22% |
| 3. Transition to University: | 84% | 13.69%* |
| 4. Students Receiving Medals/Awards: | 1,036 | n/a |
| 5. Students studying ICT 3 hrs/week or more: | 100% | 0% |
| 6. Dropout Rate: | 1% | LSS: 17%<br>USS: 18% |
| 7. Secondary Schools Accredited: | 100% | n/a |
| 8. Secondary School Teachers with 4-Year Degrees or Higher: | 90% | 43% |
| 9. Teachers Completing Career Path Plans: | 98% | n/a |
| 10. Student Projects Completed per year: | 1,792 | n/a |

*Gross Enrolment (Tertiary)

Sources: MoEYS, 2022; EMIS, 2022; World Bank, 2018

## ១.៥ សមិទ្ធផលនៃកំណែទម្រង់សាលារៀនគំរូ

វិស័យអប់រំបានកំណត់ និងអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ដំណាក់កាលទី២ នោះគឺ «**កំណែទម្រង់សាលារៀនដែលផ្តោតលើការគ្រប់គ្រងតាមសាលារៀន**»។ កន្លងមក លទ្ធផលសិក្សារបស់សិស្ស នៅគ្រប់កម្រិត ថ្នាក់មានកម្រិតទាប ការចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សាមានកម្រិតទាប ការរីកលូតលាស់យឺតទាំង រាងកាយ និងបញ្ញា សិស្សចូលរៀនយឺតនៅបឋមសិក្សា, សិស្សបោះបង់ និងត្រួតថ្នាក់ខ្ពស់នៅថ្នាក់ដំបូង កម្រិតបឋមសិក្សា សិស្សខ្សោយអំណានដោយគ្រូបង្រៀនខ្វះបច្ចេកទេសបង្រៀន។ នៅមធ្យមសិក្សា សិស្សខ្សោយមុខវិជ្ជាវិទ្យាសាស្ត្រ ដោយសិស្សខ្វះមូលដ្ឋានគ្រឹះភាសាខ្មែរ និងគណិតវិទ្យា។ ចំនួន

[1] Science stream students only.

ម៉ោងសិក្សាតិច គ្រូនិងសិស្សមកយឺត និងអវត្តមានច្រើន។ កង្វះទំនាក់ទំនងជិតស្និទ្ធរវាងសាលារៀន និងសហគមន៍ ដែលជា កត្តានាំឱ្យខ្វះការគាំទ្រ និងការចូលរួមក្នុងការដឹកនាំនិងគ្រប់គ្រងសាលារៀន។

ដើម្បីឆ្លើយតបនឹងបញ្ហាដែលកើតមានខាងលើ ក្រសួងបានកំណត់យុទ្ធសាស្ត្រកែទម្រង់សាលារៀន ដោយប្តេជ្ញាចិត្តអនុវត្តកំណែទម្រង់សាលារៀនមធ្យមសិក្សាឆ្ពោះទៅរកឧត្តមភាព (សាលារៀនគំរូ) ពីឆ្នាំ ២០១៧-២០២២ ចំនួន ១០០សាលា នៅក្រុង ស្រុក ខណ្ឌចំនួន ៩៩ ទូទាំងប្រទេស តាមរយៈការអនុវត្តគម្រោងកែលម្អការអប់រំមធ្យមសិក្សា។ ជាលទ្ធផលៈ

គម្រោងបានជួយសិស្សចូលរៀនថ្មីចំនួន ១១ ២៩២នាក់ ដែលក្នុងនោះមានសិស្សសរុបចូលរៀននៅសាលារៀនគោលដៅកើនឡើងពី ៦០០៣៨នាក់ (ស្រី ៣១ ២៩៦នាក់) ដល់ ៦៥ ១៥៥នាក់ (ស្រី ៣៤ ២៦៨នាក់) និងសិស្សចំនួន ៦ ១៧៥នាក់ (ស្រី ៣ ៣០៩នាក់ ស្មើនឹង៥៣,៦០ភាគរយ) ចូលរៀននៅតំបន់ជនបទ ដែលគម្រោងបានសាងសង់អគារសិក្សានិងបង្កើតសាលាមធ្យមសិក្សាបឋមភូមិ។ បរិមាណសិស្សសាលាមធ្យមសិក្សាទុតិយភូមិដែលមិនមែនជាគោលដៅចំនួន ៦៧ ៤៣៥នាក់ (ស្រី៣៥ ៩២១នាក់) ក៏បានទទួលប្រយោជន៍ដែរ។

សិស្សសរុប ៤៥៣ ៨៣៨នាក់ (ស្រី ២៣៣ ៣២៤នាក់) បានទទួលប្រយោជន៍ពីគម្រោងធៀបនិងចំនួនគ្រោងសិស្សមធ្យមសិក្សាបឋមភូមិតែ ២០ ៥០០នាក់ប៉ុណ្ណោះ។ មូលហេតុចំនួនពីរ ដែលនាំមកនូវផលជះនេះគឺ សហគមន៍សម្រេចបន្តការអនុវត្តកិច្ចការកំណែទម្រង់ នេះពីសាលាមធ្យមសិក្សាបឋមភូមិ ទៅមធ្យមសិក្សាទុតិយភូមិ និងធានាថាសិស្សបានបន្តការសិក្សាមានគុណភាពរហូតថ្នាក់ទី១២ និងសិស្សនៃសាលាបឋមសិក្សាចំនួន ៥៦០សាលា បានទទួលការជួយពីសាលាមធ្យមសិក្សា ដើម្បីធានាថាសិស្សបឋមសិក្សាមានសមត្ថភាពអាន និងគិតលេខ ត្រៀមរួចស្រេចចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិ។ នៅចុងបញ្ចប់នៃគម្រោងឆ្នាំ២០២១ សិស្សបឋមសិក្សាចំនួនលើសពី ៨០ភាគរយ ចេះអានអក្សរខ្មែរ និងគិតលេខ ដែលផ្ទុយនឹងឆ្នាំ២០១៧ ដែលសិស្សជាង ៩០ភាគរយមិនចេះអានអក្សរនិងគិតលេខ។

បន្ថែមលើនេះ ភាគរយនៃសិស្សបាននិទ្ទេស A B និងC មុខវិជ្ជាគណិតវិទ្យា នៃសាលារៀនគោលដៅកើនពី ១៤ភាគរយ (ស្រី១៦ភាគរយ) នៅឆ្នាំសិក្សា ២០១៨-២០១៩ ដល់ ៣៤ភាគរយ (ស្រី៣៦ភាគរយ) នៅឆ្នាំ ២០២០-២០២១ ដោយឡែកភាសាខ្មែរ កើនពី ២៥ភាគរយ (ស្រី៣០ភាគរយ) ដល់ ៤៨ភាគរយ (ស្រី៥០ភាគរយ) នៅក្នុងរយៈពេលដូចគ្នា។

កត្តាមួយទៀតដែលជួយដល់បរិស្ថានសិក្សារៀនសូត្រគឺ ការសាងសង់អគារសិក្សាចំនួន ១០០ខ្នង ដើម្បីបន្ថយអត្រាសិស្ស-ថ្នាក់រៀន សាងសង់បន្ទប់ពិសោធន៍ ៤៣៧ ជាមួយនឹងការបំពាក់សម្ភារពិសោធន៍ និងសាងសង់អគារសិក្សាថ្មីនៅឃុំដែលពុំមានសាលាមធ្យមសិក្សាបឋមភូមិចំនួន ៣០អគារ ផ្ទះគ្រូបង្រៀនចំនួន ៣០ នៅក្នុងឃុំដាច់ស្រយាលចំនួន៣០។

សាលារៀនគោលដៅចំនួន ៩៤ (ចំណុចដៅ ៧០) នៃសាលារៀនក្នុងគោលដៅរបស់គម្រោងចំនួន ១០០ (បញ្ជីឈ្មោះសាលាគោលដៅមាននៅក្នុងឧបសម្ព័ន្ធទី១) បានជាប់ពិន្ទុស្តង់ដាអប្បបរមានៃសាលារៀនមានប្រសិទ្ធភាព។ សាលាចំនួន៤ទៀត ត្រូវបានចាត់ទុកថា មានការជឿនលឿនយឺតជាង

ការរំពឹងទុក។ សាលារៀនទាំងនេះត្រូវបានក្រសួងចាត់ទុកថាជា សាលារៀនគំរូ សម្រាប់ពង្រីកបរិមាណនៅទូទាំងប្រទេសពីឆ្នាំ២០២៤ ដល់ ឆ្នាំ២០២៨។ ក្រៅពីនេះមានសាលាមធ្យមសិក្សាក្រៅគោលដៅរបស់គម្រោងចំនួន ២១០ ទៀត បានបំពេញពិន្ទុស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដោយសារនាយកសាលារៀន និងគ្រូបង្រៀនបាន ចូលរួមរៀនសូត្រក្នុងវគ្គបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រសម្រាប់គ្រូបង្រៀន និងនាយកសាលារៀន ដូចគ្នានឹងសាលារៀនគោលដៅ ដោយរៀនសូត្រតាមការអនុវត្តជាក់ស្តែងពីសាលារៀនគោលដៅ។

ឧត្តមានុវត្តន៍ និងសកម្មភាពសំខាន់ៗក្នុងការកែទម្រង់សាលារៀនគំរូ មានដូចខាងក្រោមៈ

**ក. ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពសហគមន៍ និងសាលារៀន**

- ភាពស្អាតស្អំក្នុងសហគមន៍សាលារៀន
- ប្រសិទ្ធភាពការងាររបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន
- ការកសាងភាពជាម្ចាស់សហគមន៍ និងសាលារៀនសម្រាប់ការអភិវឌ្ឍ
- ស្តង់ដានៃការគ្រប់គ្រងសាលារៀន ដោយផ្សារភ្ជាប់គ្នារវាងគោលនយោបាយ និងការអនុវត្ត
- គណនេយ្យភាពរបស់គ្រូបង្រៀន នាយកសាលារៀន គណៈកម្មការគ្រប់គ្រងសាលារៀន មាតាបិតាសិស្ស អាជ្ញាធរមូលដ្ឋាន មន្ត្រីថ្នាក់ជាតិនិងក្រោមជាតិ
- ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល
- ប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារគ្រូបង្រៀន និងនាយកសាលារៀន ផ្អែកលើសមិទ្ធកម្ម និងការដំឡើងឋានៈវិជ្ជាជីវៈ
- ការធ្វើតេស្តវង្វាយតម្លៃសមត្ថភាពសិស្សកម្រិតថ្នាក់រៀន និងសាលារៀន
- សេចក្តីណែនាំអំពីការគ្រប់គ្រងសាលារៀន
- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យសុចរិតភាព

**ខ. ការពង្រឹងភាពស្អាតស្អំក្នុងសាលារៀន**

- ការចែករំលែកទិន្នន័យ និងព័ត៌មានជាចំហរដល់សាធារណៈ
- ការចែករំលែកទិន្នន័យ និងព័ត៌មានពីក្រុមប្រតិបត្តិការងារ និងការចូលរួមពីមាតាបិតា និងសិស្ស
- ការចូលរួមពីអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំនិងសង្កាត់ និងមេភូមិ
- ការទទួលខុសត្រូវរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ការចូលរួមពីសំណាក់សហគមន៍ និងប្រជាជន
- តួនាទីសិស្សក្នុងការជួយសិស្ស ការគ្រប់គ្រងថ្នាក់រៀន និងការគ្រប់គ្រងសាលារៀន

**គ. ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ**

- ការកសាងសមត្ថភាពជំនាញ និងវិជ្ជាជីវៈគ្រូបង្រៀន (វិជ្ជាជីវៈរៀនសូត្រ វិជ្ជាជីវៈប្រតិបត្តិ វិជ្ជាជីវៈចំណេះដឹង និងវិជ្ជាជីវៈសុជីវធម៌)
- ការកសាងសមត្ថភាពជំនាញ និងវិជ្ជាជីវៈនាយកសាលារៀន និងការពង្រឹងភាពជាអ្នកដឹកនាំ
- ការកសាងសមត្ថភាពជំនាញ និងវិជ្ជាជីវៈមន្ត្រីរាជការនៅថ្នាក់ជាតិ និងក្រោមជាតិ

– ការពង្រឹងអភិបាលកិច្ចផ្ទៃក្នុងសាលារៀន និងថ្នាក់រៀន
– ការកសាងសមត្ថភាព និងការអនុវត្តនវានុវត្តន៍ ឆ្លើយតបតាមបរិយាកាសជាតិ និងឈានឆ្ពោះទៅអន្តរជាតិ។

## ១.៦ កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន

ក្រសួងបានផ្ទេរការគ្រប់គ្រងសាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាអនុវត្តន៍ មកស្ថិតក្រោមអង្គភាពនៅទីស្តីការក្រសួង ដើម្បីងាយស្រួលធ្វើការអភិវឌ្ឍ។ ក្រសួងបានបង្កើតគណៈកម្មការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ និងបានប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបង ទៅជាវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងវិទ្យាស្ថានគរុកោសល្យបាត់ដំបង ដើម្បីរ៉ាប់រងការបណ្តុះបណ្តាលគ្រូបង្រៀនថ្នាក់បរិញ្ញាបត្រអប់រំ (១២+៤) និងធ្វើវិក្រឹតការគ្រូបង្រៀនសម្រាប់កម្រិតបឋមសិក្សា និងកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យ។

ស្ថិតក្រោមកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានខិតខំធ្វើការអភិវឌ្ឍទាំងខាងផ្នែករឹង និងផ្នែកទន់ ដោយមានការគាំទ្រពីគម្រោងសាងសង់វិទ្យាស្ថានគរុកោសល្យ (The project for the construction of Teacher Education Colleges) ដែលជាជំនួយហិរញ្ញប្បទានឥតសំណងរបស់រាជរដ្ឋាភិបាលនៃប្រទេសជប៉ុន និងប្រជាជនជប៉ុន តាមរយៈស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារ JICA ដោយទទួលបានការសាងសង់អគារថ្មី ដែលមានបំពាក់សម្ភារបរិក្ខារទំនើបសម្រាប់បុគ្គលិកអប់រំ ក៏ដូចជាសម្ភារបង្រៀន និងរៀនសម្រាប់គ្រូឧទ្ទេស និងគរុសិស្ស គរុនិស្សិត ដើម្បីធ្វើការសិក្សារៀនសូត្រ។

ក្រៅពីសំណង់អគារថ្មីទាំង៤ ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន វិទ្យាស្ថានគរុកោសល្យទាំង២ ក៏ទទួលបាននូវការកែលម្អហេដ្ឋារចនាសម្ព័ន្ធនានាជាច្រើនទៀត ដោយប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន៖ ការជួសជុលអគារសិក្សាមានស្រាប់ ភ្លោងទ្វារ របងច្រកចូល សួនច្បារ ប្រព័ន្ធលូបង្ហូរទឹក ទីលានកីឡាបាល់ទាត់ បាល់ទះ ផ្លូវបេតុង និងការស្តារស្រះស្តុកទឹក។ល។

ទន្ទឹមគ្នានឹងការអភិវឌ្ឍផ្នែករឹង វិទ្យាស្ថានបានសហការជាមួយអង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា និងបានផ្តោតលើ ៖

១. ការកសាងក្របខណ្ឌកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ, ការសិក្សាតាមប្រព័ន្ធក្រេឌីតពេញលេញ, ការវាយតម្លៃតាមប្រព័ន្ធ GPA, ការលើកកម្ពស់ស្វ័យសិក្សា, និងការសិក្សាស្រាវជ្រាវរបស់គរុសិស្ស គរុនិស្សិត
២. ការអភិវឌ្ឍកម្មវិធីសិក្សាលម្អិតតាមមុខវិជ្ជា រួមមានកញ្ចប់មុខវិជ្ជាការសិក្សាអប់រំមុខវិជ្ជាឯកទេស មុខវិជ្ជាការសិក្សាកម្មវិធីសិក្សា(វិធីសាស្ត្របង្រៀន) មុខវិជ្ជារួម ជំនាញសរសេរ ការធ្វើបទបង្ហាញ ជំនាញស្រាវជ្រាវអប់រំ និងកម្មសិក្សាគរុកោសល្យ ព្រមទាំងកំពុងកសាងឯកសារបង្រៀន សម្ភារឧបទេស សៀវភៅសិក្សាគោលតាមមុខវិជ្ជាទាំងនេះផងដែរ

៣. ការអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសជាប្រចាំ ដោយផ្តោតសំខាន់លើសមត្ថភាពវិធីសាស្ត្របង្រៀន ការស្រាវជ្រាវប្រតិបត្តិ, បច្ចេកវិទ្យាព័ត៌មានសម្រាប់ការបង្រៀន និងរៀន និងការវាយតម្លៃការសិក្សា ជាដើម
៤. ការបញ្ជូនគ្រូឧទ្ទេស ទៅបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន ក្រោមការគាំទ្រអាហារូបករណ៍របស់ទីភ្នាក់ងារ JICA
៥. ការបញ្ជូនគ្រូឧទ្ទេសទៅបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅតាមគ្រឹះស្ថាននានាក្នុងប្រទេស ដូចជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ, និងវិទ្យាស្ថានជាតិអប់រំ ជាដើម ក្រោមការគាំទ្រអាហារូបករណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា
៦. ការជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាព មានគុណវុឌ្ឍិយ៉ាងទាបត្រឹមថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលកំពុងបម្រើការនៅក្នុងប្រព័ន្ធអប់រំ ឱ្យផ្លាស់ចូលបម្រើការងារជាគ្រូឧទ្ទេស នៅក្នុងវិទ្យាស្ថាន
៧. ការបង្កើតប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ដើម្បីពិនិត្យតាមដានវាយតម្លៃគុណភាពអប់រំជាប្រចាំ និងរៀបចំរបាយការណ៍ស្វ័យវង្វាយតម្លៃ សម្រាប់ស្នើសុំការវាយតម្លៃទទួលស្គាល់គុណភាពអប់រំពី គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
៨. ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈក្នុងចំណោមគ្រូឧទ្ទេស តាមរយៈការសិក្សាស្រាវជ្រាវប្រតិបត្តិ ការផ្សព្វផ្សាយ និងការបោះពុម្ពព្រឹត្តិបត្រស្រាវជ្រាវ
៩. ការផ្លាស់ប្តូរគរុនិស្សិត ក្នុងការធ្វើការងារស្រាវជ្រាវប្រតិបត្តិ ជាមួយគរុនិស្សិតនៃសាកលវិទ្យាល័យនៃប្រទេសបែលហ្ស៊ិច
១០. ការបង្កើតប្រព័ន្ធទំនាក់ទំនង ដែលផ្តល់ឱកាសដល់គ្រូឧទ្ទេស និងគរុនិស្សិតធ្វើការផ្លាស់ប្តូរចំណេះដឹង បទពិសោធ និងរួមដោះស្រាយបញ្ហានានា ដោយប្រើក្រុម telegram និង Facebook page ជាដើម។ កិច្ចការនេះបានផ្តល់ឱកាសដល់គ្រូឧទ្ទេស គរុនិស្សិត និងអតីតគរុនិស្សិតអាចចូលរួមពិភាក្សា ចែករំលែកឯកសារ បទពិសោធ និងដោះស្រាយបញ្ហានានា សំដៅបន្តគាំទ្រ ដល់គរុនិស្សិត ដែលបានបញ្ចប់ការសិក្សានៅវិទ្យាស្ថានចេញទៅបម្រើការងារនៅតាមសាលារៀន និងជាផ្នែកមួយគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពជាប្រចាំរបស់គ្រូបង្រៀន។

ដោយឡែក សាលាគរុកោសល្យនិងវិក្រឹតការ ១១ ទៀតទទួលបានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្រោមគម្រោង STEPCam។

គណៈកម្មាធិការកែទម្រង់វិទ្យាស្ថានជាតិអប់រំបានអនុវត្តក្របខណ្ឌកំណែទម្រង់ ក្នុងដំណាក់កាលទី១ បានចំនួន២ឆ្នាំមកហើយ ព្រមទាំងទទួលបានលទ្ធផលល្អទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកបណ្តុះបណ្តាលគ្រប់ប្រភេទ។ កំណែទម្រង់នេះបានផ្តោតលើ៖

- អាទិភាពទី១៖ លើកកម្ពស់ការរៀននិងបង្រៀន ធនធានសិក្សា និងហេដ្ឋារចនាសម្ព័ន្ធ
    - យុទ្ធសាស្ត្រទី១៖ កែលម្អក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត វិធីសាស្ត្របង្រៀន ឯកសារ រៀននិងបង្រៀន និងការបណ្តុះបណ្តាល ទាំងការបណ្តុះបណ្តាលដំបូង-PRESET និងការបណ្តុះបណ្តាលបន្ត-INSET

- យុទ្ធសាស្ត្រទី២៖ អភិវឌ្ឍធនធានសម្ភារសិក្សា ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឱ្យឆ្លើយតបនឹងកម្មវិធី បណ្តុះបណ្តាល និងស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូជំនាន់ថ្មី
- យុទ្ធសាស្ត្រទី៣៖ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំដល់គ្រូឧទ្ទេស គណៈគ្រប់គ្រង និងមន្ត្រី
- យុទ្ធសាស្ត្រទី៤៖ ប្រែក្លាយវិទ្យាស្ថានជាតិអប់រំ ជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ

- អាទិភាពទី២៖ ពង្រឹងអភិបាលកិច្ច ការស្រាវជ្រាវ និងកិច្ចសហប្រតិបត្តិការ
  - យុទ្ធសាស្ត្រទី៥៖ លើកកម្ពស់ការដឹកនាំ ការគ្រប់គ្រង និងអភិបាលកិច្ចល្អ
  - យុទ្ធសាស្ត្រទី៦៖ កែលម្អការជ្រើសរើស ការវាយតម្លៃលទ្ធផលសិក្សា និងលក្ខខណ្ឌរស់នៅរបស់គរុសិស្ស គរុនិស្សិត
  - យុទ្ធសាស្ត្រទី៧៖ លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍
  - យុទ្ធសាស្ត្រទី៨៖ ផ្សារភ្ជាប់រវាងវិទ្យាស្ថានជាតិអប់រំ សាលាអនុវត្តន៍ និងសាលាសហការ
  - យុទ្ធសាស្ត្រទី៩៖ សហប្រតិបត្តិការជាតិ និងអន្តរជាតិ

## ១.៧ ការអភិវឌ្ឍវិស័យឧត្តមសិក្សា

គ្រឹះស្ថានឧត្តមសិក្សាមាន ១១០គ្រឹះស្ថាន នៅឆ្នាំ២០១៣។ គ្រឹះស្ថានឧត្តមសិក្សាបានកើនដល់ ១៣២ គ្រឹះស្ថាន និងមានទីតាំងស្ថិតនៅ ២១ខេត្ត និងរាជធានី នៅឆ្នាំ២០២២ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋមាន ៤៨ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនមាន ៨៤។ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង និងស្ថាប័នចំនួន ១៦។

នៅក្នុងឆ្នាំ២០២២ គ្រឹះស្ថានឧត្តមសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា មាន ៨៤គ្រឹះស្ថាន (កើន ១៩) ធៀបនឹងឆ្នាំ២០១៣ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋមាន ១៣ (កើន ៤) និងឯកជនមាន ៧១ (កើន ១៥)។ គ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មាន ៤៩ (កើន១៤) ក្នុងនោះរដ្ឋ ១០ និងឯកជន ៣៩។ គ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលថ្នាក់បណ្ឌិត ២៥ (កើន១០) ក្នុងនោះរដ្ឋ ៧ និង ឯកជន ១៨។

ក្នុងឆ្នាំសិក្សា ២០២១-២០២២ បុគ្គលិកអប់រំនៅឧត្តមសិក្សាមាន ១៦ ៤៧១នាក់ ក្នុងនោះគ្រូមានសញ្ញាបត្របរិញ្ញាបត្រ ៣ ៨៨៧នាក់ ស្មើ ២៣,៥៩ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់ ១១ ១៣០នាក់ ស្មើ ៦៧,៥៧ភាគរយ និងបណ្ឌិត ១ ៤៥៤នាក់ ស្មើ ៨,៨៣ភាគរយ។ បើធៀបនឹងឆ្នាំសិក្សា២០១៣-២០១៤ បរិញ្ញាបត្រជាន់ខ្ពស់កើន ៤០១៣នាក់ ស្មើ ៥៦ភាគរយ និង បណ្ឌិតកើន ៦១៧នាក់ ស្មើ ៧៣,៧១ភាគរយ។ ក្នុងរយៈពេល១០ឆ្នាំចុងក្រោយ បុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិតមានការកើនឡើង តិចតួចពី ៣,៣ភាគរយ ក្នុងឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៥,៧ភាគរយ ក្នុងឆ្នាំសិក្សា ២០២១-២០២២។

និស្សិតឧត្តមសិក្សាបានថយពី ២៤៩ ០៩២នាក់ ស្រី ១០៣ ៦៧៤នាក់ ស្មើ ៤១,៦២ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ មកត្រឹម ២០៩ ០៥៩នាក់ ស្រី ៩៥ ៦១៩នាក់ ស្មើ ៤៥,៧៣ភាគរយ

នៅឆ្នាំសិក្សា ២០២១-២០២២។ តួលេខនិស្សិតថយចុះនេះដោយមូលហេតុបីយ៉ាងគឺ ១)ស្ថិតិនិស្សិតនៃក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមិនបានរាប់បញ្ចូលក្នុងរបាយការណ៍ ២)ភាគរយនៃការប្រឡងជាប់មធ្យមសិក្សាទុតិយភូមិមានការថយចុះ ៣)កត្តាជំងឺកូវីដ-១៩ ជាឧបសគ្គដល់និស្សិតខ្សត់ខ្សោយជីវភាព និងកង្វះថវិកាក្នុងការបង់ថ្លៃសិក្សាចូលរៀននៅឧត្តមសិក្សា។

- និស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររងកើនពី ១៥ ៦៣៥នាក់ ស្រី ៧ ២៩៩នាក់ ស្មើ ៤៦,៦៨ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ២០ ២៣៥នាក់ ស្រី ៧ ៨៦៣នាក់ ស្មើ ៣៨,៨៥ភាគរយ នៅឆ្នាំសិក្សា២០២១-២០២២។
- និស្សិតសិក្សាថ្នាក់បរិញ្ញាបត្រថយពី ២១៤ ២៦៦នាក់ ស្រី ៩២ ៥៤៣នាក់ ស្មើ ៤៣,១៩ ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ មកត្រឹម ១៧៥ ៩៦២នាក់ ស្រី ៨៤ ៥៣៨នាក់ ស្មើ ៤៨,០៤ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២។
- និស្សិតសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ថយពី ១៨ ០១០នាក់ ស្រី ៣ ៧៧២នាក់ ស្មើ ២០,៩ ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ មកត្រឹម ៩ ៤៨៣នាក់ ស្រី ៣ ១៥៨នាក់ ស្មើ ៣៣,៣ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២។
- និស្សិតសិក្សាថ្នាក់បណ្ឌិតកើនពី ១ ១៨១នាក់ ស្រី ៦០នាក់ ស្មើ ៥,០៨ភាគរយ នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១២១៣នាក់ ស្រី ១៣៣នាក់ ស្មើ ១០,៩៦ភាគរយ នៅឆ្នាំសិក្សា ២០២១-២០២២។
- អត្រារួមនៃការសិក្សានៅឧត្តមសិក្សាកើនពី ៩,៩ភាគរយ (ស្រី ៩,៣ភាគរយ ប្រុស ១០,៣ ភាគរយ) នៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ១៤,៩ភាគរយ (ស្រី ១៣,២ភាគរយ ប្រុស ១៥,៥ភាគរយ) នៅឆ្នាំសិក្សា ២០២១-២០២២។

ភាគរយនិស្សិតបណ្តុះបណ្តាលជំនាញស្មើមកើនពី ១៩,៦ភាគរយ (ស្រី ១១,៨ភាគរយ ប្រុស ២៥,៦ភាគរយ) នៅឆ្នាំសិក្សា ២០១៣-២០១៤ ឡើងដល់ ២៥,៦ភាគរយ (ស្រី ១៣,៨ភាគរយ ប្រុស ៣៥,៦ភាគរយ) នៅឆ្នាំសិក្សា ២០២១-២០២២។

ក្នុងអំឡុងពេលជាងមួយទសវត្សរ៍ចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងកិច្ចការកំណែទម្រង់ការអប់រំនៅឧត្តមសិក្សា តាមរយៈការកែលម្អកម្មវិធីសិក្សាឱ្យមានស្តង់ដាជាតិ និងអន្តរជាតិ ពង្រឹងសមត្ថភាពគ្រូ និងវិធីសាស្ត្របង្រៀនឲ្យស្របនឹងយុគសម័យឌីជីថល លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ និងពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ តាមរយៈការអនុវត្តកម្មវិធីភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុក និងក្រៅប្រទេសកម្មវិធីសិក្សាចំនួន ៨០ ត្រូវបានកែលម្អ និងរៀបចំថ្មី ព្រមទាំងមានកម្មវិធីចំនួន៦៧រួមមានកម្រិតបរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន៥ ត្រូវបានវាយតម្លៃជាមួយអ្នកជំនាញជាតិ និងអន្តរជាតិ ដើម្បីឱ្យឆ្លើយតបទៅនឹងស្តង់ដាជាតិ និងឈានទៅការទទួលស្គាល់ថ្នាក់តំបន់ និងអន្តរជាតិ។

ក្រសួងបានវិនិយោគថវិកាមួយចំនួនធំ លើការពង្រឹងគុណភាពនៃកម្មវិធីបណ្តុះបណ្តាលគ្រូ តាមរយៈការកែលម្អកម្មវិធីសិក្សាផ្សារភ្ជាប់ទៅនឹងការងារ និងសហគ្រាសអាជីវកម្ម/ឧស្សាហកម្ម ក្រោមគំរូភាពជាដៃគូជាមួយសាកលវិទ្យាល័យជាតិ និងអន្តរជាតិ និងលើការបង្កើនចំនួនបណ្ឌិត និងអ្នកស្រាវជ្រាវ ដើម្បី

បង្កើនគុណភាពអប់រំនៅឧត្តមសិក្សា។ លើសពីនេះ ក្រសួងក៏បាននិងកំពុងដាក់ ឱ្យអនុវត្តបណ្តាញសាកលវិទ្យាល័យនិមិត្ត (Cyber University Network) ដើម្បីលើកកម្ពស់ការអប់រំឌីជីថល និងកាត់បន្ថយគម្លាតគុណភាពសិក្សា រវាងគ្រឹះស្ថានឧត្តមសិក្សានៅទីក្រុង និងនៅតាមបណ្តាខេត្ត។ បច្ចុប្បន្ន គ្រឹះស្ថានឧត្តមសិក្សារដ្ឋចំនួន៥ ក្នុងក្រសួង និង១ទៀត ក្នុងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ បាននិងកំពុងអនុវត្តកម្មវិធីបណ្តាញ សាកលវិទ្យាល័យសាយប័រ ដោយបានផលិត១៩មេរៀនសម្រាប់ដាក់អនុវត្តការអប់រំតាមបែបឌីជីថល។

ដើម្បីបង្កើនគុណភាពស្រាវជ្រាវ ក្រសួងបានធ្វើការលើ៖ ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយចំនួន ផ្តល់ថវិកាស្រាវជ្រាវ អនុវត្តកម្មវិធីមគ្គុទេសក៍ស្រាវជ្រាវដល់ក្រុមអ្នកស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន និងគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាឲ្យបង្កើតទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីបង្កើនការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវ និងដើម្បីអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ។

ក្រសួងបានអនុវត្តគម្រោងស្រាវជ្រាវជាច្រើន ជាមួយដៃគូសហគ្រាសឧស្សាហកម្ម។ កិច្ចខិតខំប្រឹងប្រែង ទាំងឡាយនៃការស្រាវជ្រាវទាំងអស់នេះបាននាំមកនូវ "**ការបង្កើតថ្មី**" សម្រាប់បម្រើដល់កិច្ចការសង្គមសេដ្ឋកិច្ច រួមមាន៖ ការកែច្នៃផលិតផលកសិកម្ម ការបង្កើនផលិតភាពកសិកម្ម វិស្វកម្មអេឡិចត្រូនិក និងការបង្កើត ផលិតកម្មគំរូក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ ជាមួយគ្នានេះ មន្ទីរពិសោធន៍ ទំនើបៗ កសិដ្ឋានពិសោធន៍ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវជាច្រើន ក៏ត្រូវបានកសាង និងបានបំពាក់នៅតាមគ្រឹះស្ថានឧត្តមសិក្សាមួយចំនួន សម្រាប់ការស្រាវជ្រាវ និងសម្រាប់និស្សិតសិក្សាស្រាវជ្រាវ ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង តាមរយៈការសិក្សាក្នុងមន្ទីរពិសោធន៍ ឬកសិដ្ឋានពិសោធន៍។ ក្រសួងក៏បានបង្កើតវេទិកាចែករំលែកចំណេះដឹងមួយចំនួន ដូចជា៖ វេទិកាស្រាវជ្រាវថ្នាក់ជាតិ វេទិកាគោលនយោបាយអប់រំ និងទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ជាដើម។

ទិសដៅចម្បងរបស់ក្រសួងនាពេលនេះគឺ ការកសាងសមត្ថភាពស្ថាប័ន និងបង្កើតឱ្យមានប្រព័ន្ធអេកូឡូស៊ីពេញលេញមួយ ដើម្បីលើកកម្ពស់ឧត្តមភាពរបស់អ្នកស្រាវជ្រាវ និងការបណ្តុះឱ្យមានចរន្តស្រាវជ្រាវជាប្រចាំ នៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលកិច្ចការស្រាវជ្រាវនេះជាគន្លឹះដ៏សំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ឱ្យប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ក្នុង ឆ្នាំ២០៥០។

ការតែងតាំងឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំលើកដំបូងចំនួន ៣២៨រូប ក្នុងនោះសាស្ត្រាចារ្យ ៣២រូប សាស្ត្រាចារ្យរង ៥៨រូប និងសាស្ត្រាចារ្យជំនួយ ២៣៨រូប បានរួមចំណែកដ៏សំខាន់ ក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីនៃការស្រាវជ្រាវនៅកម្ពុជា។

ក្រសួងបានយកចិត្តទុកដាក់ក្នុងការបង្កើតមុខជំនាញថ្មី ដែលក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ បានបង្កើតមុខជំនាញថ្មីចំនួន ១ ១៦៥ ក្នុងនោះ កម្រិតបរិញ្ញាបត្ររង ៤៤០មុខជំនាញ បរិញ្ញាបត្រ ៥៣៨មុខជំនាញ បរិញ្ញាបត្រជាន់ខ្ពស់ ១១៧មុខជំនាញ និងបណ្ឌិត ៧០មុខជំនាញ។

ការស្រាវជ្រាវ និងនវានុវត្តន៍នៅឧត្តមសិក្សាត្រូវបានយកចិត្តទុក តាមរយៈការគាំទ្រការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ។ មជ្ឈមណ្ឌលឧត្តមភាព ដែលបានបង្កើត និងកំពុងដំណើរការមាន៤ រួមមាន៖ មជ្ឈមណ្ឌលឧត្តមភាពសម្រាប់នវានុវត្តន៍ការរៀន និងបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្ម និរន្តរភាព និងអាហារូបត្ថម្ភនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ការស្រាវជ្រាវស្ថានប្រព័ន្ធជលសាស្ត្រនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងមជ្ឈមណ្ឌលឧត្តមភាពសាកលវិទ្យាល័យជាតិគ្រប់គ្រង។ មជ្ឈមណ្ឌលឧត្តមភាពទាំងនេះ បង្កើតឡើងក្នុងគោលបំណងរួមចំណែកលើកកម្ពស់គុណភាពសិក្សា និងការស្រាវជ្រាវលើវិស័យអាទិភាពរួមមាន៖ ការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលារៀនលើជំនាញអភិវឌ្ឍកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃ ការស្រាវជ្រាវលើវិស័យកសិកម្ម ការគាំទ្រគម្រោងសរសេរសៀវភៅ និងការស្រាវជ្រាវអំពីសេដ្ឋកិច្ចឌីជីថល ការស្រាវជ្រាវលើប្រព័ន្ធជលសាស្ត្រ និងការពង្រឹងសមត្ថភាពនិស្សិត ក្នុងការ រៀបចំអាជីវកម្មថ្មី។

នៅក្នុងឆ្នាំ២០២១ ក្រសួងបានចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗ មួយចំនួនដូចជា យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង និងផ្ទៃក្រៅនៅគ្រឹះស្ថានឧត្តមសិក្សា ប្រព័ន្ធទិន្នន័យអនុវិស័យឧត្តមសិក្សា ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងគោលការណ៍ណែនាំស្តីពីក្របខណ្ឌអភិវឌ្ឍសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងគ្រឹះស្ថានឧត្តមសិក្សាក្នុងការផលិតធនធានមនុស្សប្រកបដោយគុណភាព និងមានសមត្ថភាពខ្ពស់ ឱ្យឆ្លើយតបទៅនឹងទីផ្សារការងារ និងឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។

ក្រសួងបានពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងនៅតាមគ្រឹះស្ថានឧត្តមសិក្សា ធ្វើឡើងគោរពតាមច្បាប់ស្តីពី ការអប់រំ និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ព្រមទាំងសហការ ជាមួយដៃគូពាក់ព័ន្ធ និងគម្រោងដៃគូអភិវឌ្ឍ ក្នុងការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា ក៏ដូចជាកិច្ចសហប្រតិបត្តិការក្នុងការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ និងការបង្កើតបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា។

នៅពេលខាងមុខ ក្រសួងនឹងបន្តអនុវត្តកំណែទម្រង់នៅឧត្តមសិក្សា ដើម្បីធានាបាននូវការបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់បម្រើដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដោយផ្តោតលើ (១) ការពង្រឹងអភិបាលកិច្ចនៅតាមគ្រឹះស្ថានឧត្តមសិក្សា (២)ការលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យ ឱ្យមានសញ្ញា បត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត (៣)ការជំរុញការសិក្សា ការបណ្តុះបណ្តាល និងកសាងជំនាញផ្នែកឌីជីថល និងជំនាញថ្មីៗ (៤) ការជំរុញសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រមទាំងនវានុវត្តន៍ផ្នែកឌីជីថល (៥)ការកសាងភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ និងការអភិវឌ្ឍការងារស្រាវជ្រាវនិងអភិវឌ្ឍន៍ និងនវានុវត្តន៍។

## ១.៨ ការងារអភិវឌ្ឍយុវជន

ក្រសួងបានប្រែក្លាយមជ្ឈមណ្ឌលយុវជនចំនួន ៥ ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងបានបណ្តុះបណ្តាលបំណិនសតវត្សរ៍ទី២១ដល់យុវជន ដោយផ្តោតលើ៖ ១).កម្មវិធី"បរិស្ថានល្អផ្តើមចេញពី ខ្ញុំ" ២).កម្មវិធី"កាយរឹទ្ធិដើម្បីសន្តិភាព និងការងារសហគមន៍" ៣).កម្មវិធី"ទិវាកាយរឹទ្ធិក្លាហាន"៤). កម្មវិធីផ្លាស់ប្តូរបទពិសោធន៍លើបំណិនបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលជាមួយអង្គការ និងសហគមន៍កាយរឹទ្ធិជាតិនានាក្នុងតំបន់និងពិភពលោក ៥).កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធើណិត ៦).កម្មវិធីអក្ខរកម្មឌីជីថល ៧).កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ ២០២២ ៨).កម្មវិធីយុវជន២១ (អភិវឌ្ឍសហគ្រិនបែបឌីជីថល) ៩).កម្មវិធីអប់រំសហគ្រិនភាព ១០).កម្មវិធីការគ្រប់គ្រងផ្លូវចិត្តយុវជន ១១). កម្មវិធីយុវជន STEM ១២).កម្មវិធីការងារស្ម័គ្រចិត្ត និង១៣).កម្មវិធីប្រកួតប្រជែងផែនការអាជីវកម្ម។ កម្មវិធីទាំងនេះបានជួយលើកកម្ពស់សមត្ថភាព និងជំនាញរបស់យុវជនឱ្យឆ្លើយតបនឹងការអភិវឌ្ឍសង្គម និងជំនាញសតវត្សរ៍ទី២១។

ក្រសួងបានបង្កើតកម្មវិធីយុវជនជាច្រើន ដើម្បីអភិវឌ្ឍយុវជនឱ្យមានបំណិនថ្នៃប្រឌិត នវានុវត្តន៍ ការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការតម្រង់ទិសវិជ្ជាជីវៈនិងប្រឹក្សាពីអាជីព ការធ្វើសេចក្តីសម្រេចចិត្ត ការប្រាស្រ័យទាក់ទង សាមគ្គីភាព ការធ្វើការងារជាក្រុម អក្ខរកម្មព័ត៌មានវិទ្យា អក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន ភាពជាពលរដ្ឋសកល បំណិនជីវិត និងការងារ និងការទទួលខុសត្រូវផ្ទាល់ខ្លួន និងក្នុងសង្គម រួមមានសមត្ថភាព និងការយល់ដឹងពីវប្បធម៌ចម្រុះ ដើម្បីឱ្យឆ្លើយតបទៅនឹងបរិបទបដិវត្តន៍ឧស្សាហកម្ម៤.០ និងការប្រែប្រួលឥតឈប់ឈររបស់សង្គម ដែលយុវជនត្រូវមានបំណិនសតវត្សរ៍ទី២១ ការបណ្តុះបំណិនទន់ និងបំណិនបច្ចេកទេស សម្រាប់ការប្រកួតប្រជែងក្នុងទីផ្សារការងារ។

ក្រសួងបានផ្តល់ឱកាសដល់យុវជនចូលរួមក្នុងការដឹកនាំ ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការពាររាល់សមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជា និងចូលរួមរបស់យុវជនលើឆាកអន្តរជាតិ តាមរយៈការចាត់បញ្ជូនយុវជនចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាល ការផ្លាស់ប្តូរវប្បធម៌ និងព្រឹត្តិការណ៍ថ្នាក់តំបន់ និងពិភពលោក។

ក្នុងឆ្នាំ២០២២ ស្របពេលដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡាក្នុងនាមសសរស្តម្ភសង្គម-វប្បធម៌អាស៊ានបានផ្តួចផ្តើមរៀបចំ "សេចក្តីថ្លែងការណ៍ រួមរបស់ថ្នាក់ដឹកនាំអាស៊ានស្តីពីឆ្នាំនៃយុវជនអាស៊ាន" និងបានរៀបចំកម្មវិធីយុវជនអាស៊ានចំនួន៥ ដូចជា៖ (១)កិច្ចសន្ទនាយុវជនអាស៊ានលើកទី១ (២)ការប្រកួតវីដេអូយុវជនអាស៊ានលើកទី៦ (៣) ការប្រកួតរូបថតយុវជនអាស៊ាន (៤)ការប្រកួតជជែកដេញដោលយុវជនអាស៊ាន និង(៥)ជំនួបថ្នាក់ដឹកនាំកំពូលអាស៊ាន ជាមួយតំណាងយុវជនអាស៊ាន ដែលកម្មវិធីទាំងអស់នេះបាននិងរួមចំណែកយ៉ាងសំខាន់ សម្រាប់ការអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ ដល់យុវជនកម្ពុជា និងយុវជនក្នុងតំបន់អាស៊ាន។

## ១.៩ ការងារអប់រំកាយ និងកីឡា

ក្រសួងបានរៀបចំគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា និងបានធ្វើកំណែទម្រង់ស៊ីជម្រៅការងារអប់រំកាយ និងកីឡា ឆ្ពោះទៅលើកកម្ពស់សុខុមាលភាពប្រជាជន និងពន្លឿន

ការអភិវឌ្ឍគ្រប់ប្រភេទកីឡាឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះនៃការរៀបចំប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ាន ប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ជាពិសេស បានរៀបចំផែនការយុទ្ធសាស្ត្រក្នុងការដណ្តើមមេដាយឱ្យបានច្រើនក្នុងការប្រកួត ដើម្បីលើកកម្ពស់កិត្យានុភាពជាតិលើឆាកអន្តរជាតិ ព្រមទាំង បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអប់រំកាយ និងកីឡា។ លទ្ធផលកំណែទម្រង់ មានដូចខាងក្រោម៖

- ក្រសួងបានរៀបចំជួសជុលកែលម្អ ថែទាំ និងកសាងហេដ្ឋារចនាសម្ព័ន្ធកីឡា បំពាក់សម្ភារឧបករណ៍ក្នុង និងក្រៅសាលារៀន, សហការជាមួយសហព័ន្ធកីឡាជាតិបាល់ទាត់កម្ពុជា រាជធានី ខេត្ត សាលាតម្រង់ទិសបាល់ទាត់ ជាពិសេស ពហុកីឡដ្ឋានជាតិ ដើម្បីបង្កលក្ខណៈដល់សិស្សានុសិស្ស មហាជនបាន ហាត់ប្រាណ និងលេងកីឡា ដើម្បីសុខភាព និងកីឡាករ កីឡាការិនី ស្របតាមពាក្យស្លោក "យុវជនម្នាក់ លេងកីឡាមួយប្រភេទប្រចាំជីវិត"
- ក្រសួងបានបណ្តុះបណ្តាលធនធានមនុស្សគ្រូអប់រំកាយ និងកីឡា មន្ត្រីបច្ចេកទេស អាជ្ញាកណ្តាល ថៅក្រម កីឡាករ កីឡាការិនីថ្នាល និងជម្រើសជាតិ ទាំងបរិមាណ និងគុណភាព ដើម្បីរៀបចំការប្រកួត និងចូលរួមប្រកួតក្នុង និងក្រៅប្រទេស
- ក្រសួងបានកែលម្អរចនាសម្ព័ន្ធនៃការប្រកួតកីឡាគ្រប់ប្រភេទ និងគ្រប់កម្រិត ដើម្បីពង្រឹងគុណភាពនៃការរៀបចំការប្រកួតជាតិ អន្តរជាតិ ទាំងក្នុងនិងក្រៅប្រទេស ឆ្ពោះទៅរកស្តង់ដានៃការប្រកួតកម្រិតតំបន់ (ជើងឯកថ្នាក់ជាតិតាមប្រភេទកីឡា ការប្រកួតពហុកីឡាកម្រិតបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សានិងការប្រកួតកីឡាជាតិ)
- ក្រសួងបានផ្ទេរមុខងារ និងគាំទ្រថវិកាទៅសហព័ន្ធកីឡាជាតិដែលមានឈ្មោះក្នុងបញ្ជីការប្រកួតស៊ីហ្គេមនិងអាស៊ានប៉ារ៉ាហ្គេម ដើម្បីពន្លឿនការអភិវឌ្ឍឆ្ពោះទៅធ្វើជាម្ចាស់ផ្ទះ
- ក្រសួងបានសហការជាមួយគណៈកម្មាធិការជាតិរៀបចំប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣ យ៉ាងល្អប្រសើរ ដោយបានទទួលមេដាយសរុបចំនួន ២៨២ ក្នុងនោះ មេដាយមាស ៨១ ប្រាក់ ៧៤ និងសំរឹទ្ធ ១២៧ ស្ថិតក្នុងចំណាត់ថ្នាក់លេខ ៤ ក្នុងចំណោម ១១ប្រទេស
- ក្រសួងបានសហការជាមួយគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ឆ្នាំ២០២៣ បានទទួលមេដាយសរុបចំនួន ៧៣ មេដាយមាស ៩ ប្រាក់ ១៩ សំរឹទ្ធ ៤៥ ស្ថិតក្នុងចំណាត់ថ្នាក់លេខ៨ ក្នុងចំណោម ១១ប្រទេស
- ក្រសួងបានសហការជាមួយនឹងអង្គការបេះដូងមាស រៀបចំចងក្រងកម្មវិធីសិក្សាលម្អិតអប់រំកាយសម្រាប់គ្រឹះស្ថានបឋមសិក្សាមធ្យមសិក្សា និងឧត្តមសិក្សា ព្រមទាំងបានបោះពុម្ពដាក់ឱ្យប្រើប្រាស់ជាផ្លូវការទូទាំងប្រទេស និងបានចងក្រងសៀវភៅគ្រូមុខវិជ្ជាអប់រំកាយសម្រាប់មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ដល់ថ្នាក់ទី១២ ចំនួន ១៥មុខវិជ្ជារង ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការលើកកម្ពស់សុខុមាលភាពសិស្ស និស្សិតទាំងផ្លូវកាយ និងផ្លូវចិត្ត កាត់បន្ថយភាពអសកម្មក្នុងសង្គម
- ក្រសួងបានរៀបចំសិក្ខាសាលាស្តីពីស្ថានភាពនៃការអភិវឌ្ឍតំបន់ហាត់ប្រាណ និងលេងកីឡាក្នុងតំបន់អាស៊ាន ព្រមទាំងផ្សព្វផ្សាយកីឡាប្រពៃណីជាតិ គុនខ្មែរ និងល្បុក្កតោ
- ក្រសួងបានរៀបចំតំបន់ហាត់ប្រាណអាស៊ាននៅរាជធានីភ្នំពេញ

- ក្រសួងរៀបចំគោលនយោបាយវិស័យកីឡាសម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាជាតិ។

## ១.១០ ការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងការបើកដំណើរការសាលារៀនឡើង វិញ

ការអនុវត្តវិស្សមកាលតូចមុនកាលកំណត់ និងការពន្យារពេលបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ បានចូលរួមចំណែកក្នុងការកាត់បន្ថយហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍។ នៅក្នុងអំឡុងពេលនោះ (១)សាលារៀនអាចរៀបចំការបង្រៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក ព្រមទាំងទាមទារឱ្យមាតាបិតាត្រូវចំណាយពេលច្រើនជាមួយកូនៗ ក្នុងអំឡុងពេលសិក្សា និងមិនអាចទៅធ្វើការបាន (២) សិស្សសាលាចំណោះទូទៅចំនួនប្រមាណ ៥០ភាគរយ តែប៉ុណ្ណោះ ដែលអាចទទួលបានសេវាអប់រំពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក ដោយសារបញ្ហាចំណាយ និងជីវភាពគ្រួសារ និង (៣) និស្សិតកម្រិតឧត្តមសិក្សាមួយចំនួន មិនទទួលបានសេវាអប់រំឡើយ ។

ក្រសួងអប់រំ យុវជន និងកីឡាបានវាយតម្លៃថា នៅក្នុងឆ្នាំ២០២០ និង២០២១ គ្រឹះស្ថានសិក្សាទាំងអស់នៅកម្ពុជាមិនទាន់អាចដំណើរការបានពេញលេញដូចមុនទៀតឡើយ ហើយត្រូវអនុវត្ត «**វិធានការសុវត្ថិភាពសិក្សា**» ដើម្បីការពារសុវត្ថិភាពអ្នកសិក្សា បុគ្គលិកសិក្សា និងបុគ្គលិកបម្រើការផ្សេងទៀត ព្រមទាំងផ្តល់នូវទំនុកចិត្តដល់មាតាបិតាសិស្ស។ នៅក្នុងបរិបទនេះ វិស័យអប់រំត្រូវសម្របសម្រួលទៅតាម «**ជីវិតរស់នៅធម្មតាតាមគន្លងថ្មី**» (New Normal Life) ។

ដោយថ្លឹងថ្លែងយ៉ាងប្រយ័ត្នប្រយែង រវាងតម្រូវការបន្តអនុវត្តវិធានសុវត្ថិភាពសិក្សា និងការការពារសុខភាពរបស់អ្នកសិក្សា បុគ្គលិកសិក្សា និងបុគ្គលិកបម្រើការផ្សេងទៀត ព្រមទាំងតម្រូវការក្នុងការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ ក្រសួងបានរៀបចំ "**យុទ្ធសាស្ត្រស្តីពីការបើកដំណើរការគ្រឹះស្ថានសិក្សាឡើងវិញ**" ដោយឈរលើអភិក្រមពីរគឺៈ (១) ការបើកដំណើរការឡើងវិញតាមដំណាក់កាល គ្រឹះ-ស្ថានសិក្សាណា ដែលអាចអនុវត្តបាននូវ «**ស្តង់ដាសុវត្ថិភាពសុខភាព**» អាចបើកឡើងវិញ និង (២)ការបន្តអនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ ការសិក្សាក្នុងថ្នាក់រៀន ការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងតាមបែបប្រពៃណី (សន្លឹកកិច្ចការជំនួយ) រួមទាំងការធ្វើស្វ័យសិក្សា (សម្រាប់សិស្សនៅទីជនបទ)។

ក្រសួងបានផ្សព្វផ្សាយ "សេចក្តីណែនាំស្តីពីលក្ខខណ្ឌតម្រូវនៃការលើកកម្ពស់សុខភាពសិក្សាក្នុងបរិបទនៃជំងឺកូវីដ-១៩" ដើម្បីឱ្យគ្រឹះស្ថានសិក្សាអាចត្រៀមលក្ខណៈពង្រឹងសមត្ថភាពបច្ចេកទេស ដើម្បីអាចអនុវត្តបាននូវ «ស្តង់ដាសុវត្ថិភាពសុខភាព» ដែលដាក់ចេញដោយក្រសួងសុខាភិបាល។ ជាមួយគ្នានេះដែរ ក្រសួងក៏បានរៀបចំឯកសារស្តីពី "គោលការណ៍ប្រតិបត្តិស្តង់ដា (Standard Operating Procedure-SOP)" ដែលជាលក្ខខណ្ឌតម្រូវសម្រាប់គ្រឹះស្ថានសិក្សានីមួយៗយកទៅ អនុវត្តក្នុងពេលឱ្យបើកដំណើរការឡើងវិញ ។

ក្រសួងបានរៀបចំការគាំទ្រគ្រឹះស្ថានសិក្សា តាមរយៈ**ការរៀបចំថ្នាក់ បន្ទប់រៀន និងម៉ោងសិក្សា** ដើម្បីរក្សា បាននូវគម្លាតសុវត្ថិភាពសង្គមទាំងសិស្សានុសិស្ស បុគ្គលិកសិក្សា បុគ្គលិកបម្រើការផ្សេង និងគណៈគ្រប់គ្រងគ្រឹះស្ថាន និងដើម្បីធានាបាននូវគុណភាពអប់រំ ក្រសួងបានស្នើឱ្យគ្រឹះស្ថានសិក្សាធ្វើការ

បែងចែកវេនសិក្សា និងបង្រៀនមុខវិជ្ជាសំខាន់ៗ ជាពិសេសមុខវិជ្ជាប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។

ក្រសួងបានគាំទ្រដល់ការផលិតឯកសារសម្រាប់គាំទ្រដល់ការបង្រៀន ដែលនាយកដ្ឋានជំនាញសហការជាមួយអង្គភាពក្រោមឱវាទ និងសាលារៀន ដើម្បីផលិតឯកសារចំនួនពីរគឺ ១)ឯកសារជាវីដេអូសម្រាប់គាំទ្រដល់ការបង្រៀនពីចម្ងាយ គ្រប់កម្រិតថ្នាក់ គ្រប់មុខវិជ្ជា និង ២)ឯកសារសម្រាប់សិស្សធ្វើស្វ័យសិក្សាដោយខ្លួនឯង។ ឯកសារនេះបានជួយជំរុញសិស្សឱ្យចេះធ្វើស្វ័យសិក្សា តាមរយៈការស្រង់ និងប្រមូលទិន្នន័យពីក្នុងសៀវភៅសិក្សាគោល និងជួយដល់គ្រូក្នុងការបង្រៀន និងជួយសិស្ស។

ក្រសួងបានគាំទ្រដល់ការពន្លឿនការសិក្សារបស់សិស្សថ្នាក់ទី៩ និងទី១២ ដោយប្រើប្រាស់កម្មវិធីបង្រៀនសម្របតាមសិស្ស (Adaptive Learning System) ក្នុងស្ថានភាពនៃជំងឺកូវីដ-១៩ ដើម្បី ១)ធានាបានលទ្ធផលសិក្សារបស់សិស្ស ឆ្លើយតបទៅនឹងកម្មវិធីសិក្សាគោល និងកម្មវិធីសិក្សាលម្អិតសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ និង ២)រៀបចំយន្តការដឹកនាំ និងគ្រប់គ្រងការងារបច្ចេកទេស នៅតាមសាលារៀន ដើម្បីពង្រឹងការអនុវត្តកម្មវិធី Adaptive Learning System។

## ឧបសម្ព័ន្ធទី១៖ បញ្ជីឈ្មោះសាលាមធ្យមសិក្សាគោលដៅទាំង ១០០ របស់គម្រោងកែលម្អការអប់រំនៅមធ្យមសិក្សា

| ល.រ | រាជធានី ខេត្ត | ក្រុង ស្រុក ខណ្ឌ | ឈ្មោះគ្រឹះស្ថានសិក្សា | |
|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | ថ្មពួក | វិទ្យាល័យ | ថ្មពួក |
| 2 | បន្ទាយមានជ័យ | ព្រះនេត្រព្រះ | វិទ្យាល័យ | ហ៊ុនសែន ឈ្នួរមានជ័យ |
| 3 | បន្ទាយមានជ័យ | មង្គលបូរី | វិទ្យាល័យ | មង្គលបូរី |
| 4 | បន្ទាយមានជ័យ | សិរីសោភ័ណ្ឌ | វិទ្យាល័យ | សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិ អូរអំបិល |
| 5 | បាត់ដំបង | ថ្មគោល | វិទ្យាល័យ | រូងជ្រៃ |
| 6 | បាត់ដំបង | បវេល | វិទ្យាល័យ | បវេល |
| 7 | បាត់ដំបង | ភ្នំព្រឹក | វិទ្យាល័យ | ពេជ្រចិន្តា |
| 8 | បាត់ដំបង | សង្កែ | វិទ្យាល័យ | អន្លង់វិល |
| 9 | កំពង់ឆ្នាំង | កំពង់ឆ្នាំង | វិទ្យាល័យ | ក្រុងកំពង់ឆ្នាំង |
| 10 | កំពង់ឆ្នាំង | ទឹកផុស | វិទ្យាល័យ | ហ៊ុនសែនទួលខ្ពស់ |
| 11 | កំពង់ឆ្នាំង | បរិបូណ៌ | វិទ្យាល័យ | បរិបូណ៌ត្បូង |
| 12 | កំពង់ឆ្នាំង | សាមគ្គីមានជ័យ | វិទ្យាល័យ | មិត្តភាពខ្មែរជប៉ុនមានជ័យ |
| 13 | ពោធិ៍សាត់ | ក្រគរ | វិទ្យាល័យ | ហ៊ុន សែន ១០ មករា |
| 14 | ពោធិ៍សាត់ | ក្រគរ | វិទ្យាល័យ | សម្តេចហ៊ុនសែនឈើតុំ |
| 15 | ពោធិ៍សាត់ | ក្រវ៉ាញ | វិទ្យាល័យ | ថ្មកដង្កោ |
| 16 | ពោធិ៍សាត់ | បាកាន | វិទ្យាល័យ | តាលោ |
| 17 | ប៉ៃលិន | ប៉ៃលិន | អនុវិទ្យាល័យ | ភ្នំយ៉ាត |
| 18 | ប៉ៃលិន | សាលាក្រៅ | វិទ្យាល័យ | ហ៊ុនសែនសាលាក្រៅ |
| 19 | ឧត្តរមានជ័យ | បន្ទាយអំពិល | វិទ្យាល័យ | អំពិល |

| | | | | |
|---|---|---|---|---|
| 20 | ឧត្តរមានជ័យ | សំរោង | វិទ្យាល័យ | តេជោសែន សំរោង |
| 21 | កំពត | កំពង់ត្រាច | វិទ្យាល័យ | សម្តេចហ៊ុនសែន អង្គសុរភី |
| 22 | កំពត | ជុំគិរី | វិទ្យាល័យ | ព្រៃឃ្លៃ |
| 23 | កំពត | ទឹកឈូ | វិទ្យាល័យ | ហ៊ុន សែន ត្រសេកកោង |
| 24 | កំពត | បន្ទាយមាស | វិទ្យាល័យ | កន្សោមអក |
| 25 | កំពត | អង្គរជ័យ | វិទ្យាល័យ | វត្តអង្គរជ័យ |
| 26 | កោះកុង | បុទមសាគរ | វិទ្យាល័យ | ថ្មស |
| 27 | កោះកុង | មណ្ឌលសីមា | វិទ្យាល័យ | ប៉ាក់ខ្លង |
| 28 | ព្រះសីហនុ | ព្រៃនប់ | វិទ្យាល័យ | ហ៊ុន សែន ព្រៃនប់ |
| 29 | ព្រះសីហនុ | ព្រៃនប់ | វិទ្យាល័យ | ហ៊ុន សែន វាលរេញ |
| 30 | ព្រះសីហនុ | ស្ទឹងហាវ | វិទ្យាល័យ | ស្ទឹងហាវ |
| 31 | តាកែវ | កោះអណ្តែត | វិទ្យាល័យ | សុខអាន ព្រៃមេលង |
| 32 | តាកែវ | គីរីវង់ | វិទ្យាល័យ | គីរីវង់ |
| 33 | តាកែវ | គីរីវង់ | វិទ្យាល័យ | សុខ អាន ទន្លាប់ |
| 34 | តាកែវ | ត្រាំកក់ | វិទ្យាល័យ | អង្គរការ |
| 35 | តាកែវ | ទ្រាំង | វិទ្យាល័យ | សុខអាន ព្រៃសណ្តែក |
| 36 | តាកែវ | ទ្រាំង | វិទ្យាល័យ | ព្រៃទប់ |
| 37 | តាកែវ | បាទី | វិទ្យាល័យ | សុខ អាន ត្រាំខ្នារ |
| 38 | តាកែវ | អង្គរបូរី | វិទ្យាល័យ | សំរោងពន្លៃ |
| 39 | កែប | កែប | វិទ្យាល័យ | ប៊ុនរ៉ានីហ៊ុនសែន ចរិយាវង្ស |
| 40 | កែប | ដំណាក់ចង្អើរ | អនុវិទ្យាល័យ | ពងទឹក |
| 41 | កណ្តាល | កណ្តាលស្ទឹង | វិទ្យាល័យ | ហ៊ុន សែន កំពង់កន្ទួត |
| 42 | កណ្តាល | កៀនស្វាយ | វិទ្យាល័យ | ជ័យវរ្ម័នទី៧ |
| 43 | កណ្តាល | កោះធំ | វិទ្យាល័យ | ប៊ុន រ៉ានី ហ៊ុន សែន ព្រែកតាដួង |
| 44 | កណ្តាល | កណ្តាលស្ទឹង | វិទ្យាល័យ | ហ៊ុន សែន សំពៅពូន |
| 45 | កណ្តាល | ពញាឮ | វិទ្យាល័យ | សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន ព្រែកតាទែន |
| 46 | កណ្តាល | មុខកំពូល | វិទ្យាល័យ | សិរីមង្គល |
| 47 | កណ្តាល | ល្វាឯម | វិទ្យាល័យ | ហ៊ុន សែន ល្វាស |
| 48 | កណ្តាល | ស្អាង | វិទ្យាល័យ | ហ៊ុន សែន ស្អាង |
| 49 | កណ្តាល | ស្អាង | វិទ្យាល័យ | សម្តេចតេជោហ៊ុនសែន ត្រើយស្លា |
| 50 | មណ្ឌលគិរី | កែវសីម៉ា | វិទ្យាល័យ | ហ៊ុនសែនកែវសីម៉ា |
| 51 | មណ្ឌលគិរី | កោះញែក | វិទ្យាល័យ | ហ៊ុន សែន កោះញែក |
| 52 | រតនគិរី | បានលុង | វិទ្យាល័យ | ហ៊ុន សែន ភូមិថ្មី |
| 53 | រតនគិរី | វីនសៃ | វិទ្យាល័យ | វីរៈជ័យ |
| 54 | ស្វាយរៀង | កំពង់រោទិ៍ | វិទ្យាល័យ | ហ៊ុនសែន កំពង់រោទិ៍ |
| 55 | ស្វាយរៀង | ចន្ទ្រា | វិទ្យាល័យ | ប៊ុន រ៉ានី ហ៊ុន សែន ចន្ទ្រា |
| 56 | ស្វាយរៀង | ស្វាយជ្រំ | វិទ្យាល័យ | ហ៊ុនសែន ក្រោលគោ |
| 57 | ត្បូងឃ្មុំ | ត្បូងឃ្មុំ | វិទ្យាល័យ | ហ៊ុន សែនត្រពាំងឫស្សី |

| | | | | |
|---|---|---|---|---|
| 58 | ត្បូងឃ្មុំ | តំបែរ | វិទ្យាល័យ | ហ៊ុន សែនចារថ្មី |
| 59 | ត្បូងឃ្មុំ | តំបែរ | វិទ្យាល័យ | ហ៊ុន សែន តំបែរ |
| 60 | ត្បូងឃ្មុំ | ពញាក្រែក | វិទ្យាល័យ | ក្រែក |
| 61 | កំពង់ចាម | កំពង់សៀម | វិទ្យាល័យ | ឈីនលានហាន់ជ័យ |
| 62 | កំពង់ចាម | ជើងព្រៃ | វិទ្យាល័យ | សំពងជ័យ |
| 63 | កំពង់ចាម | ស្ទឹងត្រង់ | វិទ្យាល័យ | មេសរជ្រៃ |
| 64 | កំពង់ចាម | ស្រីសន្ធរ | វិទ្យាល័យ | ព្រែកដំបូក |
| 65 | កំពង់ស្ពឺ | គងពិសី | វិទ្យាល័យ | ទំពមានជ័យ |
| 66 | កំពង់ស្ពឺ | បសេដ្ឋ | អនុវិទ្យាល័យ | អង្គសាយ |
| 67 | កំពង់ស្ពឺ | បសេដ្ឋ | វិទ្យាល័យ | ស្លាបលែង |
| 68 | កំពង់ស្ពឺ | បសេដ្ឋ | វិទ្យាល័យ | សម្តេចឪសម្តេចម៉ែបរសេដ្ឋ |
| 69 | កំពង់ស្ពឺ | ភ្នំស្រួច | វិទ្យាល័យ | បណ្ឌិតឡុងសៀម |
| 70 | ក្រចេះ | ចិត្របុរី | វិទ្យាល័យ | ថ្មគ្រែ |
| 71 | ក្រចេះ | ព្រែកប្រសប់ | វិទ្យាល័យ | ព្រែកប្រសប់ |
| 72 | ក្រចេះ | សំបូរ | វិទ្យាល័យ | សណ្តាន់ |
| 73 | រាជធានីភ្នំពេញ | ៧មករា | វិទ្យាល័យ | បាក់ទូក |
| 74 | រាជធានីភ្នំពេញ | ច្បារអំពៅ | វិទ្យាល័យ | ព្រែកឯង |
| 75 | រាជធានីភ្នំពេញ | ជ្រោយចង្វារ | វិទ្យាល័យ | ប៊ុនរ៉ានីហ៊ុនសែនកោះដាច់ |
| 76 | រាជធានីភ្នំពេញ | ជ្រោយចង្វារ | វិទ្យាល័យ | ជាស៊ីមជ្រោយចង្វារ |
| 77 | រាជធានីភ្នំពេញ | មានជ័យ | វិទ្យាល័យ | ហ៊ុនសែនចាក់អង្រែ |
| 78 | រាជធានីភ្នំពេញ | ឫស្សីកែវ | វិទ្យាល័យ | ឫស្សីកែវ |
| 79 | រាជធានីភ្នំពេញ | សែនសុខ | វិទ្យាល័យ | ទួលប្រាសាទសែនសុខ |
| 80 | ស្ទឹងត្រែង | ថាឡាបរិវ៉ាត់ | អនុវិទ្យាល័យ | ថាឡាបរិវ៉ាត់ |
| 81 | ស្ទឹងត្រែង | ស្ទឹងត្រែង | វិទ្យាល័យ | ហ៊ុន សែន ស្ទឹងត្រែង |
| 82 | ព្រះវិហារ | ព្រះវិហារ | អនុវិទ្យាល័យ | ហ៊ុន សែន ត្បែងមានជ័យ |
| 83 | ព្រះវិហារ | សង្គមថ្មី | អនុវិទ្យាល័យ | សង្គមថ្មី |
| 84 | ព្រៃវែង | កំចាយមារ | វិទ្យាល័យ | ជាច |
| 85 | ព្រៃវែង | កំពង់ត្របែក | វិទ្យាល័យ | ប៊ុនរ៉ានីហ៊ុនសែន ព្រៃពោន |
| 86 | ព្រៃវែង | បាភ្នំ | វិទ្យាល័យ | ជា ស៊ីម រក្សជ័យ |
| 87 | ព្រៃវែង | ពាមជរ | វិទ្យាល័យ | ព្រែកក្របៅ |
| 88 | ព្រៃវែង | ពារាំង | វិទ្យាល័យ | ព្រៃឈ្កៅ |
| 89 | ព្រៃវែង | ពោធិ៍រៀង | វិទ្យាល័យ | ហ៊ុនសែន ពោធិ៍រៀង |
| 90 | ព្រៃវែង | ព្រះស្តេច | វិទ្យាល័យ | ប្រមូលព្រហ្ម |
| 91 | ព្រៃវែង | មេសាង | វិទ្យាល័យ | មេសាង |
| 92 | ព្រៃវែង | ស៊ីធរកណ្តាល | វិទ្យាល័យ | ហ៊ុនសែន ព្រែកសណ្តែក |
| 93 | សៀមរាប | ប្រាសាទបាគង | វិទ្យាល័យ | ហ៊ុន សែន ប្រាសាទបាគង |
| 94 | សៀមរាប | សូទ្រនិគម | វិទ្យាល័យ | សំរោង |
| 95 | សៀមរាប | ស្រីស្នំ | វិទ្យាល័យ | ២៨ មករា |
| 96 | សៀមរាប | អង្គរធំ | វិទ្យាល័យ | តេជោហ៊ុនសែន អង្គរធំ |

| | | | | |
|---|---|---|---|---|
| 97 | កំពង់ធំ | កំពង់ស្វាយ | វិទ្យាល័យ | ទួលក្បិល |
| 98 | កំពង់ធំ | តាំងគោក | វិទ្យាល័យ | ហ៊ុនសែន តាំងគោក |
| 99 | កំពង់ធំ | បារាយណ៍ | វិទ្យាល័យ | ជាស៊ីមកំពង់ថ្ម |
| 100 | កំពង់ធំ | សន្ទុក | វិទ្យាល័យ | តាំងក្រសាំង |

# ឧបសម្ព័ន្ធទី២៖ ស្ថិតិបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សា ទុតិយភូមិ ចំណេះទូទៅ និងបំពេញវិជ្ជា

| ឆ្នាំប្រឡង | ចំនួនបេក្ខជនមកប្រឡង | | ចំនួនបេក្ខជនប្រឡងជាប់ | | ភាគរយបេក្ខជនប្រឡងជាប់ (%) | | ចំនួនបេក្ខជនប្រឡងជាប់តាមនិទ្ទេស (%) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | A | | B | | C | | D | | E | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| 2011 | 101246 | 43778 | 84809 | 38946 | 83.77 | 88.96 | 0.05% | 0.04% | 2.00% | 2.27% | 12.20% | 15.01% | 31.97% | 36.18% | 37.54% | 35.46% |
| 2012 | 111040 | 48857 | 96023 | 44727 | 86.48 | 91.55 | 0.09% | 0.13% | 3.16% | 3.99% | 16.03% | 20.00% | 33.79% | 37.82% | 33.40% | 29.60% |
| 2013 | 105298 | 47010 | 91371 | 43611 | 86.77 | 92.77 | 0.08% | 0.10% | 4.80% | 6.39% | 21.70% | 27.40% | 34.67% | 37.55% | 25.52% | 21.33% |
| 2014-1 | 89921 | 41324 | 23126 | 12139 | 25.72 | 29.38 | 0.01% | 0.01% | 0.24% | 0.21% | 1.01% | 0.98% | 2.04% | 2.12% | 22.42% | 26.06% |
| 2014-2 | 60611 | 26988 | 10871 | 5742 | 17.94 | 21.28 | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.09% | 0.08% | 17.84% | 21.19% |
| 2015 | 83325 | 40422 | 46560 | 24020 | 55.88 | 59.42 | 0.13% | 0.12% | 1.30% | 1.33% | 3.95% | 4.09% | 7.31% | 7.70% | 43.18% | 46.19% |
| 2016 | 89661 | 44012 | 55753 | 28816 | 62.18 | 65.47 | 0.45% | 0.46% | 3.12% | 3.33% | 6.24% | 6.74% | 9.85% | 10.60% | 42.51% | 44.34% |
| 2017 | 99728 | 49467 | 63668 | 32610 | 63.84 | 65.92 | 0.43% | 0.43% | 2.47% | 2.52% | 5.01% | 5.23% | 9.15% | 9.99% | 46.78% | 47.76% |
| 2018 | 113365 | 57413 | 76034 | 39834 | 67.07 | 69.38 | 0.36% | 0.34% | 1.96% | 1.97% | 5.33% | 5.81% | 13.39% | 14.78% | 46.03% | 46.48% |
| 2019 | 115206 | 59733 | 79052 | 43729 | 68.62 | 73.21 | 0.38% | 0.37% | 2.11% | 2.19% | 5.08% | 5.72% | 12.24% | 14.09% | 48.81% | 50.84% |
| 2020 | 121073 | 63893 | 121073 | 63893 | 100.00 | 100.00 | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% |
| 2021 | 109695 | 58561 | 72016 | 41733 | 65.65 | 71.26 | 1.60% | 1.79% | 4.75% | 5.33% | 10.61% | 12.35% | 21.42% | 24.27% | 27.27% | 27.52% |
| 2022 | 125739 | 67743 | 90950 | 52512 | 72.33 | 77.52 | 0.83% | 0.81% | 5.75% | 6.64% | 15.15% | 17.38% | 24.79% | 27.13% | 25.81% | 25.54% |

## ផ្នែកទី២. យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ ២០២៣-២០២៨

ក្នុងអាណត្តិទី៧ នេះ រាជរដ្ឋាភិបាលកម្ពុជានឹងដាក់ចេញយុទ្ធសាស្ត្របញ្ចកោណ ដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១។ សម្រាប់ដំណាក់កាលបន្ទាប់នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាល ទី១ ក្រសួងអប់រំ យុវជន និងកីឡានឹងបន្តការកែទម្រង់វិស័យអប់រំ ដោយផ្តោតលើការពង្រឹងគុណភាពអប់រំនៅគ្រប់កម្រិតសិក្សា ការបង្កើនការចូលរៀនមុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជំរុញការអប់រំឌីជីថល ពង្រឹងការបណ្តុះបណ្តាលជំនាញសម្រាប់យុវជន ពង្រឹងការអប់រំកាយនិងកីឡា និងភាពជាពលរដ្ឋល្អ។

ក្រសួងបានធ្វើមូលដ្ឋានីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្តីពីការអប់រំឆ្នាំ ២០៣០ និង ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៣-២០២៨ ដែលមានគោលនយោបាយពីរគឺៈ ១.ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង២.ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ជាមួយគ្នានេះ ក្រសួងនឹងបន្តពង្រឹងប្រព័ន្ធអប់រំឱ្យមានភាពរស់រវើក ឆ្លើយតបនឹងបរិការណ៍ជាតិ និងអន្តរជាតិ ដែលកំពុងមាន ការប្រែប្រួលយ៉ាងឆាប់រហ័ស ជាពិសេសការអនុវត្តវិធានការ ដើម្បីដោះស្រាយការខាតបង់ការរៀនសូត្ររបស់ សិស្សានុសិស្ស និងយុវជន ដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ក្នុងរយៈពេលកន្លងមក។

ក្រសួងនឹងផ្តល់អាទិភាពចម្បងលើការពង្រឹងគុណភាអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍមូលធនមនុស្សសម្រាប់សង្គម និងសេដ្ឋកិច្ចឌីជីថលកម្ពុជា។ ឈរលើមូលដ្ឋាននេះ ក្រសួងនឹងបន្តអនុវត្តកំណែទម្រង់សាលារៀនយ៉ាងសកម្ម សំដៅទទួលបាននូវសាលារៀនល្អ នាយកសាលាល្អ គ្រូបង្រៀនល្អ បរិស្ថានសាលារៀនល្អ និងមានការចូលរួមយ៉ាងផុលផុសពីសំណាក់សហគមន៍ គ្រួសារ និងអ្នកពាក់ព័ន្ធ។ ជាមួយនេះ ក្រសួងនឹងផ្តោតខ្លាំងលើការរៀននិងបង្រៀនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង នៅកម្រិតបឋមសិក្សា ការបង្កើនការចូលរៀននិងពង្រឹងការរៀនមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងភាសាបរទេសនៅកម្រិតមធ្យមសិក្សាចំណេះទូទៅ ការផ្តល់ឱកាសដល់ជនគ្រប់រូបក្នុងការសិក្សាពេញមួយជីវិត ការផ្តល់ការអប់រំពហុភាសាដល់កុមារជនជាតិដើមភាគតិច ការផ្តល់សេវាអប់រំពិសេសដល់កុមារមានពិការភាព និងបង្កើនចំនួនមជ្ឈមណ្ឌលឧត្តមភាពនៅឧត្តមសិក្សា ជាពិសេស ការសម្រិតសម្រាំង និងការតម្រង់ទិសការចូលសិក្សានៅកម្រិតឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឆ្លើយតបនឹងនិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ច។

ក្រសួងនឹងកសាងប្រព័ន្ធ និងអភិវឌ្ឍសមត្ថភាពរបស់ប្រព័ន្ធអប់រំឱ្យមានភាពរស់រវើក ប្រទាក់ក្រឡាគ្នា និងមានភាពបុរេសកម្ម តាមរយៈធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដោយផ្តោតជាពិសេសលើការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងដឹកនាំសាលារៀន កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ និងគ្រូបង្រៀន ការអនុវត្តគន្លងអាជីព ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ការពង្រឹងវិធីសាស្ត្របង្រៀន និងរៀនតាមបែបថ្មី ការធ្វើអធិការកិច្ច ការពង្រឹងការប្រឡងគ្រប់ប្រភេទ ការអនុវត្តតេស្តវាយតម្លៃលទ្ធផលសិក្សា

របស់សិស្សជាតិ និងអន្តរជាតិ ការអនុវត្តកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃសិស្ស(PISA) ការបង្កើតកម្មវិធីស្រាវជ្រាវផ្តោតលើការបណ្តុះបណ្តាលគ្រូ ការអនុវត្តកម្មវិធីភាពជាដៃគូនៃការអប់រំស្វែមរវាងមធ្យមសិក្សានិងឧត្តមសិក្សា និងនិន្នាការថ្មីៗ ក្នុងវិស័យអប់រំ ព្រមទាំងការបង្កើនការស្រាវជ្រាវនិងនវានុវត្តន៍នៅឧត្តមសិក្សា។

ក្រសួងនឹងបន្តអភិវឌ្ឍ និងជំរុញការអប់រំឌីជីថល សម្រាប់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងបរិបទនៃបរិវត្តកម្មសង្គម និងសេដ្ឋកិច្ចឌីជីថល ដោយត្រូវបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃប្រព័ន្ធអប់រំ បំពាក់បន្ទប់ឌីជីថល តភ្ជាប់បណ្តាញអគ្គិសនី និងអ៊ីនធើណិតនៅតាមគ្រឹះស្ថានសិក្សា លើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពឌីជីថលដល់គ្រូបង្រៀន ផលិតវីដេអូបង្រៀននិងមាតិកាឌីជីថលលើមុខវិជ្ជាគោល និងសម្រាប់ថ្នាក់ប្រឡង ព្រមទាំងផ្សព្វផ្សាយការងារទាំងនោះនៅលើវេទិកាឌីជីថល ឱ្យកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ។

ក្រសួងនឹងបន្តលើកកម្ពស់វិស័យកីឡា ដែលជាវិស័យអាទិភាពមួយរបស់ជាតិ តាមរយៈជំរុញការអនុវត្តកំណែទម្រង់ស៊ីជម្រៅវិស័យអប់រំកាយ និងកីឡា និងជំរុញការលើកទឹកចិត្ត និងបណ្តុះវប្បធម៌អប់រំកាយ និងកីឡាដល់ប្រជាជន ឱ្យប្រជាជនរស់នៅប្រកបដោយភាពស៊ីវិល័យ និងសុខដុមនីយកម្មក្នុងសង្គម។

ក្រសួងនឹងពង្រឹងកត្តាមូលដ្ឋាន សម្រាប់រៀបចំការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព ដោយផ្តោតលើស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ស្តង់ដាសាលារៀន និងស្តង់ដានាយកសាលា តាមរយៈឧត្តមានុវត្តន៍នៃការពង្រឹង (ការគ្រប់គ្រង) សាលារៀនប្រកបដោយប្រសិទ្ធភាព តាមរយៈកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀន, ការអនុវត្តយុទ្ធសាស្ត្រសហគមន៍សាលារៀន ការចុះជួយដឹកដៃក្នុងការងារ គ្រប់គ្រង និងអភិវឌ្ឍសាលារៀន (mentorship program) ការជួយគាំទ្រដល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ជំនួយបច្ចេកទេស នៅក្នុងសហគមន៍សាលារៀននិងគ្រូបង្រៀន (coaching program)។

ក្រសួងនឹងបន្តលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត និងបរិក្ខារសម្រាប់អគារធនធាន, ការបំប៉នសមត្ថភាពគ្រូមុខវិជ្ជាវិទ្យាសាស្ត្រនិងគណិតវិទ្យាអំពីវិធីសាស្ត្រ បង្រៀនថ្មី ការអនុវត្តកម្មវិធីសិក្សាថ្មី, និងការផ្តល់អាហារូបករណ៍ដល់សិស្ស និងគ្រូបង្រៀនដែលកំពុងសិក្សា និងបង្រៀន មុខវិជ្ជាវិទ្យាសាស្ត្រនៅខេត្តជួបការលំបាកទាំង៧។ ក្រសួងនឹងបន្តអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំ ដោយផ្តោតលើ ហេដ្ឋារចនាសម្ព័ន្ធរឹង និងទន់ និងបង្កើនប្រសិទ្ធភាពនៃដំណើរការរបស់វិទ្យាល័យធនធានទាំង ៦៧ ព្រមទាំងសាលាបណ្តាញ ក្នុងការជំរុញការរៀន និងបង្រៀន (ជាពិសេសត្រូវផ្សារភ្ជាប់ជាមួយការប្រើប្រាស់អគារធនធាន) មុខវិជ្ជាស្វែម។ ជាមួយគ្នានេះ ក្រសួងបន្តលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដោយជួយអភិវឌ្ឍវិទ្យាល័យធនធាន និងសាលាបណ្តាញ វិទ្យាល័យ ចំណេះទូទៅនិងបច្ចេកទេស ជាពិសេស ការផ្សារភ្ជាប់ការសិក្សានៅមធ្យមសិក្សាទៅនឹងគ្រឹះស្ថានឧត្តមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយបំពាក់បន្ថែមនូវបន្ទប់វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យទំនើប បន្ទប់បំណិនជីវិតពហុបំណង

បន្ទប់បំណិនជីវិតពហុបំណង ជំរុញការអនុវត្តកម្មវិធីមគ្គុទេសក៍អាជីពនិងការផ្តល់ប្រឹក្សា និងការរៀននិងបង្រៀនតាមបែបគម្រោង និងការរៀបចំពិព័រណ៌ស្នាដៃសិស្សនៅតាមសាលារៀន។

ក្រសួងនឹងបន្តលើកកម្ពស់គុណភាពនៃការអប់រំនៅឧត្តមសិក្សា តាមរយៈ ១) ការកែលម្អសមត្ថភាពក្នុងការរៀន និងបង្រៀននៅឧត្តមសិក្សា ២) ការកែលម្អការស្រាវជ្រាវលើមុខវិជ្ជា STEAM និងកសិកម្ម ៣) ការលើកកម្ពស់អភិបាលកិច្ចនិងការគ្រប់គ្រងនៅតាមគ្រឹះស្ថានឧត្តមសិក្សា និង ៤) ការសាងសង់អគារសិក្សា និងការបំពាក់បន្ទប់ពិសោធន៍ និងសម្ភារសម្រាប់បង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

ក្រសួងនឹងដាក់ឱ្យអនុវត្តអភិក្រមស្តីពីការគ្រប់គ្រងផ្តោតលើលទ្ធផល តាមរយៈការបង្កើតយន្តការគ្រប់គ្រង និងបែងចែកធាតុចូល ដែលមានគុណភាព និងតម្រង់ទៅរកលទ្ធផល ជាពិសេសធាតុចូល ដែលគាំទ្រដល់ការបង្កើនលទ្ធផលសិក្សារបស់សិស្ស សាលារៀនមានគុណភាពនិងសម្រេចបានតាមស្តង់ដា សាលារៀនមានប្រសិទ្ធភាព និងការបណ្តុះបណ្តាលធនធានមនុស្សដែលមានគុណភាពល្អ និងភាពជាពលរដ្ឋល្អ តាមរយៈ៖

(១) ការពង្រឹងការគ្រប់គ្រងផ្តោតលើលទ្ធផល ឆ្ពោះទៅរកការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធ និងតាមបែបអនុវិស័យ ដោយពង្រឹងការគ្រប់គ្រង និងការវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ។

(២) ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ រួមបញ្ចូលទាំងការពិនិត្យឡើងវិញមុខងារនិងភារកិច្ច ការរៀបចំផែនការប្រចាំឆ្នាំ ការអនុវត្តគន្លងអាជីព ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យតាមដាននិងវាយតម្លៃ។

(៣) ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស ដោយផ្តោតលើការបណ្តុះបណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀន ជាអ្នកដឹកនាំនិងគ្រប់គ្រង និងជាអ្នកស្រាវជ្រាវ និងវាយតម្លៃ ជាមួយគ្នានេះ ត្រូវបង្កើតយន្តការតម្រង់ទិសការងារ ការចុះជួយដឹកដៃការងារ និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ កែលម្អប្រព័ន្ធលើកទឹកចិត្ត និងការផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍគន្លងអាជីព ក៏ដូចជាការទទួលស្គាល់អ្នកជំនាញអប់រំ។ លើកកម្ពស់ការប្រឡងប្រណាំង, ការវាយតម្លៃនាយកសាលាល្អ គ្រូបង្រៀនល្អ គ្រូបង្រៀនល្អ ភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង និងនាយកសាលាស្អាត ដោយប្រើប្រាស់ប្រព័ន្ធវាយតម្លៃ ការបំពេញការងារប្រចាំឆ្នាំ។

(៤) ការប្រើប្រាស់ប្រព័ន្ធ និងការផ្លាស់ប្តូររបៀបធ្វើការ ដោយប្រែក្លាយឧត្តមានុវត្តន៍នៃការអនុវត្តគម្រោងនានា មកជាការពង្រឹងប្រព័ន្ធ និងការរៀបចំគោលនយោបាយ និងគោលការណ៍ណែនាំ។

ក្រសួងនឹងបង្កើនប្រសិទ្ធភាពនៃការអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការ និងការបង្កើនការចូលរួមរបស់សហគមន៍ មាតាបិតានៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍសាលារៀន។

## ២.១ អាទិភាព ៨ ចំណុច

## អាទិភាពស្នូលទី១៖ ការពង្រឹងអភិបាលកិច្ចសាលារៀន

### ១.១ កំណែទម្រង់នៅថ្នាក់ជាតិ

- យកចិត្តទុកដាក់លើការអប់រំចាប់ពីមត្តេយ្យសិក្សាហូតដល់មធ្យមសិក្សាទុតិយភូមិដោយផ្តោតលើ "**ការពង្រឹងសមត្ថភាពចំណេះដឹង, សុខភាព និងឥរិយាបទដល់សិស្សគ្រប់រូប**"។
- រៀបចំ "**យន្តការថ្នាក់ជាតិដើម្បីជំរុញកំណែទម្រង់**" តាមរយៈការកំណត់អាទិភាពបញ្ហាប្រឈមយុទ្ធសាស្រ្ត និងពង្រឹងការពិនិត្យតាមដាននិងវាយតម្លៃ។
- ពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពប្រព័ន្ធ និងបុគ្គល ដោយផ្តោតលើការពិនិត្យមុខងារ ដើម្បីឱ្យអង្គភាពនីមួយៗមានធនធានមនុស្សសមស្របទៅនឹងតួនាទីនិងភារកិច្ច ព្រមទាំងដាក់ឱ្យអនុវត្តនូវកិច្ចសន្យាសមិទ្ធកម្ម និងការបំពេញការងារផ្តោតលើលទ្ធផល។
- រៀបចំ "**ក្រុមការងារបច្ចេកទេសកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា**" ព្រមទាំងបង្កើត "**ក្រុមចុះជួយ coaching team**" ដោយប្រមូលផ្តុំនាយកសាលាល្អចូលនិវត្តន៍ ដើម្បីចុះជួយគាំទ្រនៅតាមសាលារៀន ការចុះជួយតម្រង់ទិសនាយកសាលារៀន និងការបង្រៀននៅក្នុងថ្នាក់។
- ផ្សព្វផ្សាយ "**ឧត្តមមានុវត្តន៍នៃកំណែទម្រង់សាលារៀន**" ដូចជាសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ ឱ្យបានទូលំទូលាយទូទាំងប្រទេស ជាពិសេសការរំលេចនូវវិធានការដែលមិនចាំបាច់ប្រើធនធានច្រើន។
- គាំទ្រចំពោះការចូលរួមក្នុង "**វង្វាយតម្លៃការសិក្សាកម្រិតអន្តរជាតិ (PISA)**" ដើម្បីលើកកម្ពស់ស្តង់ដានៃការអប់រំនៅកម្ពុជា និងរិះរកវិធានការកែលម្អដើម្បីសម្រេចបានតាមស្តង់ដា។
- ប្រើប្រាស់លទ្ធផលវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ នៅថ្នាក់ទី៣, ទី៦, ទី៨, និងទី១១ ដើម្បីកែលម្អប្រព័ន្ធអប់រំ។
- រៀបចំ"**សេចក្តីណែនាំស្តីពី ការអនុវត្តតេស្តស្តង់ដានៅតាមសាលាបឋមសិក្សា និងមធ្យមសិក្សា**" និង "**ឯកសារស្តីពីការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស**" ដើម្បីលុបបំបាត់ការយកកិច្ចការរៀនគួរទៅដាក់សម្ពាធលើសិស្សមិនរៀនគួរជាមួយ។
- ពិនិត្យឡើងវិញ និងរៀបចំ "**ស្តង់ដាសាលារៀន ស្តង់ដាសាលាគំរូ និងសាលារៀនជំនាន់ថ្មី**" ។
- រៀបចំ "**ប្រព័ន្ធព័ត៌មានសាលារៀន**" ដើម្បីគ្រប់គ្រងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការងារគ្រប់គ្រងសាលារៀនជាទូទៅ ជាពិសេសងាយស្រួលក្នុងការកំណត់សាលារៀនអាទិភាពដែលត្រូវផ្តល់ការគាំទ្រពីក្រសួងឬគម្រោងនានា និងដោះស្រាយបញ្ហាប្រឈមរបស់សាលារៀន។

### ១.២ កំណែទម្រង់នៅកម្រិតសាលារៀន

- នៅកម្រិតមត្តេយ្យសិក្សា៖ ក្រសួងនឹងពង្រឹងសាលាមត្តេយ្យដែលមានស្រាប់ ដោយមិនពង្រីកបន្ថែម និងផ្តោតលើមត្តេយ្យស្តង់ដា និងការបណ្តុះបណ្តាលគ្រូមត្តេយ្យឱ្យមានគុណភាពជាពិសេស មត្តេយ្យសិក្សាសហគមន៍។
- នៅកម្រិតបឋមសិក្សា៖ ក្រសួងនឹងផ្តោតលើកញ្ចប់អំណានដំបូង និងគណិតវិទ្យាថ្នាក់ដំបូង, ការបង្រៀនភាសាបរទេស, ការដោះស្រាយកង្វះគ្រូនៅតំបន់ជួបការលំបាក, សុខភាពនិងអាហារូបត្ថម្ភរបស់សិស្ស និងភាពក្រីក្រ។
- នៅកម្រិតមធ្យមសិក្សា៖ ក្រសួងនឹងពង្រីកអនុវិទ្យាល័យ និងវិទ្យាល័យនៅនឹងកន្លែង ស្របតាមត្រូវការរបស់ប្រជាជន ។
- នៅកម្រិតឧត្តមសិក្សា៖ ក្រសួងនឹង"**ពង្រឹងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត**" ដោយពិនិត្យឡើងវិញប្រកាសលេខ២៥១៤ អយក.ប្រក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១២ ស្តីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ព្រមទាំងប្រើប្រាស់យន្តការនៃបណ្តាញវិស័យឯកជន ក្នុងការចូលរួមវាយតម្លៃ និងធានាគុណភាពអប់រំនៅឧត្តមសិក្សា តាមរយៈការផ្តល់នូវសិទ្ធិ និងការទទួលខុសត្រូវកម្រិតណាមួយ ដោយក្រសួងគ្រាន់តែធ្វើការត្រួតពិនិត្យ។
- បន្តធ្វើកំណែទម្រង់សាលារៀន ដោយផ្តោតជាសំខាន់លើ "**សាលារៀនគំរូ**" ជាពិសេសការពង្រឹងសាលារៀនគំរូដែលមានស្រាប់ និងពង្រីកសាលារៀនធម្មតាឱ្យក្លាយជាសាលារៀនគំរូ ដោយរៀបចំ "**សេចក្តីណែនាំស្តីពី សាលារៀនគំរូ**" និងដាក់ឱ្យអនុវត្តទូទៅសម្រាប់សាលារៀនទាំងអស់
- អនុវត្ត "**វិធីសាស្ត្របង្រៀនថ្មី**" ដូចជាការបង្រៀនតាមបែបគម្រោង ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន ។ល។ ដែលបានដាក់ឱ្យអនុវត្តនៅសាលារៀនជំនាន់ថ្មី ។
- ជំរុញ និងលើកទឹកចិត្តដល់ "**ការបង្រៀននិងរៀនមុខវិជ្ជាស្ទែម**" ដោយបង្កើតគណៈកម្មការសម្រាប់ការលើកកម្ពស់វិធីសាស្ត្របង្រៀនមុខវិជ្ជាស្ទែម និងជួយគាំទ្រដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ, ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សាដូចជា វិទ្យាស្ថានបច្ចេកវិទ្យា និងគ្រូឆ្នើមផ្នែកស្ទែម ដើម្បីរៀបចំឯកសារ ចងក្រងវិធីសាស្ត្របង្រៀនល្អៗ និងជំរុញការបង្រៀននិងរៀនមុខវិជ្ជាស្ទែម។
- រៀបចំ "**សេចក្តីណែនាំស្តីពី ការពង្រឹងការរៀន និងបង្រៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ**" ដោយបែងចែកតាមអនុវិស័យអប់រំកុមារតូច បឋមសិក្សា និងមធ្យមសិក្សា ដើម្បីបំផុសស្មារតីប្រឡងប្រណាំង។
- រៀបចំ "**បណ្ណាល័យស្តង់ដា**" ដោយសហការជាមួយអង្គការដៃគូ និងផ្តោតលើសាលារៀនគំរូ៖ (១) បឋមសិក្សាផ្តោតលើវិធីសាស្ត្រអំណានក្នុងបណ្ណាល័យ ១ម៉ោង ក្នុងមួយសប្តាហ៍ និង

ការអាននៅផ្ទះ និងការរៀបចំបណ្ណាល័យដែលមានសៀវភៅ៦កម្រិត, (២) មធ្យមសិក្សាផ្តោតលើបណ្ណាល័យមានផាសុខភាព សៀវភៅស្រាវជ្រាវ និងការអនុវត្តវិធីសាស្ត្របង្រៀនទំនើបដែលតម្រូវឱ្យសិស្សធ្វើការស្រាវជ្រាវ និងអានក្នុងបណ្ណាល័យ។

- ពង្រឹង "**ការបណ្តុះបណ្តាលនាយក និងការតែងតាំងនាយក**" ព្រមទាំងការត្រួតពិនិត្យ និងការវាយតម្លៃការងាររបស់នាយក ដោយយោងលើស្តង់ដាអប្បបរមារបស់នាយក ស្របជាមួយនឹងការលើកទឹកចិត្តនាយកមានស្នាដៃ និងការអនុវត្តគន្លងអាជីពនាយក។
- រៀបចំ "**យន្តការចុះកិច្ចសន្យាការងារប្រចាំឆ្នាំរវាងនាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន**"ដោយផ្តោតលើការដាក់ចេញវិធានការឆ្ពោះសម្រេចបាននូវលទ្ធផលកែលម្អសាលារៀន។
- ត្រួតពិនិត្យវត្តមានសិស្ស និងវត្តមានគ្រូបង្រៀន។
- រៀបចំ "**វិធានការ និងយន្តការដើម្បីជួយសិស្សរៀនយឺត**" ដូចជាការរៀបចំសន្លឹកកិច្ចការស្វ័យសិក្សាតាមមេរៀនជាឯកសារហ្វឹកហាត់ប្រចាំថ្ងៃ ជំរុញគ្រូបង្រៀនឱ្យដាក់កិច្ចការសិស្ស រៀបចំក្លឹបសិក្សាតាមមុខវិជ្ជា
- រៀបចំផែនការ "**អធិការកិច្ចថ្នាក់រៀន**" ប្រចាំខែ និងចុះអធិការកិច្ចជួយគ្រូឱ្យបានច្បាស់លាស់
- ធ្វើ "**អធិការកិច្ចតាមមុខវិជ្ជា និងធ្វើអធិការកិច្ចតាមប្រធានបទ**" ដោយផ្តោតលើការអនុវត្តកម្មវិធីសិក្សានៅតាមសាលារៀន និងផ្តោតលើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា

### ១.៣ ទម្រង់នៃកំណែទម្រង់សាលារៀន

នៅកម្រិតសាលារៀន ក្រសួងនឹងពង្រឹងការគ្រប់គ្រងតាមសាលារៀនឆ្ពោះទៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស និងផ្លាស់ប្តូរវប្បធម៌សាលារៀន ដោយផ្តោតលើៈ ១).វង្វាយតម្លៃសមត្ថភាពរបស់សិស្សតាមរយៈការធ្វើតេស្តដោយតម្លាភាព គាំទ្រដល់ការរៀននិងបង្រៀន និងការរៀបចំថ្នាក់ជួយសិស្សរៀនយឺតផ្តោតលើសិស្សមិនសូវចេះអាន សរសេរ និងគិតលេខ, ២).ការបង្កើនគណនេយ្យភាពរបស់សាលារៀនបិទផ្សាយជាសាធារណៈនូវលទ្ធផលតេស្តស្វ័យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ ចំណូល ចំណាយរបស់សាលារៀន កម្រិតជាប់ស្តង់ដាររបស់សាលារៀន, ៣).ការបង្កើនស្វ័យភាព និងសិទ្ធិអំណាច ក្នុងការសម្រេចចិត្តនៅកម្រិត សាលារៀន តាមរយៈគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀនរៀបចំផែនការ កែលម្អសាលារៀននិងថ្នាក់រៀន រៀបចំកិច្ចព្រមព្រៀងលទ្ធផលប្រចាំឆ្នាំគ្រូបង្រៀន និងគណៈគ្រប់គ្រង ប្រជុំពិនិត្យតាមដានប្រចាំខែ ត្រីមាស, ៤).ការបង្កើនការចូលរួមរបស់មាតាបិតា និងភាគីពាក់ព័ន្ធនៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍសាលារៀនឱ្យសម្រេចបានជាសាលារៀនគំរូ ។

បន្ទាប់ពីបានអនុវត្តសាកល្បងកម្មវិធីកំណែទម្រង់សាលារៀន និងបទពិសោធន៍ ពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ក្រសួងនឹងបង្កើតគំរូកំណែទម្រង់សាលារៀនចំនួន ៣ប្រភេទ គឺៈ

ប្រភេទទី១ៈ សាលារៀនជំនាន់ថ្មី ដោយផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សាដើម្បីបណ្តុះធនធានមនុស្សមានបំណិនសតវត្សទី២១ ក្នុងនោះគណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនមានៈ ក).សីលធម៌ និងស្តង់ដាវិជ្ជាជីវៈខ្ពស់, ខ).គណនេយ្យភាព, នវានុវត្តន៍, គ).ចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការរៀននិងបង្រៀន, ឃ).ចេះប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មី។ សិស្សសាលារៀនជំនាន់ថ្មី

មានៈ ក).ការផ្តួច ផ្តើមគំនិត និងសហគ្រិនភាព, ខ).ចេះទំនាក់ទំនង និងសរសេរយ៉ាងប៉ិនប្រសប់, គ). ចេះវិភាគវាយតម្លៃព័ត៌មាន, ឃ). ចង់ឃើញ ចង់ដឹង និងមានការស្រមើលស្រមៃ, ច). ចេះគិតបែបវិភាគស៊ីជម្រៅ និងការដោះស្រាយបញ្ហា, ឆ).ចេះសហការ, និងជ).មានភាពហ៉ើសហ្មួន និងចេះយកចំណេះដឹងទៅអនុវត្ត។

- ក្រសួងនឹងជ្រើសរើសគ្រឹះស្ថានសិក្សាផ្តោតលើមូលដ្ឋានឌីជីថល តាមរយៈបង្កើនចំនួនសាលារៀនជំនាន់ ថ្មីពី៧ឱ្យដល់១០សាលារៀន ផ្តោតទៅលើសាលារៀនគំរូ និងសាលាធម្មតា ដែលមានសក្តានុពល តាមលទ្ធភាពថវិកានិងជ្រើសរើសសិស្សពូកែៗ ឱ្យចូលរៀនលើមុខវិជ្ជាមូលដ្ឋានគ្រឹះឌីជីថល។ ចំពោះសិស្ស ថ្នាក់ទី១០ ក្រសួងនឹងសម្រិតសម្រាំង និងតម្រង់ទិសដល់ ១).ក្រុមសិស្សឆ្នើម សម្រាប់សិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (STEAM), ២). ក្រុមសិស្សសិក្សាកម្មវិធីធម្មតា, និង ៣). ក្រុមសិស្សសិក្សាតាមកម្មវិធីអប់រំបច្ចេកទេស។
- ក្រសួងនឹងវិនិយោគលើការបំពាក់បន្ទប់ពិសោធន៍ និងបច្ចេកវិទ្យា តាមរយៈការពង្រឹងដំណើរការសាលា មធ្យមសិក្សាធនធាន និងបំពាក់បន្ទប់ពិសោធន៍ សម្ភារៈឧបទេស និងបំប៉នវិធីសាស្ត្របង្រៀន និងការបណ្តុះបណ្តាលគ្រូសម្រាប់ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- ក្រសួងនឹងបង្កើតសាលាបឋមសិក្សាដែលដំណើរការរៀននិងបង្រៀនពេញមួយថ្ងៃ ដោយប្រើប្រាស់មូលនិធិសមធម៌ (ការចូលរួមជាថវិកាបដិភាគរបស់មាតាបិតា) សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីសិក្សាទំនើប ដែលរួមមានកុំព្យូទ័រ, រ៉ូបូទិក/ឡេហ្គោ, ភាសាអង់គ្លេស, ភាសាចិន, ការអប់រំសិល្បៈ និងការអប់រំកាយ និងកីឡា ជាដើម នៅតាមតំបន់ទីក្រុង និងទីប្រជុំជនដែលមានសក្តានុពល។ បន្ទប់រៀននឹងត្រូវជួសជុល និងកែលម្អ ដោយបំពាក់ LCD Projector ឬ Smartboard, ម៉ាស៊ីនត្រជាក់, តបណ្តាញអគ្គិសនី, និងអ៊ីនធើណិត។ បរិស្ថាន អនាម័យ ទីលានកីឡា ការរៀបចំសួនច្បារ ការដាំ ដើមឈើជាដើម សុទ្ធតែជាផ្នែកមួយនៃការអភិវឌ្ឍក្នុងការអនុវត្តកម្មវិធីសិក្សាទំនើប។ ជាមួយគ្នានេះ ការលើកកម្ពស់ សុខភាពសិក្សា អនាម័យ និងអាហារូបត្ថម្ភ ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ។

ប្រភេទទី២៖ សាលារៀនគំរូ ដោយផ្តោតលើ ក).សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព, ខ).សាលារៀនមានស្វ័យភាព ក្នុងការងារផែនការកែលម្អ សាលារៀន ថ្នាក់រៀន និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន, គ).សិស្សត្រូវបាន ធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀន និងរៀន, ការជួយសិស្ស រៀនយឺត, និងផ្តល់ព័ត៌មានដល់មាតាបិតាឬអ្នកអាណាព្យាបាល និងសហគមន៍, ឃ).គ្រូបង្រៀនប្រើប្រាស់ លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ, ង).មាតាបិតា ឬអ្នក អាណាព្យាបាលនិងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍសាលារៀន។

សាលារៀនគំរូ គឺជាសាលារៀន ដែលសម្រេចបាននូវស្តង់ដាទាំង ៥ គឺ៖

**ស្តង់ដាទី១ គឺ សាលារៀនដំណើរការសម្រេចផលសម្រេចការអប់រំ និងការសិក្សារៀនសូត្ររបស់សិស្ស**

ស្តង់ដាសាលារៀន ដែលក្នុងនោះមានទាំងស្តង់ដានាយក ក៏ដូចជាមានទាំងការបង្កើតគណៈ-កម្មការគ្រប់គ្រងសាលារៀន ដែលមានការចូលរួមពីសហគមន៍មូលដ្ឋាន និងពីមាតាបិតា ដើម្បីសម្រេចនូវគណនេយ្យភាព ចំពោះមាតាបិតា ចំពោះក្រសួងអប់រំ យុវជន និងកីឡា និងចំពោះអាជ្ញាធរមូលដ្ឋាន។ ដូចនេះ ស្តង់ដាសាលារៀនគឺ សាលារៀនមានដំណើរការ និងជាទីកន្លែងមួយសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្រ ដែលគោលដៅរបស់យើង គឺលទ្ធផលសិក្សារៀនសូត្ររបស់សិស្ស។

**ស្តង់ដាទី២ គឺ ថ្នាក់រៀនដំណើរការសម្រាប់ការបង្រៀន និងការសិក្សារៀនសូត្ររបស់សិស្សម្នាក់ៗ**

ការគ្រប់គ្រងថ្នាក់រៀនដោយមានការចូលរួមពីមាតាបិតាដើម្បីជួយគាំទ្រ ឧទា.ករណីថ្នាក់រៀនអត់មានអគ្គិសនី ឬអាកាសធាតុក្តៅ ឪពុកម្តាយគួរតែពិនិត្យមើលលទ្ធភាពចូលរួមនៅក្នុងការទិញអំពូលតខ្សែភ្លើង កង្ហារ ដើម្បីឱ្យកូនបានរៀនក្នុងបរិស្ថាន ដែលចូលចិត្ត។ បរិស្ថានសាលារៀន គឺសំខាន់ណាស់សម្រាប់ក្មេង ប្រសិនបើចង់កែលម្អ។ ជាពិសេស កម្រិតបឋមសិក្សា ត្រូវចាប់ផ្តើមពីវិធីធ្វើឱ្យក្មេងស្រឡាញ់សាលារៀន មានឯកសណ្ឋានល្អ ចង់មកសាលា ចេះច្រៀងចម្រៀង និងហាត់កីឡា។ល។ ដូច្នេះ ការរៀបចំបរិស្ថានសិក្សាឱ្យបានល្អ ដើម្បីឱ្យ ក្មេងចង់មកសាលារៀន។

ថ្នាក់រៀនមានដំណើរការ តម្រូវឱ្យគ្រូបង្រៀនរៀបចំផែនការបង្រៀន៣ឆ្នាំ ផែនការប្រចាំឆ្នាំតាមមុខវិជ្ជា, ចំនួនថ្នាក់រៀនមានការប្រជុំពិនិត្យតាមដានប្រចាំខែទៀងទាត់លើការរៀនសូត្រ, ចំនួននិងភាគរយសិស្សមានផែនការសិក្សារៀនសូត្រប្រចាំឆ្នាំនិងបានអនុវត្តការតាមដានផែនការនេះប្រចាំឆ្នាំសិក្សា, ចំនួននិងភាគរយសិស្សរៀនសូត្របំណិនរកចំណូលផ្នែកកសិកម្មនិងបច្ចេកទេស, ចំនួនដងនៃការប្រកួតប្រជែងអំណាន និងគណិតវិទ្យាប្រចាំឆ្នាំសិក្សា, ចំនួននិងភាគរយសិស្សអវត្តមានលើស៤ដងក្នុងមួយឆ្នាំសិក្សា, និងចំនួនដងគ្រូអវត្តមានមិនមានគ្រូជំនួសប្រចាំឆ្នាំសិក្សា ។ល។

**ស្តង់ដាទី៣ គឺការចូលរួមរបស់សហគមន៍និងមាតាបិតា នៅក្នុងការគ្រប់គ្រង និងដំណើរការសាលារៀន**

ប្រសិនបើមាតាបិតាមិនជួយគាំទ្រនោះទេ សាលារៀនក៏មិនជោគជ័យដែរ។ កំណែទម្រង់សាលារៀនកន្លងមកបានបង្ហាញថា សាលារៀនជោគជ័យ គឺដោយសារមានការចូលរួមពីអាជ្ញាធរមូលដ្ឋានសហគមន៍ មាតាបិតា នៅក្នុងការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន ព្រមទាំងចូលរួមក្នុងការរៀបចំផែនការ ការកែលម្អសាលារៀន ឧទា.តើសាលារៀនមានបញ្ហាអ្វី ត្រូវដោះស្រាយបែបណា? ខ្វះអ្វីខ្លះ? ដែលចំណុចទាំងនេះ គឺជាចំណុចគន្លឹះដើម្បីគាំទ្រគ្នាទៅវិញទៅមក។

ការចូលរួមរបស់សហគមន៍ និងមាតាបិតានៅក្នុងការគ្រប់គ្រង និងដំណើរការសាលារៀន តាមរយៈការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងមានរបបប្រជុំទៀងទាត់។ នាយក និងនាយករងទទួលការសម្រេចចិត្តពី គ.គ.ស. ឬ ក.ប.ស. លើការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំ។ មាតាបិតាជួយជំរុញការសិក្សា និងទប់ស្កាត់ការបោះបង់ការសិក្សា និងការមករៀនវិញទៀងទាត់។ បរិមាណចំណូលមូលនិធិគាំទ្រពីសហគមន៍ដល់សាលារៀនប្រចាំឆ្នាំ។

## ស្តង់ដាទី៤ គឺ ដំណើរប្រតិបត្តិការ និងរដ្ឋបាលសាលារៀន

សាលារៀនមានដំណើរការល្អ អាស្រ័យលើការរៀបចំផែនការសកម្មភាពអនុវត្តច្បាស់លាស់ រយៈពេលមធ្យម និងប្រចាំឆ្នាំ ព្រមទាំងផ្តោតលើផលសម្រេចនៃការអប់រំ និងឈរលើមូលដ្ឋាននៃការធ្វើតេសត្តស្តង់ដា ប្រចាំខែ និងប្រចាំឆ្នាំ។ លទ្ធផលតេស្តស្តង់ដាប្រចាំខែត្រូវបានយកប្រើប្រាស់ ដើម្បីជួយដល់ការសិក្សារៀនសូត្ររបស់សិសរៀនយឺត។ សាលារៀនត្រូវធ្វើអធិការកិច្ចផ្ទៃក្នុង និងការប្រជុំបច្ចេកទេសជាទៀងទាត់តាមផែនការ។ គ្រូបង្រៀន និងនាយកសាលាត្រូវបានបញ្ជូនឱ្យចូលរៀនវគ្គអភិវឌ្ឍសមត្ថភាពជាប្រចាំ។

មានន័យថារដ្ឋបាលសាលារៀន ត្រូវយកចិត្តទុកដាក់លើការគ្រប់គ្រងគ្រូ តើមានបញ្ហាអ្វី? ដូចជា ខ្វះគ្រូ លើសគ្រូ គ្រូបង្រៀនអត់ទៅតាមមុខវិជ្ជា ការរៀបចំផែនការការដំណើរការសាលារៀន ការផ្តល់សម្ភារៈឧបទេស រួមទាំងវិធីសាស្រ្តបង្រៀន។ ម៉្យាងទៀត គោលដៅរបស់យើងបំណងគឺចង់បណ្តុះបំណិនសតវត្សទី២១ ចង់ឱ្យសិស្សមាន វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទាគឺចាប់ផ្តើមពីការផ្តោតទៅលើវិធីសាស្រ្តបង្រៀនទំនើប។ សាលារៀនត្រូវខិតខំរិះរកវិធីសាស្រ្តបង្រៀនថ្មីៗ និងអភិវឌ្ឍសមត្ថភាពគ្រូលើផ្នែកឌីជីថល ជាដើម។

## ស្តង់ដាទី៥ គឺ គណនេយ្យភាព

សាលារៀនត្រូវកំណត់គោលដៅ និងត្រូវតែមានសូចនាករវាស់វែង ប្រសិនបើមិនសម្រេចបានតាមសូចនាករ តើសាលារៀនត្រូវធ្វើយ៉ាងណា។ សាលារៀនត្រូវមានរបាយការណ៍ជាទៀងទាត់ និងផ្សព្វផ្សាយជា សាធារណៈ។ គ្រូបង្រៀនត្រូវគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ ដូចជាការបង្រៀនគ្រប់ម៉ោងតាមកម្មវិធីសិក្សា កំណត់ ។ អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវចុះពិនិត្យសាលារៀន ជួយគាំទ្រ និងផ្តល់ការហ្វឹកហាត់។

ការអនុវត្តកម្មវិធីសិក្សាគឺសំខាន់ណាស់ យ៉ាងហោចណាស់ឱ្យបាន៦ម៉ោងក្នុង១ថ្ងៃ ឬក្នុង១ថ្ងៃ៤ម៉ោងឱ្យពេញម៉ោង ជាពិសេសកាត់បន្ថយអវត្តមានរបស់គ្រូ និងអវត្តមានរបស់សិស្ស។ ប្រព័ន្ធព័ត៌មានសាលារៀនដែលមានភាពច្បាស់លាស់ និងសាលារៀនត្រូវមានSchool Profile ដើម្បីអាចពិនិត្យមើលអំពីបញ្ហាតាមសាលារៀន។

ចំណុចបន្ទាប់ទៀត គឺការធ្វើតេស្តស្តង់ដាដែលមានតម្លាភាព ដើម្បីលើកទឹកចិត្តឱ្យគ្រូខំបង្រៀនឱ្យសិស្សរៀនពិតប្រាកដ។ ការរៀបចំធ្វើតេស្តនេះគឺ ដើម្បីឆ្លើយតបទៅនឹងវង្វាយតម្លៃលទ្ធផលសិក្សាសិស្សនៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ និងប្រព័ន្ធវង្វាយតម្លៃអន្តរជាតិ។ មួយទៀតដើម្បី ប្រៀបធៀបចំណេះដឹងសិស្សយើងជាមួយអន្តរជាតិ ហើយសាលារៀនដែលទទួលបានក្លាយជា សាលារៀនគំរូ ទាល់តែសិស្សយ៉ាងហោចណាស់រៀនបានពិន្ទុ A B C អីជាដើម។

ការអប់រំចរិយាធម៌ សីលធម៌ ពលរដ្ឋ ក៏ជាផ្នែកមួយសំខាន់ ដើម្បីឱ្យសិស្សស្គាល់ពីវប្បធម៌ខ្មែរ ទំនៀមទម្លាប់ ជាពិសេស ព្រះពុទ្ធសាសនា ជាដើម្បីលើកកម្ពស់ការអប់រំចរិយាធម៌។

– ក្រសួងនឹងបណ្តុះបណ្តាលអ្នកអនុវត្តកំណែទម្រង់សាលារៀន ដែលមាន៖ ១).ក្រុមស្នូលពី ៥

ទៅ ១២ នាក់, ២). មន្ត្រីឯកទេសពី ៦៨ ទៅ ១៣៣ នាក់, ៣). ការបង្កើនគុណវុឌ្ឍិគ្រូបង្រៀន តាមរយៈកម្មវិធី បង្កើនគុណវុឌ្ឍិគ្រូបង្រៀន (TUP) ពី ២២៧៧ ទៅ ៩០០០ នាក់, និងការបង្កើនគុណវុឌ្ឍិនាយក សាលារៀនពី ៦០៥ ទៅ ២៧១៣ នាក់ (LUP)។

- ក្រសួងនឹងពង្រីកសាលារៀនគំរូពី ១០០សាលា ដល់ ១៧០០សាលា រួចដល់ ១៣០០០ សាលា។ ជាមួយគ្នានេះ ក្រសួងនឹងដាក់ឱ្យអនុវត្តការគ្រប់គ្រងសាលារៀនតាមបែបឌីជីថល ដោយបង្កើនចំនួន គ្រឹះស្ថានសិក្សាដែលភ្ជាប់ដោយប្រព័ន្ធអ៊ិនធើណិតពី ៣០០ ដល់ ៣០០០ សាលា និងអភិវឌ្ឍប្រព័ន្ធ គ្រប់គ្រងសាលារៀនតាមឌីជីថល (Apps) របស់ជាតិមួយ។
- ក្រសួងនឹងធ្វើការវាយតម្លៃសាលាបឋមសិក្សា ដែលសម្រេចបានស្តង់ដាជាសាលាគំរូ ហើយបន្តជួយគាំទ្របន្ថែម ដើម្បីឱ្យនាយកសាលា និងគ្រូបង្រៀនក្នុងសាលាគំរូ មានលទ្ធភាពចុះទៅជួយនាយកសាលា និងគ្រូបង្រៀនដទៃទៀត។
- ក្រសួងបន្តអនុវត្តគោលនយោបាយស្តីពី កិច្ចការពារកុមារនៅតាមសាលារៀន ដើម្បីកាត់បន្ថយ និង ឈានទៅលុបបំបាត់អំពើហិង្សាលើកុមារទាំងក្នុងសាលារៀន ក្រៅសាលារៀន និងនៅក្នុងគ្រួសារ តាមរយៈការបំប៉នសមត្ថភាពគ្រូបង្រៀនស្តីពី ការអប់រំវិន័យបែបវិជ្ជមាន។

យុទ្ធសាស្ត្រកំណែទម្រង់សាលារៀនបឋមសិក្សានិងមធ្យមសិក្សា ឆ្ពោះទៅរកឧត្តមភាព (សាលារៀនគំរូ)

**១. កំណែទម្រង់សាលារៀនជាអាទិភាពសម្រាប់កែលម្អគុណភាពសិក្សា**

- ក្រសួងនឹងពិនិត្យឡើងវិញស្តង់ដាសាលារៀន និងរៀបចំស្តង់ដាសាលាគំរូ ព្រមទាំងរៀបចំក្រុមការងារ បឋមសិក្សា, ក្រុមការងារមធ្យមសិក្សា, ក្រុមការងារសាលាគរុកោសល្យ និងក្រុមការងារតេស្តវង្វាយតម្លៃ ដើម្បីគាំទ្រដល់សាលារៀន
- ក្រសួងនឹងសិក្សា ដើម្បីពង្រីកសាលារៀនជំនាន់ថ្មីនៅទីរួមខេត្តមានសក្តានុពល ជាពិសេសរាជធានីភ្នំពេញ
- ក្រសួងលើកទឹកចិត្ត និងជំរុញឱ្យមានការប្រឡងប្រណាំងសាលារៀនល្អ, នាយកសាលាល្អ, និងគ្រូ បង្រៀនល្អ ឱ្យបានកាន់តែច្រើន ទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា តាមរយៈការរៀបចំយន្តការវាយតម្លៃនៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ, មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។
- ក្រសួងនឹងរៀបចំប្រព័ន្ធព័ត៌មានសាលារៀន ដើម្បីគ្រប់គ្រងព័ត៌មានគ្រូបង្រៀន ព័ត៌មានសិស្ស និងការងារគ្រប់គ្រងសាលារៀនជាទូទៅ ជាពិសេសងាយស្រួលក្នុងការកំណត់សាលារៀនអាទិភាព ដែល ត្រូវផ្តល់ការគាំទ្រពីក្រសួង ឬគម្រោងនានា និងដោះស្រាយបញ្ហាប្រឈមរបស់សាលារៀន។
- ក្រសួងនឹងកែលម្អសាលារៀនគ្រប់កម្រិតនៅរាជធានីភ្នំពេញ ដើម្បីឱ្យសាលារៀនមានការប្រែប្រួល និងដោះស្រាយបញ្ហាប្រឈមនានា ដូចជាការថយចុះចំនួនសិស្សនៅតំបន់កណ្តាលក្រុង, កង្វះគ្រូនៅ សាលារៀនជាយក្រុង, ការអប់រំចរិយាធម៌, និងសាលារៀនឯកជន។

- ក្រសួងនឹងប្រើប្រាស់យន្តការគម្រោង ដើម្បីអនុវត្តការកែលម្អសាលារៀននៅរាជធានីភ្នំពេញ ឱ្យបានលេចធ្លោដូចករណីវិទ្យាល័យព្រះស៊ីសុវត្ថិ ក៏ដូចជាការបង្កើតក្រុមការងារសម្រាប់សាលាបឋមសិក្សា, សាលាមធ្យមសិក្សា ដើម្បីចុះជួយពង្រឹងការគ្រប់គ្រងនិងដឹកនាំសាលារៀន និងការចុះជួយដឹកដៃ (Mentoring)។
- ក្រសួងនឹងរៀបចំសេចក្តីណែនាំស្តីពី ការដោះស្រាយបញ្ហារៀនគួរ និងការបង្កើតក្លឹបសិក្សាដែលគាំទ្រ ដោយការសិក្សាស្រាវជ្រាវច្បាស់លាស់។
- ក្រសួងនឹងរៀបចំវេទិកា ដើម្បីផ្សព្វផ្សាយអំពី គោលនយោបាយកែលម្អសាលារៀន និងចែករំលែកបទ ពិសោធន៍ល្អៗនៃការដឹកនាំសាលារៀនល្អ។
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការនឹងរៀបចំការវិភាគអំពីនិន្នាការចំនួនសិស្ស និងតម្រូវការ បន្ទប់រៀនជាទៀងទាត់ សម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យមើល និងដោះស្រាយបញ្ហានៅកម្រិតសាលារៀន។

## ២. ការផ្តោតលើការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា និងម៉ោងសិក្សា

- ក្រសួងនឹងពិនិត្យជ្រើសរើសសាលារៀនដែលមានសក្តានុពល ដើម្បីបង្កើនម៉ោងសិក្សាពី ៤ ម៉ោងក្នុង១ថ្ងៃ (នាពេលបច្ចុប្បន្ន) ទៅ ៦ម៉ោងក្នុង១ថ្ងៃ ឬ៤០ម៉ោងក្នុង១សប្តាហ៍ ដោយគិតគូរអំពីលទ្ធភាពរបស់បន្ទប់រៀន និងចំនួនគ្រូបង្រៀន។
- ក្រសួងនឹងចេញសេចក្តីណែនាំ ដើម្បីដោះស្រាយបញ្ហាវត្តមានរបស់គ្រូបង្រៀន វត្តមានរបស់សិស្ស ព្រមទាំង ការពង្រឹងវិន័យនៅក្នុងនិងក្រៅសាលារៀន។
- ក្រសួងនឹងរៀបចំយន្តការដើម្បីជំរុញការបង្កើតក្លឹបសិក្សា ស្វ័យសិក្សា និងការជួយសិស្សរៀនយឺត។

## ៣. ការផ្តោតលើសមត្ថភាពអំណាន និងគណិតវិទ្យា ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស

- ក្រសួងនឹងប្រើប្រាស់លទ្ធផលវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ នៅថ្នាក់ទី៣, ទី៦, ទី៨, និងទី១១ ដើម្បីកែលម្អប្រព័ន្ធអប់រំ
- ក្រសួងនឹងជំរុញការបង្រៀនអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង និងការបង្រៀនភាសាបរទេស នៅសាលាបឋមសិក្សា តាមរយៈការបញ្ជ្រាបម៉ូឌុលអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង នៅតាមសាលាគរុកោសល្យ និងការបំប៉នគ្រូបឋមសិក្សា ព្រមទាំងប្រើប្រាស់សៀវភៅចាស់ៗពីទសវត្ស ឆ្នាំ ១៩៦០ និង១៩៧០ មកប្រើប្រាស់ ដើម្បីជំរុញអំណានទាំងនៅបឋមសិក្សា និងមធ្យមសិក្សា។
- អង្គភាពជំនាញពាក់ព័ន្ធនឹងចុះពិនិត្យ និងវាយតម្លៃការអនុវត្តការបង្រៀនអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង ដើម្បីដោះស្រាយបញ្ហាប្រឈម និងជំរុញការអនុវត្ត។
- ក្រសួងនឹងពង្រីកការរៀបចំបណ្ណាល័យតាមស្តង់ដា ដោយសហការជាមួយអង្គការពាក់ព័ន្ធ

ព្រមទាំង រៀបចំវេទិកានានាដើម្បីជំរុញ និងគាំទ្រអំណាននៅក្នុងបណ្ណាល័យ។

- អង្គភាពជំនាញនឹងរៀបចំនូវឧត្តមានុវត្តន៍នៃការបង្រៀនអំណាន និងគណិតវិទ្យា តាមរយៈការបង្កើត ក្រុមការងារ និងការផលិតវីដេអូបង្រៀន ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។
- ក្រសួងនឹងជំរុញ និងលើកទឹកចិត្តដល់ការបង្រៀននិងរៀនមុខវិជ្ជាស្នែម ដោយបង្កើតគណៈកម្មការ សម្រាប់ការលើកកម្ពស់វិធីសាស្ត្របង្រៀនមុខវិជ្ជាស្នែម និងជួយគាំទ្រដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ, ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សាដូចជាវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងគ្រូឆ្នើមផ្នែកស្នែម ដើម្បីរៀបចំឯកសារ ចងក្រងវិធីសាស្ត្របង្រៀនល្អៗ និងជំរុញការបង្រៀននិងរៀនមុខវិជ្ជាស្នែម។
- ក្រសួងនឹងសិក្សា ព្រមទាំងដាក់ចេញនូវវិធានការលើកកម្ពស់ការអប់រំចរិយាធម៌ និងការលើកកម្ពស់ការ ស្នេហាជាតិ នៅតាមសាលារៀន ដោយដកស្រង់ពិសោធន៍ពីប្រទេសមួយចំនួន។

## ៤. ការកែលម្អសាលាគរុកោសល្យ និងការសម្រួចវិធីសាស្ត្របង្រៀន

- ក្រសួងនឹងបន្តកែលម្អសាលាគរុកោសល្យ ទាំងផ្នែករឹង និងផ្នែកទន់ ដោយផ្តោតលើវិធីសាស្ត្របង្រៀនថ្មី ដូចជាការអនុវត្ត Project Based Learning នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា, ការប្រើប្រាស់ បច្ចេកវិទ្យាក្នុងការបង្រៀន ។ល។
- ក្រសួងនឹងបង្កើតក្រុមការងារចុះជួយគាំទ្រសាលាគរុកោសល្យ។
- ក្រសួងនឹងរៀបចំសេចក្តីសង្ខេបស្តីពី ឧត្តមានុវត្តន៍របស់សាលាគរុកោសល្យ និងវិធានការសម្រាប់កែលម្អ សាលាគរុកោសល្យ។
- ក្រសួងនឹងរៀបចំវេទិកាចែករំលែកឧត្តមានុវត្តន៍នៃវិធីសាស្ត្របង្រៀន ដោយមានការចូលរួមពីសាលារៀនជំនាន់ថ្មី និងគរុសិស្ស គរុនិស្សិត។

## ៥. ការពង្រឹងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ និងតាមសាលារៀន

- ក្រសួងនឹងរៀបចំសេចក្តីណែនាំ ដើម្បីជំរុញការអនុវត្តតេស្តស្តង់ដានៅតាមសាលាបឋមសិក្សា និង មធ្យមសិក្សា។
- ក្រសួងនឹងពិនិត្យមើលយន្តការ និងគោលការណ៍នៃវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិឡើងវិញ ដើម្បីបន្សុីវាំងស្តង់ដានៃវង្វាយតម្លៃ កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។
- ក្រសួងនឹងរៀបចំឯកសារស្តីពីការធ្វើតេស្តស្តង់ដាប្រចាំខែ ត្រីមាស ឆមាស ដើម្បីលុបបំបាត់ការយកកិច្ចការរៀនគួរ រួចដាក់សម្ពាធលើសិស្សមិនរៀនគួរជាមួយ។

ប្រភេទទី៣៖ សាលារៀនធម្មតា ដោយផ្តោតលើ ក).ការកែលម្អលទ្ធផលនៃការសិក្សារបស់សិស្សស្រប តាមការរកឃើញនៃលទ្ធផលតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១, ខ).ការពង្រឹងវត្តមានគ្រូ និងវត្តមានសិស្ស, គ).ការពង្រឹងការគ្រប់គ្រងតាមសាលារៀន ។

- ក្រសួងនឹងបន្តពង្រឹងគុណភាព ដោយផ្តោតលើវិជ្ជាសម្បទា បំណិនសម្បទា (បំណិនវិជ្ជាជីវៈ

និងទន់) ចរិយាសម្បទា (សីលធម៌ និងវិន័យ) តាមរយៈកំណែទម្រង់សាលារៀន និងសហគមន៍សាលារៀន ដោយមានការចូលរួមពីសហគមន៍ និងមាតាបិតា ដើម្បីបង្កើនម៉ោងសិក្សារបស់សិស្ស និងកាត់បន្ថយ ការបង្រៀនគួរ ព្រមទាំងពង្រឹងការបង្រៀនភាសាបរទេស។

- ក្រសួងនឹងផ្តល់ការលើកទឹកចិត្តបន្ថែមចំពោះគ្រឹះស្ថានសិក្សានៅតាមតំបន់ដាច់ស្រយាល និងជួបការ លំបាក ដោយបន្តសាងសង់ផ្ទះគ្រូ និង ផ្តល់ប្រាក់ឧត្តម្ភឱ្យបានសមស្រប។ ជាមួយគ្នានេះ ក្រសួងនឹងខិតខំដោះស្រាយបញ្ហាខ្វះគ្រូ ដោយអនុវត្តរូបមន្តពង្រឹង ៨០% ពង្រីក ២០%, បន្តជ្រើសរើសបេក្ខជន ដោយតម្រូវ ឱ្យដាក់ពាក្យនៅតាមសាលានិងនាយកផ្តល់ទិដ្ឋាការទទួល, ការប្រើប្រាស់ប្រព័ន្ធព័ត៌មាន វិទ្យា (Apps) ក្នុងការបែកចែកគ្រូ និងសៀវភៅគោល, និងការពិនិត្យឡើងវិញប្រព័ន្ធលើកទឹកចិត្ត និង ប្រព័ន្ធមុខងារសាធារណៈ (ការតម្លើងលឿនកាំប្រាក់នៅតំបន់ជួបការលំបាក), ការបង្កើនរយៈពេលដែលត្រូវផ្លាស់ទីកន្លែងតាមសហព័ទ្ធ (៦ឆ្នាំ), និងការដាក់កាតព្វកិច្ចឱ្យគ្រូចេញថ្មីត្រូវចុះកិច្ចសន្យាទៅបង្រៀនកន្លែងជួបការលំបាក ក្នុងរយៈពេល (៦ឆ្នាំ) មុននឹងប្តូរបាន។
- ក្រសួងនឹងបន្តវិនិយោគលើការបង្កើតបណ្ណាល័យសតវត្សទី២១ ដោយបន្តអនុវត្តស្តង់ដាបណ្ណាល័យ, ការវិនិយោគលើបច្ចេកវិទ្យា និងធនធានសិក្សាបន្ថែមជាទម្រង់សៀវភៅរឹង និងសៀវភៅអេឡិចត្រូនិច រួមទាំងការផ្តល់ធនធានសម្រាប់ការសរសេរសៀវភៅថ្មី ។
- ក្រសួងនឹងបណ្តុះបណ្តាលគ្រូបង្គោលតាមប្រព័ន្ធជឿនលឿន ដោយផ្តល់ធនធានសម្រាប់ការបណ្តុះបណ្តាលគ្រូតាមប្រព័ន្ធនៃសាលារៀនជំនាន់ថ្មី និងរៀបចំកិច្ចសហប្រតិបត្តិការ ដើម្បីបញ្ជូនគ្រូបង្គោល និងគ្រូឧទ្ទេសទៅសិក្សានៅបរទេស តាមប្រព័ន្ធទំនើប ដូចជា Cambridge Teacher Training Program ។
- ក្រសួងនឹងបន្តអភិវឌ្ឍវិទ្យាល័យអប់រំពិសេស ដោយផ្តោតលើការបង្រៀនសិស្សដែលមានពិការភាព ភ្នែក គ-ថ្លង់ និងសតិបញ្ញា ពីមត្តេយ្យសិក្សា ដល់វិទ្យាល័យ នៅខេត្តបាត់ដំបង សៀមរាប កំពង់ចាម កណ្តាល និងរាជធានីភ្នំពេញ ព្រមទាំងអភិវឌ្ឍកម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច អនុវត្តចាប់ពីមត្តេយ្យសិក្សា ដល់ថ្នាក់ទី៣ លើភាសាព្នងទំពួន ការ៉ែត គ្រឹង ព្រៅ និងចារាយ នៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង ក្រចេះ និងខេត្តព្រះវិហារ ។

### ១.៤ ការគ្រប់គ្រងគ្រឹះស្ថានសិក្សាឯកជន

- ជំរុញការអនុវត្តសេចក្តីណែនាំស្តីពី ការលើកកម្ពស់ការសិក្សាភាសាខ្មែរ និងវប្បធម៌ អរិយធម៌ខ្មែរ នៅតាមគ្រឹះស្ថានសិក្សាចំណោះទូទៅឯកជនដែលអនុវត្តកម្មវិធីសិក្សាអន្តរជាតិ
- រៀងរាល់ថ្ងៃចន្ទមុនពេលចូលរៀន ត្រូវឱ្យសិស្សច្រៀងវគ្គទីមួយ នៃបទនគររាជ និងបទពង្សាវតារខ្មែរ
- ពិនិត្យ និងតាមដានលើការងារអនុវត្តកម្មវិធីសិក្សា និងដំណើរការប្រឡងនានា

- វាយតម្លៃការគ្រប់គ្រង និងដំណើការគ្រឹះស្ថានសិក្សាឯកជន មុននឹងសម្រេចបង្កើតបន្ថែម។

## ១.៥ ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- កំណត់កូតាសម្រាប់ "**សិស្សនិទ្ទេស A, B, C ដើម្បីជ្រើសរើសចូលធ្វើគ្រូបង្រៀន**" ដោយឆ្លងកាត់ការវាយតម្លៃទៅតាមលក្ខណៈវិនិច្ឆ័យដែលនឹងបានកំណត់ (អាចជ្រើសរើសផ្អែកតាមលំដាប់ពិន្ទុពេលប្រឡង)។ ដោយឡែក កូតានៅសល់សម្រាប់បេក្ខជនផ្សេងទៀត ដោយត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសដូច ធម្មតា ដែលនឹងដឹកនាំដោយក្រុមការងារថ្នាក់ជាតិ និងមានការចូលរួមពីសំណាក់តំណាងទីស្តីការគណៈរដ្ឋមន្ត្រី។
- អនុវត្ត "**វិធានការម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងគ្រូបង្រៀន និងបុគ្គលិកអប់រំ**" ដោយទប់ស្កាត់មិនឱ្យមានករណីអន្តរាគមន៍។
- រៀបចំ "**រង្វាន់លើកទឹកចិត្តគ្រូល្អ និងនាយកល្អ**" ដែលសម្រេចបានសមិទ្ធកម្មល្អប្រសើរតាមរយៈការរៀបចំជាប្រាក់លើកទឹកចិត្ត ប្រាក់តំបន់ជួបការលំបាក និងប្រាក់ស្នាដៃ ដោយសារបៀវត្សគ្រូបង្រៀនមិនអាចកើនលើសពីមន្ត្រីរាជការផ្សេង។
- រៀបចំការសិក្សា និងយន្តការ "**ដោះស្រាយបញ្ហាលើស ខ្វះគ្រូ**" ដោយផ្តោតលើការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពគ្រូដែលមានស្រាប់ ជាជាងការផ្តោតលើការជ្រើសរើសគ្រូថ្មី (ដោយត្រូវរៀបចំក្រុមការងារ អចិន្ត្រៃយ៍) និងរៀបចំយន្តការលើកទឹកចិត្ត, ព្រមទាំងផ្សារភ្ជាប់ជាមួយការអនុវត្តគន្លងអាជីព។ ក្រសួងនឹងប្រើប្រាស់ថវិកាគម្រោង និងថវិកាជាតិមកសិក្សាអំពី ការដោះស្រាយបញ្ហាលើសខ្វះគ្រូ។ ជាមួយគ្នានោះក្រសួងនឹងធ្វើអាទិភាពចំណាយ ដើម្បីប្រមូលផ្តុំធនធានសម្រាប់ការដោះស្រាយបញ្ហារបស់គ្រូបង្រៀន ដូចជា ការសាងសង់ផ្ទះគ្រូ, ការបង្កើនប្រាក់ឧបត្ថម្ភគ្រូបង្រៀននៅតំបន់ជួបការលំបាក ។ល។
- ពិនិត្យឡើងវិញ "**តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល**" និងការពិនិត្យឡើងវិញការឧបត្ថម្ភសម្រាប់តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ដោយយកថវិកាគម្រោងមកសិក្សា និងរៀបចំក្រុមការងារ។
- រៀបចំ "**ក្រុមការងារដឹកនាំកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ**" និងរៀបចំ "**ក្រុមការងារថ្នាក់ជាតិចុះជួយគាំទ្រសាលាគរុកោសល្យ**", សម្រួចការប្រើប្រាស់ថវិកានៅថ្នាក់ជាតិ, កិច្ចសហការល្អនៅកម្រិតខេត្ត, អនុវត្តឱ្យម៉ឺងម៉ាត់, និងមានយន្តការពិនិត្យតាមដាន ដើម្បីជួយដល់នាយកសាលារៀន និងគ្រូបង្រៀន។
- បន្តអនុវត្ត "**ការប្រឡងប្រណាំងគ្រូល្អ នាយកល្អ**" និងរៀបចំយន្តការវាយតម្លៃការអនុវត្តស្តង់ដាអប្បបរមាគ្រូបង្រៀន ស្តង់ដាអប្បបរមានាយកសលា ជាពិសេសការដោះស្រាយទិដ្ឋភាពអវិជ្ជមាននៃការបង្រៀនគួរ ការត្រួតពិនិត្យវត្តមាន និងការអនុវត្តកម្មវិធីសិក្សា ព្រមទាំងការប្រើប្រាស់នូវឧត្តមានុវត្តន៍នៃយន្តការលើកទឹកចិត្ត និងការស្តីបន្ទោស ដូចជាការផ្តល់បណ្ណសរសើរចំពោះគ្រូដែលមិនដែលអវត្តមាន។

គ្រូបង្រៀនគឺជាបេះដូងនៃប្រព័ន្ធអប់រំ, គ្រូបង្រៀនគឺជាកម្លាំងជួរមុខ ដូចនេះគ្រូបង្រៀនសតវត្ស ទី២១ ត្រូវប្រកបដោយស្តង់វិជ្ជាជីវៈខ្ពស់ តាមរយៈការធ្វើកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដែលផ្តោតលើ៖

១) ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការ ដើម្បីផ្តល់ឱ្យគរុនិស្សិតប្រតិបត្តិគុណសម្បទា និងបំណិនសតវត្សរ៍ទី២១ មានគុណវុឌ្ឍិអនុលោមតាម «ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន» ដោយកំណត់ស្តង់ដាគុណវុឌ្ឍិ៖ (ក)១២+២=គ្រូមត្តេយ្យ (ខ) ១២+៤=គ្រូបឋម (គ) ១២+៤= គ្រូមូលដ្ឋាន និង (ឃ) បរិញ្ញា+២=គ្រូឧត្តម។

២) ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេស ផ្តោតលើ (ក) ខ្លឹមសារមេរៀន (ខ) គរុកោសល្យ ជាពិសេសវិធីសាស្ត្របង្រៀនសម្បូរបែប តាមបែបសកម្ម (គ) បច្ចេកវិទ្យា។

៣) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដូចជាការបំពាក់បរិក្ខាររៀន និងបង្រៀនស្របតាមបច្ចេកវិទ្យាថ្មីៗ បណ្ណាល័យ និងសម្ភារឧបទេស ឯកសាររៀននិងបង្រៀនទំនើប សម្បូណ៌បែប

៤) ការអភិវឌ្ឍភាពជាអ្នកដឹកនាំគ្រប់គ្រង ដោយផ្តោតលើ (ក) ការគ្រប់គ្រងការរៀន និងបង្រៀន (ខ) ការគ្រប់គ្រងរដ្ឋបាល (គ) ការគ្រប់គ្រងហិរញ្ញវត្ថុ (ឃ) ការគ្រប់គ្រងបុគ្គលិក និងធនធាន

៥) ការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ តាមរយៈការពង្រឹងគុណភាពកម្មសិក្សាគរុកោសល្យ

៦) ការធានាគុណភាព៖ ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង គណៈកម្មាធិការជាតិទទួលស្គាល់គុណភាពអប់រំ ការវាយតម្លៃឯករាជ្យ។

- ក្រសួងនឹងបង្កើនគុណភាពគ្រូឧទ្ទេស ដោយជ្រើសរើសចេញពីសាលាគរុកោសល្យ និងគ្រូល្អ ដើម្បីយក ទៅបណ្តុះបណ្តាលបន្ត ព្រមទាំងអនុវត្តគន្លងជាជីព ដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយប្រើប្រាស់ច្រកចំនួនពីរគឺ៖ ១).ការជ្រើសរើសគ្រូល្អ និងនាយកល្អ តាមយន្តការមានស្រាប់ ប្រចាំឆ្នាំ និង២).ការជ្រើសរើសគ្រូល្អ នាយកល្អ និងអ្នកឯកទេសអប់រំ ក្នុងក្របខណ្ឌសាលារៀន ជំនាន់ថ្មី និងសាលារៀនគំរូ។
- ក្រសួងនឹងបន្តធ្វើវិក្រឹតការគ្រូបង្រៀនលើវិធីសាស្ត្របង្រៀន និងការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ឱ្យបានដល់គ្រប់គ្រូបង្រៀនថ្នាក់ទី១ ទី២ និងទី៣ នៅទូទាំងប្រទេស
- ក្រសួងនឹងរៀបចំបង្កើតយន្តការប្រឹក្សាគរុកោសល្យ សម្រាប់ការចុះគាំទ្រដល់គ្រូបង្រៀនកម្រិតថ្នាក់ដំបូង ដើម្បីធានាគុណភាព ប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តកញ្ចប់សម្ភារៈអំណាន និងគណិតវិទ្យា ថ្នាក់ដំបូង
- ក្រសួងនឹងអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងនាយកសាលាចំនួន ១៣០០០ នាក់ ក្នុងរយៈពេលពីឆ្នាំ ២០២២ ដល់ ២០២៧។

- ក្រសួងនឹងធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដែលមានចក្ខុវិស័យក្នុងការ កសាងគ្រូបង្រៀនមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពវិជ្ជាជីវៈ ដោយមានការទទួល ស្គាល់ពីសង្គមក្នុងនោះ៖ ១).ទាក់ទាញ និងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន,២).ជានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន, ៣).ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារជាប់ជាប្រចាំ, ៤).ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។
- ក្រសួងនឹងរៀបចំយន្តការដើម្បីអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីបណ្តុះ ស្មារតីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពេញមួយជីវិតការងារដល់បុគ្គលិកអប់រំ ដោយផ្តោតលើ៖ ១).ធានាឱ្យមាន ក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ, ២).ធានាថាបុគ្គលិកអប់រំគ្រប់រូបនឹងទទួលបាន វគ្គវិក្រឹតការទៀតទាត់, ៣).ធានាការផ្សារភ្ជាប់រវាងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពបុគ្គលិក អប់រំ, និង៤).ធានាឱ្យមានប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការផ្សារភ្ជាប់កំណែទម្រង់គ្រូបង្រៀន និងកំណែទម្រង់ការគ្រប់គ្រងសាលារៀន។
- ក្រសួងនឹងជំរុញការអនុវត្តគោលនយោបាយមគ្គុទេសក៍អាជីពនិងការផ្តល់ប្រឹក្សា តាមរយៈការរៀបចំមុខងារគ្រូផ្នែកមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សា ដើម្បីជួយសិស្សនៅតាមសាលារៀនគ្រប់កម្រិត ក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈ ការសិក្សារៀនសូត្រ និងការអភិវឌ្ឍអាជីព។
- ក្រសួងនឹងចាប់ផ្តើមដំឡើងកម្រិតនៃការបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យ ក្នុងនោះចាប់ពី សាលាបឋមសិក្សាដល់វិទ្យាល័យ (១២+៤) , (បរិញ្ញាបត្រ+១), និង (បរិញ្ញាបត្រ+២)។ ក្រសួងនឹង ផ្សារភ្ជាប់សាលាគរុកោសល្យ និងសាលារៀនជំនាន់ថ្មី និងសាលារៀនគំរូ, និងធានាស្តង់ដាសាលាគរុកោសល្យ។
- ក្រសួងនឹងអនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពី គ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ដែលផ្តោត លើគំនិតអភិវឌ្ឍតាមបែបបរិវត្តកម្ម និងយុទ្ធសាស្ត្រច្នៃប្រឌិតឆ្ពោះទៅមុខក្នុងការធ្វើបរិវត្តកម្មការអប់រំ និងការអភិវឌ្ឍគ្រូបង្រៀន ដែលនឹងនាំឱ្យមានការរីកចម្រើនទាំងគុណភាពបង្រៀន និងរៀននៅគ្រប់ កម្រិតសិក្សា ដោយផ្អែកលើផ្នែកយុទ្ធសាស្ត្រចំនួន៤ ដូចខាងក្រោម៖
  - ការគ្រប់គ្រង (Teacher Management )
  - ភាពជាអ្នកដឹកនាំតាមបែបបរិវត្តកម្ម (Transformational Leadership)
  - ការអប់រំគ្រូបង្រៀន (Teacher Education)
  - អត្តសញ្ញាណ និងការអភិវឌ្ឍគ្រូបង្រៀន (Teacher Identity and Development)
- ក្រសួងនឹងចាប់ផ្តើមបណ្តុះបណ្តាលគ្រូជំនាញអប់រំពិសេសលើផ្នែក គ ថ្លង់ ពិការភ្នែក និងសតិបញ្ញា នៅវិទ្យាស្ថានជាតិអប់រំពិសេស ដោយផ្តោតលើការបណ្តុះជំនាញឯកទេសបន្ថែម

១ឆ្នាំ ដែលជ្រើសរើស គ្រូកម្រិតបឋមសិក្សា និងគ្រូកម្រិតមធ្យមសិក្សាបឋមភូមិ (១២+២+១) និង (១២+៤+១) និងគ្រូ កម្រិតមធ្យមសិក្សាទុតិយភូមិ (១២+៤+១+១)។

- ក្រសួងនឹងដាក់បញ្ចូលការបណ្តុះបណ្តាលគ្រូអប់រំពហុភាសា នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្ត ស្ទឹងត្រែង។
- វិទ្យាស្ថានអប់រំពិសេស នឹងរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូជំនាញអប់រំពិសេសផ្នែក គ ថ្លង់ ពិការភ្នែក និងពិការសតិបញ្ញា និងពង្រឹងការស្រាវជ្រាវភាសាសញ្ញា និងអក្សរប្រែយ៍ខ្មែរ ។

## ១.៦ ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

ក្នុងការលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងដើម្បីត្រៀមលក្ខណៈកែលម្អលទ្ធផលនៃការអនុវត្តតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមកម្មវិធីអន្តរជាតិ PISA ក្រសួងត្រូវបង្កើនចំនួនសិស្ស និងទាក់ទាញសិស្សនៅមធ្យមសិក្សា និងឧត្តមសិក្សាឱ្យចូលរៀនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាកត្តាសំខាន់ ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្ម ៤.០ និងគោលនយោបាយជំរុញឌីជីថលរបស់រាជរដ្ឋាភិបាល។ ដូចនេះ ក្រសួងនឹង៖

១) បង្កើនចំនួនសាលារៀនជំនាន់ថ្មី, សាលារៀនគំរូ និងបង្កើនម៉ោងបង្រៀន និងការបង្រៀនផ្តោតលើមុខវិជ្ជាស្ទែម

២) វិនិយោគបន្ថែម និងបង្កើនគុណភាពនៃការបណ្តុះបណ្តាលគ្រូមុខវិជ្ជាស្ទែមឱ្យដល់កម្រិតស្តង់ដាវិជ្ជាជីវៈ

៣) កែលម្អវិធីសាស្ត្របង្រៀនតាមមុខវិជ្ជាស្ទែម ដោយផ្តោតលើវិធីវិទ្យាសាស្ត្រ, វិធីរិះរក, និងវិធីផ្សេងទៀត សម្រាប់ការបង្រៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ព្រមទាំងបង្កើនម៉ោងបង្រៀន និងការបង្រៀន ផ្តោតលើមេរៀនសំខាន់ៗ និងគាំទ្រសិស្សឱ្យបង្កើតកិច្ចការគម្រោងស្រាវជ្រាវតូចៗពាក់ព័ន្ធនឹងស្ទែមនៅតាមសាលារៀន

៤) វិនិយោគបន្ថែមលើការបំពាក់សម្ភារៈឧបទេស និងជំរុញការធ្វើពិសោធន៍ នៅតាមសាលារៀនជំនាន់ថ្មី វិទ្យាល័យធនធាន សាលារៀនគំរូ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស

៥) ជំរុញការបង្កើតក្លឹបសិក្សាក្រោយម៉ោងសិក្សា និងពង្រឹងក្រុមប្រឹក្សាយុវជន និងបង្កើតប្រព័ន្ធអេកូឡូស៊ី ដូចជាពិព័ណ៌វិទ្យាសាស្ត្រ និងពិព័ណ៌ស្នាដៃសិស្ស ការប្រកួតប្រជែងស្នាដៃ និងការបង្កើតភាពជាដៃគូ រវាងគ្រឹះស្ថានមធ្យមសិក្សាជាមួយគ្រឹះស្ថានឧត្តមសិក្សា និងក្រុមហ៊ុនឯកជន។

- ក្រសួងនឹងពង្រឹងហេដ្ឋារចនាសម្ព័ន្ធទន់ ដោយពង្រឹងគុណតម្លៃគណៈគ្រប់គ្រង និងគ្រូបង្រៀន និង កែប្រែវប្បធម៌សាលារៀន ការអនុវត្តគន្លងអាជីព និងការបណ្តុះបណ្តាលវិជ្ជាជីវជាប្រចាំ ការគ្រប់គ្រង ផ្តោតលើលទ្ធផល ទៅតាមកម្រិតនៃការវិនិយោគ។
- ក្រសួងនឹងពង្រឹងការគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សា, ពិនិត្យឡើងវិញសៀវភៅគោលលើ

មុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា, បណ្តុះបណ្តាលពីវិធីសាស្ត្រវិទ្យាសាស្ត្រ, បំពាក់សម្ភារៈឧបទេសបង្រៀន មុខវិជ្ជាវិទ្យាសាស្ត្រ, បណ្តុះបណ្តាលពីការប្រើប្រាស់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ, កែលម្អការ ប្រើប្រាស់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ, ពង្រឹងការប្រើប្រាស់បណ្ណាល័យ ដោយផ្តល់សៀវភៅសិក្សា គោល និងឯកសារសិក្សាស្រាវជ្រាវផ្សេងៗទៀតឱ្យបានគ្រប់គ្រាន់ និងកំណត់កាលវិភាគដល់សិស្សចូល បណ្ណាល័យ។

- ក្រសួងនឹងការលើកកម្ពស់ការអប់រំបច្ចេកទេសស្របតាមស្តង់ដា ដោយជំរុញឱ្យមានការប្រឡងប្រណាំង វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសល្អ។
- ផ្សារភ្ជាប់មធ្យមសិក្សាទៅនឹងឧត្តមសិក្សា តាមរយៈការផ្តល់ប្រឹក្សាអាជីព និងការលើកកម្ពស់ការបណ្តុះបណ្តាលបំណិនជីវិត នៅតាមគ្រឹះស្ថានមធ្យមសិក្សា ដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សា ឬ គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ។
- បង្កើតក្លឹបសិក្សា ដូចជាការបង្កើតក្លឹបសិក្សាសរសេរកូដ ការផលិតមនុស្សយន្ត រួមទាំងកម្មវិធីសិក្សា ដែលជាជំនាញទន់ជាច្រើនទៀត ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងក្នុងសតវត្សទី២១ ។

## អាទិភាពស្នូលទី២៖ ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា ឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់សិស្ស

- ចរិយា (បាលី និងសំស្ក្រឹត) ការប្រព្រឹត្តិ (Character education)
- សីលធម៌ (Moral education)៖ ការប្រព្រឹត្តិល្អ ការកាន់ចរិយាល្អ។ សីលធម៌ គឺជាកិរិយាមាយាទ សណ្តាប់ធ្នាប់ និង ដំបូន្មានដែលនាំឱ្យចៀសវាងអំពើអាក្រក់។
- ការប្រើពាក្យការអប់រំចរិយាធម៌ គឺដើម្បីឱ្យមានសង្គតិភាពជាមួយ គោលដៅនៃកម្មវិធីសិក្សា គឺចរិយាសម្បទា។
- គោលដៅនៃការអប់រំ គឺ៖ (១) វិជ្ជាសម្បទា (២) បំណិនសម្បទា ជាពិសេស សុខភាព និង (៣) ឥរិយាបថល្អ។

### ២.១. ការអប់រំចរិយាធម៌

ការអប់រំចរិយាធម៌ (Character Education) គឺជាអាទិភាពថ្មីសម្រាប់នីតិកាលទី៧ ដោយក្រសួងអប់រំ យុវជន និងកីឡានឹងដាក់ចេញវិធានការដូចតទៅ៖

- យកចិត្តទុកដាក់លើ "**ការអភិវឌ្ឍផ្នែកទន់**" ជាពិសេសការអនុវត្តកម្មវិធីសិក្សាឱ្យបានពី ៤ម៉ោងទៅ ៦ម៉ោង ក្នុង១ថ្ងៃ (ឬ៤០ម៉ោងក្នុង១សប្តាហ៍) ដោយនៅសាលាបឋមសិក្សាផ្តោតលើអំណានដំបូង និងគណិតវិទ្យាដំបូង និងនៅអនុវិទ្យាល័យ និងវិទ្យាល័យផ្តោតលើវិធីសាស្ត្របង្រៀនថ្មី។ ក្រសួងនឹងបញ្ជ្រាប និងបញ្ចូលកម្មវិធីអភិវឌ្ឍយុវជនទូទៅនៅក្នុងសាលារៀន ដូចជាការអប់រំបរិស្ថាន អនាម័យស្អាត សីលធម៌ ។ល។ ដើម្បីកាត់បន្ថយពេលទំនេររបស់

សិស្ស និងបង្កើតទម្លាប់ល្អរបស់សិស្ស។

- រៀបចំ "**កម្មវិធីអប់រំចរិយាធម៌**" ដោយផ្តោតលើការចេះគោរពចាស់ទុំតាមរយៈការសំពះ ការស្លៀកពាក់ស្អាតបាត និងអនាម័យល្អ។
- រៀបចំ "**សេចក្តីណែនាំស្តីពី ការអប់រំចរិយាសម្បទា**" ដោយដកស្រង់ពីមុខវិជ្ជាសីលធម៌ និងពលរដ្ឋវិទ្យា។
- រៀបចំវិធានការ ដើម្បីលើកកម្ពស់ការយល់ដឹងពីវប្បធម៌ និងអារ្យធម៌ខ្មែរ ដូចជាការសំពះ និងឥរិយាបថល្អសម្រាប់កុមារ និងយុវជន។
- "**ការផ្តល់ពិន្ទុសិស្ស នឹងផ្តោតលើចំណេះដឹងខាងផ្នែកៈ (១) វិជ្ជាសម្បទា (២) បំណិនសម្បទា និង (៣) ចរិយាសម្បទា**"។ ដូចនេះការផ្តល់ពិន្ទុប្រចាំខែ និងប្រចាំឆ្នាំដល់សិស្ស នឹងរាប់បញ្ចូលនូវការចូលរួមក្នុងការងារសង្គម ការចូលរួមក្នុងក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន កម្មវិធីមិត្តជួយមិត្ត កម្មវិធីបង្រៀនសិស្សខ្សោយ ក្លឹបសិក្សា ការជួយដល់ការងារសហគមន៍ ការសម្អាតថ្នាក់រៀន បន្ទប់ទឹក សាលារៀន ការដាំដើមឈើ សួនបន្លែ ការលើកកម្ពស់បរិស្ថានសាលារៀនស្អាត ការងារស្ម័យសិក្សា ការហាត់កីឡាដើម្បីសុខភាព ការអប់រំប្រឆាំងការប្រើប្រាស់សារធាតុញៀន ការងារស្ម័គ្រចិត្ត។

## ២.២.ការអភិវឌ្ឍយុវជនដើម្បីលើកកម្ពស់បំណិនសតវត្សទី ២១

យុវជនសតវត្សទី២១ ជាយុវជនបន្តវេន និងជាសសរទ្រូងសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជានៅឆ្នាំ២០៣០ និង២០៥០។ ដូចនេះ យុវជននឹងត្រូវទទួលបាននូវការអភិវឌ្ឍ លើគ្រប់ទិដ្ឋភាព និងតាមគ្រប់រូបភាព ក្នុងនោះ ៖

ក) កម្មវិធីអភិវឌ្ឍយុវជនទាំងបំណិនរឹង និងបំណិនទន់ ដោយផ្តោតលើបំណិនសតវត្សទី២១ និង លើកកម្ពស់ភាពជាអ្នកដឹកនាំ រួមមាន៖១).បំណិនត្រិះរិះពិចារណា, ២).នវានុវត្តន៍ និងដោះស្រាយបញ្ហា ៣).សហការ, ៤).ទំនាក់ទំនង និងប្រាស្រ័យទាក់ទង, ៥).អក្ខរកម្មព័ត៌មាន៖ យល់ពីព្រឹត្តិការណ៍ ទិន្នន័យ និងស្ថិតិ, ៦).អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ៖ ចេះបែងចែកព័ត៌មានសំខាន់ និង ព័ត៌មានក្លែងក្លាយ, ៧).អក្ខរកម្មបច្ចេកវិទ្យា៖ ចេះប្រើបច្ចេកវិទ្យា និងបន្សាំខ្លួនងាយស្រួល, ៨). ភាព ទន់ភ្លន់៖ ចេះបត់បែនតាមសភាពការណ៍ដែលវិវត្តយ៉ាងលឿន, ៩).ភាពជាអ្នកដឹកនាំ៖ ធ្វើការលើសពីការរំពឹងទុក ចេះគ្រប់គ្រងនិងដឹកនាំអង្គភាព មានគំនិតផ្តួចផ្តើម មានឥរិយាបថវិជ្ជមាន មានចក្ខុវិស័យ ផ្តល់ការលើកទឹកចិត្ត មានការទទួលខុសត្រូវ តស៊ូពេលលំបាក ចេះស្តាប់មតិយោបល់អ្នកដ៏ទៃ ចេះសម្រេចចិត្ត, ១០). ការមានគំនិតផ្តួចផ្តើម និងសហគ្រិនភាព, ១១). ផលិតភាព និង ១២). បំណិនសង្គម៖ មានបំណិនទំនាក់ទំនង

ខ) ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ទាំងការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបំណិនទន់ ដើម្បីឱ្យយុវជនមានសមត្ថភាពចូលរួមដោះស្រាយ បញ្ហារួមរបស់ប្រទេសជាតិ, មានភាពក្លាហាន និងមានភាពឈ្លាសវៃក្នុងការបញ្ចេញមតិ, មានសមត្ថភាពត្រិះរិះពិចារណា សិក្សាស្រាវជ្រាវ ចែករំលែក គំនិត និងជំនាញក្នុងការនិយាយសាធារណៈ ប្រកបដោយក្រមសីលធម៌ និងចំណេះដឹងពិតប្រាកដ

គ)	ការផ្តល់ឱកាសឱ្យយុវជនបញ្ចេញគំនិតយោបល់, បង្ហាញទេពកោសល្យ ដើម្បីបង្កើតសង្គមពុទ្ធិ និង ស្វែងរកសុខដុមនីយកម្មសម្រាប់ទាំងអស់គ្នា, បង្កើតទំនាក់ទំនងល្អ រវាងយុវជននិងយុវជន និងលើកកម្ពស់តម្លៃមិត្តភាព

ឃ)	ការបង្កើតជាថ្នាលដោយផ្តោតលើបំណិនរឹង និងបំណិនទន់សម្រាប់យុវជនហាត់ការ ឱ្យមានភាព រឹងមាំ មានភាពចាស់ទុំគំនិត និងចេះគិតយ៉ាងហ្មត់ចត់ រួមមាន៖ ១).ការប្រកួតប្រជែង ព័ត៌មាន វិទ្យា, ២).ការប្រកួតប្រជែងផែនការអាជីវកម្ម, ៣).ការប្រកួតប្រជែងមនុស្សយន្ត, ៤).ការងារ ស្ម័គ្រចិត្ត, ៥).កាយរឹទ្ធិ, និង៦).ការបោះជំរំ

ង) ការបណ្តុះបណ្តាលយុវជនឱ្យចូលរួមដោះស្រាយបញ្ហារួមរបស់ប្រទេសជាតិ គាំទ្ររដ្ឋាភិបាល កសាងសមត្ថភាពយុវជនឱ្យមានភាពក្លាហាន មានភាពឈ្លាសវៃ, ពង្រឹងសមត្ថភាពត្រិះរិះ ពិចារណា សិក្សាស្រាវជ្រាវ ចែករំលែកគំនិត និងជំនាញក្នុងការនិយាយសាធារណៈ ប្រកបដោយក្រមសីលធម៌ និងចំណេះដឹងពិតប្រាកដ។

**អាទិភាពស្នូលទី៣៖ ការលើកកម្ពស់សុខភាពសិក្សា ដោយយកចិត្តទុកដាក់លើសុខភាពរបស់សិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលា**

- បន្តអនុវត្ត "**កម្មវិធីផ្តល់អាហារតាមសាលារៀន**" ដែលជាផ្នែកមួយនៃការលើកកម្ពស់ សុវត្ថិភាពសង្គម សមធម៌ សុខភាពសិក្សា ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។
- គិតគូរភាពជាម្ចាស់ និងនិរន្តរភាពរបស់កម្មវិធីផ្តល់អាហារតាមសាលារៀន អាស្រ័យលើលទ្ធភាពថវិកា។
- បន្តអនុវត្ត"**កម្មវិធីផ្តល់អាហារូបករណ៍ជាសាច់ប្រាក់**"ដែលជាផ្នែកមួយនៃប្រព័ន្ធសុវត្ថិភាពសង្គម

ក្នុងបរិបទនៃគន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ សាលារៀនត្រូវធានាបាននូវនិរន្តរភាពនៃដំណើរការ និងធានាសុវត្ថិភាពសុខភាព រួមទាំងសុខភាពផ្លូវចិត្ត សម្រាប់បុគ្គលិកអប់រំ និងសិស្សានុសិស្ស។ ដូចនេះ សាលារៀនត្រូវ៖

១)	បង្កើតគណៈកម្មការសុខភាពសិក្សានៅតាមសាលារៀន

២)	កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាពដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា បរិស្ថានសាលារៀនបៃតង សាលាស្អាតគ្មានសំរាម

៣)	លើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ ផ្តោតលើទឹកទទួលទាន កន្លែងលាងដៃ បង្គន់អនាម័យ ការពាក់ម៉ាស និងការរក្សាគម្លាត

៤)	លើកកម្ពស់អាហារូបត្ថម្ភ ដោយផ្តោតលើសុវត្ថិភាពចំណីអាហារ ការផ្តល់អាហារតាមសាលារៀន និងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ

៥) អប់រំអំពីសុខភាពសិក្សា និងគន្លងប្រក្រតីភាពថ្មី ដោយអនុវត្តតាមខ្លឹមសាររបស់កម្មវិធីសិក្សាមុខវិជ្ជាសុខភាពសិក្សា និងការហាត់ប្រាណ និងលេងកីឡា។

## អាទិភាពស្នូលទី៤៖ ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំ ស្របតាមពាក្យស្លោក ភាពជាដៃគូ រដ្ឋ និងសហគមន៍ ដើម្បីការអប់រំ

- ចេញគោលការណ៍ឱ្យសាលារៀនអាចបង្កើត "**មូលនិធិសមធម៌**" ដើម្បីប្រើប្រាស់ថវិកាបដិភាគពីមាតាបិតាសិស្សសម្រាប់គាំទ្រដល់ការបន្ថែមមុខវិជ្ជាថ្មីៗ ក៏ដូចជាការរៀបចំកម្មវិធីជួយសិស្សរៀនយឺត ការបង្កើតក្លឹបសិក្សា នៅតាមសាលាដែលមានសក្តានុពល ព្រមទាំងកាត់បន្ថយការបង្រៀនគួរ។
- ដាក់ចេញគោលនយបាយដើម្បីជំរុញ "***ភាពជាដៃគូសាធារណៈនិងសហគមន៍ក្នុងការអប់រំ***" ដោយចាប់ផ្តើមអនុវត្តនៅតាមសាលារៀនគំរូ និងរៀបចំសេចក្តីណែនាំអនុវត្តនៅគ្រប់គ្រឹះស្ថានសិក្សារួមទាំងរៀបចំយន្តការថ្នាក់ជាតិចុះជួយជំរុញនៅទូទាំងប្រទេស ក្នុងគោលដៅផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងបំផុសស្មារតីចូលរួម ជាពិសេសការបង្កើតទំនាក់ទំនងល្អរវាងមាតាបិតាសិស្ស និងគ្រូបង្រៀន ដើម្បីផ្តល់ព័ត៌មាន និងជួយគ្នាទៅវិញទៅមកអំពីការអប់រំសិស្ស។
- លើកទឹកចិត្តឱ្យសហគមន៍ចូលរួមក្នុងការសាងសង់ និងជួសជុលអគារសិក្សា ដោយកំណត់អាទិភាពថវិកាជាតិទៅលើការសាងសង់ផ្ទះគ្រូ នៅតំបន់ដាច់ស្រយាល និងជួបការលំបាក។

## អាទិភាពទី៥៖ ការអប់រំឌីជីថល

នៅក្នុងដំណាក់កាលកូវីដ កម្ពុជាបានដើរទៅមុខ ១០ឆ្នាំមុនកាលកំណត់ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ។ គ្រូបង្រៀនបានខិតខំរៀនពីការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីបង្រៀនសិស្សនៅពេលសាលាត្រូវបានផ្អាកដំណើរការជាបណ្តោះអាសន្ន។ ដូចនេះ ក្រសួងនឹងបន្តលើកកម្ពស់ការអប់រំឌីជីថល តាមរយៈ ៖

១) លើកកម្ពស់អក្ខកម្មឌីជីថល៖ បញ្ជ្រាបអក្ខរកម្មឌីជីថល ទៅក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ។

២) លើកកម្ពស់ការអប់រំឌីជីថល៖ បន្តអនុវត្តមុខវិជ្ជាឌីជីថល ដូចជាការសរសេរកូដ ការផលិតមនុស្សយន្ត ។ល។ នៅសាលារៀនជំនាន់ថ្មី និងដាក់ឱ្យអនុវត្តនៅតាមវិទ្យាល័យធនធានវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស និងវិទ្យាល័យដែលមានសក្តានុពល ដោយសហការជាមួយគ្រឹះស្ថាន ឧត្តមសិក្សា និងផ្នែកឯកជន។

៣) កសាងជំនាញផ្នែកឌីជីថលនៅកម្រិតឧត្តមសិក្សា៖ បង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល នៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលមានស្រាប់ ដោយផ្តល់អាហារូបករណ៍ដល់ការបណ្តុះបណ្តាល សាស្ត្រាចារ្យផ្នែកឌីជីថលនៅក្រៅប្រទេស ការបង្កើតអាហារូបករណ៍ផ្នែកបច្ចេកវិទ្យាឌីជីថលដល់ និស្សិតឆ្នើម ដោយសហការជាមួយផ្នែករដ្ឋ និងផ្នែកឯកជន។

៤) ធ្វើបច្ចុប្បន្នកម្មទេពកោសល្យជំនាញឌីជីថល៖ សហការជាមួយក្រសួង ដៃគូ ក្រុមហ៊ុនពាក់ព័ន្ធ។

៥) គាំទ្រដល់វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យខាងផ្នែកឌីជីថល៖ ផ្តល់ថវិកាគាំទ្រ និងអាហារូបករណ៍ដល់ វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ក្នុងការបណ្តុះបណ្តាលជំនាញឌីជីថល។

- ក្រសួងនឹងរៀបចំបង្កើតបន្ទប់រៀនឌីជីថលនៅតាមសាលារៀន ដោយបំពាក់សម្ភារអេឡិចត្រូនិក រួមមាន LCD Projector/ Smart TV, Smartboard, អ៊ីនធើណិត

- ក្រសួងនឹងជំរុញការអនុវត្តការរៀននិងបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា ដើម្បីធានាថាសិស្សថ្នាក់ទី៤-៦ បានសិក្សាភាសាអង់គ្លេសស្របតាមកម្មវិធីសិក្សា

- ក្រសួងនឹងផ្តល់ការអប់រំចំណេះដឹងជាមូលដ្ឋានគ្រឹះ សម្រាប់ការអប់រំដោយឆ្លើយតបជាមួយយុគ្គសម័យ បច្ចេកវិទ្យា តាមរយៈការធ្វើកំណែទម្រង់សាលារៀន និងកំណែទម្រង់ការបណ្តុះ-បណ្តាលគ្រូ ដោយធ្វើ យ៉ាងណាឱ្យភាគីពាក់ព័ន្ធទាំងអស់មានសមត្ថភាពខ្ពស់ផ្នែកបច្ចេកវិទ្យា និងការអនុវត្តវិធីសាស្ត្របង្រៀន ដោយប្រើប្រាស់បច្ចេកវិទ្យាដូចជា ការផ្តល់សម្ភារៈឧបទេស និងការបណ្តុះបណ្តាលដល់គ្រូ ក្នុងការ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងការបង្រៀនសិស្ស។

- ក្រសួងនឹងបង្កើនបរិស្ថានសមស្របសម្រាប់ការអប់រំឌីជីថល ដែលរួមមាន៖

១) ប្រព័ន្ធគ្រប់គ្រងការសិក្សា(LMS)៖ ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្តល់ការអប់រំអេឡិចត្រូនិកដោយប្រើ ប្រាស់កម្មវិធី Apps បន្ទប់រៀនសិប្បនិម្មិត (Virtual) និងមានបន្ទប់ពិភាក្សា ដំណរភ្ជាប់វេបសាយ (Weblinks) បណ្ណាល័យ ប្រតិទិន និងធនធានសិក្សាផ្សេងទៀត។ កម្មវិធីកុំព្យូទ័របែប Apps ដែលមានផ្ទុកនូវខ្លឹមសារឌីជីថល ជាវីឌេអូមេរៀនគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់រៀន។

២) ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្ទាល់ខ្លួន(PLS)៖ ឧបករណ៍គាំទ្រដល់ការសិក្សាផ្ទាល់ខ្លួន ដោយសិស្សអាចទាញយកខ្លឹមសារឌីជីថល ជាអត្ថបទ បទបង្ហាញ PowerPoint ឬវីដេអូ ដើម្បីរក្សាទុកក្នុងឧបករណ៍អេឡិចត្រូនិកផ្ទាល់ខ្លួនទុកសម្រាប់សិក្សានៅកន្លែងណានិងពេលណា ដែលខ្លួនចង់រៀន។

៣) ការសិក្សាក្នុងថ្នាក់រៀនបញ្ច្រាស (Flipped Classroom)៖ សិស្សអាចប្រើប្រាស់ខ្លឹមសារមេរៀន បទបង្ហាញដែលគ្រូបានថតជាវីដេអូ និងធនធានសិក្សាអេឡិត្រូនិកដ៏ទៃទៀត ដែលទទួលបានតាមអ៊ិនធើណិត និងយូធូប ដើម្បីសិក្សាស្រាវជ្រាវមេរៀននៅផ្ទះ ទៅតាមល្បឿនដែលខ្លួនចង់។ នៅក្នុងថ្នាក់រៀន គ្រូមានតួនាទីជាអ្នកសម្របសម្រួលការពិភាក្សា ការធ្វើពិសោធន៍ ផ្តល់ការគាំទ្រ និងមតិត្រឡប់។

៤) ការកែលម្អវេទិកាឌីជីថល៖ ការកែលម្អវេទិកាឌីជីថលដែលមានស្រាប់របស់ក្រសួងអប់រំ យុវជន និង កីឡាឱ្យបានកាន់តែប្រសើរ និងការផលិតវីដេអូបង្រៀនដែលចាំបាច់បន្ថែមទៀត។

៥) ការបង្កើតបន្ទប់ឌីជីថលតាមគ្រឹះស្ថានសិក្សា៖ បង្កើតបន្ទប់មួយសម្រាប់ការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក។

៦) ការអភិវឌ្ឍសមត្ថភាព៖ អភិវឌ្ឍសមត្ថភាពសាលារៀន គណៈគ្រប់គ្រង និងបុគ្គលិករដ្ឋបាល ដើម្បីជួយគាំទ្រដល់ការអប់រំឌីជីថល និងការគាំទ្រដល់ការបំប៉នសិស្ស ដើម្បីឱ្យពួកគេអាចរៀនតាមបែបឌីជីថល។

៧) ការអនុវត្តវិធីសាស្ត្របង្រៀនថ្មី៖ ការអនុវត្តវិធីសាស្ត្របង្រៀនទំនើប ដើម្បីលើកកម្ពស់បំណិនសតវត្សទី២១ ជាមួយប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ (Blended Learning) ឬ ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System)។

## អាទិភាពទី៦៖ ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

កំណែទម្រង់នៅឧត្តមសិក្សា នឹងជានាបាននូវការបណ្តុះធនធានមនុស្សសម្រាប់បម្រើដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងនោះ៖

១) គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តោតលើការពង្រឹងអភិបាលកិច្ច, ការលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យឱ្យមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

២) កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ក្នុងការជំរុញការសិក្សា ការបណ្តុះបណ្តាល និងកសាង ជំនាញផ្នែកឌីជីថលនៅថ្នាក់ឧត្តមសិក្សា និងនៅគ្រប់កម្រិតបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងជំរុញការកែលម្អកម្មវិធីសិក្សា ដើម្បីបន្សុីគ្នារវាងតម្រូវការជំនាញ និងការបណ្តុះបណ្តាល

៣) រៀបចំ និងអនុវត្តកម្មវិធី និង/ឬ គំនិតផ្តួចផ្តើម ថ្នាក់ជាតិ ក្នុងការអភិវឌ្ឍ និងការបណ្តុះបណ្តាលធនធានមនុស្សដែលមានទេពកោសល្យឌីជីថល រួមមានជាអាទិ៍ ការបង្កើតមូលនិធិថ្នាក់ជាតិសម្រាប់ផ្តល់អាហារូបករណ៍លើផ្នែកបច្ចេកវិទ្យាឌីជីថល ទាំងក្នុង និងក្រៅប្រទេស ដោយកៀរគរការធ្វើសហហិរញ្ញប្បទានពីវិស័យសាធារណៈ វិស័យឯកជន និងគ្រឹះស្ថានសិក្សា និងបណ្តុះបណ្តាល

៤) រៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និងការបណ្តុះគំនិតថ្មី ដោយផ្អែក លើតម្រូវការជំនាញថ្មី (New skills Requirement)

៥) ជំរុញសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងនវានុវត្តន៍ផ្នែកឌីជីថល នៅតាមបណ្តាសាកលវិទ្យាល័យ គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ វិទ្យាស្ថាននិងមជ្ឈមណ្ឌលស្រាវជ្រាវនានា តាមរយៈការចងក្រងជាប្រព័ន្ធនូវបណ្តាស្ថាប័ន-គ្រឹះស្ថានស្រាវជ្រាវ

៦) កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ និងការអភិវឌ្ឍការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍ រួមមានជាអាទិ៍ ការរៀបចំឱ្យមានបណ្តុះមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថល ដើម្បីជំរុញការផ្លាស់ប្តូរទិន្នន័យ, ព័ត៌មាននិងចំណេះដឹងគួបផ្សំនឹងការរៀបចំ មូលនិធិថវិកាគាំទ្រ តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

## យុទ្ធសាស្ត្រកំណែទម្រង់ការអប់រំឧត្តមសិក្សាឆ្ពោះទៅរកឧត្តមភាព

### ១. ការធ្វើទំនើបកម្មកម្មវិធីសិក្សា, វិធីសាស្ត្របង្រៀន និង វិធីសាស្ត្រវាយតម្លៃ

- បន្តកែលម្អគុណភាពនៃការបង្រៀន និងការរៀន លើមុខជំនាញផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា និងកសិកម្ម នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង គ្រឹះស្ថានឧត្តមសិក្សាឯកជន តាមរយៈការធ្វើទំនើបកម្មកម្មវិធីសិក្សា, វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា។
- រៀបចំក្របខណ្ឌអភិវឌ្ឍកម្មវិធីសិក្សា ដើម្បីជួយគ្រឹះស្ថានឧត្តមសិក្សាក្នុងការរៀបចំ និងអនុវត្តកម្មវិធីសិក្សាឱ្យបានត្រឹមត្រូវ និងធានាបាននូវគុណភាពនៃការអប់រំនិស្សិតឱ្យមានចំណេះដឹង និងជំនាញ និងជាពលរដ្ឋល្អពិតប្រាកដ ស្របតាមស្តង់ដាជាតិ និងអន្តរជាតិ តាមរយៈ៖ ១).ការធ្វើទំនើបកម្ម និងការអនុវត្តកម្មវិធីសិក្សាតាមបែបការអប់រំផ្អែកលើលទ្ធផល (Outcome-based Education) ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដោយបញ្ចូលនូវបញ្ញត្តិសេដ្ឋកិច្ចបៃតង, ២).ការធ្វើទំនើបកម្ម និងការអនុវត្តវិធីសាស្ត្របង្រៀននិងរៀនតាមបែបគម្រោង/តាមបែបរិះរក (Project-based/inquiry-based learning approaches) ជាមួយនឹងការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល, ៣).ការកែលម្អវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សាស្របតាមការអប់រំផ្អែកលើលទ្ធផល និងវិធីសាស្ត្របង្រៀននិងរៀនតាមបែបគម្រោង/តាមបែបរិះរក។
- បន្តលើកកម្ពស់បំណិនសហគ្រិនភាព តាមរយៈមជ្ឈមណ្ឌលភ្ញាស់វិជ្ជាធុរកិច្ច និងមជ្ឈមណ្ឌលឧត្តមភាព ។

### ២. ការលើកកម្ពស់សមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍

- បន្តកសាងសមត្ថភាពនៃការស្រាវជ្រាវ និងនវានុវត្តន៍ ដែលឆ្លើយតបនឹងតម្រូវការរបស់ទីផ្សារ, សហគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈការផ្តល់មូលនិធិវិនិយោគដល់គ្រឹះស្ថានឧត្តមសិក្សាគោលដៅ និងលក្ខខណ្ឌចាំបាច់សម្រាប់ផលិតកស្តុតាងស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីគាំទ្រផលិតផល និង ផលិតផលគំរូដែលចេញពីការស្រាវជ្រាវសម្រាប់ឧស្សាហកម្ម/វិស័យអាទិភាព។
- ប្រើប្រាស់មូលនិធិស្រាវជ្រាវ ដើម្បីកសាងថ្នាលអ្នកស្រាវជ្រាវវ័យក្មេង ។
- អភិវឌ្ឍស្តង់ដាទស្សនាវដ្តីស្រាវជ្រាវនៅឧត្តមសិក្សាដែលមានសក្តានុពល ឱ្យទទួលបានស្តង់ដាអាស៊ាន និងអន្តរជាតិ (ASEAN Citation Index and Scopus)។
- រៀបចំយន្តការក្នុងការផ្តល់មូលនិធិស្រាវជ្រាវដល់គ្រឹះស្ថានឧត្តមសិក្សា និងក្របខ័ណ្ឌគតិយុត្តសម្រាប់ការធ្វើពាណិជ្ជកម្មលើផលិតផលស្រាវជ្រាវដើម្បីរកចំណូល ។
- បន្តគាំទ្រគ្រឹះស្ថានឧត្តមសិក្សា ក្នុងការធ្វើឱ្យប្រសើរឡើងនូវមន្ទីរពិសោធន៍ស្រាវជ្រាវឱ្យទទួលបានស្តង់ដាជាតិ និងស្តង់ដាអន្តរជាតិ (ISO) ដើម្បីផ្តល់សេវាស្តង់ដាតេស្តផលិតផល ។

- រៀបចំគោលការណ៍ណែនាំសម្រាប់ការបង្កើតមជ្ឈមណ្ឌលឧត្តមភាព ។
- រៀបចំវេទិកាជាមួយដៃគូពាក់ព័ន្ធដើម្បីផ្សព្វផ្សាយ និងកៀរគរការវិនិយោគលើស្នាដៃ និងលទ្ធផលស្រាវជ្រាវ ។

## ៣. ការកែលម្អសមធម៌ និង គុណភាព

- ជួសជុលនិងសាងសង់អគារសិក្សា(បន្ទប់រៀន) ដើម្បីបង្កើនចំនួននិស្សិតចូលរៀននៅឧត្តមសិក្សា។
- ជួសជុល និងសាងសង់អន្តេវាសិកដ្ឋានសម្រាប់និស្សិតនារី និងនិស្សិតមកពីគ្រួសារក្រីក្រ ។
- កែលម្អ និងកសាងហេដ្ឋារចនាសម្ព័ន្ធ (បណ្ណាល័យ, បន្ទប់ពិសោធន៍) ចាំបាច់សម្រាប់ការបង្រៀន និងការរៀនតាមបែបគម្រោង/តាមបែបរិះរក និង ការស្រាវជ្រាវ និងនវានុវត្តន៍ ។
- បន្ត និងពង្រីកការអនុវត្តបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ជាមួយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ។
- បន្តអនុវត្តគោលនយោបាយផ្តល់អាហារូបករណ៍ដល់និស្សិតមកពីគ្រួសារក្រីក្រ, និស្សិតនារី និងនិស្សិតមានពិការភាពឱ្យបានបន្តការសិក្សានៅឧត្តមសិក្សា។
- អនុវត្តកម្មវិធីភាពជាដៃគូនៃការអប់រំស្ទែម (STEAM) រវាងមធ្យមសិក្សា និង ឧត្តមសិក្សាដើម្បីលើកកម្ពស់សមត្ថភាព និង លទ្ធភាពរបស់សិស្សបន្តការសិក្សានៅឧត្តមសិក្សា។

## ៤. ការលើកកម្ពស់អន្តរជាតូបនីយ៍កម្មឧត្តមសិក្សា

- បន្តអនុវត្តកម្មវិធីចល័តនិស្សិតអន្តរជាតិអាស៊ី (ASIAN International Mobility Students, AIMS) ជាមួយបណ្ដាសាកលវិទ្យាល័យនៃប្រទេសក្នុងតំបន់។
- បន្តគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការប្រតិបត្តិកម្មវិធីភាពជាដៃគូជាមួយសាកលវិទ្យាល័យក្នុងតំបន់ និង ពិភពលោកដើម្បីពង្រីកកម្មវិធីអន្តរជាតិ។
- គាំទ្រគ្រឹះស្ថានឧត្តមសិក្សាក្នុងការរៀបចំ និងប្រតិបត្តិកម្មវិធីសិក្សាដើម្បីបានការទទួលស្គាល់គុណភាពកម្រិតតំបន់/អន្តរជាតិ។

## ៥. ការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ចស្ថាប័ន

- ផ្តល់ការគាំទ្របច្ចេកទេសដល់គ្រឹះស្ថានឧត្តមសិក្សាដើម្បីរៀបចំ និងអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេលវែង និងការពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល។
- បន្តផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តសិក្សាក្នុងការប្រតិបត្តិប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ, ប្រព័ន្ធឌីជីថលគ្រប់គ្រងទិន្នន័យ, ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស, ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ, គោលការណ៍ណែនាំស្តីពីការសិក្សានិស្សិតក្រោយបញ្ចប់ការសិក្សា និងប្រព័ន្ធគាំទ្រផ្សេងៗទៀត ។

- ធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យឧត្តមសិក្សាតាមបែបឌីជីថល និងការផ្តល់សេវាកម្មតាមប្រព័ន្ធឌីជីថល ដើម្បីបង្កើនល្បឿន និងប្រសិទ្ធភាពការងារ។
- រៀបចំ និងអនុវត្តផែនទីបង្ហាញផ្លូវសម្រាប់ឧត្តមសិក្សា ដើម្បីផលិតមូលធនមនុស្សឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណ។
- រៀបចំគោលនយោបាយក្នុងការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា។

**៦. ការពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង**

- បន្តជួយគ្រឹះស្ថានឧត្តមសិក្សាទាំងរដ្ឋ និងឯកជនអនុវត្តប្រព័ន្ធធានាគុណភាពអប់រំកម្រិតកម្មវិធីសិក្សា និង កម្រិតគ្រឹះស្ថានសិក្សា។
- រៀបចំគោលការណ៍ណែនាំសម្រាប់ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង។
- ធ្វើកិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយបណ្តាញសាកលវិទ្យាល័យអាស៊ាន (ASEAN University Network, AUN) /ស្ថាប័នតំបន់/សាកលវិទ្យាល័យអន្តរជាតិ ដើម្បីកសាងសមត្ថភាពឧត្តមសិក្សាកម្ពុជាឱ្យមានការទទួលស្គាល់គុណភាពកម្រិតតំបន់/អន្តរជាតិ។

**៧. ការអភិវឌ្ឍសមត្ថភាព**

- បន្តបង្កើនគុណវុឌ្ឍិកម្រិតបណ្ឌិតសម្រាប់បុគ្គលិកអប់រំនៅឧត្តមសិក្សា។
- បន្តកែលម្អសមត្ថភាពគ្រូបង្រៀននៅឧត្តមសិក្សាដើម្បីអនុវត្តទំនើបកម្មកម្មវិធីសិក្សា, វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សា។
- កែលម្អសមត្ថភាពមន្ត្រីប្រតិបត្តិដើម្បីបង្កើនគណនេយ្យភាព, តម្លាភាព និងប្រសិទ្ធភាពការងារតាមរយៈការអនុវត្តប្រព័ន្ធអភិបាលកិច្ចទំនើប ។

## អាទិភាពទី៧៖ ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព

ប្រព័ន្ធអប់រំត្រូវមានភាពធន់ និងភាពរស់រវើកក្នុងការកំណត់អាទិភាពទាំងផ្នែកចំណាយ និងការបំពេញការងារ ដោយមានកំណត់ជាសមិទ្ធកម្មច្បាស់លាស់។ ឈរលើមូលដ្ឋាននេះ ក្រសួងនឹកដាក់ឱ្យអនុវត្តអភិក្រមស្តីពី ការគ្រប់គ្រងផ្តោតលើលទ្ធផលឆ្ពោះទៅរកការដោះស្រាយបញ្ហាជាលក្ខណៈប្រព័ន្ធ និងតាមបែបអន្តរវិស័យ, ការពង្រឹងប្រព័ន្ធគ្រប់គ្រងអប់រំ ដោយត្រូវរួមបញ្ចូលគ្នានូវការពិនិត្យឡើងវិញមុខងារនិងភារកិច្ច, ការរៀបចំផែន ការប្រចាំឆ្នាំ, ការអនុវត្តគន្លងអាជីព, ការអភិវឌ្ឍសមត្ថភាព និងការពិនិត្យតាមដាននិងវាយតម្លៃ។ ការពង្រឹង ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ដោយត្រូវផ្តោតលើការបណ្តុះ-បណ្តាលវិជ្ជាជីវៈជាគ្រូបង្រៀន, ភាពជាអ្នកដឹកនាំ និងគ្រប់គ្រង និងជាអ្នកស្រាវជ្រាវ និងវាយតម្លៃ, ការកែលម្អប្រព័ន្ធលើកទឹកចិត្ត និងការផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍគន្លងអាជីព ក៏ដូចជាការទទួលស្គាល់អ្នកជំនាញអប់រំ តាមរយៈការលើកកម្ពស់ការប្រណាំងប្រជែង, ការវាយតម្លៃនាយកសាលាល្អ គ្រូបង្រៀនល្អ គ្រូបង្រៀនល្អភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង និងសាលារៀនស្អាតជាដើម ដោយប្រើប្រាស់ប្រព័ន្ធវាយតម្លៃការបំពេញការងារប្រចាំឆ្នាំ និងការពង្រឹងប្រព័ន្ធនិងផ្លាស់ប្តូររបៀបធ្វើការ ដោយប្រែក្លាយ

ឧត្តមានុវត្តន៍នៃការអនុវត្តគម្រោងនានា មកជាការពង្រឹងប្រព័ន្ធ និងការរៀបចំគោលនយោបាយ និង គោលការណ៍ណែនាំ។

**អាទិភាពទី៨៖ ការអភិវឌ្ឍការអប់រំកាយ និងកីឡា**

- ក្រសួងបន្តលើកកម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និងសុខុមាលភាពល្អ, កាយសម្បទាមាំមួន, ឆន្ទៈមោះមុត, អំណត់ព្យាយាម, មានវិន័យ, មានស្មារតីក្រុម, គំនិតច្នៃប្រឌិត, និងមានការតស៊ូស្វិតស្វាញ សំដៅដណ្ដើមបានលទ្ធផលល្អប្រសើរ ក្នុងការប្រកួតកីឡាលើឆាកអន្តរជាតិ និងមាន ជីវភាពរស់នៅស្របតាមពាក្យស្លោក "កីឡារស់ប្រកបដោយសុខដុមរមនាក្នុងសង្គមក្រោម ម្លប់សន្តិភាព" ព្រមទាំងបន្តជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"។
- ក្រសួងជំរុញការអនុវត្តកំណែទម្រង់ស៊ីជម្រៅវិស័យអប់រំកាយ និងកីឡា តាមរយៈការពង្រឹងការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា, ការពង្រឹងយន្តការដែលមានស្រាប់ រួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កីឡា ការបណ្តុះបណ្តាលធនធានមនុស្ស និងការលើកទឹកចិត្ត ដែលជាកត្តាចម្បងក្នុងការបង្កើនប្រសិទ្ធភាព និងគុណភាពនៃការត្រៀមខ្លួនរបស់អត្តពលិក, និងការពង្រឹងគុណភាពនៃការប្រកួតគ្រប់កម្រិត តាមរយៈការពង្រឹងសហព័ន្ធកីឡាជាតិ ការពង្រឹងការអនុវត្តកម្មវិធីអប់រំកាយ និងកីឡាក្នុងម៉ោងសិក្សា ការពង្រឹងការអនុវត្តកម្មវិធីកីឡាក្រៅម៉ោងសិក្សា។
- ក្រសួងជំរុញការលើកទឹកចិត្ត និងបណ្តុះវប្បធម៌អប់រំកាយ និងកីឡា ដល់ប្រជាជនឱ្យយល់ដឹងអំពីសារៈសំខាន់នៃការហាត់ប្រាណ និងលេងកីឡាជាប្រចាំ ដើម្បីសុខភាពផ្សារភ្ជាប់ទៅនឹងកិច្ចការសង្គម វប្បធម៌ ឈានទៅចូលរួមលុបបំបាត់ភាពអសកម្មផ្សេងៗក្នុងសង្គម ដើម្បីឱ្យប្រជាជនរស់នៅប្រកបដោយ ភាពស៊ីវិល័យ និងសុខដុមនីយកម្មក្នុងសង្គម។

## ២.២ អន្តរាគមន៍បញ្ហាឆ្លងវិស័យ

### ២.២.១ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំពេញមួយជីវិត

- ការប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- ការអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ និងសមត្ថភាពគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ
- ការសម្របសម្រួលអន្តរវិស័យ ដើម្បីអនុវត្តគោលនយោបាយស្តីពី ការអប់រំពេញមួយជីវិត។

### ២.២.២ កំណែទម្រង់រដ្ឋបាលសាធារណៈ

- ការពិនិត្យ និងកែសម្រួលឡើងវិញនូវគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពី ការគ្រប់គ្រងបុគ្គលិកអប់រំ
- ការអនុម័ត និងដាក់ឱ្យអនុវត្តក្របខណ្ឌយុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា
- ការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងបុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (បុគ្គលិកអប់រំ ផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ)
- ការពង្រឹងប្រសិទ្ធភាពនៃការបែងចែកផែនការក្របខ័ណ្ឌប្រចាំឆ្នាំ និងការអនុវត្តគោលការណ៍ស្តីពី ការប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀន

- ការរៀបចំគោលការណ៍ណែនាំ ក្នុងការពង្រាយនិងផ្លាស់ប្តូរទីកន្លែងរបស់គ្រូបង្រៀន ដើម្បីដោះស្រាយបញ្ហាលើស និងខ្វះគ្រូបង្រៀន
- ការដោះស្រាយកង្វះគ្រូបង្រៀនមុខវិជ្ជាបំណិនជីវិត និងកង្វះគ្រូបង្រៀនអប់រំបច្ចេកទេស
- ការប្រើប្រាស់ទិន្នន័យ និងប្រព័ន្ធ HRMIS ដើម្បីគ្រោងតម្រូវការគ្រូបង្រៀនកម្រិតសាលារៀន និងរាជធានី ខេត្ត
- ការពង្រាយគ្រូបង្រៀន និងការពង្រាយគ្រូឡើងវិញ
- ការអនុវត្តផែនការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនជាប្រចាំ
- ការសិក្សា និងកំណត់ឡើងវិញតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការផ្តល់ប្រាក់ឧបត្ថម្ភតំបន់ជួបការលំបាក និងដាច់ស្រយាល
- ការអនុវត្តប្រព័ន្ធលើកទឹកចិត្តផ្អែកលើសមិទ្ធកម្ម
- ការអនុវត្តប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិក
- ការអនុវត្តកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំ និងគ្រប់គ្រងអប់រំ
- ការអនុវត្តគន្លងអាជីពគ្រូបង្រៀន។

### ២.២.៣ ការងារសំណង់ និងហេដ្ឋារចនាសម្ព័ន្ធ

- ការរៀបចំស្តង់ដាហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត
- ការរៀបចំផែនទីសិក្សាសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំ
- ការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំ
- ការបំពាក់ឧបករណ៍ និងសម្ភារបរិក្ខារឌីជីថល នៅតាមគ្រឹះស្ថានសិក្សា
- ការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅថ្នាក់ក្រោមជាតិ
- ការធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ
- ការអភិវឌ្ឍសមត្ថភាពនៅតាមអង្គភាពប្រើប្រាស់អំពីលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំលើការងារគ្រប់គ្រងសម្ភារ និងទ្រព្យសម្បត្តិរដ្ឋ។

### ២.២.៤ ការអនុវត្តកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល

- ការពិនិត្យតាមដានការអនុវត្តកម្មវិធីសិក្សា នៅតាមគ្រឹះស្ថានសិក្សា
- ការបែងចែក និងគ្រប់គ្រងសៀវភៅសិក្សាគោល នៅតាមគ្រឹះស្ថានសិក្សា
- ការអនុវត្តកម្មវិធីសិក្សា និងម៉ោងសិក្សាពេញលេញ នៅតាមគ្រឹះស្ថានសិក្សាដែលមានសក្តានុពល
- ការរៀបចំក្រុមអ្នកនិពន្ធ អ្នករៀបរៀង ក្រុមពិនិត្យសៀវភៅសិក្សាគោល
- ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យយល់ដឹងពីកម្មវិធីសិក្សា។

### ២.២.៥ ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យអប់រំ

- ការរៀបចំថវិកាឆ្លើយតបនឹងគោលនយោបាយ និងអាទិភាព
- ការអនុវត្តថវិកាសមិទ្ធកម្មនៅតាមអង្គភាពថវិកា

- ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការយុទ្ធសាស្ត្រថវិកា ឆ្លើយតបនឹងគោលនយោបាយ
- ការអភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុនៅតាមអង្គភាព និងសាលារៀន
- ការអភិវឌ្ឍ និងការប្រើប្រាស់ប្រព័ន្ធ FMIS ក្នុងការគ្រប់គ្រង និងការគ្រោងថវិកា
- ថវិកាចំណាយចរន្តរបស់ក្រសួង មិនទាន់ឆ្លើយតបទៅនឹងសូចនាករគោលដៅ ២០ភាគរយ នៃចំណាយចរន្តថ្នាក់ជាតិ
- ការវិភាគការប្រើប្រាស់ ការបើកផ្តល់ និងប្រសិទ្ធភាពនៃថវិកាសាលារៀន ដើម្បីគាំទ្រដល់ការរៀន និងបង្រៀន
- អធិការកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព គណនេយ្យភាពសមិទ្ធកម្ម ឆ្លើយតបកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤
- ពង្រឹងអភិបាលកិច្ចល្អលើការគ្រប់គ្រង ការប្រព្រឹត្តតាមការណែនាំ និងការបំពេញការងារ ឆ្លើយតបកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។

### ២.២.៦ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ

- ការរៀបចំយន្តការគាំទ្រ និងឯកសារបច្ចេកទេសគាំទ្រការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ការរៀបចំសេចក្តីណែនាំស្តីពី គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡា ដែលបានប្រគល់ និងធ្វើប្រតិភូកម្មមុខងារគាំទ្រផ្នែករដ្ឋបាលទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការរៀបចំលក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងលក្ខខណ្ឌផ្សេងៗទៀតនៃការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ
- ការរៀបចំនីតិវិធីក្នុងការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ អនុវត្តមុខងារដែលបានប្រគល់ និងធ្វើប្រតិភូកម្ម
- ការរៀបចំនីតិវិធីដើម្បីកំណត់និងផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តមុខងារ ដែលបានប្រគល់ និងធ្វើប្រតិភូកម្ម
- ការរៀបចំនីតិវិធី ដើម្បីកំណត់ និងផ្ទេរបុគ្គលិកអប់រំដែលបម្រើការងារនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានសិក្សាបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ការរៀបចំគោលការណ៍ស្តីពី ការផ្លាស់ប្តូរទីកន្លែងបម្រើការងារ និងការផ្ទេរក្របខណ្ឌគ្រូបង្រៀន
- ការរៀបចំគោលការណ៍ស្តីពី ការតែងតាំង និងការបញ្ចប់មុខតំណែងនាយក នាយករងនៃគ្រឹះស្ថានសិក្សា មត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ
- ការរៀបចំគោលការណ៍ស្តីពី ការបង្កើត ការបិទ ការរំលាយបញ្ចូលគ្នា ការបំបែក ការប្រែក្លាយ និងការគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈនិងឯកជន និងការបង្កើត និងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍
- ការរៀបចំគោលការណ៍ ស្តីពី គណនេយ្យភាពរវាងគ្រឹះស្ថានសិក្សាសាធារណៈ រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងក្រសួងអប់រំ យុវជន និងកីឡា។

### ២.២.៧ ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

- បន្តរៀបចំច្បាប់ស្តីពីការអប់រំកាយ និងកីឡា និងលិខិតបទដ្ឋានអនុវត្តច្បាប់ស្តីពីការអប់រំកាយ និងកីឡា
- រៀបចំអនុក្រឹត្យស្តីពី ការគ្រប់គ្រងទារកដ្ឋាន
- រៀបចំលិខិតបទដ្ឋានប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- រៀបចំលិខិតបទដ្ឋានគតិយុត្តគាំទ្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាទៅតាមអនុវិស័យ
- កែសម្រួលព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនទាំងបីកម្រិត
- រៀបចំលិខិតបទដ្ឋានពាក់ព័ន្ធការរៀបចំនិងការប្រព្រឹត្តទៅរបស់គ្រឹះស្ថានសិក្សាសាធារណៈគ្រប់កម្រិត
- រៀបចំលិខិតបទដ្ឋានពាក់ព័ន្ធឋានានុក្រមរដ្ឋបាល និងការគ្រប់គ្រងអប់រំ
- រៀបចំប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន
- រៀបចំប្រកាសស្តីពីនីតិវិធីចុះកិច្ចសន្យា ឬកិច្ចព្រមព្រៀង
- រៀបចំលិខិតបទដ្ឋានពាក់ព័ន្ធការគ្រប់គ្រងយុវជន និងកុមារ។

## ២.៣ ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ

### ២.៣.១ ការងារពិនិត្យតាមដាន និងវាយតម្លៃ

- ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធី ឬគម្រោងរបស់រដ្ឋ និងដៃគូអភិវឌ្ឍ តាមដំណាក់កាល
- ការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាសមិទ្ធកម្មប្រចាំឆ្នាំ
- ការពិនិត្យតាមដាន និងវាយតម្លៃអាទិភាព និងកម្មវិធីកំណែទម្រង់វិស័យអប់រំ
- ការបង្កើនប្រសិទ្ធភាពនៃយន្តការពិនិត្យតាមដាន និងវាយតម្លៃរួមគ្នារវាងក្រសួង និងដៃគូពាក់ព័ន្ធ ដូចជា វិបស្សនាអប់រំ, សន្និបាតអប់រំ ។ល។

### ២.៣.២ ការងារធានាគុណភាព និងអធិការកិច្ចអប់រំ

- អធិការកិច្ចតាមប្រធានបទ
- អធិការកិច្ចសាលារៀនតាមកាលកំណត់របស់ការិយាល័យអធិការកិច្ច នៃមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តទាំង២៥
- ការធ្វើបច្ចុប្បន្នកម្មសៀវភៅបញ្ញត្តិនៃការធានាគុណភាពអប់រំកម្រិតមត្តេយ្យ និងមធ្យមសិក្សាចំណេះទូទៅនៅកម្ពុជា និងការរៀបចំសៀវភៅជំនួយស្មារតីអធិការកិច្ចផ្នែកមត្តេយ្យសិក្សា
- ការអភិវឌ្ឍសមត្ថភាពមន្ត្រីការិយាល័យអធិការកិច្ច ស្តីពីប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ សម្រាប់រាជធានី ខេត្ត
- ការអភិវឌ្ឍសមត្ថភាពក្រុមបំប៉ន ពិនិត្យតាមដាននិងវាយតម្លៃនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និង សាលារៀន ស្តីពីស្វ័យវាយតម្លៃសាលារៀន (អធិការកិច្ចផ្ទៃក្នុង)
- ការរៀបចំដំណើរការការងារអធិការកិច្ចតាមតំបន់
- ការអភិវឌ្ឍសមត្ថភាពគរុសិស្ស គរុនិស្សិត និងគ្រូបង្រៀនអំពី វង្វាយតម្លៃការសិក្សារបស់សិស្ស

- ការអភិវឌ្ឍសមត្ថភាពប្រព័ន្ធ និងបុគ្គលអំពីតេស្តវង្វាយតម្លៃការសិក្សារបស់សិស្ស ថ្នាក់ជាតិ, ថ្នាក់តំបន់ និងអន្តរជាតិ
- ការប្រើប្រាស់លទ្ធផលនៃតេស្តវង្វាយតម្លៃគ្រប់ប្រភេទ ដើម្បីកែលម្អប្រព័ន្ធអប់រំ និងការបង្រៀននិងរៀន
- ការរៀបចំ ឯកសារជំនួយស្មារតីស្តីពី ការអនុវត្តតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
- ការអនុវត្តវង្វាយតម្លៃការសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១
- ការអនុវត្តវង្វាយតម្លៃអំណាន និងគណិតវិទ្យាថ្នាក់ដំបូងថ្នាក់ជាតិ (EGRA-EGMA)
- ការអនុវត្តតេស្តវង្វាយតម្លៃការសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM)
- ការអនុវត្តកម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃការសិក្សារបស់សិស្ស (PISA)
- ការកែសម្រួលនីតិវិធីវាស់ស្ទង់សមត្ថភាពកម្រិតសមមូល
- ការរៀបចំស្តង់ដាវាយតម្លៃការអប់រំវិជ្ជាជីវៈ។

## ២.៤ ការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការដើម្បីគាំទ្រដល់កម្មវិធីកំណែទម្រង់

ដើម្បីគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៣-២០២៨ និងយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ យុវជន និងកីឡា រាជរដ្ឋាភិបាលនឹងបង្កើនការចំណាយមកលើក្រសួងអប់រំ យុវជន និងកីឡា។ ក្រៅពីថវិកាកម្មវិធីដែលជាបន្ទុករបស់រាជរដ្ឋាភិបាលហិរញ្ញប្បទានដៃគូអភិវឌ្ឍធំៗ នឹងចូលរួម ចំណែកផងដែរ ដូចជា ៖

### ១- គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP2)

ជាឥណទានកម្ចីរបស់រាជរដ្ឋាភិបាលកម្ពុជាពីធនាគារអភិវឌ្ឍន៍អាស៊ីមានថវិកា ៥៣,៥លានដុល្លារ (៥០ លានដុល្លារគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ី និង ៣,៥លានដុល្លារ ជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា) មានរយៈពេលអនុវត្ត ៥ឆ្នាំ (២០១៩-២០២៤)។ គម្រោងផ្តោតលើ ១).ការលើកកម្ពស់គុណភាព គ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិ ២).ការលើកកម្ពស់គុណភាពនិងការ ឆ្លើយតបទីផ្សារការងារនៃការអប់រំមធ្យមសិក្សាទុតិយភូមិ និង ៣).ការពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ការធ្វើផែនការការគ្រប់គ្រង និងការផ្តល់សេវាអប់រំ។

### ២- គម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP)

មានថវិកា ៧០,២៥លានដុល្លារ អាមេរិក ក្នុងនោះ ៦០លានដុល្លារ អាមេរិកជាហិរញ្ញប្បទានកម្ចីពីធនាគារពិភពលោក (IDA) និង៩,២៥លានដុល្លារអាមេរិកជាហិរញ្ញប្បទានឥតសំណង ពីមូលនិធិសាកលសម្រាប់ការអប់រំ (GPE) និង ១លានដុល្លារអាមេរិកជាបដិភាគរបស់រាជរដ្ឋាភិបាល មានរយៈពេលអនុវត្ត ៥ឆ្នាំ ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៦។ វត្ថុបំណងនៃគម្រោង គឺកែលម្អ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស កែលម្អគុណភាព និងសមធម៌ការអប់រំចំណេះទូទៅឲ្យ សម្រេចបានស្តង់ដាអប្បបរមា នៅតំបន់គោលដៅដែល កំពុងអនុវត្តដោយផ្តោតលើសាលាគោលដៅ ១ ៦៣៣សាលា ក្នុងនោះសាលាមត្តេយ្យ

សិក្សារដ្ឋ ២១៣សាលា បឋមសិក្សារដ្ឋ ១ ០០០ និងសាលាមធ្យមសិក្សារដ្ឋ ៤២០សាលា។ សាលារៀនគោលដៅទាំងនេះ មានទីតាំងស្ថិតនៅ ២០៣ ក្រុង ស្រុក ខណ្ឌ ក្នុង ២៥ រាជធានី ខេត្ត។

**៣- គម្រោងសម្រាប់ការបង្កើតវិស្វកម្មបរិស្ថាននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

ដើម្បីលើកកម្ពស់ធនធានមនុស្ស កម្រិតឧត្តមសិក្សានៅប្រទេសកម្ពុជា មានថវិកា ៦,៩លានដុល្លារអាមេរិក ជាជំនួយឥតសំណង ក្រោមការគាំទ្រពី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) អនុវត្តពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៦។ គម្រោងមានគោលបំណងបង្កើតប្រព័ន្ធអប់រំកម្រិតឧត្តមសិក្សាក្នុងជំនាញវិស្វកម្មបរិស្ថាននៅប្រទេសកម្ពុជា ដោយការបង្កើត និងដំណើរការដេប៉ាតឺម៉ង់វិស្វកម្មបរិស្ថាននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**៤-គម្រោងកសាងសមត្ថភាពបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិនៅប្រទេស កម្ពុជា**

ជាជំនួយឥតសំណងមានថវិកា ៧លានដុល្លារអាមេរិក អនុវត្តពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៦ គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ។ គោលបំណងលើកកម្ពស់គុណភាពការបណ្តុះបណ្តាលគ្រូមុខវិជ្ជាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ (ICT) និងការអប់រំមធ្យមសិក្សាបឋមភូមិ។ គម្រោងនេះមានសមាសធាតុផ្សំ៦ រួមមាន៖ ១)ការកែលម្អ បរិយាកាសបង្រៀនសម្រាប់គរុនិស្សិត និងគ្រូឧទ្ទេសនៅមជ្ឈមណ្ឌល គរុកោសល្យភូមិភាគ ២)ការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជា ICT និងសម្ភារឧបទេស ៣)កម្មវិធីកសាងសមត្ថភាពគ្រូឧទ្ទេស និងគ្រូតាមសាលារៀនគោលដៅ ៤)ការកែលម្អបរិយាកាសសិក្សាសម្រាប់សិស្ស និងគ្រូនៅតាមសាលារៀនគោលដៅ ៥)ការអភិវឌ្ឍកម្មវិធីសិក្សាមុខវិជ្ជា ICT និងសៀវភៅសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ និង ៦) ការពង្រឹងកម្មវិធីគាំទ្រការអប់រំមុខវិជ្ជា ICT ។

**៥- គម្រោងបង្កើតប្រព័ន្ធបណ្តុះធុរៈកិច្ចរវាងសាកលវិទ្យាល័យ និងឧស្សាហកម្មនៅកម្ពុជា**

មានថវិកា ៧,៩១លានដុល្លារអាមេរិក គាំទ្រដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) មានរយៈពេលអនុវត្តពីឆ្នាំ២០១៩ ដល់ឆ្នាំ ២០២៤ ដើម្បីកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យា និងពង្រឹងសមត្ថភាពប្រតិបត្តិការរបស់មជ្ឈមណ្ឌលសម្រាប់ការធ្វើឱ្យមានប្រព័ន្ធអេកូឡូស៊ីធុរកិច្ច តាមរយៈការបង្កើតប្រព័ន្ធបណ្តុះអាជីវកម្មនៅកម្ពុជា។

**៦-មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពជំណាក់កាលទី៣ (CDPF 3)**

មានថវិកា ៣២លានដុល្លារអាមេរិក ជាហិរញ្ញប្បទានឥតសំណងគាំទ្រដោយសហភាពអឺរ៉ុបរដ្ឋាភិបាលស៊ុយអែត អង្គការយូនីសេហ្វ មូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ (ផ្នែកអថេរមានទឹកប្រាក់ ៦,២ លាន ដុល្លារអាមេរិក) និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ មាន រយៈពេលអនុវត្តពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២៣។ មូលនិធិនេះសម្រាប់ពង្រឹងសមត្ថភាពមន្ត្រី និងស្ថាប័ន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការរៀបចំផែនការ ការពិនិត្យតាមដានការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយ និងកំណែទម្រង់។

**៧- គម្រោង "ការផ្តល់អាហារតាមសាលារៀនសម្រាប់ការអប់រំ"**

ទទួលមូលនិធិម៉ាក់ហ្គិនដូល នៃក្រសួងកសិកម្មសហរដ្ឋអាមេរិក (USDA/McGovern-Dole) តាមរយៈ កម្មវិធីស្បៀងអាហារពិភពលោក ចាប់ពីឆ្នាំ២០០១ រហូតដល់ឆ្នាំ២០២៣ បាន ៦ដំណាក់កាល ក្នុងទំហំទឹក ប្រាក់ ៨២,៩៨០,៥០១.០០ដុល្លារសហរដ្ឋអាមេរិក និងគ្រោងអនុវត្តដំណាក់កាលទី៧ ក្នុងទំហំទឹកប្រាក់ ២២,២៤៩,០៦២.០០ដុល្លារសហរដ្ឋអាមេរិក។

**៨. គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ (STEP-Up)**

ជាហិរញ្ញប្បទានកម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី (កិច្ចព្រមព្រៀងនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២) មានរយៈពេលអនុវត្ត ៦ឆ្នាំ ចាប់ពីឆ្នាំ២០២៣ និងមានហិរញ្ញប្បទានសរុប ៧៨,២៤លានដុល្លារសហរដ្ឋអាមេរិក (ធនាគារអភិវឌ្ឍន៍អាស៊ី ៧០លានដុល្លារ និងថវិកាបដិភាគពីរាជរដ្ឋាភិបាលកម្ពុជា ៨,២៤លានដុល្លារ)។ គម្រោងនេះផ្តោតលើលទ្ធផល៣គឺៈ ១).ពង្រីកការទទួលបានការសិក្សាមធ្យមសិក្សាទុតិយភូមិប្រកបដោយសមធម៌ និងស្តង់ដា ២).ពង្រឹងការរៀននិងការបង្រៀនវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ប្រកបដោយគុណភាព និង ៣).ពង្រឹងសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់សាលារៀន និងស្ថាប័ន ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពប្រកបដោយប្រសិទ្ធភាព។

## ៣. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល បញ្ហាប្រឈមមួយចំនួន ចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាប្រឈមទាំងនោះមានដូចជាៈ

### ការអប់រំកុមារតូចៈ

- ការចុះឈ្មោះចូលរៀនរបស់កុមារអាយុ៣ឆ្នាំ ទៅ ៥ឆ្នាំ គ្រប់រូបភាពនៅមានកម្រិត
- ការពង្រីកហេដ្ឋារចនាសម្ព័ន្ធកម្មវិធីអប់រំកុមារតូច មិនទាន់ឆ្លើយតបទៅនឹងតម្រូវការ
- ការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា និងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សាមិនទាន់បានពេញលេញ
- ការគាំពារ និងអភិវឌ្ឍកុមារតូចក្នុងវ័យ ១ ០០០ថ្ងៃដំបូង មិនទាន់ត្រូវបានយកចិត្តទុកដាក់
- សមត្ថភាពបុគ្គលិកអប់រំផ្នែកអប់រំកុមារតូចនៅមិនទាន់ឆ្លើយតបតាមក្របខណ្ឌគុណវុឌ្ឍិ។

### ការអប់រំបឋមសិក្សាៈ

- កង្វះគ្រូបង្រៀនប្រមាណមួយភាគបីនៃគ្រូបង្រៀនសរុប
- ការអនុវត្តកញ្ចប់សម្ភារអំណាន និងគណិតវិទ្យាថ្នាក់ដំបូង ព្រមទាំងកម្មវិធីប្រឹក្សាគរុកោសល្យទើបបានប្រមាណ២៨ភាគរយ នៃកម្រិតថ្នាក់ទី១ ទី២ និងទី៣ ទូទាំងប្រទេស
- សមត្ថភាពគ្រូបង្រៀនលើវិធីសាស្ត្របង្រៀនភាសាខ្មែរ គណិតវិទ្យា ការអប់រំស្នេម ភាសាបរទេស ICT ថ្នាក់ទី៤ ដល់ទី៦ នៅមានកម្រិត
- ការអនុវត្តការរៀន និងបង្រៀនតែមួយពេលមិនទាន់ឆ្លើយតបទៅនឹងស្តង់ដាអន្តរជាតិ
- ការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅមានទំហំតូចប្រមាណ ២២ភាគរយ នៃសាលាបឋមសិក្សាទូទាំងប្រទេស
- កង្វះអគារសិក្សា និងបន្ទប់សម្រាប់រៀបចំបណ្ណាល័យ បន្ទប់ពិសោធន៍ ទីចាត់ការ និងបន្ទប់កុំព្យូទ័រជាដើម

- កង្វះហេដ្ឋារចនាសម្ព័ន្ធសុខភាពសិក្សា និងការយល់ដឹងអំពីសុខភាពសិក្សានៅតាមសាលារៀន
- កង្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារបម្រើឱ្យការរៀននិងបង្រៀនពីចម្ងាយ និងការអប់រំឌីជីថល
- ការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ និងកម្មវិធីអាហារូបករណ៍ នៅមានទំហំមិនទាន់សមស្រប។

## ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស៖

- គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាង និងអគ្គិសនី ស្របតាមកម្មវិធីសិក្សា
- កង្វះមន្ត្រីជំនាញដែលមានសមត្ថភាពឆ្លើយតបទៅនឹងបរិវត្តកម្មអប់រំ
- សហគ្រាស កសិដ្ឋាន និងផ្នែកឯកជនពុំទាន់ផ្តល់កិច្ចសហការពេញលេញក្នុងការចុះកម្មសិក្សា និងទស្សនកិច្ចសិក្សា
- ការផ្សព្វផ្សាយស្តីពីកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មីៗ គោលវិធីស្ទែម និងវិធីសាស្ត្រល្អៗផ្សេងទៀត រួមទាំងវិធីសាស្ត្រតាក់តែងវិញ្ញាសា មិនទាន់បានទូលំទូលាយដល់គ្រូបង្រៀន។

## ការអប់រំឧត្តមសិក្សា៖

- គ្រូបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សាកម្រិតបណ្ឌិតមានត្រឹម ៨ភាគរយ
- កង្វះសមត្ថភាពអ្នកស្រាវជ្រាវស៊ីជម្រៅ ដើម្បីឆ្លើយតបទៅនឹងសង្គមឌីជីថល
- ខ្វះគោលការណ៍ប្រតិបត្តិសកម្មភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ បំពាក់មូលដ្ឋានសម្ភាររូបវន្ត និងសម្ភារបច្ចេកវិទ្យាចាំបាច់មិនទាន់ឆ្លើយតបទៅនឹងបច្ចុប្បន្នភាព
- សមត្ថភាពអ្នកគ្រប់គ្រង និងអ្នកបច្ចេកទេសនៅមានកម្រិត សម្រាប់កិច្ចដំណើរការបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា
- ការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងឧត្តមសិក្សាមិនទាន់បានល្អ
- ការអនុវត្តប្រព័ន្ធតាមដានស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាមិនទាន់បានរៀបចំជាក់លាក់ និងមានប្រសិទ្ធភាព
- ការចូលរៀនរបស់ក្រុមនិស្សិតជួបការលំបាកមានបញ្ហាប្រឈម ជាពិសេសនិស្សិតនារី។

## ការអប់រំក្រៅប្រព័ន្ធ៖

- កង្វះលិខិតបទដ្ឋានគតិយុត្ត និងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមមជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត
- សម្ភារគាំទ្រកម្មវិធីបណ្តុះបណ្តាល គ្រឿងសម្ភារឯកសណ្ឋានកាយរឹទ្ធិ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមមជ្ឈមណ្ឌលយុវជនមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់យុវជន
- សមត្ថភាពគ្រប់គ្រង ដឹកនាំកម្មវិធីយុវជន និងបំណិនឌីជីថលរបស់មន្ត្រីទទួលបន្ទុកការងារយុវជនមិនទាន់ឆ្លើយតបតម្រូវការនៃកម្មវិធីយុវជន។

**ការអភិវឌ្ឍយុវជននូវជំនាញបច្ចេកទេស និងជំនាញទន់៖**

- កង្វះលិខិតបទដ្ឋានគតិយុត្ត និងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមមជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត
- សម្ភារគាំទ្រកម្មវិធីបណ្តុះបណ្តាល គ្រឿងសម្ភារឯកសណ្ឋានកាយរឹទ្ធិ និងហេដ្ឋារចនាសម្ព័ន្ធនៅ តាមមជ្ឈមណ្ឌលយុវជនមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់យុវជន
- សមត្ថភាពគ្រប់គ្រង ដឹកនាំកម្មវិធីយុវជន និងបំណិនឌីជីថលរបស់មន្ត្រីទទួលបន្ទុកការងារយុវជនមិនទាន់ឆ្លើយតបតម្រូវការនៃកម្មវិធីយុវជន។

**កំណែទម្រង់ការអប់រំកាយនិងកីឡា៖**

- ហេដ្ឋារចនាសម្ព័ន្ធកីឡាមិនទាន់មាននៅតាមខេត្តដែលមានសក្តានុពល
- សមត្ថភាពមន្ត្រីជំនាញផ្នែកកីឡាកម្រិតខ្ពស់មួយចំនួននៅមានកម្រិត និងបរិមាណមិនទាន់គ្រប់គ្រាន់
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងស្ថិតិកីឡាមិនទាន់អនុវត្តបានពេញលេញ
- ការអនុវត្តកម្មវិធីអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សានៅតាមគ្រឹះស្ថានសិក្សាមួយ ចំនួនមិនទាន់អនុវត្តបានពេញលេញ។

## ៤. វិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល

ជារួម ដើម្បីចូលរួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ២០២៤-២០២៦ ឱ្យមានគុណភាព ត្រូវជានាការផ្សារភ្ជាប់ថវិកាទៅនឹងអាទិភាពគោលនយោបាយដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលថ្មីនីតិកាលទី៧នៃរដ្ឋសភា ស្របតាមគោលការណ៍ណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងក្នុងក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ត្រូវបន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម ខ្ពស់ ព្រមទាំងសុខមាលភាពដើម្បីផ្គត់ផ្គង់ពលករជំនាញប្រកបដោយផលិតភាពខ្ពស់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការទីផ្សារ។

ក្នុងពេលស្ថានភាពការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ២០២៣នេះ ដោយមានការគិតគូរក្នុងគោលដៅបង្កើនគុណភាព នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។ ជាពិសេស ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង កម្មវិធី សូចនាករសមិទ្ធកម្ម សម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធីសមស្របទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ជាពិសេសការរៀបចំផែនការនេះ ក៏ត្រូវផ្តោតលើសកម្មភាពអាទិភាពផងដែរ ដើម្បីគាំទ្រដល់ដំណើរការងារបង្រៀន និងរៀនពីចម្ងាយ តាមអនឡាញ និងតាមប្រព័ន្ធវីដេអូ តាមរយៈវិធីសាស្ត្របង្រៀនថ្មីៗ ក្នុងបរិបទការគ្រប់គ្រងតាមសាលារៀនសំដៅឈានទៅសម្រេចគោលនយោបាយអប់រំរបស់ក្រសួង។

លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០២៤-២០២៨ ដើម្បីចូលរួមចំណែកសម្រេចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០២៤-២០២៨ ក្នុងនោះការអភិវឌ្ឍមូលធនមនុស្សក្នុងនីតិកាលទី៧ បានបន្តផ្តោតលើ ១) ការពង្រឹងគុណភាពវិស័យអប់រំ

វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២) ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស តាមរយៈទស្សនាទាន " យុវជនមានជំនាញមួយយ៉ាងតិចប្រចាំជីវិត" ។

ក្នុងដំណាក់កាលនេះ ក្រសួងអប់រំ យុវជន និងកីឡាបានបន្តផ្ដោតលើអាទិភាពកំណែទម្រង់វិស័យអប់រំក្នុងនោះរួមមាន៖ (១) កំណែទម្រង់គោលនយោបាយកម្រិតថ្នាក់ជាតិ (២) កំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ និង (៣) កំណែទម្រង់កម្រិតសាលារៀន

ជាងនេះទៅទៀត ក្រសួងក៏កំពុងបន្តអនុវត្តកំណែទម្រង់គោលនយោបាយកម្រិតថ្នាក់ជាតិដែលក្នុងនោះរួមមាន៖ (១) ការអនុវត្តកំណែទម្រង់តាមសសរស្តម្ភទាំង៥ (២) ការអនុវត្តកម្មវិធីសិក្សាថ្មីនិងសៀវភៅសិក្សាគោល ដោយផ្ដោតលើវិធីសាស្ត្របង្រៀនថ្មី (៣) កំណែទម្រង់ការគ្រប់គ្រងអប់រំ និង(៤) កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ (៥)កំណែទម្រង់ការអប់រំគ្រូនៅតាមសាលាគរុកោសល្យ (៦) កំណែទម្រង់កម្រិតសាលារៀន (៧) កំណែទម្រង់កម្រិតឧត្តមសិក្សា (៨) កំណែទម្រង់ការអភិវឌ្ឍន៍យុវជន និង (៩) កំណែទម្រង់ការអប់រំកាយ និងកីឡា ជាពិសេស ក្រសួងអប់រំ យុវជន និងកីឡា ទើបតែបានកែសម្រួលគោលនយោបាយអប់រំទាំងពីរក្នុងគោលបំណងសំដៅ "*ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការ អភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា" និងពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់"* ដើម្បីធានាឱ្យការរៀបចំផែនការយុទ្ធសា- ស្ត្រថវិកានេះមានលក្ខណៈអនុវិស័យក្នុងការរួមចំណែកសម្រេចគោលនយោបាយរាជរដ្ឋាភិបាលផងដែរ។

គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាព ជាអាទិភាពរបស់ក្រសួងត្រូវបានសម្រួចដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធអប់រំមួយ ដែលធានាគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីសំណាក់ដៃគូអភិវឌ្ឍនិងអ្នកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ឱ្យអស់សក្តានុពលធនធានសរុប ដើម្បីឈានទៅអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

## II. គោលបំណងគោលនយោបាយ

ក្រសួងអប់រំ យុវជន និងកីឡាបានកែសម្រួលខ្លឹមសារដែលមានលក្ខណៈគ្របដណ្ដប់ជាអនុវិស័យលើគោលនយោបាយអប់រំ (១) ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា និង (២) ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ជាពិសេសគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួងអប់រំ យុវជន និងកីឡាមានគោលបំណងគោលនយោបាយ ដូចខាងក្រោម៖

<table>
<tr><th>គោលបំណងគោលនយោបាយ</th><th>បម្រើឱ្យគោលដៅយុទ្ធសាស្ត្រ និង វិធានការគោលនយោបាយ នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤</th><th>ស្ថិតនៅក្នុងវិស័យណាមួយ នៅក្នុងផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ</th></tr>
<tr><td>ទី១ ៖ ធានាឱ្យការអប់រំមាន គុណភាពប្រកបដោយសមធម៌បរិ-យាបន្ននិងលើកកម្ពស់ឱកាសក្នុង ការសិក្សាពេញមួយជីវិតសម្រាប់ ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និង ការលើកកម្ពស់វិស័យកីឡា។</td><td rowspan="2">ការអភិវឌ្ឍធនធានមនុស្ស សំដៅ លើកកម្ពស់ចំណេះដឹង ជំនាញ វិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាព ល្អ និងកាយសម្បទារឹងមាំតួនាទី ស្ត្រី និងកិច្ចគាំពារសង្គម។ ការអភិវឌ្ឍធនធានមនុស្សបន្ត ផ្តោតលើ ៖ ១) ការពង្រឹងគុណ ភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា ២)ការបណ្តុះ បណ្តាលជំនាញបច្ចេកទេស ៣) ការលើកកម្ពស់សេវាសុខភាព សាធារណៈ និងអាហារូបត្ថម្ភ និង ៤) ការពង្រឹងសមភាពយេនឌ័រ និងការ គាំពារសង្គម។</td><td rowspan="2">ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស</td></tr>
<tr><td>ទី២ ៖ ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជា អ្នកដឹកនាំនិងការគ្រប់គ្រងអប់រំ គ្រប់លំដាប់ថ្នាក់។</td></tr>
</table>

## III. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកម្មវិធីចំនួន៥ ដូចខាងក្រោម៖

**១. កម្មវិធីទី១៖** ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងមិនផ្លូវការ

**គោលបំណងនៃកម្មវិធី៖** ពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពសម្រាប់កុមារអាយុពី 0ឆ្នាំ ទៅក្រោម៦ឆ្នាំ បង្កើនការចូលរៀននិងពង្រឹងការរៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ នៅ កម្រិតអប់រំចំណេះទូទៅ បង្កើនអត្រាអក្ខរកម្មមនុស្សពេញវ័យ ផ្តល់ការអប់រំពហុភាសាដល់កុមារជន ជាតិដើមភាគតិច ផ្តល់ការអប់រំពិសេសដល់កុមារពិការ និងការអប់រំបំណិនជីវិតនៅតាមសាលា មធ្យមសិក្សា។

**២. កម្មវិធីទី២៖** ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ

**គោលបំណងនៃកម្មវិធី៖** អភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម។

**៣. កម្មវិធីទី៣៖** ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

**គោលបំណងនៃកម្មវិធី៖** អភិវឌ្ឍធនធានមនុស្សលើវិស័យអប់រំកាយ និងកីឡាប្រកបដោយគុណភាពប្រសិទ្ធភាព និងលើកកម្ពស់ការប្រកួតកីឡាគ្រប់ប្រភេទឱ្យមានគុណផលខ្ពស់។

**៤. កម្មវិធីទី៤៖** ការអភិវឌ្ឍយុវជន

**គោលបំណងនៃកម្មវិធី៖** អនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា និងឆ្លើយតបតាមតម្រូវការចំបាច់របស់យុវជន។

**៥. កម្មវិធីទី៥៖** ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ

**គោលបំណងនៃកម្មវិធី៖** ពង្រឹងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលការងារវិមជ្ឈការនិងវិសហមជ្ឈការ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

| កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និងអង្គភាពទទួលខុសត្រូវ | | | | | | |
|---|---|---|---|---|---|---|
| **គោលបំណងគោលនយោបាយ** | **ឈ្មោះកម្មវិធី និងអនុកម្មវិធី** | **អ្នកគ្រប់គ្រង** | **អង្គភាពទទួលខុសត្រូវ** | | | |
| ទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា | **កម្មវិធី ទី ១** | **អគ្គនាយក** | **អគ្គនាយកដ្ឋានអប់រំ** | (១) | (២) | (៣) |
| | អនុកម្មវិធី ១.១ | ប្រធាននាយកដ្ឋាន | នា. អប់រំកុមារតូច | | ✓ | |
| | អនុកម្មវិធី ១.២ | ប្រធាននាយកដ្ឋាន | នា. បឋមសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៣ | ប្រធាននាយកដ្ឋាន | នា. មធ្យមសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៤ | ប្រធាននាយកដ្ឋាន | នា. អប់រំក្រៅប្រព័ន្ធ | | ✓ | |
| | អនុកម្មវិធី ១.៥ | ប្រធាននាយកដ្ឋាន | នា. សុខភាពសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៦ | ប្រធាននាយកដ្ឋាន | នា. តម្រង់ទិសវិជ្ជាជីវៈ | | ✓ | |
| | អនុកម្មវិធី ១.៧ | ប្រធាននាយកដ្ឋាន | នា. បណ្តុះបណ្តាល និងក្រឹត្យការ | | ✓ | |
| | អនុកម្មវិធី ១.៨ | ប្រធាននាយកដ្ឋាន | នា. អភិវឌ្ឍកម្មវិធីសិក្សា | | ✓ | |
| | អនុកម្មវិធី ១.៩ | ប្រធាននាយកដ្ឋាន | នា.អប់រំពិសេស | | ✓ | |
| ទី២៖ ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ | **កម្មវិធីទី ២** | **អគ្គនាយក** | **អគ្គនាយកដ្ឋានឧត្តមសិក្សា** | | | |
| | អនុកម្មវិធី ២.១ | ប្រធាននាយកដ្ឋាន | នា. ឧត្តមសិក្សា | | ✓ | |
| | អនុកម្មវិធី ២.២ | ប្រធាននាយកដ្ឋាន | នា. ស្រាវជ្រាវវិទ្យាសាស្ត្រ | | ✓ | |
| | អនុកម្មវិធី ២.៣ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ✓ | | |
| | អនុកម្មវិធី ២.៤ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យត្បូងឃ្មុំ | | | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធី ២.៥ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិ ជាស៊ីម កំចាយមារ | ✓ | | |
| | អនុកម្មវិធី ២.៦ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ✓ | | |
| | អនុកម្មវិធី ២.៧ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានជាតិអប់រំ | ✓ | | |
| | អនុកម្មវិធី ២.៨ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យស្វាយរៀង | ✓ | | |
| | អនុកម្មវិធី ២.៩ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិមានជ័យ | ✓ | | |
| | អនុកម្មវិធី ២.១០ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិបាត់ដំបង | ✓ | | |
| | អនុកម្មវិធី ២.១១ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យជាតិគ្រប់គ្រង | ✓ | | |
| | អនុកម្មវិធី ២.១២ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច | ✓ | | |
| | អនុកម្មវិធី ២.១៣ | អគ្គលេខាធិការ | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ✓ | | |
| | អនុកម្មវិធី ២.១៤ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | | ✓ | |
| | អនុកម្មវិធី ២.១៥ | សាកលវិទ្យាធិការ | សាកលវិទ្យាល័យក្រចេះ | | | ✓ |
| | អនុកម្មវិធី ២.១៦ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | | ✓ | |
| | អនុកម្មវិធី ២.១៧ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | | ✓ | |
| | អនុកម្មវិធី ២.១៨ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | | ✓ | |
| | **កម្មវិធីទី ៣** | **អគ្គនាយក** | **អគ្គនាយកដ្ឋានកីឡា** | | ✓ | |
| | អនុកម្មវិធី ៣.១ | ប្រធាននាយកដ្ឋាន | នា. អប់រំកាយ និងកីឡា | | | ✓ |
| | អនុកម្មវិធី ៣.២ | ប្រធាននាយកដ្ឋាន | នា. អប់រំកាយ និងកីឡាសិស្ស និស្សិត | | | ✓ |
| | អនុកម្មវិធី ៣.៣ | នាយកវិទ្យាស្ថាន | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | | | ✓ |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធី ៣.៤ | ប្រធានមជ្ឈមណ្ឌល | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | | | ✓ |
| | អនុកម្មវិធី ៣.៥ | ប្រធាននាយកដ្ឋាន | នា.រៀបចំនិងគ្រប់គ្រងព្រឹត្តិការណ៍កីឡា | | | ✓ |
| | អនុកម្មវិធី ៣.៦ | ប្រធានមជ្ឈមណ្ឌល | មជ្ឈមណ្ឌលជាតិព័ត៌មានវិទ្យា និងស្ថិតិកីឡា | | | ✓ |
| | **កម្មវិធីទី ៤** | **អគ្គនាយក** | **អគ្គនាយកដ្ឋានយុវជន** | | ✓ | |
| | អនុកម្មវិធី ៤.១ | ប្រធាននាយកដ្ឋាន | នា. យុវជន | | | ✓ |
| | អនុកម្មវិធី ៤.២ | ប្រធាននាយកដ្ឋាន | នា. គ្រប់គ្រងមជ្ឈមណ្ឌលយុវជន | | | ✓ |
| | អនុកម្មវិធី ៤.៣ | ប្រធាននាយកដ្ឋាន | នា.សហប្រតិបត្តិការកាយរឹទ្ធិ | | | ✓ |
| | **កម្មវិធីទី ៥** | **អគ្គនាយក** | **អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ** | | | |
| | អនុកម្មវិធី ៥.១ | ប្រធាននាយកដ្ឋាន | នា. ផែនការ | | | ✓ |
| | អនុកម្មវិធី ៥.២ | ប្រធាននាយកដ្ឋាន | នា. បុគ្គលិក | | ✓ | |
| | អនុកម្មវិធី ៥.៣ | ប្រធាននាយកដ្ឋាន | នា. ហិរញ្ញវត្ថុ | | ✓ | |
| | អនុកម្មវិធី ៥.៤ | ប្រធាននាយកដ្ឋាន | នា. សវនកម្មផ្ទៃក្នុង | | ✓ | |
| | អនុកម្មវិធី ៥.៥ | ប្រធាននាយកដ្ឋាន | នា. ធានាគុណភាពអប់រំ | | ✓ | |
| | អនុកម្មវិធី ៥.៦ | ប្រធាននាយកដ្ឋាន | អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | | ✓ | |
| | អនុកម្មវិធី ៥.៧ | ប្រធាននាយកដ្ឋាន | នា. ព័ត៌មាន និងកិច្ចការអាស៊ាន | | ✓ | |
| | អនុកម្មវិធី ៥.៨ | ប្រធាននាយកដ្ឋាន | នា. នីតិកម្ម | | ✓ | |
| | អនុកម្មវិធី ៥.៩ | ប្រធាននាយកដ្ឋាន | នា. សំណង់ | | ✓ | |
| | អនុកម្មវិធី ៥.១០ | ប្រធាននាយកដ្ឋាន | នា. សម្ភារ និងទ្រព្យសម្បត្តិរដ្ឋ | | ✓ | |
| | អនុកម្មវិធី ៥.១១ | ប្រធាននាយកដ្ឋាន | នា. រដ្ឋបាល | | ✓ | |

| | | | | | | |
|---|---|---|---|---|---|---|
| | អនុកម្មវិធី ៥.១២ | ប្រធាននាយកដ្ឋាន | នា. ទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ | | ✓ | |
| | អនុកម្មវិធី ៥.១៣ | ប្រធាននាយកដ្ឋាន | នា.ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | | | ✓ |
| | អនុកម្មវិធី ៥.១៤ | ប្រធាននាយកដ្ឋាន | នា.គោលនយោបាយ | | | ✓ |
| | អនុកម្មវិធី ៥.១៥ | ប្រធាននាយកដ្ឋាន | នា.ពិនិត្យតាមដាន និងវាយតម្លៃ | | | ✓ |
| | អនុកម្មវិធី ៥.១៦ | ប្រធាននាយកដ្ឋាន | នា. បច្ចេកវិទ្យាព័ត៌មាន | | ✓ | |
| | អនុកម្មវិធី ៥.១៧ | ប្រធាននាយកដ្ឋាន | នា. កិច្ចការប្រឡង | | | ✓ |

បានឃើញ និងឯកភាព
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

បានឃើញ និងពិនិត្យត្រឹមត្រូវ
**អគ្គនាយកគោលនយោបាយ និងផែនការ**

**លីម សុធា**

ថ្ងៃ ចន្ទ ១៥ រោច ខែ បឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣
**រៀបចំដោយ**

**ចាន់ សេដ្ឋារ័ត្ន**

## IV. ការកំណត់រចនាសម្ព័ន្ធថវិកាសមិទ្ធកម្ម

### ក. ការកំណត់សូចនាករសមិទ្ធកម្ម និងគោលដៅ

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់សូចនាករសមិទ្ធកម្មនិងគោលដៅ ដើម្បីតាមដានវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តកម្មវិធី អនុកម្មវិធី និង គោលបំណង គោល នយោបាយនីមួយៗដូចខាងក្រោមៈ

**សូចនាករសមិទ្ធកម្ម និងគោលដៅនៃកម្មវិធី និងអនុកម្មវិធី**

| **សេចក្ដីពណ៌នា** (**បន្ថែមជួរដេកមួយសម្រាប់សូចនាករលទ្ធផលចុងក្រោយ និងសូចនាករលទ្ធផលក្នុងឆ្នាំនីមួយៗ**) | **ឆ្នាំគ្រោងថវិកា** ២០២៤ (លានរៀល) | **គោលដៅសូចនាករសមិទ្ធកម្ម** | | | | | |
|---|---|---|---|---|---|---|---|
| | | **ឆ្នាំមុន*** (២០២២) | **ឆ្នាំបច្ចុប្បន្ន** (២០២៣) | **ឆ្នាំគ្រោងថវិកា** (២០២៤) | | **ឆ្នាំគ្រោងថវិកា** (២០២៥) | **ឆ្នាំគ្រោងថវិកា** (២០២៦) |
| | | | | **គោលដៅ** | **មូលហេតុនៃការផ្លាស់ប្ដូរ** (**ធៀបនឹងគោលដៅឆ្នាំ ២០២៣**) | | |
| *គោលបំណងគោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាស ក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា* | | | | | | | |
| *គោលបំណងគោលនយោបាយទី២៖ ពង្រឹងសមត្ថភាពស្ថាប័នដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់* | | | | | | | |
| កម្មវិធីទី ១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ | ៨៥,០៣៦ | | | | | | |
| សូចនាករលទ្ធផលចុងក្រោយ ១.១៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាព (មត្តេយ្យសិក្សារដ្ឋ សហគមន៍ និងឯកជន) | | ៦០% | ៦៥% | ៦៨% | ពង្រឹងការអនុវត្តប្រកាសលេខ ១៤៥៤ អយក.ប្រក, ចុះថ្ងៃទី១០ សីហា ២០២២ ស្ដីពីការបើកមត្តេយ្យសិក្សានៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ | ៧១% | ៧៤% |
| សូចនាករលទ្ធផលចុងក្រោយ ១.២៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | ៩២% | ៨៧% | ៨៨% | គោលដៅឆ្នាំ២០២៣សម្រេចបានត្រឹមតែ ៨៦.៨% | ៩១% | ៩៣% |
| សូចនាករលទ្ធផលចុងក្រោយ ១.៣៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | ៥៧% | ៦០% | ៦៣% | | ៦៦% | ៦៩% |
| សូចនាករលទ្ធផលចុងក្រោយ ១.៤៖ អត្រាអក្ខរកម្មពេញវ័យ (អាយុ១៥ ឆ្នាំឡើង) | | ៨៥% | ៨៧% | ៩០% | | ៩២% | ៩៥% |
| **អនុកម្មវិធីទី ១.១៖ ការពង្រីកការអប់រំកុមារតូច** | ១៤,៨៧០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ក៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ នៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងឯកជន | | ៦០% | ៦៥% | ៦៨% | ពង្រឹងការអនុវត្តប្រកាសលេខ ១៤៥៤ អយក.ប្រក, ចុះថ្ងៃទី១០ សីហា ២០២២ ស្ដីពីការបើកមត្តេយ្យសិក្សានៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ | ៧០% | ៧៣% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ខ៖ អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សារដ្ឋមត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន | | ៣៤% | ៣៧% | ៣៩% | ពង្រឹងការអនុវត្តប្រកាសលេខ ១៤៥៤ អយក.ប្រក, ចុះថ្ងៃទី១០ សីហា ២០២២ ស្ដីពីការបើកមត្តេយ្យសិក្សានៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ | ៤១% | ៤៣% |
| ច.ស.ក.ទី១ ៖ គាំពារនិងការអភិវឌ្ឍកុមារតូច | ១៤,៧១០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ក៖ ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា | | ១,២៥០ | ១,៣០៥ | ១,៤៣៨ | អនុលោមតាមសូចនាករផលសម្រេចនិងចំណុចដៅរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ ស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ និងការធ្វើចំណោលដល់ឆ្នាំ២០២៥ | ១,៥០០ | ១,៦៥០ |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអនុវិស័យអប់រំកុមារតូច | ១៦០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ក៖ ចំនួនសាលាមត្តេយ្យសិក្សាដែលទទួលការគាំទ្របន្ថែមលើការអភិវឌ្ឍសាលារៀន | | មិនទាន់អនុវត្ត | ១០ | ២០ | អនុសាសន៍គន្លឹះស្មារតីនៃសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២១-២០២២ និងទិសដៅឆ្នាំសិក្សា២០២២-២០២៣ | ៣០ | ៤០ |
| **អនុកម្មវិធីទី ១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា** | ១៧,៥៥២ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.កៈ អត្រាពិតនៃការសិក្សា | | ៩៣% | ៩៦% | ៩៦% | | ៩៧% | ៩៧% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.ខៈ អត្រាត្រួតថ្នាក់ | | ៨% | ៦% | ៥% | | ៤% | ៣% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.គៈ អត្រាបោះបង់ការសិក្សា | | ៧% | ៨% | ៦% | | ៥% | ៤% |
| ច.ស.ក.ទី១ ៖ អភិវឌ្ឍការអប់រំបឋមសិក្សា ដើម្បីធានាឱ្យការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន | ១២,៧៨៦ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.១.ក ៖ ចំនួនបុគ្គលិកអប់រំបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែមលើវិធីសាស្ត្ររៀននិងបង្រៀន | | ១០,៧៩៣ | ១៣,៩៥៤ | ១០,០០០ | | ១០,០០០ | ១០,០០០ |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំបឋមសិក្សា | ៤,៧៦៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.២.កៈ ចំនួនមន្ត្រីអប់រំបឋមសិក្សាបានទទួលការបំប៉នសមត្ថភាពលើការគាំទ្រការគ្រប់គ្រងតាមសាលារៀន | | ៥២០ | ២,៥២០ | ២,៦០០ | | ២,៦០០ | ២,៦០០ |
| **អនុកម្មវិធីទី ១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា** | ៦,៦១៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.កៈ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | ៦៩% | ៦៥% | ៦៨% | | ៧១% | ៧៤% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ខៈ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | ៣៩% | ៤៤% | ៤៥% | | ៤៨% | ៥១% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.គៈ អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ | | ៧៨% | ៨៤% | ៨៥% | | ៨៧% | ៨៩% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ឃៈ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | ៥៧% | ៦០% | ៦២% | | ៦៤% | ៦៧% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ងៈ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | ១៧% | ១៨% | ១៦% | | ១៤% | ១២% |
| ច.ស.ក.ទី១ ៖ បង្កើនការចូលរៀននៅមធ្យមសិក្សា និង ជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរ និងរៀនចប់នៅមធ្យមសិក្សា | ៦,៥៨៨ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.កៈ ចំនួនភ្នាក់ងារផ្លាស់ប្តូរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកម្មវិធីការគ្រប់គ្រងតាមសាលារៀន | | ១០០ នាក់ | ៤៥០ នាក់ | ៤៥០ នាក់ | | ៤៥០ នាក់ | ៤៥០ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.ខៈ ភាគរយបេក្ខជនប្រឡងជាប់សញ្ញាបត្រថ្នាក់ពីរភាសា បារាំង-ខ្មែរ | | បឋមភូមិ ៧៦,១%<br>ទុតិយភូមិ ៨០,៤% | បឋមភូមិ<br>៧៦,២% | បឋមភូមិ<br>៧៦,៩% | | បឋមភូមិ ៧៧,១%<br>ទុតិយភូមិ ៨១,៥% | បឋមភូមិ<br>៧៦,៤% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.គៈ ចំនួនសាលារៀនបានចុះជួយ (ពិនិត្យតាមដាន និងវាយតម្លៃ) | | ១០០ សាលា | ១០០ សាលា | ១៥០ សាលា | | ១៥០ សាលា | ១៥០ សាលា |
| ច.ស.ក.ទី២ ៖ លើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងក្រោមជាតិ | ២៦ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.២.កៈ ចំនួនសាលារៀនជំនាន់ថ្មី | | ៧ | ៧ | ៧ | ៧ | ៧ | ៧ |
| **អនុកម្មវិធីទី ១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ** | ២,០១២ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.កៈ ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | | ១៥,១២២ | ១៥,៥០០ | ១៥,៩០០ | ពង្រីកថ្នាក់អក្ខរកម្មតាមរោងចក្រសិប្បកម្ម និងពន្ធនាគារ | ១៦,១០០ | ១៦,៣០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ខៈ ចំនួនសិស្សបានបញ្ចប់ថ្នាក់កម្មវិធីសមមូល | | ២,៩៦១ | ៣,១០០ | ៣,៤០០ | ចំនួនថ្នាក់កើនឡើង | ៣,៥០០ | ៣,៦០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.គៈ ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | | ៨,៣២២ | ៨,៥០០ | ៤,៨៦៥ | អត្រាសិស្សបោះបង់នៅបឋមសិក្សា ៧,២% (២០២១-២០២២) | ៧,០២៤ | ៧,០២៤ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ឃ៖ ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរ | | ៩,៥៣៤ | ៩,៥០០ | ៩,៤៩០ | បំពាក់សម្ភារៈ និងបង្កើនថ្នាក់ជំនាញមុខរបរងាយៗ | ១០,២៩០ | ១១,០៩០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ង៖ ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលសមត្ថភាព ស្តីពីការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | | ២៦៥ | ៣០០ | ៣០០ | បង្កើនសមត្ថភាពមន្ត្រី | ៣០០ | ៣០០ |
| ច.ស.ក.ទី១ ៖ អភិវឌ្ឍការអប់រំក្រៅប្រព័ន្ធ | ១,២៦៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ក៖ ចំនួនកម្មករ-កម្មការិនីដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមរោងចក្រសហគ្រាស តាមសហគមន៍ ពន្ធធនាគារ និងមណ្ឌលកែប្រែ | | ១៥,១២២ | ១៥,៥០០ | ១៥,៩០០ | ពង្រីកថ្នាក់អក្ខរកម្មតាមរោងចក្រ សិប្បកម្ម និងពន្ធនាគារ | ១៦,១០០ | ១៦,៣០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ខ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលបឋមសិក្សា និងសមមូលមធ្យមសិក្សា | | ២,៩៦១ | ៣,១០០ | ៣,៤០០ | ចំនួនថ្នាក់កើនឡើង | ៣,៥០០ | ៣,៦០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.គ៖ចំនួនកុមារដែលបានបញ្ជូនចូលរៀនសាលាចំណោះទូទៅក្នុងប្រព័ន្ធ | | ៨,៣២២ | ៨,៥០០ | ៤,៨៦៤ | អត្រាសិស្សបោះបង់នៅបឋមសិក្សា ៧,២% (២០២១-២០២២) | ៧,០២៤ | ៧,០២៤ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ឃ៖ ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរ | | ៩,៥៣៤ | ៩,៥០០ | ៩,៤៩០ | បំពាក់សម្ភារៈ និងបង្កើនថ្នាក់ជំនាញមុខរបរងាយៗ | ១០,២៩០ | ១១,០៩០ |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពបុគ្គលិកអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ | ៧៤៧ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.២.ក៖ ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | | ១៦៥ | ៣០០ | ៣០០ | បង្កើនសមត្ថភាពមន្ត្រី | ៣០០ | ៣០០ |
| **អនុកម្មវិធីទី ១.៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា** | ១,១៥២ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ក៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ១ (ចំណាត់ថ្នាក់ផ្កាយ ១) | | ៣២% | | ៣០% | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ខ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ២ (ចំណាត់ថ្នាក់ផ្កាយ ២) | | ៤១% | | ៤០% | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.គ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ៣ (ចំណាត់ថ្នាក់ផ្កាយ៣) | | ៦% | | ៣% | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ឃ៖ ភាគរយសាលារៀនមានបង្គន់អនាម័យ | | ១០០% | | ១០០% | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ង៖ ភាគរយសាលារៀនមានទឹកស្អាត | | ៨៧% | | ៩៥% | | | |
| ច.ស.ក.ទី១ ៖ លើកកម្ពស់សុខភាពសិក្សា | ៧៤៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិត មន្ត្រីតែងតាំងស៊ីប់ និងនិស្សិតជាប់អាហារូបករណ៍បានពិនិត្យសុខភាព និងកាយសម្បទា | | ៨២៤ | ៨៨៥ | ៦០០ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ខ៖ ចំនួនគ្រឹះស្ថានសិក្សាចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា | | ៩ រាជធានី ខេត្ត | ៧ រាជធានី ខេត្ត | ១៥ រាជធានី ខេត្ត | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.គ៖ ចំនួនមន្ត្រីបានចូលរួម សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន និងកិច្ចប្រជុំ ក្នុងនិងក្រៅប្រទេស | | ២៤៦ | ២៦៩ | ៧៥០ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ឃ៖ ចំនួនសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព( ស.ភ.សិស្ស និងស.ភ.គ្រូ) បានបោះពុម្ពតាមកម្រិតថ្នាក់ | | N/A | ៧៩,១៥២ | ១,៣៦០,០០០ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ច.ស.ក.ទី២ ៖ អភិវឌ្ឍស្ថាប័ននិងសមត្ថភាពមន្ត្រីសុខភាពសិក្សាគ្រប់លំដាប់ថ្នាក់ | ៤០៩ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.ក៖ ចំនួនមន្ត្រីសុខភាពសិក្សាថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ បានចូលរួមការអប់រំផ្សព្វផ្សាយអំពីការលើកកម្ពស់សុខភាពសិក្សា | | ៥,៧៩៩ | ១,៣២០ | ៥០០ | | ៥០០ | ៥០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.ខ៖ ចំនួនសិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សា បានចូលរួមការអប់រំផ្សព្វផ្សាយការអប់រំសុខភាព និងប្រធានបទសុខភាពសាធារណៈ | | ៧,៨៦៧ | ២,១៥៣ | ២,០០០ | | ២,០០០ | ២,០០០ |
| **អនុកម្មវិធីទី ១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស** | ៧,០៥៧ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.ក៖ ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដែលផ្តល់សេវាអប់រំបច្ចេកទេស | | ១៨ | ១៩ | ១៩ | តម្រូវការសាលាបន្ថែម | ២០ | ២១ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.ខ៖ ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សា | | ១១៥ | ១១៥ | ១២០ | គ្មានថវិកា | ១២៥ | ១៣០ |
| ច.ស.ក.ទី១ ៖ អភិវឌ្ឍការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត អប់រំតម្រង់ទិសវិជ្ជាជីវៈ និងប្រឹក្សាអាជីព | ៧,០២៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ក៖ ចំនួនសិស្សផ្នែកអប់រំបច្ចេកទេសដែលចូលរៀននៅគ្រឹះស្ថានផ្តល់សេវាអប់រំបច្ចេកទេសកម្រិត៩+៣ កើនឡើង | | ៣,២៩៤ | ៣,២៥៩ | ៤,៨២៤ | ពង្រីកជំនាញបន្ថែម ការផ្សព្វផ្សាយបានទូលំទូលាយ | ៥,៣២៤ | ៥,៦២៤ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ខ៖ ចំនួនសិស្សទទួលបានសេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា | | ២០,៩១៥ | ២៩,២៩៩ | ៣១,៧៩៩ | គ្មាន | ៣៤,២៩៩ | ៣៦,៧៩៩ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.គ៖ ចំនួនគ្រឹះស្ថានមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឯកសារណែនាំស្តីពីការជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម ឬជំនាញបច្ចេកទេសវិជ្ជាជីវៈ | | ០ | ៩៨ | ១០០ | គោលដៅខេត្តផ្សេងៗ | ៩៩ | ៩៩ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ឃ៖ ចំនួនសាលាមធ្យមសិក្សាអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា | | | | ៩២៣ | | ១,១០៣ | ១,១០៣ |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | ៣៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៦.២.ក៖ ចំនួនបុគ្គលិកអប់រំ ទទួលបានការអភិវឌ្ឍសមត្ថភាពក្នុងប្រទេស និងក្រៅប្រទេស | | ០ | ២ | ៣ | តម្រូវការអភិវឌ្ឍសមត្ថភាព | ៤ | ៥ |
| **អនុកម្មវិធីទី ១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងក្រើតការគ្រូបង្រៀន** | ៨,១៣៩ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.ក៖ ចំនួនគរុសិស្ស គរុនិស្សិតបានទទួលការបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | | ៣,៣២៨ | ២,៧០៧ | ២,៤៨៨ | គរុនិស្សិតឆ្នាំទី៤ ប្រឡងបញ្ចប់ | ៤,៤៧៦ | ៤,៤៧៤ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.ខ៖ ចំនួនមន្ត្រីគ្រប់គ្រងអប់រំ និងនាយក នាយករង គ្រូឧទ្ទេស គ្រូបង្រៀនបឋមសិក្សា មធ្យមសិក្សាចំណេះទូទៅបានទទួលការលើកកម្ពស់សមត្ថភាព | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.គ៖ ចំនួនគណៈគ្រប់គ្រងសាលារៀន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គ្រូបង្រៀន និងគ្រូឧទ្ទេសបានដំឡើងគុណវុឌ្ឍិ | | | | | | | |
| ច.ស.ក.ទី១ ៖ ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន | ៦,៩៣៧ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិតត្រូវបានជ្រើសរើសតាមប្រព័ន្ធ ១២+២ និង ១២+៤ និងទទួលការបណ្តុះបណ្តាល នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន | | ៣,៣២៨ | ២,៧០៧ | ២,៤៨៨ | គរុនិស្សិតឆ្នាំទី៤ ប្រឡងបញ្ចប់ | ៤,៤៧៦ | ៤,៤៧៤ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.១.ខ៖ ចំនួនគរុសិស្ស គរុនិស្សិតត្រូវបានពិនិត្យតាមដានការ អនុវត្តកម្មសិក្សាគរុកោសល្យ | | | | ១,៤៩០ | សូចនាករថ្មី | ២,៩៨០ | ២,៩៨០ |
| ច.ស.ក.ទី២ ៖ លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងគុណវុឌ្ឍិ គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគ្រូបង្រៀន | ១,២០៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.ក៖ ចំនួននាយកសាលារៀនចំណេះទូទៅបានទទួលការ បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | | ៥០ | ៥៤ | ៤០ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.ខ៖ ចំនួនមន្ត្រីអប់រំ គ្រូឧទ្ទេស និងគ្រូបង្រៀនទទួលបានការលើកកម្ពស់សមត្ថភាព | | ៣៤៤ | ១៩៦ | ៦៤៨ | បំប៉នឯកសារណែនាំស្តីពីការអនុវត្តកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីត | ៨៣៤ | ៧៦១ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.គ៖ ចំនួនគណៈគ្រប់គ្រងសាលារៀន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គ្រូបង្រៀន និងគ្រូឧទ្ទេស ចូលរួមវគ្គវិក្រឹតការដើម្បីដំឡើងគុណវុឌ្ឍិ | | ០ | ០ | | | | |
| **អនុកម្មវិធីទី ១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារៈសិក្សា និងបណ្ណាល័យ** | ២៧,២៧៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.ក៖ ចំនួនសៀវភៅសិក្សាគោលត្រូវបានផ្គត់ផ្គង់សម្រាប់សិស្សថ្នាក់ទី១ ដល់ទី១២ | | ៥លាន ច្បាប់ | ៥លាន ច្បាប់ | ៥លាន ច្បាប់ | ឯកសារមួយចំនួនត្រូវប្តូរពីព៌ណសខ្មៅ ទៅជាពណ៌ធម្មជាតិ | ៥លាន ច្បាប់ | ៥លាន ច្បាប់ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.ខ៖ ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យ និង សម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា | | ៧៥ នាក់ | ៧៥ នាក់ | ៧៨ នាក់ | បង្កើនវិញ្ញាសាមួយទៀត | ៧៨ នាក់ | ៧៨ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.គ៖ ចំនួនឯកសារគរុកោសល្យនិងកម្មវិធីសិក្សា | | ៧ ចំណងជើង | ២ ចំណងជើង | ២ ចំណងជើង | បានរៀបចំហើយ | ២ ចំណងជើង | ២ ចំណងជើង |
| ច.ស.ក.ទី១ ៖ អភិវឌ្ឍ ផ្សព្វផ្សាយ និងពិនិត្យតាមដានកម្មវិធីសិក្សា សម្ភារសិក្សា ឯកសារគរុកោសល្យ និងការងារបណ្ណាល័យ | ២៧,២៣៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ក៖ ចំនួនសៀវភៅសិក្សាគោល ដែលសិស្សទទួលបានតាមផលធៀប១:១ សម្រាប់ថ្នាក់ទី១-៩ និង២:១ សម្រាប់មធ្យមសិក្សាទុតិយភូមិសម្រាប់ថ្នាក់ទី១០-ទី១២ និងចំនួនសៀវភៅអំណានផ្សេងៗ | | ៥ ២៧៦ ០០០ ច្បាប់ | ៥ ២៧៦ ០០០ ច្បាប់ | ៥ ២៧០ ០០០ ច្បាប់ | ឯកសារមួយចំនួនត្រូវប្តូរពីព៌ណសខ្មៅ ទៅជាពណ៌ធម្មជាតិ | ៥ ២៧០ ០០០ ច្បាប់ | ៥ ២៧០ ០០០ ច្បាប់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ខ៖ ចំនួនសាលារៀនទទួលបានពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីសិក្សានិងផ្សព្វផ្សាយ | | ១០៤ សាលារៀន | ១០០ សាលារៀន | ១២០ សាលារៀន | បង្កើនគុណភាពនិងប្រសិទ្ធិភាពលើការអនុវត្តកម្មវិធីសិក្សា | ១៥០ សាលារៀន | ១៥០ សាលារៀន |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.គ៖ ចំនួនឯកសារគរុកោសល្យនិងកម្មវិធីសិក្សា | | ៧ ចំណងជើង | ២ ចំណងជើង | ២ ចំណងជើង | បានរៀបចំរួចមួយចំនួនហើយ | ២ ចំណងជើង | ២ ចំណងជើង |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ឃ៖ ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យ និងសម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា | | ៧៥ នាក់ | ៧៥ នាក់ | ៧៨ នាក់ | បង្កើនវិញ្ញាសាមួយទៀត | ៧៨ នាក់ | ៧៨ នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ង៖ ចំនួនបណ្ណាល័យដែលទទួលបានការគាំទ្រផ្នែកបច្ចេកទេសនិងសម្ភារៈបរិក្ខា | | ៣៨ សាលារៀន | ៤០ សាលារៀន | ៤០ សាលារៀន | | ៥០ សាលារៀន | ៥០ សាលារៀន |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រី ស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា ឯកសារគរុកោសល្យ | ៤០ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.២.ក៖ ចំនួនមន្ត្រីនាយកដ្ឋានទទួលបានការបណ្ដុះបណ្ដាលស្ដីពី ការអភិវឌ្ឍកម្មវិធីសិក្សា និងឯកសារគរុកោសល្យ | | ២០ | ២០ | ២៥ | | ២៥ | ២៥ |
| **អនុកម្មវិធីទី ១.៩៖ ពង្រីកការអប់រំបរិយាបន្នគ្រប់កម្រិតសិក្សា** | ៥៧១ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.ក៖ ចំនួនគ្រូបង្រៀនថ្នាក់អប់រំពហុភាសាសម្រាប់បឋមសិក្សា | | ២៤២ | ២៣៥ | ២៣៥ | កុមារជនជាតិភាគតិចមួយចំនួនអាចនិយាយ និងរៀនភាសាខ្មែរបាន ហើយសាលារៀនមួយចំនួនមានសិស្សតិច | ២៣៥ | ២៣៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.ខ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ បានកសាងសមត្ថភាពស្ដីពីការអប់រំបរិយាបន្ន និងអប់រំពិសេស | | ៣៧ | ១២០ | ១៣០ | ពង្រឹងការអប់រំបរិយាបន្ន និងអប់រំថ្នាក់សមាហរណកម្ម | ១៤០ | ១៥០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.គ៖ ចំនួនសិស្សមានពិការភាព(គ ថ្លង់ ពិការភ្នែក និងសតិបញ្ញា...) ដែលបានរៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម | | ៩៩៣ | ១០៥៩ | ១០៧០ | មានការកើនឡើងសិស្សមានពិការភាពសតិបញ្ញា និងអូទីស្សឹម | ១០៨០ | ១០៩០ |
| ច.ស.ក.ទី១ ៖ លើកកម្ពស់ និងអភិវឌ្ឍការអប់រំបរិយាបន្នគ្រប់កម្រិតសិក្សា | ២៧៨ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.១.ក៖ ចំនួនសៀវភៅសិក្សា និងសម្ភារៈសិក្សាអប់រំពហុភាសាត្រូវបានបោះពុម្ព | | ២៤ ៦០០ ក្បាល | ២០០ ក្បាល | ២០០០ ក្បាល | តម្រូវការតែភាសាចារាយ | ២០០០ ក្បាល | ៦០០០ ក្បាល |
| ច.ស.ក.ទី២ ៖ លើកកម្ពស់សមត្ថភាពបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់លើការអប់រំបរិយាបន្ន | ២៩៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.ក៖ ចំនួនគ្រូ និងអ្នកពាក់ពន្ធ័អប់រំពហុភាសាត្រូវបានទទួលវគ្គបំប៉នសមត្ថភាពស្ដីពីការអប់រំពហុភាសា | | ២០ | ៣០ | ៣០ | | ១០០ | ១០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.ខ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានកសាងសមត្ថភាពស្ដីពីការអប់រំបរិយាបន្ន និងអប់រំពិសេស | | ៣៧ | ១២០ | ១៣០ | ពង្រឹងការអប់រំបរិយាបន្ន និងអប់រំថ្នាក់សមាហរណកម្ម | ១៥០ | ១៥០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.គ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានបណ្ដុះបណ្ដាលជំនាញអប់រំពិសេស ស្ដីពីការអប់រំពិសេស សម្រាប់បង្រៀននៅវិទ្យាល័យអប់រំពិសេស | | ២០ | ២៣ | ២០ | | ១០ | ១០ |
| កម្មវិធីទី ២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ | ១៧,១២៧ | | | | | | |
| សូចនាករលទ្ធផលចុងក្រោយ ២.១៖ អត្រាចូលរៀនរួមនៅឧត្តមសិក្សា (១៨-២២) | | ១៥% | ១៤% | ១៧% | ការធ្វើចំណោលចំនួននិស្សិតនឹងមានការកើនឡើងតាមរយៈយុទ្ធសាស្ត្រគាំទ្ររបស់ក្រសួង | ១៨% | ១៩% |
| សូចនាករលទ្ធផលចុងក្រោយ ២.២៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតគ្រឹះស្ថានសិក្សា | | ១៧ | N/A | ៣០ | ការធ្វើចំណោលនេះផ្អែកលើទិន្នន័យមូលដ្ឋានឆ្នាំ ២០២៣ ដែលចំនួនគ្រឹះស្ថានមានការចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងកើនឡើង ដោយសារគ្រឹះស្ថានឧត្តមសិក្សាឱ្យតម្លៃទៅលើប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងរបស់ក្រសួង | ៣៥ | ៤០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលចុងក្រោយ ២.៣៖ ចំនួនគម្រោងស្រាជ្រាវប្រតិបត្តិ និងនាវានុវត្តន៍គាំទ្រការអភិវឌ្ឍ | | | | ១៥ គម្រោង | សូចនាករចំនួនគម្រោងស្រាវជ្រាវ និងនវានុវត្តន៍មានការកើនឡើងនេះជាសូចនាករគន្លឹះសម្រាប់កម្មវិធី ព្រោះសូចនាករនេះធ្វើឱ្យសូចនាករមួយចំនួនទៀតអនុវត្តបានសម្រេចដូចជាចំនួនអ្នកស្រាវជ្រាវកើនឡើង ចំនួនអត្ថបទកើនឡើង និងផលិតផលដែលប្រើប្រាស់នៅទីផ្សារកើនឡើង។ល។ | ១៥ គម្រោង | ១៥ គម្រោង |
| **អនុកម្មវិធីទី ២.១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា** | ២,៨៨៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់សិក្សា | | ២០ | N/A | ៣០ | | ៣៥ | ៤០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ខ៖ ចំនួនកម្មវិធីត្រូវបានវាយតម្លៃតាមប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | | ១០៧ | N/A | ១៣៥ | ការធ្វើចំណោលចំនួនកម្មវិធីផ្អែកតាមគ្រឹះស្ថានឧត្តមសិក្សាដែលបានចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | ១៥០ | ១៦៥ |
| ច.ស.ក.ទី១ ៖ បង្កើនចំនួននិស្សិតមានសមត្ថភាពខ្ពស់ស្របតាមទីផ្សារការងារ | ១,៩៩៨ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.១.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តកម្មវិធីបណ្ដាញសាកលវិទ្យាល័យសាយប័រ | | ១ | ៥ | ៦ | កម្មវិបណ្ដាញសាកលវិទ្យាល័យសាយប័រ មានថវិកាគាំទ្រ និងចាប់ផ្ដើមអនុវត្តលើគ្រឹះស្ថានគោលដៅ៥របស់ក្រសួង | ៦ | ៦ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ក៖ ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលផ្នែកស្ទែម | | ២៦% | N/A | ០ | ការធ្វើចំណោលចំនួនគ្រឹះស្ថានចូលរួមមានការកើនឡើង តាមរយៈការផ្ដល់អាហារូបករណ៍របស់រដ្ឋនៅតាមគ្រឹះស្ថានឧត្តសិក្សាសារណៈនិងឯកជនជារៀងរាល់ឆ្នាំ | ០ | ០ |
| ច.ស.ក.ទី២ ៖ កសាងប្រព័ន្ធអភិបាលកិច្ច ដើម្បីអភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | ៨៨៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.២.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | | ២០ | ២១ | ៣០ | ក្រសួងមានពង្រីកការចុះជួយគាំទ្រគ្រឹះស្ថានឧត្តមសិក្សាផ្សេងៗទៀតលើការរៀបចំ និងអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | ៣៥ | ៤០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.២.ខ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំផែនការរយៈពេលវែង មធ្យម និងខ្លី | | ៦ | ៦ | ១២ | គ្រឹះស្ថានឧត្តមសិក្សារដ្ឋដែលទទួលបានការបណ្ដុះបណ្ដាលនឹងរៀបចំផែនការយុទ្ធសាស្ត្ររយៈពេលវែងឱ្យស្របនឹងយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា | ១៩ | ២៧ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.២.គ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យឧត្តមសិក្សា | | ៣៣ | N/A | ៤៣ | ការធ្វើចំណោលចំនួនគ្រឹះស្ថានចូលរួមមានការកើនឡើង ដោយមានការចុះជួយបណ្ដុះបណ្ដាលពីក្រុមការងារជំនាញរបស់ក្រសួង | ៤៨ | ៥៣ |
| **អនុកម្មវិធីទី ២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា** | ២,១៧១ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.ក៖ ចំនួនអត្ថបទស្រាវជ្រាវត្រូវបានបោះពុម្ពនៅទស្សនាវដ្ដី២លេខក្នុង១ឆ្នាំ | | | | ១៦ | បោះពុម្ព១ឆ្នាំ២លេខក្នុង១លេខ៨អត្ថបទ | ១៦ | ១៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.ខ៖ ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវ | | | | ១០ | ទិសដៅកំណែទម្រង់ឧត្តមសិក្សា | ១០ | ១០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.គ៖ ចំនួនគម្រោងស្រាវជ្រាវ និងនវានុវត្តន៍មានការកើនឡើង | | | | ១៥ | ទិសដៅកំណែទម្រង់ឧត្តមសិក្សា | ១៥ | ១៥ |
| ច.ស.ក.ទី១ ៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវ និងនវានុវត្តន៍ | ១,១៧២ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ២.២.១.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សា ត្រូវបានពិនិត្យ និងវាយតម្លៃលើការបណ្តុះបណ្តាល | | | | ១៥ | ចុះសម្របសម្រួលដល់ទីតាំង | ១៥ | ១៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.១.ខ៖ ចំនួនអត្ថបទស្រាវជ្រាវត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្នែម | | | | ១៦ | បោះពុម្ព១ឆ្នាំ២លេខក្នុង១លេខ៨អត្ថបទ | ១៦ | ១៦ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.១.គ៖ ចំនួនគម្រោងស្រាវជ្រាវ និងនវានុវត្តន៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាមានការកើនឡើង | | | | ១៥ | ជំរុញកំណើនស្រាវជ្រាវ និងនវានុវត្តន៍នៅឧត្តមសិក្សា | ១៥ | ១៥ |
| ច.ស.ក.ទី២ ៖ ពង្រឹងអភិបាលកិច្ចស្ថាប័ន និងសមត្ថភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា | ៩៩៩ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.២.ក៖ ចំនួនបុគ្គលិកអប់រំ និងគ្រឹះស្ថានឧត្តមសិក្សាដែលបានចូលរួមអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារផ្សារភ្ជាប់នឹងសមិទ្ធកម្ម | | | | ៧៤ | បុគ្គលិកអប់រំចូលរួមការអនុវត្តការងារផ្សារភ្ជាប់នឹងសមិទ្ធកម្មក្នុងកំណែទម្រង់ឧត្តមសិក្សា និងហិរញ្ញវត្ថុសាធារណៈ | ៧៤ | ៧៤ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.២.ខ៖ ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវ | | | | ១០ | ចុះសម្របសម្រួលដល់ទីតាំង | ១០ | ១០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.២.គ៖ ចំនួននិស្សិតទទួលបានអាហារូបករណ៍ | | | | ១៥ | បង្កើនបរិមាណធនធានមនុស្សគាំទ្រកំណែទម្រង់យុទ្ធសាស្ត្រវិស័យអប់រំ និងថ្នាក់ជាតិ | ១៥ | ១៥ |
| **អនុកម្មវិធីទី ២.៣៖ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវ ប្រកបដោយប្រសិទ្ធភាព** | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.ក៖ ភាគរយនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំទី៤ ថ្នាក់អាហារូបករណ៍និងបង់ថ្លៃប្រឡងជាប់បរិញ្ញាបត្រ | | ៩១% | | ៩៥% | | ៩៦% | ៩៦% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.ខ៖ ចំនួននិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ សិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | | | | ៩៥០ | | ១,០០០ | ១,០០០ |
| ច.ស.ក.ទី១ ៖ កែលម្អសមត្ថភាពរៀននិងបង្រៀន និង ការស្រាវជ្រាវ | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.ក៖ ចំនួននិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញសិក្សាផ្នែក STEM | | | | ១៥,២៥៤ | | ១៦,០០០ | ១៦,០០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.ខ៖ ចំនួនគម្រោងសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | | | | ៥ | | ៦ | ៦ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.គ៖ ចំនួនកម្មវិធីសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានកែលម្អ | | | | ៥ | | ៦ | ៦ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.ឃ៖ ភាគរយនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញបញ្ចប់ការសិក្សាមានការងារធ្វើនៅតាមស្ថាប័ននានា | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.២.កៈ ភាគរយនៃបុគ្គលិកអប់រំសាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបានការបំប៉នសមត្ថភាពតាមមុខជំនាញ | | | | ៦៨% | | ៦៩% | ៦៩% |
| **អនុកម្មវិធីទី ២.៤៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ** | ១០២ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៤.កៈ ចំនួនសិស្សនិស្សិតចូលរៀនបរិញ្ញាបត្រ បរិញ្ញាបត្ររង និងគុណវុឌ្ឍិ១ ២ ៣ ទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ត្រូវបានបង្កើន | | | ៣៨៦ | ១,៦០០ | ដោយសារនិស្សិតភាគច្រើនទៅភ្នំពេញដើម្បីធ្វើការផងនិងរៀនផង | ១,៧០០ | ១,៨០០ |
| ច.ស.ក.ទី១ ៖ កែលម្អសមត្ថភាពរៀននិងបង្រៀន និងការស្រាវជ្រាវ | | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៤.១.កៈ កម្មវិធីសិក្សានឹងត្រូវកែលម្អតាមតម្រូវការទីផ្សារ | | | ៣ | ៨ | ដោយសារបានធ្វើច្រើនហើយនៅ២០២៣ | ៩ | ៩ |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍ សមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | ១០២ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៤.២.កៈ ភាគរយនៃបុគ្គលិកអប់រំនិងសាស្ត្រាចារ្យកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតត្រូវបានបង្កើនគុណវុឌ្ឍិ | | | ៥% | ៥% | ដោយសារពុំមានអ្នកដាក់ពាក្យរៀនច្រើន | ៨% | ៨% |
| **អនុកម្មវិធីទី ២.៥៖ លើកកម្ពស់គុណភាព នៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ** | ២,២១៦ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.កៈ ភាគរយនិស្សិតដែលបញ្ចប់ការសិក្សាទទួលបានការងារធ្វើនៅតាមស្ថាប័ននានា | | ៩៥% | N/A | ៩៦% | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.ខៈ ចំនួនអត្ថបទនៃការសិក្សាស្រាវជ្រាវរបស់គ្រូបុគ្គលិកអប់រំត្រូវបានបោះពុម្ពប្រចាំឆ្នាំ | | ០ | N/A | ៦ | | ៦ | ៦ |
| ច.ស.ក.ទី១ ៖ អភិវឌ្ឍការបណ្តុះបណ្តាលប្រកបដោយគុណភាព និងឆ្លើយតបទៅនឹងទីផ្សារការងារ | ៣៨៩ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៥.១.កៈ ចំនួននិស្សិតរៀនមុខវិជ្ជាវិទ្យាសាស្ត្រ STEAM | | ៨៧៣ | ៧៧៣ | ៩៩០ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.១.ខៈ ចំនួនគម្រោងដែលបុគ្គលិកអប់រំបានសិក្សាស្រាវជ្រាវ | | ០ | N/A | ៦ | | ៧ | |
| ច.ស.ក.ទី២ ៖ លើកកម្ពស់អភិបាលកិច្ច អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | ១,៨២៧ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.២.កៈ ចំនួនមន្ត្រីអប់រំបានចូលរួមវគ្គសិក្ខាសាលា និងការបណ្តុះបណ្តាលស្តីពីការងារដឹកនាំ និងគ្រប់គ្រង | | ១០០ | ៣៧ | ១៤០ | | ១៥០ | ១៦០ |
| **អនុកម្មវិធីទី ២.៦៖ ការអភិវឌ្ឍការបណ្តុះបណ្តាល និងស្រាវជ្រាវ** | ៧,០៤៨ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.កៈ ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬ បន្តការសិក្សា | | ៩៩% | N/A | ៩០% | ៩៨%គឺទិន្នន័យគិតត្រឹមបំណាច់ខែធ្នូសម្រាប់ឆ្នាំ ២០២២ ចំណែកឯ ៩០%គឺទិន្នន័យគិតត្រឹមបំណាច់ខែតុលា | ៩០% | ៩០% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.ខៈ ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ | | ៦២ | ១៩៤ | ៦០ | | ៦០ | ៦០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.គៈ ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត | | ២៧% | ២៧% | ២៨% | វិទ្យាស្ថានបានបញ្ជូនបុគ្គលិកអប់រំទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅក្រៅប្រទេសជាបន្តបន្ទាប់ | ២៨% | ២៨% |
| ច.ស.ក.ទី១ ៖ លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល ការស្រាវជ្រាវ និងនវានុវត្តន៍ | ១,៦០៣ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.កៈ ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬ បន្តការសិក្សា | | ៩៩% | 0% | ៩០% | ៩៨%គឺទិន្នន័យគិតត្រឹមបំណាច់ខែធ្នូសម្រាប់ឆ្នាំ ២០២២ ចំណែកឯ ៩០%គឺទិន្នន័យគិតត្រឹមបំណាច់ខែតុលា | ៩០% | ៩០% |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.ខៈ ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬ ចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ | | ៦២ | ១៩៤ | ៦០ | | ៦០ | ៦០ |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពគ្រឹះស្ថាន និងមន្ត្រីជំនាញ | ៥,៤៤៥ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.២.កៈ ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត | | | ២៧% | ២៨% | វិទ្យាស្ថានបានបញ្ជូនបុគ្គលិកអប់រំទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅក្រៅប្រទេសជាបន្តបន្ទាប់ | ២៨% | ២៨% |
| **អនុកម្មវិធីទី ២.៧ៈការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ** | ១០,០៣៨ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.កៈ ចំនួនគរុនិស្សិត និងនិស្សិតបានបញ្ចប់ការបណ្តុះបណ្តាលប្រចាំឆ្នាំ | | ១,៣២៧ | ៣១៧ | ២,១១៤ | បង្កើនចំនួន(បរិញ្ញា+១) ទៅ(បរិញ្ញា+២) ដើម្បីពង្រឹងគុណភាពគ្រូបង្រៀន | ២,២០០ | ២,៥០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.ខៈ ចំនួនបុគ្គលិកអប់រំបានទទួលការអភិវឌ្ឍន៍វិជ្ជាជីវៈ និងការស្រាវជ្រាវ | | ៧,៦៦១ | ១,៩៣៦ | ៤,៤៤៩ | តម្រូវការបង្កើនការបំប៉នមន្ត្រីថ្នាក់ក្រោមជាតិដើម្បីមានសមត្ថភាពពេញលេញចូលរួមធ្វើកំណែទម្រង់វិស័យអប់រំ(Step Up) | ៤,៦៧១ | ៤,៩០៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.គៈ ចំនួនបុគ្គលិកអប់រំវិទ្យាស្ថានជាតិអប់រំបានទទួលការអភិវឌ្ឍន៍សមត្ថភាពទាំងក្នុង និងក្រៅប្រទេស | | ១១៣ | ៣៨៦ | ៣៩៦ | បង្កើនចំនួនមន្ត្រីអប់រំដើម្បីកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រប់ប្រភេទ និងបង្កើតវគ្គបំប៉នថ្មីអំពីការពង្រឹងសមត្ថភាពផ្សេងៗ | ៣៩៦ | ៤២០ |
| ច.ស.ក.ទី១ ៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលដំបូង ការបណ្តុះបណ្តាលបន្ត និងការស្រាវជ្រាវ | ៩,៦៦៤ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.១.កៈ ចំនួនគរុសិស្ស គរុនិស្សិត និស្សិត បានទទួលបណ្តុះបណ្តាលគ្រប់វគ្គ។ | | ១,៣២៧ | ៣១៧ | ២,១១៤ | បង្កើនចំនួន(បរិញ្ញា+១) ទៅ(បរិញ្ញា+២) ដើម្បីពង្រឹងគុណភាពគ្រូបង្រៀន | ២,២០០ | ២,៥០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.១.ខៈ ចំនួនមន្ត្រីអប់រំថ្នាក់រាជធានី ខេត្ត និងគ្រូបង្រៀនបានទទួលគ្រប់វគ្គបំប៉ន។ | | ៧,៦៤៦ | ១,៩៣៦ | ៤,៤៤៩ | តម្រូវការបង្កើនការបំប៉នមន្ត្រីថ្នាក់ក្រោមជាតិដើម្បីមានសមត្ថភាពពេញលេញចូលរួមធ្វើកំណែទម្រង់វិស័យអប់រំ | ៤,៦៧១ | ៤,៩០៥ |
| សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៧.១.គៈ ចំនួនប្រធានបទបានស្រាវជ្រាវដោយបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ | | ៣ | ៧ | ៨ | តាមចេនាសម្ព័ន្ធថ្មីរបស់វិទ្យាស្ថានជាតិអប់រំ | ១០ | ១១ |
| ច.ស.ក.ទី២ ៖ ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | ៣៧៣ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.២.កៈ ចំនួនបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំបានចូលរួមវគ្គបំប៉នសមត្ថភាពទាំងក្នុងនិងក្រៅប្រទេស | | ១១៣នាក់ | ៣៨៦នាក់ | ៣៧៨នាក់ | បង្កើនចំនួនមន្ត្រីអប់រំដើម្បីកែលម្អកម្មវិធីបណ្តុះបណ្តាលគ្រប់ប្រភេទ និងបង្កើតវគ្គបំប៉នថ្មីអំពីការពង្រឹងសមត្ថភាពផ្សេងៗ | ៣៩៦នាក់ | ៤២០នាក់ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.២.ខៈ ចំនួនបុគ្គលិកអប់រំបានទទួលការបំប៉នស្តីពីដំណើរការលើកកម្ពស់គុណភាពអប់រំ | | | ៧០នាក់ | ១០៤នាក់ | អនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុង(ក្រុមខណ្ឌកំណែទម្រង់) | ១០៤នាក់ | ១០៤នាក់ |
| **អនុកម្មវិធីទី ២.៨ៈ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ** | ២,៥២៧ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.ក៖ ចំនួននិស្សិតបញ្ចប់ការសិក្សាស្របតាមតម្រូវការទីផ្សារ | | ៦៤៨ | ៦៣៥ | ៧២០ | | ៧៤០ | ៧៦០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.ខ៖ ចំនួនគម្រោងស្រាវជ្រាវបានអនុវត្ត និងប្រើប្រាស់ដោយទីផ្សារ | | ៣ | ៥ | ៦ | | ៧ | ៨ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.គ៖ ចំនួនពិន្ទុនៃការវាយតម្លៃកម្រិតអភិវឌ្ឍគ្រឹះស្ថានប្រចាំឆ្នាំ | | | | ៨ | | ១១ | ១៤ |
| ច.ស.ក.ទី១ ៖កែលម្អសមត្ថភាពរៀននិងបង្រៀន និង ការស្រាវជ្រាវ | ១,១០៧ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ក៖ ចំនួនកម្មវិធីសិក្សាត្រូវបានកែលម្អ ឬបង្កើតថ្មី | | | | ៤ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ខ៖ ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លីស្របតាមតម្រូវការកម្មវិធីសិក្សាដែលបានកែលម្អ ឬបង្កើតថ្មី | | | | ២០ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.គ៖ ចំនួនមុខវិជ្ជាដែលបានអនុវត្តវិធីសាស្ត្របង្រៀន PBL/IBL ដាក់បញ្ចូលក្នុងប្រព័ន្ធ LMS | | | ២ | ២៦ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ឃ៖ ចំនួននិស្សិតចូលរៀនឆ្នាំទី១ | | | | ១,១៧០ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ង៖ ចំនួនអត្ថបទស្រាវជ្រាវបានបោះពុម្ពផ្លូវការ ឬធ្វើបទបង្ហាញក្នុងសន្និសីទ | | | | ៦ | | | |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និង មន្ត្រីជំនាញ | ១,៤២០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.២.ក៖ ចំនួនរបាយការណ៍ស្វ័យវាយតម្លៃកម្រិតកម្មវិធីត្រូវបានផលិត | | ២ | ៣ | ៥ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.២.ខ៖ ចំនួនបុគ្គលិកចូលរួមការចុះកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ | | ០ | ៥០ | ៧៥ | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.គ៖ អត្រានៃសេចក្តីពេញចិត្តរបស់និស្សិតលើបរិស្ថានសិក្សា | | | | ៨០% | | | |
| **អនុកម្មវិធីទី ២.៩៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ** | ២០ | | | | | | |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.ក៖ ចំនួននិស្សិតចូលរៀនក្នុងកម្មវីធីបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងសង្គម | | ៥២៣ | ៨៦៧ | ៩០០ | | ១,១០០ | ១,១០០ |
| សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.ខ៖ ចំនួនកម្មវិធីអប់រំតាមមុខជំនាញដែលបានកែលម្អស្របតាមប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធី | | ២ | | ៣ | | ៣ | ៣ |
| សេចក្តីពណ៌នាកម្មវិធីទី ១៖ លើកកម្ពស់ការចូលរៀនរបស់កុមារអាយុ ៥ឆ្នាំ នៅមត្តេយ្យសិក្សាឱ្យបានពេញលេញ និងប្រសើរឡើង មានគុណភាព ដើម្បីត្រៀមលក្ខណៈសម្បត្តិចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សាប្រកបដោយប្រសិទ្ធភាព។ អត្រាបញ្ចប់ការសិក្សា ជាបរិមាណផលធៀបនៃចំនួនអ្នកសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ បានបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សា និងចំនួនប្រជាជនមានអាយុ៦ដល់១១ឆ្នាំ។ អត្រាបញ្ចប់ការសិក្សាផ្តល់នូវព័ត៌មានលម្អិតអំពីស្ថានភាព គុណភាពអប់រំ សមធម៌ និង បរិយាបន្ន របស់កុមារមានវ័យសិក្សានៅមធ្យមសិក្សាបឋមភូមិ ជាទិន្នន័យគន្លឹះសម្រាប់ការរៀបចំគោលនយោបាយអន្តរាគមន៍។ ដើម្បីឱ្យប្រជាជនឆ្លងផុតគ្រោះមិនចេះអក្សរ និងអភិវឌ្ឍន៍ធនធានមនុស្សចូលរួមអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយគុណភាព។ | |
| តួនាទីអ្នកទទួលខុសត្រូវ៖ អគ្គនាយក | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ អគ្គនាយកដ្ឋានអប់រំ |
| *សូចនាករលទ្ធផលចុងក្រោយ ១.១៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំគ្រប់រូបភាព (មត្តេយ្យសិក្សារដ្ឋ សហគមន៍ និងឯកជន)* | |
| *សូចនាករលទ្ធផលចុងក្រោយ ១.២៖ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា* | |
| *សូចនាករលទ្ធផលចុងក្រោយ ១.៣៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ* | |

| |
|---|
| *សូចនាករលទ្ធផលចុងក្រោយ ១.៤៖ អត្រាអក្ខរកម្មពេញវ័យ (អាយុ១៥ ឆ្នាំឡើង)* |
| **ឈ្មោះអនុកម្មវិធីទី ១.១៖ ការពង្រីកការអប់រំកុមារតូច** |
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន \| ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានអប់រំកុមារតូច |
| សេចក្តីពណ៌នាអនុកម្មវិធីទី ១.១ ៖ លើកកម្ពស់ការចូលរៀនរបស់កុមារអាយុ ៥ឆ្នាំ នៅមត្តេយ្យសិក្សាឱ្យបានពេញលេញ និងប្រសើរឡើង មានគុណភាព ដើម្បីត្រៀមលក្ខណៈសម្បត្តិចូលរៀនថ្នាក់ទី១ នៃសាលាបឋមសិក្សា ប្រកបដោយប្រសិទ្ធភាព។ លើកកម្ពស់ និងផ្តល់ឱកាសការសិក្សាមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន នៅមត្តេយ្យសិក្សាគ្រប់រូបភាពសម្រាប់កុមារអាយុ ៣ឆ្នាំ ទៅ៥ឆ្នាំ ដើម្បីអភិវឌ្ឍសមត្ថភាពកុមារបានពេញលេញ និងប្រសើរឡើង។ |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ក៖ អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ នៅមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ និងឯកជន* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.ខ៖ អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សារដ្ឋមត្តេយ្យសិក្សាសហគមន៍ និងមត្តេយ្យសិក្សាឯកជន* |
| **ច.ស.ក.ទី១ ៖ គាំពារនិងការអភិវឌ្ឍកុមារតូច** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.១.ក៖ ចំនួនមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា* |
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពមន្ត្រីអនុវិស័យអប់រំកុមារតូច** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.១.២.ក៖ ចំនួនសាលាមត្តេយ្យសិក្សាដែលទទួលការគាំទ្របន្ថែមលើការអភិវឌ្ឍសាលារៀន* |
| **ឈ្មោះអនុកម្មវិធីទី ១.២៖ ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា** |
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន \| ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានបឋមសិក្សា |
| សេចក្តីពណ៌នាអនុកម្មវិធីទី ១.២ ៖ បុគ្គលិកអប់រំបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែមលើវិធីសាស្ត្ររៀននិងបង្រៀន និងទទួលបានការបំប៉នសមត្ថភាពលើការគាំទ្រការគ្រប់គ្រងតាមសាលារៀនដើម្បីកុមាររៀនចេះ រៀនចប់ ប្រឡងជាប់ មានការងារល្អធ្វើ រកចំណូលបានខ្ពស់។ |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.ក៖ អត្រាពិតនៃការសិក្សា* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.ខ៖ អត្រាត្រួតថ្នាក់* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.គ៖ អត្រាបោះបង់ការសិក្សា* |
| **ច.ស.ក.ទី១ ៖ អភិវឌ្ឍការអប់រំបឋមសិក្សា ដើម្បីធានាឱ្យការចូលរៀនមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.១.ក ៖ ចំនួនបុគ្គលិកអប់រំបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែមលើវិធីសាស្ត្ររៀននិងបង្រៀន* |
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំបឋមសិក្សា** |

| | |
|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.២.២.ក៖ ចំនួនមន្ត្រីអប់រំបឋមសិក្សាបានទទួលការបំប៉នសមត្ថភាពលើការគាំទ្រការគ្រប់គ្រងតាមសាលារៀន* | |
| **ឈ្មោះអនុកម្មវិធីទី ១.៣៖ ការចូលរៀនប្រកបដោយសមធម៌ ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា** | |
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| សេចក្តីពណ៌នាអនុកម្មវិធីទី ១.៣ ៖ រកគម្លាតកុមារដល់វ័យសិក្សាចូលរៀននៅធម្យមសិក្សាបឋមភូមិ នឹងចំនួនសិស្សចូលរៀនជាក់ស្តែងប្រចាំឆ្នាំសិក្សា ។ រកគម្លាតកុមារដល់វ័យសិក្សាចូលរៀននៅធម្យមសិក្សាទុតិយភូមិ នឹងចំនួនសិស្សចូលរៀនជាក់ស្តែងប្រចាំឆ្នាំសិក្សា ។ អត្រាចូលរៀនខ្ពស់នឹងសម្រេចបានអត្រាចូលរៀនប្រចាំឆ្នាំ និង នាំឱ្យអត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅកាន់មធ្យមសិក្សាទុតិយភូមិកាន់តែខ្ពស់ឡើង។ អត្រាបញ្ចប់ការសិក្សាផ្តល់នូវព័ត៌មានលម្អិតអំពីស្ថានភាព គុណភាពអប់រំ សមធម៌ និង បរិយាបន្ន របស់កុមារមានវ័យសិក្សានៅមធ្យមសិក្សាបឋមភូមិ ជាទិន្នន័យគន្លឹះសម្រាប់ការរៀបចំគោលនយោបាយអន្តរាគមន៍។ អត្រាបញ្ចប់ការសិក្សាផ្តល់នូវព័ត៌មានលម្អិតអំពីស្ថានភាព គុណភាពអប់រំ សមធម៌ និង បរិយាបន្ន របស់កុមារមានវ័យសិក្សានៅមធ្យមសិក្សាបឋមភូមិ ជាទិន្នន័យគន្លឹះសម្រាប់ការរៀបចំគោលនយោបាយអន្តរាគមន៍។ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ក៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ខ៖ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.គ៖ អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ឃ៖ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.ង៖ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ* | |
| **ច.ស.ក.ទី១ ៖ បង្កើនការចូលរៀននៅមធ្យមសិក្សា និង ជួយសិស្សរៀនមានសមត្ថភាពបញ្ញាល្អប្រសើរ និងរៀនចប់នៅមធ្យមសិក្សា** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.ក៖ ចំនួនភ្នាក់ងារផ្លាស់ប្តូរនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើកម្មវិធីការគ្រប់គ្រងតាមសាលារៀន* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.ខ៖ ភាគរយបេក្ខជនប្រឡងជាប់សញ្ញាបត្រថ្នាក់ពីរភាសា បារាំង-ខ្មែរ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.១.គ៖ ចំនួនសាលារៀនបានចុះជួយ (ពិនិត្យតាមដាន និងវាយតម្លៃ)* | |
| **ច.ស.ក.ទី២ ៖ លើកកម្ពស់ការងារគ្រប់គ្រងថ្នាក់ជាតិ និងក្រោមជាតិ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៣.២.ក៖ ចំនួនសាលារៀនជំនាន់ថ្មី* | |
| **ឈ្មោះអនុកម្មវិធីទី ១.៤៖ ការពង្រីកការអប់រំក្រៅប្រព័ន្ធ** | |
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |

សេចក្តីពណ៌នាអនុកម្មវិធីទី ១.៤ ៖ រៀបចំបណ្តុះបណ្តាលគ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ បើកថ្នាក់អក្ខរកម្មសម្រាប់ប្រជាសហគមន៍ដែលមិនចេះអក្សរ នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ទីវត្តអារាម វិហារសាសនា។ បើកថ្នាក់អក្ខរកម្ម សម្រាប់កម្មករ កម្មការិនីនៅតាមរោងចក្រ សហគ្រាស និងបើកថ្នាក់អក្ខរកម្មសម្រាប់ជនជាប់ឃុំ នៅតាមពន្ធនាគារ មណ្ឌលកែប្រែ។ បើកវគ្គបណ្តុះបណ្តាលគ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ បើកថ្នាក់កម្មវិធីសមមូលបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិសម្រាប់ កុមារ យុវជន និងសិស្សបោះបង់ការសិក្សា នៅតាមសាលារៀន មជ្ឈមណ្ឌលសិក្សាសហគមន៍ មជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ទីវត្តអារាម រោងចក្រ សហគ្រាស ពន្ធនាគារ មណ្ឌលកែប្រែ...។ល។ តម្រង់ទិសគ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ បើកថ្នាក់បំប៉នរយៈពេល ២ខែនៅមហាវិស្សមកាល សម្រាប់សិស្សដែលបានបោះបង់ការសិក្សាចាប់ពីថ្នាក់ទី៣ ដល់ទី៦ នៃសាលាបឋមសិក្សាចំណេះទូទៅ។ តម្រង់ទិសគ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ បើកវគ្គបណ្តុះបណ្តាលជំនាញមុខរបរងាយៗ រយៈពេលចន្លោះពី១ខែ ដល់៦ខែ នៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍ និងមជ្ឈមណ្ឌលសិក្សាសិក្សាពេញមួយជីវិតសម្រាប់យុវជនក្រៅសាលា និងប្រជាសហគមន៍។ អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធដូចជាមន្ត្រីទទួលបន្ទុកការងារអប់រំក្រៅប្រព័ន្ធទាំងថ្នាក់ជាតិ និងក្រោមជាតិ លើការងារផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ។

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ក៖ ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ខ៖ ចំនួនសិស្សបានបញ្ចប់ថ្នាក់កម្មវិធីសមមូល*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.គ៖ ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ឃ៖ ចំនួនអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរ*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.ង៖ ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលសមត្ថភាព ស្តីពីការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ*

**ច.ស.ក.ទី១ ៖ អភិវឌ្ឍការអប់រំក្រៅប្រព័ន្ធ**

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ក៖ ចំនួនកម្មករ-កម្មការិនីដែលបានបញ្ចប់ថ្នាក់អក្ខរកម្មនៅតាមរោងចក្រសហគ្រាស តាមសហគមន៍ ពន្ធនាគារ និងមណ្ឌលកែប្រែ*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ខ៖ ចំនួនអ្នកសិក្សាដែលបានបញ្ចប់ថ្នាក់សមមូលបឋមសិក្សា និងសមមូលមធ្យមសិក្សា*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.គ៖ចំនួនកុមារដែលបានបញ្ជូនចូលរៀនសាលាចំណេះទូទៅក្នុងប្រព័ន្ធ*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.១.ឃ៖ ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរ*

*ច.ស.ក.ទី២ ៖ អភិវឌ្ឍស្ថាប័ន និងសមត្ថភាពបុគ្គលិកអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៤.២.ក៖ ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ*

**ឈ្មោះអនុកម្មវិធីទី ១.៥៖ ការពង្រឹងនិងពង្រីកកម្មវិធីលើកកម្ពស់សុខភាពសិក្សា**

| | |
|---|---|
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានសុខភាពសិក្សា |

| |
|---|
| សេចក្តីពណ៌នាអនុកម្មវិធីទី ១.៥ ៖ គ្រឹះស្ថានសិក្សារៀបចំតម្លើងបរិក្ខារលាងសម្អាតដៃដោយមានទឹកស្អាត សាប៊ូ និងអាចប្រើប្រាស់បាន ព្រមទាំងមានភាពស្អាតជាប់ជាប្រចាំ។ គ្រឹះស្ថានសិក្សា រៀបចំតម្លើងបរិក្ខារលាងសម្អាតដៃតាមសមាមាត្រអ្នកសិក្សានិងបុគ្គលិកអប់រំ សម្រាប់អនុវត្តវិធានការអនាម័យផ្ទាល់ខ្លួនជាប្រចាំគ្រប់វេនសិក្សា។ ការតម្លើងបរិក្ខារនេះ ត្រូវរៀបចំតាមជម្រើសផ្សេងៗ អនុលោមតាមធនធាននិងស្ថានភាពរបស់គ្រឹះស្ថានសិក្សាដូចជានៅជិតបង្គន់អនាម័យ ជិតបន្ទប់រៀន ឬក្បែរអាហារដ្ឋាន។ កញ្ចប់បរិក្ខារលាងសម្អាតដៃ រួមមាន ទឹកស្អាត សាប៊ូ និងអាចប្រើប្រាស់បាន សម្រាប់មនុស្សគ្រប់រូប ព្រមទាំងមានភាពស្អាតជាប់ជាប្រចាំ។ ការកសាងបង្គន់អនាម័យនៅតាមគ្រឹះស្ថានសិក្សា អាចអនុវត្តស្របតាមអនុក្រឹត្យលេខ២៥នៃស្តង់ដាជាតិសម្រាប់បង្គន់អនាម័យដោយគិតពីសមាមាត្ររវាងចំនួនបង្គន់អនាម័យនិងចំនួនសិស្ស ពោលត្រូវមានបង្គន់អនាម័យពីរ និងបង្គន់នោមបី សម្រាប់សិស្សប្រុស ១០០នាក់ និងបង្គន់អនាម័យបី សម្រាប់សិស្សស្រី ១០០នាក់។ ការសាងសង់បង្គន់អនាម័យ ត្រូវធានាថាសិស្សគ្រប់រូបអាចប្រើប្រាស់បាន ពិសេសត្រូវមាន ជម្រាលសម្រាប់សិស្សពិការកាយសម្បទា។ បង្គន់អនាម័យដែលសាងសង់រួចត្រូវមានដំណើរការល្អសម្រាប់សិស្សអាចចូលប្រើប្រាស់បាន គ្រប់ម៉ោងសិក្សា មានទឹកលាងសម្អាតយកមកពីប្រភពដែលបានកែលម្អគ្រប់គ្រាន់ មានបែងចែករវាងបង្គន់ស្រី និងប្រុសដាច់ដោយឡែកពីគ្នា។ គ្រឹះស្ថានសិក្សា ត្រូវមានបម្រុងសំឡីអនាម័យសម្រាប់សិស្សស្រីប្រើប្រាស់ពេលត្រូវការបន្ទាន់ និងមានធុងសំរាមក្នុងបង្គន់អនាម័យស្រីនីមួយៗ។ សាលារៀនមានអនាម័យនិងបរិស្ថានស្អាត ទាក់ទាញសិស្សចូលរៀនកាន់តែច្រើននិងទៀងទាត់ លោកគ្រូ អ្នកគ្រូរីករាយពេលឃើញសិស្សមានសុខភាពល្អ។ គ្រឹះស្ថានសិក្សា អាចចាប់ផ្តើមដោយឱ្យសិស្សយកទឹកទទួលទានពីផ្ទះរបស់ខ្លួន ហើយបន្តិចម្តងៗរហូតដល់តម្លើងបណ្តាញទឹកស្អាតសម្រាប់ទទួលទានពេញលេញ ដូចជា ធុងចម្រោះប្រព័ន្ធបន្សុទ្ធទឹកស្អាត ឬទឹកសម្រាប់ទទួលទានធុងតូចធំ តាមធនធានរបស់គ្រឹះស្ថានសិក្សានីមួយៗ។ |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ក៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ១ (ចំណាត់ថ្នាក់ផ្កាយ ១)* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ខ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ២ (ចំណាត់ថ្នាក់ផ្កាយ ២)* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.គ៖ ភាគរយសាលារៀនអនុវត្តស្តង់ដាអប្បរមាទឹកស្អាតនិងអនាម័យកម្រិត ៣ (ចំណាត់ថ្នាក់ផ្កាយ៣)* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ឃ៖ ភាគរយសាលារៀនមានបង្គន់អនាម័យ* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.ង៖ ភាគរយសាលារៀនមានទឹកស្អាត* |
| **ច.ស.ក.ទី១ ៖ លើកកម្ពស់សុខភាពសិក្សា** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិត មន្ត្រីតែងតាំងស៊ប់ និងនិស្សិតជាប់អាហារូបករណ៍បានពិនិត្យសុខភាព និងកាយសម្បទា* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ខ៖ ចំនួនគ្រឹះស្ថានសិក្សាចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីលើកកម្ពស់សុខភាពសិក្សា* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.គ៖ ចំនួនមន្ត្រីបានចូលរួម សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន និងកិច្ចប្រជុំក្នុងនិងក្រៅប្រទេស* |

| | |
|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.១.ឃ៖ ចំនួនសៀវភៅសិក្សាគោលមុខវិជ្ជាអប់រំសុខភាព(ស.ភ.សិស្ស និងស.ភ.គ្រូ) បានបោះពុម្ពតាមកម្រិតថ្នាក់* | |
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍស្ថាប័ននិងសមត្ថភាពមន្ត្រីសុខភាពសិក្សាគ្រប់លំដាប់ថ្នាក់** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.ក៖ ចំនួនមន្ត្រីសុខភាពសិក្សាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចូលរួមការអប់រំផ្សព្វផ្សាយអំពីការលើកកម្ពស់សុខភាពសិក្សា* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៥.២.ខ៖ ចំនួនសិស្សានុសិស្សនៅតាមគ្រឹះស្ថានសិក្សា បានចូលរួមការអប់រំផ្សព្វផ្សាយការអប់រំសុខភាព និងប្រធានបទសុខភាពសាធារណៈ* | |
| **ឈ្មោះអនុកម្មវិធីទី ១.៦៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីអប់រំបច្ចេកទេស** | |
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| សេចក្តីពណ៌នាអនុកម្មវិធីទី ១.៦ ៖ អភិវឌ្ឍសិស្សកម្រិតមធ្យមសិក្សាទុតិយភូមិ ឱ្យមានសមត្ថភាពជំនាញបច្ចេកទេស មានគំនិតច្នៃប្រឌិត នវានុវត្តន៍ ស្មារតីផលិតភាពនិងសហគ្រិនភាព ប្រកបដោយគុណធម៌ និងចីរភាព។ តាមរយៈការអនុវត្តយន្តការការងារបច្ចេកទេសរបស់គ្រូប្រឹក្សាតាមសាលារៀនដែលរួមមាន ការអនុវត្តសេវាមគ្គុទ្ទេសក៍ក្នុងថ្នាក់រៀន សេវាប្រឹក្សាទល់មុខ និងសេវាការងារបណ្តាញ សិស្សានុសិស្សនឹងទទួលបានការគាំទ្រលើដំណើរការសិក្សារៀនសូត្រ ការបណ្តុះឥរិយាបថវិជ្ជមានក្នុងការរស់នៅ និងការគិតគូរពីគោលដៅអាជីពមុខរបរនាថ្ងៃអនាគត ដើម្បីឱ្យពួកគេអាចធ្វើសមាហរណកម្មទៅកាន់សង្គម និងចូលទៅកាន់ទីផ្សារការងារ ប្រកបដោយប្រសិទ្ធភាព។ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.ក៖ ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសដែលផ្តល់សេវាអប់រំបច្ចេកទេស* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.ខ៖ ចំនួនគ្រឹះស្ថានមធ្យមសិក្សាអនុវត្តកម្មវិធីមគ្គុទេសក៍អាជីព និងការផ្តល់ប្រឹក្សា* | |
| **ច.ស.ក.ទី១ ៖ អភិវឌ្ឍការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត អប់រំតម្រង់ទិសវិជ្ជាជីវៈ និងប្រឹក្សាអាជីព** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ក៖ ចំនួនសិស្សផ្នែកអប់រំបច្ចេកទេសដែលចូលរៀននៅគ្រឹះស្ថានផ្តល់សេវាអប់រំបច្ចេកទេសកម្រិត៩+៣ កើនឡើង* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ខ៖ ចំនួនសិស្សទទួលបានសេវាមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.គ៖ ចំនួនគ្រឹះស្ថានមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឯកសារណែនាំស្តីពីការជ្រើសរើសប្រភេទថ្នាក់វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គម ឬជំនាញបច្ចេកទេសវិជ្ជាជីវៈ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៦.១.ឃ៖ ចំនួនសាលាមធ្យមសិក្សាអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា* | |
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៦.២.ក៖ ចំនួនបុគ្គលិកអប់រំ ទទួលបានការអភិវឌ្ឍសមត្ថភាពក្នុងប្រទេស និងក្រៅប្រទេស* | |
| **ឈ្មោះអនុកម្មវិធីទី ១.៧៖ ការអភិវឌ្ឍការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន** | |

| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
|---|---|
| សេចក្តីពណ៌នាអនុកម្មវិធីទី ១.៧ ៖ ជូនដំណឹងដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តឱ្យបំពេញអំពីតម្រូវការកង្វះខាតគ្រូបង្រៀនតាមកម្រិត និងមុខវិជ្ជា ហើយធ្វើការបែងចែក ទៅតាមអាទិភាពនៃតម្រូវការតាមចំនួនក្របខណ្ឌថ្មីដែលទទួលបានពីក្រសួងមុខងារសាធារណៈ បន្ទាប់មកផ្សព្វផ្សាយដល់បេក្ខជនដើម្បីដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀន។ បេក្ខជនដែលប្រឡងជាប់ត្រូវទទួលការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដោយគោរពទៅតាមលក្ខខណ្ឌ នៃការបណ្តុះបណ្តាលឱ្យបានជោគជ័យ និងចេញទៅបង្រៀននៅតាមសាលារៀនចំណោះទូទៅដែលបានជ្រើសរើសមុនពេលប្រឡង។ គរុសិស្ស 12+2 ត្រូវទទួលការបណ្តុះបណ្តាលរយៈពេល២ឆ្នាំ ក្នុងនោះអនុវត្តកម្មសិក្សាគរុកោសល្យរយៈពេល ១៤សប្តាហ៍ (6+8) ។ គរុនិស្សិត12+4 ត្រូវទទួលការបណ្តុះបណ្តាលរយៈពេល៤ឆ្នាំ មានចំនួន ១២០ក្រេឌីត ក្នុងនោះអនុវត្តកម្មសិក្សាគរុកោសល្យរយៈពេល ២២សប្តាហ៍ (2+5+5+10)។ បើកវគ្គបំប៉ន និងសិក្ខាសាលា អំពីការគ្រប់គ្រងនៅតាមសាលារៀន វិធីសាស្រ្តបង្រៀន ការគ្រប់គ្រងបណ្ណាល័យ ចំណេះដឹងយេនឌ័រ ប្រឹក្សាសាលារៀនបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិជូនមន្ត្រីអប់រំ នាយកសាលា គ្រូឧទ្ទេស និងគ្រូបង្រៀន។ ជូនដំណឹងទៅគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនឱ្យបំពេញពាក្យសុំចុះឈ្មោះចូលរួមកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រង និងគ្រូបង្រៀន ផ្តោតលើឯកទេសនីមួយៗ។ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.ក៖ ចំនួនគរុសិស្ស គរុនិស្សិតបានទទួលការបណ្តុះបណ្តាលនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.ខ៖ ចំនួនមន្ត្រីគ្រប់គ្រងអប់រំ និងនាយក នាយករង គ្រូឧទ្ទេស គ្រូបង្រៀន បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅបានទទួលការលើកកម្ពស់សមត្ថភាព* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.គ៖ ចំនួនគណៈគ្រប់គ្រងសាលារៀន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គ្រូបង្រៀន និងគ្រូឧទ្ទេសបានដំឡើងគុណវុឌ្ឍិ* | |
| ច.ស.ក.ទី១ ៖ ជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិតត្រូវបានជ្រើសរើសតាមប្រព័ន្ធ ១២+២ និង ១២+៤ និងទទួលការបណ្តុះបណ្តាល នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.១.ខ៖ ចំនួនគរុសិស្ស គរុនិស្សិតត្រូវបានពិនិត្យតាមដានការអនុវត្តកម្មសិក្សាគរុកោសល្យ* | |
| ច.ស.ក.ទី២ ៖ លើកកម្ពស់សមត្ថភាពវិជ្ជាជីវៈ និងគុណវុឌ្ឍិ គណៈគ្រប់គ្រង គ្រូឧទ្ទេស និងគ្រូបង្រៀន | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.ក៖ ចំនួននាយកសាលារៀនចំណេះទូទៅបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.ខ៖ ចំនួនមន្ត្រីអប់រំ គ្រូឧទ្ទេស និងគ្រូបង្រៀនទទួលបានការលើកកម្ពស់សមត្ថភាព* | |

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៧.២.គ៖ ចំនួនគណៈគ្រប់គ្រងសាលារៀន គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន គ្រូបង្រៀន និងគ្រូឧទ្ទេស ចូលរួមវគ្គវិក្រឹតការដើម្បីដំឡើងគុណវុឌ្ឍិ*

**ឈ្មោះអនុកម្មវិធីទី ១.៨៖ ការអភិវឌ្ឍកម្មវិធីសិក្សា សម្ភារសិក្សា និងបណ្ណាល័យ**

| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
|---|---|

សេចក្ដីពណ៌នាអនុកម្មវិធីទី ១.៨ ៖ ដើម្បីផ្គត់ផ្គង់សៀវភៅសិក្សគោលឱ្យបានគ្រប់គ្រាន់នឹងសមស្របនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងធានាថាសិស្សមានសៀវភៅសិក្សាប្រើប្រាស់គឺចាំបាច់ត្រូវផ្គត់ផ្គង់សៀវភៅសិក្សាគោលជាប្រចាំដោយការផលិតសៀវភៅថ្មីនិងផ្គត់ផ្គង់បន្ថែមជំនួសចំនួនសៀវភៅខូច និងការផ្ដល់តម្រូវការបន្ថែមទៅតាមមុខវិជ្ជា កម្រិតថ្នាក់ និងការបង្កើនគុណភាពសៀវភៅ។ ការងារពិនិត្យតាមដាន ផ្សព្វផ្សាយ វាយតម្លៃលើការអនុវត្តកម្មវិធីសិក្សា ឯកសារគរុកោសល្យ ការធ្វើតម្រូវការសៀវភៅសិក្សាគោល ការងារបណ្ណាល័យ និងការអភិវឌ្ឍឯកសារនិងសម្ភារសិក្សាគឺជាធាតុចូលដ៏សំខាន់ដើម្បីធានបានថាសិស្សមានសៀវភៅសិក្សាគោលប្រើប្រាស់គ្រប់គ្រាន់នឹងធ្វើឱ្យការអនុវត្តកម្មវិធីសិក្សាបានត្រឹមត្រូវពេញលេញនិងមានប្រសិទ្ធភាពខ្ពស់។

-រៀបចំឱ្យមានការប្រឡងប្រជែងយកជ័យលាភីលេខ១ដល់លេខ៣ ផ្នែកស្នូត តែងនិពន្ធ អានអត្ថបទ និងវិភាគអត្ថបទ។

-រៀបចំការតាំងពិព័រណ៍សៀវភៅអំណានគ្រប់ប្រភេទ

-រៀបចំកម្មវិធីបង្ហាញស្នាដៃអ្នកនិពន្ធ

-រៀបចំសិក្ខាសាលាផ្សព្វផ្សាយពីបណ្ណាល័យស្តង់ដា ការអភិវឌ្ឍឯកសារគរុកោសល្យ កម្មវិធីសិក្សា វិធីសាស្ត្របង្រៀនថ្មីៗ និងការផលិតសម្ភារសិក្សា គឺដើម្បីគាំទ្រនិងលើកកម្ពស់គុណភាពអប់រំ ការអភិវឌ្ឍធនធានមនុស្សដែលមានគុណភាព តាមរយៈការរៀននិងបង្រៀន ដើម្បីឱ្យឆ្លើយតបទៅនឹងការរីកចំរើននៃសង្គមសេដ្ឋកិច្ច បច្ចេកវិទ្យា ក្នុងបរិបទតំបន់និងសាកល។

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.ក៖ ចំនួនសៀវភៅសិក្សាគោលត្រូវបានផ្គត់ផ្គង់សម្រាប់សិស្សថ្នាក់ទី១ដល់ទី១២*

*សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.ខ៖ ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យ និងសម្ដែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា*

*សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.គ៖ ចំនួនឯកសារគរុកោសល្យនិងកម្មវិធីសិក្សា*

**ច.ស.ក.ទី១ ៖ អភិវឌ្ឍ ផ្សព្វផ្សាយ និងពិនិត្យតាមដានកម្មវិធីសិក្សា សម្ភារសិក្សា ឯកសារគរុកោសល្យ និងការងារបណ្ណាល័យ**

*សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ក៖ ចំនួនសៀវភៅសិក្សាគោល ដែលសិស្សទទួលបានតាមផលធៀប១:១ សម្រាប់ថ្នាក់ទី១-៩ និង២:១ សម្រាប់មធ្យមសិក្សាទុតិយភូមិសម្រាប់ថ្នាក់ទី១០-ទី១២ និងចំនួនសៀវភៅអំណានផ្សេងៗ*

*សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ខ៖ ចំនួនសាលារៀនទទួលបានពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីសិក្សានិងផ្សព្វផ្សាយ*

*សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.គ៖ ចំនួនឯកសារគរុកោសល្យនិងកម្មវិធីសិក្សា*

<table>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ឃ៖ ចំនួនសិស្សចូលរួមប្រកួតតែងនិពន្ធ សូត្រកំណាព្យ និងសម្តែងសិល្បៈក្នុងទិវាជាតិអំណាន ១១មីនា</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំទី ១.៨.១.ង៖ ចំនួនបណ្ណាល័យដែលទទួលបានការគាំទ្រផ្នែកបច្ចេកទេសនិងសម្ភារបរិក្ខារ</td></tr>
<tr><td colspan="2">ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រី ស្តីពីការអភិវឌ្ឍកម្មវិធីសិក្សា ឯកសារគរុកោសល្យ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ១.៨.២.ក៖ ចំនួនមន្ត្រីនាយកដ្ឋានទទួលបានការបណ្តុះបណ្តាលស្តីពី ការអភិវឌ្ឍកម្មវិធីសិក្សា និងឯកសារគរុកោសល្យ</td></tr>
<tr><td colspan="2">ឈ្មោះអនុកម្មវិធីទី ១.៩៖ ពង្រីកការអប់រំបរិយាបន្នគ្រប់ភូមិសិក្សា</td></tr>
<tr><td>តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន</td><td>ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានអប់រំពិសេស</td></tr>
<tr><td colspan="2">សេចក្តីពណ៌នាអនុកម្មវិធីទី ១.៩ ៖ ពង្រីកថ្នាក់អប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិចកម្រិតបឋមសិក្សាពីថ្នាក់ទី១ ដល់ទី៣ តាមរយៈ មានសៀវភៅសិក្សាជាភាសាកំណើតស្របនឹងកម្មវិធីសិក្សាជាតិ និងគ្រូជាជនជាតិដើមភាគតិច ហើយវិធីសាស្រ្តបង្រៀន ឆ្លើយតបនឹងតម្រូវការសិស្ស ធានាកុមារជនជាតិដើមភាគតិចទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ (បង្កើនការចូលរៀន ការឡើងថ្នាក់ កាត់បន្ថយការត្រួតថ្នាក់ និងការបោះបង់ការសិក្សារបស់កុមារជនជាតិដើមភាគតិច) ។ ពង្រីកថ្នាក់អប់រំបរិយាបន្នសម្រាប់កុមារមានពិការភាពគ្រប់ភូមិសិក្សា ដើម្បីធានាថាកុមារមានតម្រូវការពិសេស កុមារមានពិការភាពគ្រប់ប្រភេទ បានចូលរៀនក្នុងថ្នាក់ធម្មតា ប្រកបដោយសមធម៌ និងបរិយាបន្ន ដែលចូលរួមកាត់បន្ថយការត្រួតថ្នាក់ ការបោះបង់។ ពង្រីក និងពង្រឹងថ្នាក់អប់រំពិសេស និងអប់រំសមាហរណកម្ម សម្រាប់កុមារមានពិការភាពកម្រិតធ្ងន់គ្រប់កម្រិតថ្នាក់នៅវិទ្យាល័យអប់រំពិសេស និងថ្នាក់អប់រំសមាហរណកម្ម ដើម្បីធានាការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន ដែលចូលរួមកាត់បន្ថយការត្រួតថ្នាក់ បោះបង់ និងបង្កើនការឡើងថ្នាក់ ជាពិសេសផ្តល់ឱកាសដល់អ្នកមានពិការភាពទទួលវគ្គបណ្តុះបណ្តាល និងបំប៉នវិជ្ជាជីវៈដើម្បីទទួលបានសមធម៌ និងសមភាពការងារក្នុងសង្គម ។</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.ក៖ ចំនួនគ្រូបង្រៀនថ្នាក់អប់រំពហុភាសាសម្រាប់បឋមសិក្សា</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.ខ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធ បានកសាងសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេស</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.គ៖ ចំនួនសិស្សមានពិការភាព(គ ថ្លង់ ពិការភ្នែក និងសតិបញ្ញា...) ដែលបានរៀននៅវិទ្យាល័យអប់រំពិសេស និងថ្នាក់សមាហរណកម្ម</td></tr>
<tr><td colspan="2">ច.ស.ក.ទី១ ៖ លើកកម្ពស់ និងអភិវឌ្ឍការអប់រំបរិយាបន្នគ្រប់ភូមិសិក្សា</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.១.ក៖ ចំនួនសៀវភៅសិក្សា និងសម្ភារសិក្សាអប់រំពហុភាសាត្រូវបានបោះពុម្ព</td></tr>
<tr><td colspan="2">ច.ស.ក.ទី២ ៖ លើកកម្ពស់សមត្ថភាពបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់លើការអប់រំបរិយាបន្ន</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.ក៖ ចំនួនគ្រូ និងអ្នកពាក់ពន្ធ័អប់រំពហុភាសាត្រូវបានទទួលវគ្គបំប៉នសមត្ថភាពស្តីពីការអប់រំពហុភាសា</td></tr>
</table>

| |
|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.ខ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានកសាងសមត្ថភាពស្តីពីការអប់រំបរិយាបន្ន និងអប់រំពិសេស* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ១.៩.២.គ៖ ចំនួនគ្រូបង្រៀន និងអ្នកពាក់ព័ន្ធត្រូវបានបណ្តុះបណ្តាលជំនាញអប់រំពិសេសស្តីពីការអប់រំពិសេស សម្រាប់បង្រៀននៅវិទ្យាល័យអប់រំពិសេស* |
| **កម្មវិធីទី ២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ** |
| គោលបំណងកម្មវិធី/អនុកម្មវិធី៖ អភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឱ្យឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម។ |
| សេចក្តីពណ៌នាកម្មវិធីទី ២ ៖ ចំនួននិស្សិតចូលរៀននៅឧត្តមសិក្សាមានការកើនឡើងទាំងបរិមាណ និងគុណភាពឆ្លើយតបទៅនឹងកំណែទម្រង់ឧត្តមសិក្សា និងយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ ស្របតាមសសរស្តម្ភនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គឺ ការងារ និងសមធម៌ ។ ការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងលើកម្រិតអភិវឌ្ឍន៍សមត្ថភាពគ្រឹះស្ថានតាមប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងមានលក្ខណៈជាក់ស្តែង និងឆ្លុះបញ្ចាំងពីស្ថានភាពអភិវឌ្ឍន៍សមត្ថភាពរបស់គ្រឹះស្ថាន។ លទ្ធផលដែលទទួលបានពីការធ្វើស្វ័យវាយតម្លៃនឹងបង្ហាញអំពីស្ថានភាពជាក់ស្តែងនៃកម្រិតអភិវឌ្ឍន៍គ្រឹះស្ថានស្ថានឧត្តមសិក្សានីមួយៗ និងចំណុចដែលត្រូវកែលម្អទៅតាមសូចនាករដែលបានកំណត់ ហើយលទ្ធផលនៃរបាយការណ៍ស្វ័យវាយតម្លៃនេះនឹងត្រូវបានយកទៅប្រើប្រាស់ ដើម្បីរៀបចំផែនការសកម្មភាព៥ឆ្នាំ សម្រាប់អភិវឌ្ឍន៍សមត្ថភាពគ្រឹះស្ថានក្នុងការឈានទៅសម្រេចបាននូវកម្រិតអភិវឌ្ឍន៍ខ្ពស់ជាងបច្ចុប្បន្ន ដូចជាប្រែក្លាយគ្រឹះស្ថានពីកម្រិតមិនទាន់ចាប់កំណើតទៅទើបចាប់កំណើត ឬ ពីកម្រិតទើបចាប់កំណើតទៅមានវិជ្ជាជីវៈដំបូង ឬ ពីក្រមិតមានវិជ្ជាជីវៈដំបូងទៅកម្រិតមានវិជ្ជាជីវៈពេញលេញ។ សូចនាករនេះវាស់វែងវឌ្ឍនភាពនៃការអភិវឌ្ឍ និងការលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យអប់រំនៅកម្ពុជាតាមរយៈសូចនាករគន្លឹះនៃការស្រាវជ្រាវប្រតិបត្តិ និងនវានុវត្តន៍គឺចំនួនគម្រោងស្រាវជ្រាវ និងនវានុវត្តន៍ ត្រូវបានអនុវត្ត នៅតាមគ្រឹះស្ថានឧត្តមសិក្សា ព្រោះសូចនាករនេះជាសូចនាករគន្លឹះ និងមានសារៈសំខាន់បំផុតក្នុងការធ្វើឱ្យសូចនាករមួយចំនួនទៀតអនុវត្តបានសម្រេចដូចជាចំនួនអ្នកស្រាវជ្រាវកើនឡើង ចំនួនអត្ថបទកើនឡើង និងផលិតផលដែលប្រើប្រាស់នៅទីផ្សារកើនឡើង។ល។ |

| | |
|---|---|
| តួនាទីអ្នកទទួលខុសត្រូវ៖ អគ្គនាយក | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ អគ្គនាយកដ្ឋានឧត្តមសិក្សា |
| *សូចនាករលទ្ធផលចុងក្រោយ ២.១៖ អត្រាចូលរៀនរួមនៅឧត្តមសិក្សា (១៨-២២)* | |
| *សូចនាករលទ្ធផលចុងក្រោយ ២.២៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតគ្រឹះស្ថានសិក្សា* | |
| *សូចនាករលទ្ធផលចុងក្រោយ ២.៣៖ ចំនួនគម្រោងស្រាជ្រាវប្រតិបត្តិ និងនាវានុវត្តន៍គាំទ្រការអភិវឌ្ឍ* | |
| **ឈ្មោះអនុកម្មវិធីទី ២.១៖ ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សា** | |
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានឧត្តមសិក្សា |

សេចក្តីពណ៌នាអនុកម្មវិធីទី ២.១ ៖ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនក្រោមឱវាទក្រសួងអយក.បាននឹងកំពុងបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររងនិងបរិញ្ញាបត្រឱ្យមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាឆ្លើយតបទៅនឹងកំណែទម្រង់ឧត្តមសិក្សានិងយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០ ក្នុងការបង្កើនផលិតភាព និងជំរុញកំណើនសេដ្ឋកិច្ច និងសង្គម។ សូចនាករនេះនឹងបង្ហាញអំពីចំនួននិស្សិតដែលកំពុងសិក្សានៅឧត្តមសិក្សាដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ គ្រឹះស្ថានឧត្តមសិក្សាក្រោមឱវាទក្រសួងអប់រំនឹងចូលរួមសម្រេចសូចនាករនេះដោយបញ្ចូលនិន្នន័យដោយប្រើប្រាស់ទម្រង់ទិន្នន័យដែលរៀបចំដោយការិយាល័យស្ថិតិ និងព័ត៌មាន និងសូចនាករដែលបានរៀបចំនៅក្នុង Data Management។ សូចនាករនៅក្នុងប្រព័ន្ធនេះគឺនឹងឆ្លើយតបទៅនឹងតម្រូវការទិន្នន័យដើម្បីរៀបរបាយការណ៍សន្និបាតរបាយការណ៍សម្រាប់រៀបចំគោលនយោបាយ និងផែនការនានា។ ការចូលរួមអនុវត្តប្រព័ន្ធនេះនឹងជួយចូលរួមរៀបចំផែនការដោយផ្អែកលើមូលដ្ឋានភស្តុតាងច្បាស់លាស់។ ការវាយតម្លៃកម្មវិធីជាប្រចាំនេះ តាមប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង មានលក្ខណៈជាក់ស្តែង និងឆ្លុះបញ្ចាំងពីស្ថានភាពនៃកម្មវិធីដែលបាន និងកំពុងធ្វើការបណ្តុះបណ្តាល។ លទ្ធផលដែលទទួលបានពីការធ្វើស្វ័យវាយតម្លៃ នឹងបង្ហាញអំពីស្ថានភាពជាក់ស្តែងនៃកម្មវិធីនោះ និងចំណុចដែលត្រូវកែលម្អទៅតាមសូចនាករដែលបានកំណត់។ លទ្ធផលនៃរបាយការណ៍ស្វ័យវាយតម្លៃនេះនឹងត្រូវបានយកទៅប្រើប្រាស់ ដើម្បីកែលម្អកម្មវិធីឱ្យសមស្របតាមសូចនាករក្នុងការឈានទៅសម្រេចបានពិន្ទុអប្បបរមានៃកម្មវិធីជាតិមានស្តង់ដា។

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់សិក្សា*

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ខ៖ ចំនួនកម្មវិធីត្រូវបានវាយតម្លៃតាមប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង*

**ច.ស.ក.ទី១ ៖ បង្កើនចំនួននិស្សិតមានសមត្ថភាពខ្ពស់ស្របតាមទីផ្សារការងារ**

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.១.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តកម្មវិធីបណ្តាញសាកលវិទ្យាល័យសាយប័រ*

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.ក៖ ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលផ្នែកស្ទែម*

**ច.ស.ក.ទី២ ៖ កសាងប្រព័ន្ធអភិបាលកិច្ច ដើម្បីអភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ**

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.២.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង*

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.២.ខ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានរៀបចំផែនការរយៈពេលវែង មធ្យម និងខ្លី*

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.១.២.គ៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានគ្រប់គ្រងទិន្នន័យឧត្តមសិក្សា*

**ឈ្មោះអនុកម្មវិធីទី ២.២៖ ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា**

| | |
|---|---|
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ |

| | |
|---|---|
| សេចក្តីពណ៌នាអនុកម្មវិធីទី ២.២ ៖ សូចនាករនេះសម្រាប់វាស់វែង និងពិនិត្យតាមដានលើកំណើនអត្ថបទស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលមានសមត្ថភាព អាចសរសេររបាយការណ៍ស្រាវជ្រាវ ឬនិក្ខេបបទ និងលទ្ធផលស្រាវជ្រាវ ពីមួយឆ្នាំ ទៅមួយឆ្នាំ សម្រាប់គាំទ្រ និងអភិវឌ្ឍដល់ការស្រាវជ្រាវនៅឧត្តមសិក្សា ស្របនឹងគោលនយោបាយទី១ របស់ក្រសួងអប់រំ យុវជន និងកីឡា។ សូចនាករនេះសម្រាប់វាស់វែង និងពិនិត្យតាមដានលើការគ្រប់គ្រងស្នាដៃស្រាវជ្រាវ និងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រច្បាស់លាស់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាពនៃការបង្រៀន ការរៀន និងការស្រាវជ្រាវស្របនឹងគោលនយោបាយទី១ របស់ក្រសួងអប់រំ យុវជន និងកីឡា។ សូចនាករនេះសម្រាប់វាស់វែង និងពិនិត្យតាមដានលើកំណើនបុគ្គលិកអប់រំ អ្នកស្រាវជ្រាវ និងនិស្សិត(ថ្នាក់ក្រោយបរិញ្ញាបត្រ)ដែលបានអភិវឌ្ឍសមត្ថភាពតាមរយៈការអនុវត្តគម្រោង និងនវានុវត្តន៍ ដើម្បីបំពេញការងារនៅតាមគ្រឹះស្ថានឧត្តមសិក្សាប្រកបដោយប្រសិទ្ធភាពស្របនឹងគោលនយោបាយទី២របស់ក្រសួងអប់រំ យុវជននិងកីឡា។ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.ក៖ ចំនួនអត្ថបទស្រាវជ្រាវត្រូវបានបោះពុម្ពនៅទស្សនាវដ្តី២លេខក្នុង១ឆ្នាំ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.ខ៖ ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.គ៖ ចំនួនគម្រោងស្រាវជ្រាវ និងនវានុវត្តន៍មានការកើនឡើង* | |
| ច.ស.ក.ទី១ ៖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាព នៃការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវ និងនវានុវត្តន៍ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ២.២.១.ក៖ ចំនួនគ្រឹះស្ថានឧត្តមសិក្សា ត្រូវបានពិនិត្យ និងវាយតម្លៃលើការបណ្តុះបណ្តាល* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.១.ខ៖ ចំនួនអត្ថបទស្រាវជ្រាវត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្វែម* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.១.គ៖ ចំនួនគម្រោងស្រាវជ្រាវ និងនវានុវត្តន៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាមានការកើនឡើង* | |
| ច.ស.ក.ទី២ ៖ ពង្រឹងអភិបាលកិច្ចស្ថាប័ន និងសមត្ថភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.២.ក៖ ចំនួនបុគ្គលិកអប់រំ និងគ្រឹះស្ថានឧត្តមសិក្សាដែលបានចូលរួមអភិវឌ្ឍសមត្ថភាពក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងារផ្សារភ្ជាប់នឹងសមិទ្ធកម្ម* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.២.ខ៖ ចំនួនគ្រឹះស្ថានដែលរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ និងការស្រាវជ្រាវ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.២.២.គ៖ ចំនួននិស្សិតទទួលបានអាហារូបករណ៍* | |
| ឈ្មោះអនុកម្មវិធីទី ២.៣៖ការពង្រឹងគុណភាពអប់រំ និងស្រាវជ្រាវ ប្រកបដោយប្រសិទ្ធភាព | |
| តួនាទីអ្នកទទួលខុសត្រូវ៖ សាកលវិទ្យាធិការ | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ សាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ |

| | |
|---|---|
| សេចក្តីពណ៌នាអនុកម្មវិធីទី ២.៣ ៖ ដើម្បីសម្រេចនូវគោលបំណងនៃសូចនាករនេះសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវ ពង្រឹងសមត្ថភាពស្ថាប័ន ពង្រឹងគុណភាព ផ្ទៃក្នុង កែលម្អកម្មវិធីសិក្សា បំប៉នសមត្ថភាពបុគ្គលិកអប់រំជាពិសេសលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យបង្រៀន ផ្តល់នូវការស្រាវជ្រាវ និង នវានុវត្តន៍ដល់និស្សិត ប្រកបដោយគុណភាពផ្សារភ្ជាប់ក្នុងសកម្មភាពឧស្សាហកម្ម កសិកម្មនិងសង្គម ដែលមានការគាំទ្រដំណើរការអង្គភាពទាំងផ្នែកសម្ភារនិងបរិក្ខារ ព្រមទាំងសេវាកម្មផ្សេងៗទៀត ដើម្បីគាំទ្រដល់ការរៀន និងបង្រៀនតាមបែបសម័យបច្ចេកវិទ្យាឌីជីថល។ ដើម្បីសម្រេចនូវគោលបំណងនៃសូចនាករនេះសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវ ពង្រឹងសមត្ថភាពស្ថាប័ន ពង្រឹងគុណភាព ផ្ទៃក្នុង កែលម្អកម្មវិធីសិក្សា បំប៉នសមត្ថភាពបុគ្គលិកអប់រំជាពិសេសលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យបង្រៀន ផ្តល់នូវការស្រាវជ្រាវនិង នវានុវត្តន៍ដល់និស្សិត ប្រកបដោយគុណភាពផ្សារភ្ជាប់ក្នុងសកម្មភាពឧស្សាហកម្ម កសិកម្មនិងសង្គម ដែលមានការគាំទ្រដំណើរការអង្គភាពទាំងផ្នែកសម្ភារនិងបរិក្ខារ ព្រមទាំងសេវាកម្មផ្សេងៗទៀត ដើម្បីគាំទ្រដល់ការរៀន និងបង្រៀនតាមបែបសម័យបច្ចេកវិទ្យាឌីជីថល។ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.ក៖ ភាគរយនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ឆ្នាំទី៤ ថ្នាក់អាហារូបករណ៍និងបង់ថ្លៃប្រឡងជាប់បរិញ្ញាបត្រ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.ខ៖ ចំនួននិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ សិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ* | |
| ច.ស.ក.ទី១ ៖ កែលម្អសមត្ថភាពរៀននិងបង្រៀន និង ការស្រាវជ្រាវ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.ក៖ ចំនួននិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញសិក្សាផ្នែក STEM* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.ខ៖ ចំនួនគម្រោងសិក្សាស្រាវជ្រាវរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.គ៖ ចំនួនកម្មវិធីសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានកែលម្អ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.១.ឃ៖ ភាគរយនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញបញ្ចប់ការសិក្សាមានការងារធ្វើនៅតាមស្ថាប័ននានា* | |
| ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៣.២.ក៖ ភាគរយនៃបុគ្គលិកអប់រំសាកលវិទ្យាល័យភូមិន្ទភ្នំពេញទទួលបានការបំប៉នសមត្ថភាពតាមមុខជំនាញ* | |
| ឈ្មោះអនុកម្មវិធីទី ២.៤៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | |
| តួនាទីអ្នកទទួលខុសត្រូវ៖ សាកលវិទ្យាធិការ | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ |
| សេចក្តីពណ៌នាអនុកម្មវិធីទី ២.៤ ៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៤.ក៖ ចំនួនសិស្សនិស្សិតចូលរៀនបរិញ្ញាបត្រ បរិញ្ញាបត្ររង និងគុណវុឌ្ឍិ១ ២ ៣ ទាំងអាហារូបករណ៍ និងមិនមែនអាហារូបករណ៍ត្រូវបានបង្កើន* | |
| ច.ស.ក.ទី១ ៖ កែលម្អសមត្ថភាពរៀននិងបង្រៀន និងការស្រាវជ្រាវ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៤.១.ក៖ កម្មវិធីសិក្សានឹងត្រូវកែលម្អតាមតម្រូវការទីផ្សារ* | |

| | |
|---|---|
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍ សមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៤.២.ក៖ ភាគរយនៃបុគ្គលិកអប់រំនិងសាស្ត្រាចារ្យកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតត្រូវបានបង្កើនគុណវុឌ្ឍិ* | |
| **ឈ្មោះអនុកម្មវិធីទី ២.៥៖ លើកកម្ពស់គុណភាព នៃការបណ្ដុះបណ្ដាល និងការស្រាវជ្រាវ** | |
| តួនាទីអ្នកទទួលខុសត្រូវ៖ សាកលវិទ្យាធិការ | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ សាកលវិទ្យាល័យជាតិ ជា ស៊ីមកំចាយមារ |
| សេចក្ដីពណ៌នាអនុកម្មវិធីទី ២.៥ ៖ ដើម្បីលើកកម្ពស់គុណភាពនៃការបណ្ដុះបណ្ដាល និងការស្រាវជ្រាវ សាកលវិទ្យាល័យផ្ដោតយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការធ្វើទំនើបកម្មសម្ភារបរិក្ខារៀន និងបង្រៀន ការកែលម្អកម្មវិធីសិក្សា ការសិក្សាស្រាវជ្រាវ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ និងដៃគូអភិវឌ្ឍន៍ ក្នុងនិងក្រៅប្រទេស ដើម្បីធ្វើឲ្យយន្តការនៃការបណ្ដុះបណ្ដាលដល់សិស្ស-និស្សិតឱ្យមានសមត្ថភាពពេញលេញលើ ចំណេះដឹង ជំនាញ ព្រមទាំងអភិវឌ្ឍអាកប្បកិរិយាសមស្របជាពលរដ្ឋល្អ ចេះរួមរស់ជាមួយគ្នា ដោយសុខដុមរមនា និងមនសិការជាតិ ហើយឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងវប្បធម៌ក្នុងប្រទេស តំបន់ និងអន្តរជាតិ។ ដើម្បីលើកកម្ពស់គុណភាពនៃការបណ្ដុះបណ្ដាល និងការស្រាវជ្រាវ សាកលវិទ្យាល័យផ្ដោតយកចិត្តទុកដាក់លើការអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការធ្វើទំនើបកម្មសម្ភារបរិក្ខារៀន និងបង្រៀន ការកែលម្អកម្មវិធីសិក្សា ការសិក្សាស្រាវជ្រាវ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ និងដៃគូអភិវឌ្ឍន៍ ក្នុងនិងក្រៅប្រទេស ដើម្បីធ្វើឲ្យយន្តការនៃការបណ្ដុះបណ្ដាលដល់សិស្ស-និស្សិតឱ្យមានសមត្ថភាពពេញលេញលើ ចំណេះដឹង ជំនាញ ព្រមទាំងអភិវឌ្ឍអាកប្បកិរិយាសមស្របជាពលរដ្ឋល្អ ចេះរួមរស់ជាមួយគ្នា ដោយសុខដុមរមនា និងមនសិការជាតិ ហើយឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងប្រទេស តំបន់ និងអន្តរជាតិ។ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.ក៖ ភាគរយនិស្សិតដែលបញ្ចប់ការសិក្សាទទួលបានការងារធ្វើនៅតាមស្ថាប័ននានា* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.ខ៖ ចំនួនអត្ថបទនៃការសិក្សាស្រាវជ្រាវរបស់គ្រូបុគ្គលិកអប់រំត្រូវបានបោះពុម្ពប្រចាំឆ្នាំ* | |
| **ច.ស.ក.ទី១ ៖ អភិវឌ្ឍការបណ្ដុះបណ្ដាលប្រកបដោយគុណភាព និងឆ្លើយតបទៅនឹងទីផ្សារការងារ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៥.១.ក៖ ចំនួននិស្សិតរៀនមុខវិជ្ជាវិទ្យាសាស្ត្រ STEAM* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.១.ខ៖ ចំនួនគម្រោងដែលបុគ្គលិកអប់រំបានសិក្សាស្រាវជ្រាវ* | |
| **ច.ស.ក.ទី២ ៖ លើកកម្ពស់អភិបាលកិច្ច អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៥.២.ក៖ ចំនួនមន្ត្រីអប់រំបានចូលរួមវគ្គសិក្ខាសាលា និងការបណ្ដុះបណ្ដាលស្ដីពីការងារដឹកនាំ និងគ្រប់គ្រង* | |
| **ឈ្មោះអនុកម្មវិធីទី ២.៦៖ ការអភិវឌ្ឍការបណ្ដុះបណ្ដាល និងស្រាវជ្រាវ** | |
| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |

| |
|---|
| សេចក្តីពណ៌នាកម្មវិធីទី ២.៦ ៖  ការបណ្តុះបណ្តាលនិស្សិតឱ្យមានសមត្ថភាពខ្ពស់ប្រកបដោយទេពកោសល្យស្របតាមចក្ខុវិស័យកម្ពុជាមុនឆ្នាំ២០៣០ ជាអាទិភាពចម្បងរបស់វិទ្យាស្ថានដើម្បីរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ភាពមានការងារធ្វើរបស់និស្សិត ការបង្កើនប្រសិទ្ធភាព និងផលិតភាពក្នុងសហគ្រាស។ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ កម្មវិធីសិក្សានីមួយៗរបស់វិទ្យាស្ថានបានពិនិត្យនិងកែលម្អជាប្រចាំជាមួយដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុនសហគ្រាស និងភាគីពាក់ព័ន្ធនានា។ ក្រៅពីនេះ សមត្ថភាពបង្រៀនរបស់សាស្ត្រចារ្យត្រូវបានលើកកម្ពស់ជាប្រចាំ។ ការអនុវត្តសកម្មភាពស្រាវជ្រាវដែលបានលើកកម្ពស់ក៏បានចូលរួមចំណែកក្នុងការបង្កើនគុណភាពនៃការបណ្តុះបណ្តាលដែរ។ វិទ្យាស្ថានមានកម្មវិធីចុះកម្មសិក្សានៅតាមក្រុមហ៊ុនសហគ្រាស ស្ថាប័នរដ្ឋនិងឯកជននានា ដើម្បីផ្សារភ្ជាប់ការសិក្សាទៅនឹងការអនុវត្តជាក់ស្តែង បង្កើតបណ្តាញទំនាក់ទំនង ផ្តល់ឱកាសឱ្យនិស្សិតបង្ហាញសមត្ថភាពរបស់ខ្លួន ដើម្បីទទួលបានការងារធ្វើភ្លាមៗក្រោយពីបញ្ចប់ការសិក្សា។ ការិយាល័យទំនាក់ទំនងសហគ្រាសរបស់វិទ្យាស្ថានបានរៀបចំពិព័រណ៍ការងារជារៀងរាល់ឆ្នាំដើម្បីជំរុញការទទួលបានការងាររបស់និស្សិត។ ការចូលរួមក្នុងគម្រោងស្រាវជ្រាវរបស់និស្សិតបានលើកកម្ពស់ចំណេះដឹងផ្នែកស្រាវជ្រាវ ការសរសេរនិក្ខេបបទបែបវិទ្យាសាស្ត្រ ការធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ ការសរសេរអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ ដើម្បីត្រៀមខ្លួនរួចជាស្រេចក្នុងការបន្តការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រទាំងក្នុងនិងក្រៅប្រទេស។  ការអនុវត្តគម្រោងស្រាវជ្រាវប្រតិបត្តិ ផ្តើមអាជីវកម្ម និងផ្ទេរបច្ចេកវិទ្យាដើម្បីសុខដុមនីយកម្មនិងការអភិវឌ្ឍមុនឆ្នាំ២០៣០ ជាអទិភាពមួយក្នុងចំណោមអាទិភាពធំៗរបស់វិទ្យាស្ថាន។ ក្នុងបរិបទនេះ វិទ្យាស្ថាន បានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ដែលជាសេនាធិការឱ្យវិទ្យាស្ថានលើការងារស្រាវជ្រាវ។ បច្ចុប្បន្ននេះ វិទ្យាស្ថាន បានបង្កើតអង្គភាពស្រាវជ្រាវចំនួន៥អង្គភាព នៅក្រោមចំណុះមជ្ឈមណ្ឌលស្រាវជ្រាវ និងនវានុវត្តន៍ គឺ (1)បច្ចេកវិទ្យាថាមពលនិងការគ្រប់គ្រង (ETM) (2)បច្ចេកវិទ្យាអាហារនិងអាហារូបត្ថម្ភ (FTN) (3)មេកាត្រូនិចនិងបច្ចេកវិទ្យាព័ត៌មាន (MIT) (4)វិទ្យាសាស្ត្ររូបធាតុនិងរចនាសម្ព័ន្ធ (MSS) និង (5)ធនធានទឹកនិងបរិស្ថាន (WAE)។ ជារៀងរាល់លើឆ្នាំ មជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍រៀបចំសន្និសីទវិទ្យាសាស្ត្របង្កើតជាវេទិកាចែករំលែករបកគំហើញស្រាវជ្រាថ្មីៗទាំងកម្រិតជាតិ និងអន្តរជាតិ។ លើសពីនេះ មជ្ឈមណ្ឌលក៏បានជំរុញការបោះពុម្ពក្នុងកម្រិតអន្តរជាតិ។  ការកសាងធនធានមនុស្សជាផ្នែកមួយនៃយុទ្ធសាស្ត្រទី២ក្នុងផែនការយុទ្ធសាស្ត្រ២០២១-២០៣០ របស់វិទ្យាស្ថាន។ ការកសាងធនធានមនុស្សថ្នាក់បណ្ឌិតឱ្យស្របតាមផែនការគឺមានភាពចាំបាច់ណាស់សម្រាប់អភិវឌ្ឍវិទ្យាស្ថានទាំងផ្នែកកម្មវិធីបណ្តុះបណ្តាល ផ្នែកស្រាវជ្រាវ និងផ្នែកអភិបាលកិច្ច ។ ការបង្កើនធនធានមនុស្សថ្នាក់បណ្ឌិតរបស់វិទ្យាស្ថានតាមរូបភាព៣យ៉ាងគឺ (១)ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតក្នុងវិទ្យាស្ថានផ្ទាល់ (២)បញ្ជូនបុគ្គលិកទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅបណ្តាសាកលដៃគូ (៣)បញ្ជូនបុគ្គលិកទៅបន្តការសិក្សាថ្នាក់បណ្ឌិតនៅបណ្តាសាកលអន្តរជាតិផ្សេងៗទៀត។ |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.ក៖ ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬ បន្តការសិក្សា* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.ខ៖ ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ* |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.គ៖ ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត* |
| **ច.ស.ក.ទី១ ៖ លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល ការស្រាវជ្រាវ និងនវានុវត្តន៍** |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.ក៖ ភាគរយនិស្សិតបញ្ចប់ការសិក្សាមានការងារធ្វើ ឬ បន្តការសិក្សា* |

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.១.ខ៖ ចំនួនប្រធានបទស្រាវជ្រាវសរុបដែលបានបោះពុម្ពផ្សាយ ឬ ចូលរួមធ្វើបទបង្ហាញក្នុងសន្និសីទវិទ្យាសាស្ត្រ*

**ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពគ្រឹះស្ថាន និងមន្ត្រីជំនាញ**

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.៦.២.ក៖ ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត*

**ឈ្មោះអនុកម្មវិធីទី ២.៧៖ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងស្រាវជ្រាវ**

| តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ វិទ្យាស្ថានជាតិអប់រំ |
|---|---|

សេចក្តីពណ៌នាអនុកម្មវិធីទី ២.៧ ៖ និស្សិតថ្នាក់បណ្ឌិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បរិញ្ញាបត្រគ្រប់ជំនាញនៅវិទ្យាស្ថានជាតិអប់រំ ជាធនធានមនុស្សដ៏សំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍វិស័យអប់រំនៅកម្ពុជា។ និស្សិតថ្នាក់បណ្ឌិតត្រូវបានជ្រើសដោយយកចិត្តទុកដាក់បំផុតចេញពីមន្ត្រីអប់រំគ្រប់កម្រិតថ្នាក់ដែលកំពុងបម្រើការនៅតាមស្ថាប័ន និងគ្រឹះស្ថានអប់រំនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយបន្ទាប់ពីបានបញ្ចប់ការសិក្សា និស្សិតនឹងទទួលបាននូវចំណេះដឹង និងជំនាញបន្ថែមទៀតទាក់ទងទៅនឹងការគ្រប់គ្រងអប់រំ ការរៀបចំគោលនយោបាយអប់រំ ការរៀបចំកម្មវិធីសិក្សានិងវិធីសាស្ត្របង្រៀន ដែលអាចជួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការធ្វើកំណែទម្រង់វិស័យអប់រំ។ បន្ទាប់ពីបញ្ចប់ការសិក្សា និស្សិតនឹងចូលរួមអភិវឌ្ឍការងារគ្រប់គ្រងអប់រំនៅតាមគ្រឹះស្ថាននានាដែលពួកគាត់កំពុងបម្រើការងារ។ ការវិនិយោគលើធនធានគ្រូបង្រៀន អាចធានាបាននូវការអប់រំប្រកបដោយគុណភាព និងបរិយាបន្នដែលបានចែងនៅក្នុងគោលនយោបាយអប់រំ។ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំជាការងារអាទិភាពមួយក្នុងវិស័យអប់រំទាំងមូល។ វិទ្យាស្ថានជាតិអប់រំបានចូលរួមចំណែកក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំគ្រប់ប្រភេទ។ ការបំប៉នមន្ត្រីគ្រប់គ្រងអប់រំថ្នាក់រាជធានី ខេត្ត នឹងជួយអភិវឌ្ឍជំនាញគ្រូបង្រៀន។ អធិការអប់រំដែលកំពុងបម្រើការងារនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវទទួលការបំប៉នបន្ថែមទៅជំនាញថ្មីៗដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃការអប់រំ ដើម្បីអាចវាយតម្លៃការអប់រំនៅតាមសាលារៀន និងជួយអភិវឌ្ឍការអប់រំគ្រប់កម្រិតថ្នាក់។ ការបំប៉នគ្រូឧទ្ទេសថ្នាក់ជាតិគឺធានាបាននូវគុណភាពក្នុងការបណ្តុះបណ្តាលបន្តគ្រប់ប្រភេទ។ វគ្គបំប៉ននាយកវិទ្យាល័យគឺជួយនាយកសាលាឱ្យអនុវត្តនូវការគ្រប់គ្រងតាមសាលារៀន និងជំរុញបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលាឱ្យអាចអនុវត្តការងារបានកាន់តែល្អប្រសើរ។ ការបំប៉នប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ នឹងផ្តល់នូវចំណេះដឹងនិងជំនាញថ្មីៗផ្នែកវិធីសាស្ត្របង្រៀន ការបង្រៀនពិសោធន៍វិទ្យាសាស្ត្រ និងការអប់រំស្ទែម។ ការបណ្តុះបណ្តាលបន្តនៅក្នុងផ្នែកនេះគឺជាយន្តការមួយដែលវិទ្យាស្ថានជាតិអប់រំចូលរួមជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការពង្រឹងការអនុវត្តការងាររបស់មន្ត្រីអប់រំនៅថ្នាក់ក្រោមជាតិ។ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំជាការងារអាទិភាពមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ វិទ្យាស្ថានជាតិអប់រំ មានផែនការក្នុងការអភិវឌ្ឍសមត្ថភាពការងារបុគ្គលិកអប់រំដែលមានចែងក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន ឆ្លើយតបនឹងបរិបទនៃការបណ្តុះបណ្តាលគ្រូបង្រៀន។ ក្នុងន័យនេះ ចំនួនបុគ្គលិកអប់រំវិទ្យាស្ថានជាតិអប់រំ ត្រូវបានបញ្ជូនឱ្យបន្តការសិក្សាទាំងក្នុង និងក្រៅប្រទេសជារៀងរាល់ឆ្នាំដើម្បីធានាបាននូវគុណភាពនៃការបណ្តុះបណ្តាល ការឆ្លើយតបទៅនឹងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំ និងតម្រូវការនៃការបណ្តុះបណ្តាលគ្រូ។

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.ក៖ ចំនួនគរុនិស្សិត និងនិស្សិតបានបញ្ចប់ការបណ្តុះបណ្តាលប្រចាំឆ្នាំ*

*សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.ខ៖ ចំនួនបុគ្គលិកអប់រំបានទទួលការអភិវឌ្ឍន៍វិជ្ជាជីវៈ និងការស្រាវជ្រាវ*

<table>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.គ៖ ចំនួនបុគ្គលិកអប់រំវិទ្យាស្ថានជាតិអប់រំបានទទួលការអភិវឌ្ឍន៍សមត្ថភាពទាំងក្នុង និងក្រៅប្រទេស</td></tr>
<tr><td colspan="2">ច.ស.ក.ទី១ ៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលដំបូង ការបណ្តុះបណ្តាលបន្ត និងការស្រាវជ្រាវ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.១.ក៖ ចំនួនគរុសិស្ស គរុនិស្សិត និស្សិត បានទទួលបណ្តុះបណ្តាលគ្រប់វគ្គ។</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.១.ខ៖ ចំនួនមន្ត្រីអប់រំថ្នាក់រាជធានី ខេត្ត និងគ្រូបង្រៀនបានទទួលគ្រប់វគ្គបំប៉ន។</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំទី ២.៧.១.គ៖ ចំនួនប្រធានបទបានស្រាវជ្រាវដោយបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំ</td></tr>
<tr><td colspan="2">ច.ស.ក.ទី២ ៖ ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.២.ក៖ ចំនួនបុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំបានចូលរួមវគ្គបំប៉នសមត្ថភាពទាំងក្នុងនិងក្រៅប្រទេស</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៧.២.ខ៖ ចំនួនបុគ្គលិកអប់រំបានទទួលការបំប៉នស្តីពីដំណើរការលើកកម្ពស់គុណភាពអប់រំ</td></tr>
<tr><td colspan="2">ឈ្មោះអនុកម្មវិធីទី ២.៨៖ ការលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ</td></tr>
<tr><td>តួនាទីអ្នកទទួលខុសត្រូវ៖ សាកលវិទ្យាធិការ</td><td>ឈ្មោះអង្គភាពទទួលខុសត្រូវ៖ សាកលវិទ្យាល័យស្វាយរៀង</td></tr>
<tr><td colspan="2">សេចក្តីពណ៌នាអនុកម្មវិធីទី ២.៨ ៖ សាកលវិទ្យាល័យ រៀបចំកែលម្អកម្មវិធីសិក្សា កែលម្អបរិស្ថានសិក្សា បំពាក់សម្ភារសម្រាប់បំរើការរៀន និងបង្រៀន និងរៀបចំការប្រឡងឆមាស ប្រឡងបញ្ចប់ការសិក្សា ការពារសារណាបទបញ្ចប់ការសិក្សា ការចូលរួមកាងារសហគមន៍នានា។ សាកលវិទ្យាល័យរៀបចំ បង្កើតគម្រោងស្រាវជ្រាវ និងគម្រោងប្រកួតប្រជែងលើគម្រោងអាជីវកម្ម។ សាកលវិទ្យាល័យរៀបចំ បង្កើតគម្រោងស្រាវជ្រាវ និងគម្រោងប្រកួតប្រជែងលើគម្រោងអាជីវកម្ម។</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.ក៖ ចំនួននិស្សិតបញ្ចប់ការសិក្សាស្របតាមតម្រូវការទីផ្សារ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.ខ៖ ចំនួនគម្រោងស្រាវជ្រាវបានអនុវត្ត និងប្រើប្រាស់ដោយទីផ្សារ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.គ៖ ចំនួនពិន្ទុនៃការវាយតម្លៃកម្រិតអភិវឌ្ឍគ្រឹះស្ថានប្រចាំឆ្នាំ</td></tr>
<tr><td colspan="2">ច.ស.ក.ទី១ ៖កែលម្អសមត្ថភាពរៀននិងបង្រៀន និង ការស្រាវជ្រាវ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ក៖ ចំនួនកម្មវិធីសិក្សាត្រូវបានកែលម្អ ឬបង្កើតថ្មី</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ខ៖ ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លីស្របតាមតម្រូវការកម្មវិធីសិក្សាដែលបានកែលម្អ ឬបង្កើតថ្មី</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.គ៖ ចំនួនមុខវិជ្ជាដែលបានអនុវត្តវិធីសាស្ត្របង្រៀន PBL/IBL ដាក់បញ្ចូលក្នុងប្រព័ន្ធ LMS</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ឃ៖ ចំនួននិស្សិតចូលរៀនឆ្នាំទី១</td></tr>
</table>

| | |
|---|---|
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.ង៖ ចំនួនអត្ថបទស្រាវជ្រាវបានបោះពុម្ពផ្សាយ ឬធ្វើបទបង្ហាញក្នុងសន្និសីទ* | |
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និង មន្ត្រីជំនាញ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.២.ក៖ ចំនួនរបាយការណ៍ស្វ័យវាយតម្លៃកម្រិតកម្មវិធីត្រូវបានផលិត* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.២.ខ៖ ចំនួនបុគ្គលិកចូលរួមការចុះកិច្ចព្រមព្រៀងលទ្ធផលឆ្នាំ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៨.១.គ៖ អត្រានៃសេចក្តីពេញចិត្តរបស់និស្សិតលើបរិស្ថានសិក្សា* | |
| **ឈ្មោះអនុកម្មវិធីទី ២.៩៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាល និងការស្រាវជ្រាវ** | |
| តួនាទីអ្នកទទួលខុសត្រូវ៖សាកលវិទ្យាធិការ | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ សាកលវិទ្យាល័យជាតិមានជ័យ |
| សេចក្តីពណ៌នាអនុកម្មវិធីទី ២.៩ ៖ ចំនួននិស្សិតចូលរៀននៅសាកលវិទ្យាល័យមានការកើនឡើងមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នាឆ្លើយតបទៅនឹងកំណែទម្រង់ឧត្តមសិក្សា ផែនការយុទ្ធសាស្ត្រអប់រំ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់សាកលវិទ្យាល័យជាតិមានជ័យ។ | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.ក៖ ចំនួននិស្សិតចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលវិទ្យាសាស្ត្រ និងសង្គម* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.ខ៖ ចំនួនកម្មវិធីអប់រំតាមមុខជំនាញដែលបានកែលម្អស្របតាមប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធី* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.គ៖ ចំនួនឯកសារសិក្សាពិសោធន៍ស្រាវជ្រាវត្រូវបានបង្កើត និងបោះពុម្ព* | |
| **ច.ស.ក.ទី១ ៖ កែលម្អសមត្ថភាពរៀននិងបង្រៀន និងការស្រាវជ្រាវ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.១.ក៖ ភាគរយនិស្សិតគ្រប់ជំនាញបញ្ចប់ការសិក្សាមានការងារធ្វើ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.១.ខ៖ ភាគរយនៃការអភិវឌ្ឍន៍ស្តង់ដា និងសៀវភៅណែនាំសម្រាប់ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងរបស់សាកលវិទ្យាល័យជាតិមានជ័យ* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.១.គ៖ ភាគរយនៃការរៀបចំបន្ទប់ស្ទីឌីយូត្រូវបានបង្កើតសម្រាប់ចងក្រងមុខវិជ្ជាឌីជីថល* | |
| **ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ** | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.១.ក៖ ចំនួនកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិកើនឡើង* | |
| *សូចនាករលទ្ធផលក្នុងឆ្នាំ ២.៩.២.ខ៖ ភាគរយនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យនិស្សិត បុគ្គលិក និងបណ្ណាល័យ* | |
| **ឈ្មោះអនុកម្មវិធីទី ២.១០៖ ការពង្រឹងគុណភាព ប្រសិទ្ធភាពអប់រំ និងស្រាវជ្រាវ** | |
| តួនាទីអ្នកទទួលខុសត្រូវ៖សាកលវិទ្យាធិការ | ឈ្មោះអង្គភាពទទួលខុសត្រូវ៖ សាកលវិទ្យាល័យជាតិបាត់ដំបង |

<table>
<tr><td colspan="2">សេចក្ដីពណ៌នាអនុកម្មវិធីទី ២.១០៖ ផ្ដល់សេវាអប់រំល្អជូននិស្សិត(រៀបចំ និងផ្សព្វផ្សាយបទបញ្ញាផ្ទៃក្នុងរបស់និស្សិត, បទបញ្ញាផ្ទៃក្នុងរបស់គ្រូបង្រៀន, គោលការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងសេវាសិក្សា) ផ្ដល់ព័ត៌មានគ្រប់ជ្រុងជ្រោយជូននិស្សិត, តាមដានលទ្ធផលសិក្សារបស់និស្សិត, មានទំនាក់ទំនងជាមួយអ្នកអាណាព្យាបាលរបស់និស្សិត និងប្រឹក្សាយោបល់ជូននិស្សិតលើបញ្ហាការសិក្សា។ មានកិច្ចសហប្រតិបត្តិការល្អជាមួយដៃគូវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីនិស្សិតមានឱកាសចុះធ្វើកម្មសិក្សាដោយផ្ទាល់ និងទទួលបានបទពិសោធន៍។ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយម្ចាស់សហគ្រិន អ្នកអាណាព្យាបាលនិស្សិត និងភាគីពាក់ព័ន្ធ ដើម្បីស្វែងយល់ពីតម្រូវការទីផ្សារការងារ។ ជំរុញនិស្សិតសិក្សាគម្រោងស្រាវជ្រាវដែលសហគ្រាសត្រូវការ។ បំពាក់សម្ភាររូបវន្តសម្រាប់និស្សិតអនុវត្តលើការស្រាវជ្រាវ។</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលចុងក្រោយ ២.១០.ក៖ ចំនួននិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលចុងក្រោយ ២.១០.ខ៖ ចំនួនលទ្ធផលគម្រោងស្រាវជ្រាវ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលចុងក្រោយ ២.១០.គ៖ ចំនួនលទ្ធផលវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងកម្រិតគ្រឹះស្ថានសិក្សា</td></tr>
<tr><td colspan="2">ច.ស.ក.ទី១ ៖ កែលម្អសមត្ថភាពរៀននិងបង្រៀន និងការស្រាវជ្រាវ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.១០.១.ក៖ ចំនួននិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.១០.១.ខ៖ ចំនួនគម្រោងស្រាវជ្រាវរបស់និស្សិត និងបុគ្គលិកអប់រំ</td></tr>
<tr><td colspan="2">ច.ស.ក.ទី២ ៖ អភិវឌ្ឍសមត្ថភាពស្ថាប័ន និងមន្ត្រីជំនាញ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.១០.២.ក៖ ចំនួនលទ្ធផលអនុវត្តការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុងកម្រិតកម្មវិធីអប់រំ និងកម្រិតគ្រឹះស្ថានសិក្សា</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.១០.២.ខ៖ ចំនួនបុគ្គលិកអប់រំនៃសាកលវិទ្យាល័យជាតិបាត់ដំបងត្រូវបានវាយតម្លៃការងារ</td></tr>
<tr><td colspan="2">សូចនាករលទ្ធផលក្នុងឆ្នាំ ២.១០.២.គ៖ ភាគរយនិស្សិតមានការងារក្រោយបញ្ចប់ការសិក្សា</td></tr>
<tr><td colspan="2">ឈ្មោះអនុកម្មវិធីទី ២.១៣៖ ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា</td></tr>
<tr><td>តួនាទីអ្នកទទួលខុសត្រូវ៖ ប្រធាន</td><td>ឈ្មោះអង្គភាពទទួលខុសត្រូវ៖ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា</td></tr>
<tr><td colspan="2">សេចក្ដីពណ៌នាអនុកម្មវិធីទី ២.១៣៖ ការវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាប្រព្រឹត្តទៅតាមដំណាក់កាលដូចខាងក្រោម៖<br>១. គ្រឹះស្ថានឧត្តមសិក្សាផ្ញើរបាយការណ៍ស្វ័យវាយតម្លៃមកគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា<br>២. គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាពិនិត្យគុណភាពនៃរបាយការណ៍ស្វ័យវាយតម្លៃ<br>៣. គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាចុះពិនិត្យមើលលើលក្ខណៈសម្បត្តិរបស់គ្រឹះស្ថានឧត្តមសិក្សា<br>៤. គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាចាត់តាំងក្រុមមន្ត្រីវាយតម្លៃចុះវាយតម្លៃផ្ទាល់នៅគ្រឹះស្ថាន</td></tr>
</table>

ឧត្តមសិក្សា ដោយប្រើវិធីសាស្រ្ត ដូចជា ការសិក្សាឯកសារ ការសង្កេត ការស្ទង់មតិ និង ការសម្ភាសជាមួយនឹងគណៈគ្រប់គ្រង គ្រូបង្រៀន និស្សិត អតីតនិស្សិត និយោជក និងភាគីពាក់ព័ន្ធ

៥. គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាផ្ញើរបាយការណ៍លទ្ធផលនៃការវាយតម្លៃជូនគ្រឹះស្ថានឧត្តមសិក្សាដើម្បីពិនិត្យនិងផ្ទៀងផ្ទាត់

៦. គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាសម្រេចលើលទ្ធផលនៃការវាយតម្លៃ។

